# របាយការណ៍

# ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា

# ២០០២

សុក ហាច និង Sarthi Acharya

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធ្នូ ២០០២

© រក្សាសិទ្ធិឆ្នាំ២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

# **របាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា ២០០២**

## **ធ្នូ ២០០២**

***សុក-ហាច និង Sarthi Acharya***

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះ៥៦ ផ្លូវ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា ( ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទៈ ( ៨៥៥-២៣) ៨៨១-៧០១ ទូរស័ព្ទ/ទូរសារៈ ( ៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែលៈ cdri@camnet.com.kh website: http://www.cdri.org.kh

បកប្រែដោយៈ អែម សូ៉ានី
កែសម្រួល និងរចនាដោយៈ អ៊ុំ ចាន់ថា និង យូ សិទ្ធីរិទ្ធ
បោះពុម្ពនៅកម្ពុជា ដោយរោងពុម្ពជប៉ុន ផ្ទះ៧៤ ផ្លូវ៩៩ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

# មាតិកា

**បញ្ជីតារាង និងក្រាហ្វិក**.......................................................i
**បញ្ជីអក្សរកាត់**..........................................................................iii
**បុព្វកថា**.......................................................................................v
**សេចក្តីថ្លែងអំណរគុណ**.................................................................vii

**ជំពូក១. សេចក្តីផ្តើម**...................................................................... ១

**ជំពូក២. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា**.................................................... ៥
២.១ សេចក្តីផ្តើម .............................................................................. ៥
២.២ ស្ថានភាពនយោបាយ និងសង្គមកិច្ចនៅកម្ពុជា.................................. ៦
២.៣ ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងពេលថ្មីៗ.......................................... ៧
២.៤ សេចក្តីសន្និដ្ឋានៈ និទស្សន៍ខាងសេដ្ឋកិច្ច .................................. ១០

**ជំពូក៣. របាយការណ៍លំអិតពីលទ្ធផលប្រតិបត្តិការសេដ្ឋកិច្ច**........... ១៣
៣.១ សេចក្តីផ្តើមៈ បរិស្ថានសេដ្ឋកិច្ចពិភពលោក............................ ១៣
៣.២ ដំណើរការប្រតិបត្តិសេដ្ឋកិច្ចកម្ពុជា...................................... ១៧

៣.៣ ថ្លៃ និងរូបិយវត្ថុ.......................................................... ៣២
៣.៤ ហិរញ្ញវត្ថុសាធារណៈ.......................................................... ៣៦
៣.៥ ជញ្ជីងទូទាត់.......................................................... ៤៤
៣.៦ វិនិយោគ និងការប្រមូលផ្តុំមូលធន.......................................................... ៤៦
៣.៧ ការងារ និងប្រាក់កំរៃ.......................................................... ៤៩
៣.៨ ភាពក្រីក្រ និងការអភិវឌ្ឍវិមជ្ឈការ.......................................................... ៥២
៣.៩ សេចក្តីសន្និដ្ឋាន និងសេចក្តីសង្ឃឹមទៅអនាគត.......................................................... ៥៤

**ជំពូក៤ ការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងប្រទេសកម្ពុជា**.......................................................... ៥៩
៤.១ សេចក្តីផ្តើម.......................................................... ៥៩
៤.២ សនិទានភាព និងទ្រង់ទ្រាយនៃវិស័យឯកជនកាន់កាប់.......................................................... ៦២
៤.៣ ការពិនិត្យត្រួសៗខាងម៉ាក្រូសេដ្ឋកិច្ច.......................................................... ៧០
៤.៤ លទ្ធផលរកឃើញក្នុងករណីសិក្សា.......................................................... ៧៧
៤.៥ បញ្ហាសំខាន់ៗ និងអនុសាសន៍ខាងគោលនយោបាយ.......................................................... ១១០
៤.៦ សេចក្តីសន្និដ្ឋាន.......................................................... ១២២

**បញ្ជីឯកសារពិភាក្សារបស់ វបសអ**.......................................................... ១៤៧

# បញ្ជីតារាង និងក្រាហ្វិក

## បញ្ជីក្រាហ្វិក

ក្រាហ្វិក៣.១ ចំនួនទេសចរអន្តរជាតិចូលទស្សនាប្រាសាទអង្គរ (ពាន់នាក់)...................... ៣១

ក្រាហ្វិក៣.២ ការប្រើប្រាស់សញ្ញ៉ូយកម្ពុជាតាមរយៈប្រព័ន្ធធនាគារ .................................៣៥

ក្រាហ្វិក៣.៣ ថវិកាកំណត់ផ្តល់ឱ្យក្រសួងសុខាភិបាលនៅឆ្នាំ២០០១ ................................ ៤១

ក្រាហ្វិក៣.៤ បំណុលបរទេសនៅជំពាក់ និងរដ្ឋាភិបាលទទួលស្គាល់ .................................៤៣

ក្រាហ្វិក៣.៥ គំរោងអនុម័តដោយ CDC គិតជាទ្រព្យសកម្មជាប់លាប់ ............................. ៤៧

ក្រាហ្វិក៣.៦ ស្តុកនៃការវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ)..................................... ៤៨

ក្រាហ្វិក៤.១ ការចុះបញ្ជីក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា..................................................៧៦

## បញ្ជីតារាង

តារាង៣.១ កំណើន ផសស ពិភពលោក និងអត្រាអតិផរណា........................................... ១៥

តារាង៣.២ កំណើន ផសស ពិត តាមផ្នែក (គិតជា%)................................................... ១៨

តារាង៣.៣ រចនាសម្ព័ន្ធនៃ ផសស ចារិក (គិតជា%)..................................................... ១៨

តារាង៣.៤ រចនាសម្ព័ន្ធនៃការនាំចេញសំលៀកបំពាក់នៅកម្ពុជា (លានដុល្លារ)................. ២៦

តារាង៣.៥ គំរោងវិនិយោគ និងការងារនៅក្នុងឧស្សាហកម្មកាត់ដេរ ............................... ២៧
តារាង៣.៦ ចំនួនភ្ញៀវមកដល់ប្រទេសអាស៊ានមួយចំនួន (គិតជាលាននាក់) .................... ២៩
តារាង៣.៧ ចំនួនភ្ញៀវអន្តរជាតិមកដល់កម្ពុជា (ពាន់នាក់) ............................................ ៣០
តារាង៣.៨ អតិផរណា និងអត្រាប្តូរប្រាក់នៅភ្នំពេញ..................................................... ៣៣
តារាង៣.៩ ថវិកាសរុបរបស់ប្រទេសកម្ពុជាសំរាប់ឆ្នាំ ២000 និង ២00១...................... ៣៧
តារាង៣.១0 ចំណូលថវិកាក្នុងស្រុក នៅឆ្នាំ ២000 និង ២00១ .................................. ៣៩
តារាង៣.១១ ថវិកាចំណាយតាមរយៈរតនាគារជាតិ ..................................................... ៣៩
តារាង៣.១២ ការបើកផ្តល់កំចី (លានដុល្លារ) ............................................................... ៤៣
តារាង៣.១៣ គណនីចរន្តកម្ពុជា.................................................................................... ៤៤
តារាង៣.១៤ គណនីមូលធនរបស់កម្ពុជា....................................................................... ៤៦
តារាង៣.១៥ កំលាំងពលកម្មនៅកម្ពុជា (ពាន់នាក់) ...................................................... ៥0
តារាង៣.១៦ ផសស ចារិក តាមអនុវិស័យ (លានដុល្លារ)............................................. ៥១
តារាង៣.១៧ ប្រាក់ចំណូលដុលប្រចាំថ្ងៃរបស់កម្មករ (ជារៀល).................................... ៥២
តារាង៤.១ កំណើនសេដ្ឋកិច្ច និងផលិតភាពពីឆ្នាំ១៩៩៣-២000 .................................. ៧0
តារាង៤.២ ការបែងចែកសហគ្រាសអាជីវកម្មនៅក្នុងគំរូតាង.......................................... ៧៩

# បញ្ជីអក្សរកាត់

ADB ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank)

AFTA តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (Asean Free Trade Area)

ASEAN សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (Association of Southeast Asian Nations)

CDC ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia)

CDRI វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute)

C-T-P ក្រុមហ៊ុនសំណង់-ពាណិជ្ជកម្ម-ចំការដំណាំ (Construction, Trade and Plantation Company)

EU សហភាពអឺរ៉ុប (European Union)

FDI វិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment)

GMAC សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (Garment Manufactuters' Association of Cambodia)

GSP ប្រព័ន្ធអនុគ្រោះទូទៅ (Generalised System of Preferences)

ILO អង្គការពលកម្មអន្តរជាតិ (International Labour Organisation)

MEF ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Ministry of Economy and Finance)

MFN សិទ្ធិបានទទួលលក្ខខណ្ឌអនុគ្រោះបំផុត (Most Favoured Nation)

| | |
|---|---|
| MPDF | កម្មវិធីអភិវឌ្ឍន៍គំរោងតំបន់ទន្លេមេគង្គ (Mekong Project Development Facility) |
| NBC | ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia) |
| NIS | វិជ្ជាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) |

# បុព្វកថា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បានផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា២០០២ លេខ២ ។ របាយការណ៍នេះបានចាប់ផ្តើមបោះពុម្ពនៅឆ្នាំ២០០១ ក្នុងគោលដៅពិនិត្យ និងវិភាគហ្មត់ចត់អំពីដំណើរប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ ។ លើសពីនេះ ជារៀងរាល់ឆ្នាំ ឯកសារនឹងរាយការណ៍លំអិតពីវិស័យណាមួយនៃសេដ្ឋកិច្ចកម្ពុជា ។ របាយការណ៍លេខ១ ដែលចេញផ្សាយនៅឆ្នាំ២០០១ បានសិក្សាអំពីសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០០ និងបានផ្តល់នូវសេចក្តីសង្ខេបពីការវិភាគសេដ្ឋកិច្ចនៅក្នុងរយៈពីឆ្នាំ១៩៩៤-២០០០ ។ ប្រធានបទសំខាន់នៃរបាយការណ៍លេខ១ គឺការអភិវឌ្ឍវិស័យទំនើប ដោយផ្តោតជាពិសេសលើឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ។

របាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា ២០០២ លេខ២ រាយការណ៍ពីលទ្ធផលប្រតិបត្តិការសេដ្ឋកិច្ចឆ្នាំ២០០១ជាអាទិ៍ កំនើនសេដ្ឋកិច្ច ការនាំចេញ រូបិយវត្ថុ ថ្លៃ និងអតិផរណា ថវិកានិងហិរញ្ញវត្ថុសាធារណ លំហូរចូលពីអន្តរជាតិនូវទុន និងជំនួយ ជញ្ជីងពាណិជ្ជកម្មនិងជញ្ជីងទូទាត់ ដីធ្លី កសិកម្មនិងការអភិវឌ្ឍន៍ជនបទ ប្រាក់ចំណូល កំលាំងពលកម្មនិងភាពក្រីក្រ និងវិមជ្ឈការ ។ ស្របតាមរបៀបរបបរបស់ វបសអ ក្នុងការតាក់តែងរបាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំរបាយការណ៍លេខ២ នេះ ក៏មានការសិក្សាស្រាវជ្រាវមួយ ព្រមទាំងតារាងស្ថិតិបន្ថែម ដែលមានចុះទិន្នន័យ

ស្ដីពីអថេរសេដ្ឋកិច្ចសំខាន់ៗមួយចំនួន ។ ប្រធានបទជ្រើសរើសសំរាប់របាយការណ៍នេះគឺការអភិវឌ្ឍន៍វិស័យឯកជន ។ ការរកឃើញជាមូលដ្ឋាននៅក្នុងរបាយការណ៍នេះគឺការអភិវឌ្ឍន៍វិស័យឯកជនដែលកាន់កាប់គ្រប់គ្រងដោយអ្នកក្នុងស្រុក ហើយមាននៅពាសពេញប្រទេស វាអាចជួយធានានូវការលូតលាស់មានចីរភាព និងតុល្យភាព ។ ការអភិវឌ្ឍន៍បែបនេះមានប្រយោជន៍ដល់ការបង្កើតការងារ ការកាត់បន្ថយភាពក្រីក្រ ជួយធានាឱ្យមានស្ថិរភាព និងសន្តិភាពយូរអង្វែងនៅក្នុងប្រទេស ។ គំហើញនៅក្នុងរបាយការណ៍នេះ ផ្អែកលើករណីសិក្សាគំរូតាងតូចមួយនៃសហគ្រិនធុនតូច និងធុនធំនៅកម្ពុជា ។ ការសិក្សានេះ មិនអាចតំណាងបាននូវមតិយោបល់ ឬដំណើរការប្រតិបត្តិការនៃវិស័យឯកជនទាំងមូលនៅក្នុងប្រទេសក៏ពិតមែន ប៉ុន្តែ វាអាចក្លាយជាមូលដ្ឋានគ្រឹះសំរាប់ការស្រាវជ្រាវ និងវិភាគស៊ីជំរៅថែមទៀតក្នុងវិស័យនេះ ។

យើងមានជំនឿយ៉ាងស្មោះថា គំហើញនានាដែលបង្ហាញជូនក្នុងរបាយកាណ៍នេះ នឹងបានជាប្រយោជន៍ដល់អ្នកកសាងគោលនយោបាយ និងអ្នកវិភាគពីសេដ្ឋកិច្ចកម្ពុជានានាជាមិនខាន ។ យើងរង់ចាំយ៉ាងរីករាយនូវមតិផ្សេងៗពីមជ្ឈដ្ឋានអ្នកអានជាទីរាប់អាន និងពីដៃគូនានានៅក្នុងការងារអភិវឌ្ឍន៍កម្ពុជា ដើម្បីបន្តកែលំអស្នាដៃរបស់យើងខ្ញុំ ។

*ភ្នំពេញ ខែសីហា ២០០២*

*អេវ៉ា មីស្លីវិក, នាយិកា*

*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធ សូមសំដែងនូវការដឹងគុណ ចំពោះកិច្ចសហប្រតិបត្តិការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងផែនការ ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ ។ ចំពោះបុគ្គលិកផ្នែកស្រាវជ្រាវនៃ វបសអ មានលោក ច័ន្ទ សុផល, សូ សុវណ្ណារិទ្ធិ, កង ច័ន្ទតារារ័ត្ន, ព្រុំ តុលា, ជា ហួត, គីម សេតារា, លោកស្រី ប៉ុន ដូរីណា និងជីម ចរិយា ដែលបានជួយដល់ការងារយ៉ាងសំខាន់នៅក្នុងការចុះស្រាវជ្រាវដល់កន្លែង ។ ក្រុមអ្នកនិពន្ធសូមអរគុណជាពិសេសចំពោះការគាំទ្រ និងឱវាទរបស់លោកស្រីនាយិកា អេវ៉ា មីស្លីវិក និងយោបល់ដ៏មានប្រយោជន៍ពី Adam Sack, Steven Schonberger និង Bruce McKenney ។

ក្រុមអ្នកនិពន្ធ ក៏សូមសំដែងសេចក្តីដឹងគុណជាពិសេសដល់អ្នកឆ្លើយសម្ភាសន៍នៅក្នុងករណីសិក្សា ដែលបានផ្តល់ពតិមានជាច្រើន និងមានតំលៃបំផុត ។ របាយការណ៍នេះមិនអាចកសាងឡើងបានទេ បើសិនជាគ្មានកិច្ចសហប្រតិបត្តិការទាំងឡាយដូចបានបញ្ជាក់រួចហើយ ។

# ជំពូកទី ១

# សេចក្តីផ្តើម

ប្រទេសកម្ពុជារីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងទសវត្សរ៍នេះ ចាប់តាំងពីការចុះហត្ថលេខាកិច្ចព្រមព្រៀងក្រុងប៉ារីស ក្នុងឆ្នាំ១៩៩១ មក ។ ជាមួយនឹងការមានសន្តិភាពឡើងវិញ ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងរូបភាពជាឧស្សាហកម្មកាត់ដេរ និងទេសចរណ៍បានលេចធ្លោឡើង ។ នៅក្នុងទសវត្សរ៍១៩៩០ ឧស្សាហកម្មកាត់ដេរមានកំណើនប្រចាំឆ្នាំប្រហែល ៣០% ហើយការនាំចេញសំលៀកបំពាក់ក្នុងឆ្នាំ២០០១ ឡើងដល់ជាង ១.០០០លានដុល្លារ ។ កម្ពុជាបានបោះជំហានយ៉ាងលឿនធ្វើអន្តរកាលពីសេដ្ឋកិច្ចតាមផែនការប្រមូលផ្តុំ ទៅជាសេដ្ឋកិច្ចទីផ្សារ ។ កម្ពុជាបានកសាងទំនាក់ទំនងជាដៃគូយ៉ាងសំខាន់និងជាយុទ្ធសាស្ត្រ ជាមួយភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងពហុភាគី សំរាប់ការស្តាបនាឡើងវិញនូវស្ថាប័នរូបវន្ត និងសង្គមកិច្ចផ្សេងៗ ដែលត្រូវបានបំផ្លាញនៅក្នុងរយៈពេល ៣០ឆ្នាំនៃសង្គ្រាម និងការរើកវរ ។

នៅក្នុងវិស័យកសិកម្មក៏មានការរីកចំរើនខ្លះដែរ ប៉ុន្តែកត្តាខាងស្ថាប័ន ដូចជាកំណែទំរង់ដីធ្លី ការវាស់វែងខាងសុរិយោដី ព្រមទាំងទំនាក់ទំនងទីផ្សារដែលមិនទាន់មានគ្រប់គ្រាន់ នៅតែបន្តរាំងស្ទះដល់ដំណើរការរីកលូតលាស់ ។ ដូច្នេះហើយ ផ្នែកផលិតកម្មស្រូវដែលជារបរចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជាភាគច្រើន គឺមានទិន្នផលក្នុងកំរិតដ៏ទាបបំផុតនៅអាស៊ីអគ្នេយ៍ ។ ផ្នែកដទៃទៀត ពុំមានការរីកចំរើនគួរឱ្យពេញចិត្ត ដូចក្នុងវិស័យកាត់ដេរ ឬទេសចរណ៍នោះទេ ។ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ

សមស្រប, ទំនុកចិត្តក៏រិតទាបរបស់អ្នកវិនិយោគ, សមត្ថភាពបច្ចេកទេសមានក៏រិត, និងអត្រាសន្សំទាប... គឺជាហេតុផលមួយចំនួនដែលបានញ៉ាំងឱ្យការរីកចំរើនជាទូទៅនៅយឺតយ៉ាវ និងគ្មានតុល្យភាព ។ ការវិនិយោគមិនគ្រប់គ្រាន់លើវិស័យអភិវឌ្ឍន៍ធនធានមនុស្ស ដូចជា ខាងអប់រំ, សុខាភិបាល និងសុខមាលភាពជាដើម ក៏ចូលរួមចំណែកបង្កអតុល្យភាពនេះដែរ ។ ប្រហែលដោយសារកត្តាទាំងនេះហើយ ដែលផលចំណេញនៃការរីកចំរើន មិនបានធ្លាក់ដល់ដៃប្រជាជនទូទៅ ។

ថ្វីបើពត៌មានខ្លះៗស្តីពីលទ្ធផលប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា មានចុះផ្សាយជាហូរហែរនៅក្នុងរបាយការណ៍ និងទស្សនាវដ្តីផ្សេងៗរបស់ទីភ្នាក់ងារពហុភាគីក្តី ក៏ប៉ុន្តែការវាយតំលៃដោយឯករាជ្យ និងសព្វជ្រុងជ្រោយចេញពីប្រភពជាតិណាមួយ គឺសឹងតែគ្មានសោះរហូតដល់ឆ្នាំ២០០១នេះ ។ ជាលទ្ធផល ទាំងមជ្ឈដ្ឋានអ្នកអាន ទាំងអ្នកកសាងគោលនយោបាយ គេខ្វះខាតឯកសារជាក់លាក់មួយ ដែលអាចផ្តល់ពត៌មានថ្មីៗ និងទាន់ពេលស្តីពីការអភិវឌ្ឍន៍ប្រទេស ។ ពិតហើយ មានរបាយការណ៍សេដ្ឋកិច្ចជាច្រើនដែលក្រសួង-មន្ទីររដ្ឋ និងភ្នាក់ងារផ្តល់ជំនួយនានាបានផ្សព្វផ្សាយ ប៉ុន្តែភាគច្រើនវាជាឯកសារស្តីពីលទ្ធផលប្រតិបត្តិការតាមវិស័យ និងកសាងឡើង សំរាប់បំរើការងារផ្ទៃក្នុងរបស់ស្ថាប័នទាំងនេះ ។ក្នុងប្រទេសធំៗភាគច្រើន របាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយដោយក្រសួងសេដ្ឋកិច្ច ឬធនាគារកណ្តាលរបស់ប្រទេសទាំងនោះ ក៏ប៉ុន្តែនៅកម្ពុជា គឺពុំទាន់ដោះស្រាយបាននៅឡើយទេ ។ ដើម្បីបំពេញកង្វះខាតនេះ វិបសអ បានចាប់ផ្តើមបោះពុម្ពផ្សាយនូវរបាយការណ៍ប្រចាំត្រីមាសស្តីពីលទ្ធផលប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុង និងក្រៅប្រទេសនៅឆ្នាំ១៩៩៧ ក្នុងទស្សនាវដ្តីប្រចាំត្រីមាសរបស់ វិបសអ ឈ្មោះថា *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ។ នៅឆ្នាំ២០០១ វិទ្យាស្ថានបានកំណត់ថា វាជាការសំខាន់ដែលត្រូវបោះពុម្ពផ្សាយនូវកំរងឯកសារថ្មីមួយទៀតឈ្មោះថា *របាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំ* ។ ដោយឡែកចំពោះឯកសារនេះ វាជារបាយការណ៍លេខ២ នៃកំរងឯកសារខាងលើ ហើយមានគោលដៅផ្តល់ពត៌មាន

និងការវិភាគស៊ីជំរៅស្តីពីការលូតលាស់សេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ ។ របាយការណ៍លេខ ១ ចេញផ្សាយនៅឆ្នាំ២០០១ បានផ្តល់នូវការវិភាគពីដំណើរការសេដ្ឋកិច្ចពីឆ្នាំ១៩៩៤ -២០០០ ។ របាយការណ៍ប្រចាំឆ្នាំលេខ២នេះ នឹងពិនិត្យពីលទ្ធផលប្រតិបត្តិការសេដ្ឋកិច្ចសំរាប់ឆ្នាំ២០០១ ដូច្នេះគឺមានលទ្ធភាពពិចារណារឹតតែស៊ីជំរៅថែមទៀត ។

ជំពូកពីរ បង្ហាញពីការពិនិត្យត្រួសៗពីការលូតលាស់ជាទូទៅនៅក្នុងសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០០១ រួមទាំងការព្យាករណ៍រយៈពេលខ្លីសំរាប់ឆ្នាំ២០០២ និង ២០០៣ ។ ការព្យាករណ៍នេះ ពឹងផ្អែកលើការយល់ឃើញ ដែលផុសចេញពីការពិនិត្យលទ្ធផលប្រតិបត្តិការសេដ្ឋកិច្ចក្នុងឆ្នាំ២០០១ និងឆ្នាំមុនៗ ។ សរុបមក ជំពូកពីរ វាជាសេចក្តីសង្ខេបនៃខ្លឹមសារលំអិតក្នុងជំពូកបី ដោយបង្ហាញច្បោលៗពីស្ថានភាព និងដំនើរការសេដ្ឋកិច្ច ដើម្បីបំរើដល់មជ្ឈដ្ឋានអ្នកអានដែលគ្មានពេលអានឯកសារនេះគ្រប់គ្រាន់ ប៉ុន្តែត្រូវការពត៌មានជាក់ស្តែងខ្លះៗស្តីពីដំនើរការសេដ្ឋកិច្ចបច្ចុប្បន្ន ។ ចំពោះអ្នកកសាងគោលនយោបាយ និងអ្នកជំនួញ ឯកសារនេះគឺជាប្រភពពត៌មានមួយទៀត ដែលគេអាចយកមកប្រើភ្លាមៗបាន ។ ជំពូកនេះ បែងចែកជាបីផ្នែកគឺ សេណារីយ៉ូខាងនយោបាយ និងសង្គមកិច្ច, របាយការណ៍ពីការលូតលាស់សេដ្ឋកិច្ចក្នុងពេលថ្មីៗ និងនិទស្សន៍សំរាប់ពេលអនាគត ។

ជំពូកបី បកស្រាយប្រធានបទជាច្រើនជាអាទិ៍: កំនើនសេដ្ឋកិច្ច, ការនាំចេញ, រូបិយវត្ថុ, ថ្លៃ និងអតិផរណា, ថវិកានិងហិរញ្ញវត្ថុសាធារណ:, លំហូរចូលពីអន្តរជាតិនូវទុន និងជំនួយ, ជញ្ជីងពាណិជ្ជកម្ម និងជញ្ជីងទូទាត់, ដីធ្លី, កសិកម្ម និងការអភិវឌ្ឍន៍ជនបទ, ប្រាក់ចំណូល, ពលកម្ម និងភាពក្រីក្រ, និងវិមជ្ឈការ ។

*របាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំលេខ១ ឆ្នាំ២០០១* បានបញ្ជាក់ហើយថា ក្នុង *របាយការណ៍*នីមួយៗនឹងមានការពិភាក្សាយ៉ាងលំអិតពីវិស័យមួយ ឬច្រើន ដែលមានលក្ខណ:សំខាន់ចំពោះសេដ្ឋកិច្ច ។ ជំពូកបួន នៃឯកសារនេះ បង្ហាញពីលទ្ធផលនៃការសិក្សាផ្អែកលើការស្រាវជ្រាវមួយស្តីពីការអភិវឌ្ឍន៍វិស័យឯកជននៅកម្ពុជា ។ ដោយ

ឡែកមានធ្វើការណើសិក្សាស៊ីជំរៅជាច្រើន អំពីសហគ្រិនក្នុងស្រុកទាំងធំ ទាំងតូច នៅតាមតំបន់ខុសៗគ្នានៃកម្ពុជា ។ ការស្រាវជ្រាវនេះផ្តល់ជាសេចក្តីសន្និដ្ឋានថា ត្រូវមានវិធានការសំខាន់ៗមួយចំនួនដើម្បីបំពេញបន្ថែម និងពង្រឹងគោលនយោបាយនានាដែលរដ្ឋាភិបាល និងសហគមន៍អន្តរជាតិកំពុងអនុវត្ត ហើយដែលស្ថិតនៅក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ធនធានមនុស្សនិងបច្ចេកវិទ្យា, និងសេវាអភិវឌ្ឍន៍អាជីវកម្ម ។ ទោះបីការសិក្សានេះមិនអាចតំនាងយោបល់ ឬបង្ហាញពីលទ្ធផលប្រតិបត្តិការនៃវិស័យឯកជនទាំងមូលនៅក្នុងប្រទេសបានក៏ពិតមែន ប៉ុន្តែ វាអាចក្លាយជាមូលដ្ឋានគ្រឹះសំរាប់ការស្រាវជ្រាវ និងវិភាគស៊ីជំរៅថែមទៀតក្នុងវិស័យដែលបានសិក្សា ។

របាយការណ៍នេះបញ្ចប់ដោយតារាងឧបសម្ព័ន្ធ ដែលមានចុះទិន្នន័យនៃអញ្ញាតសេដ្ឋកិច្ចសំខាន់ៗ សំរាប់រយៈពេលជាងបួនទសវត្សរ៍ដែលបញ្ចប់នៅឆ្នាំ២០០១ ។ តារាងមានបង្ហាញនូវសន្ទស្សន៍សេដ្ឋកិច្ចសំខាន់ៗដូចជា ការងារ, ផលិតផលក្នុងស្រុកសរុប (ផសស), ចំណូលពីការនាំចេញ, ការនាំចូល, ថវិការដ្ឋ, ចំណូលនិងចំណាយ, ព្រមទាំងឱនភាព និងអតិរេកបច្ចុប្បន្ន ។

ទាក់ទិននឹងទិន្នន័យ គួរបញ្ជាក់ផងដែរពីចំណុចខ្លះដែលត្រូវប្រុងប្រយ័ត្ន ។ នៅកម្ពុជា ក៏ដូចជានៅប្រទេសឯទៀតៗមាន ក្រសួង-មន្ទីរជាច្រើន បានកសាងទិន្នន័យដើម ។ ប៉ុន្តែ ក្នុងនេះគេមិនទាន់បង្កើតប្រពន្ធ័មួយសំរាប់ផ្ទៀងផ្ទាត់ចុះឡើង និងដាក់បញ្ចូលគ្នានូវទិន្នន័យដើមដើម្បីឱ្យស៊ីគ្នាទៅវិញទៅមកបាននៅឡើយទេ ។ ឧទាហរណ៍តួលេខកំនើនតាមវិស័យខ្លះ មិនបានបូកបញ្ចូលទៅក្នុងអត្រាកំនើនសរុបទេ ។ តួលេខខុសគ្នាបែបនេះ បង្ហាញពីតំរូវការបង្កើតការិយាល័យកណ្តាល ឬនាយកដ្ឋានស្ថិតិសេដ្ឋកិច្ច ដើម្បីប្រមូល និងផ្ទៀងផ្ទាត់បន្សីទិន្នន័យមកពីប្រភពផ្សេងៗគ្នា ។ ការងារនេះមានអនុវត្តន៍ជាធម្មតាហើយនៅក្នុងប្រទេសភាគច្រើន ។

## ជំពូកទី ២

# ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

## ២.១ សេចក្តីផ្តើម

ចាប់តាំងពីការចុះហត្ថលេខានៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលបានត្រួសត្រាយផ្លូវសំរាប់ដំណើរការសន្តិភាព ប្រទេសកម្ពុជាមានការរីកចំរើនយ៉ាងទៀងទាត់ឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ ។ តាំងពីពាក់កណ្តាលទសវត្សរ៍១៩៩០ រហូតមកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាបានប្រឹងប្រែងយ៉ាងច្រើន ដើម្បីធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ច និងទីផ្សារពលកម្មអន្តរជាតិ ។ បន្ទាប់ពីការកាត់ផ្តាច់មួយរយៈពេលខ្លីដោយសារការវាយប្រយុទ្ធនៅថ្ងៃទី៥-៦ កក្កដា ១៩៩៧ ប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ាន ហើយបច្ចុប្បន្ន កំពុងខិតខំចូលជាសមាជិកពេញសិទ្ធិនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ទៀតផង ។

ការសិក្សាពីសេដ្ឋកិច្ចណាមួយ ត្រូវផ្សារភ្ជាប់នឹងបរិបទ ហើយឆ្នាំ២០០១ មានព្រឹត្តិការណ៍ចំបងមួយគឺការធ្លាក់ចុះសេដ្ឋកិច្ចជាសាកល ដែលបានប៉ះពាល់ដល់ប្រទេសមានសេដ្ឋកិច្ចខ្លាំងៗ ហើយមានភាពយ៉ាប់យ៉ឺនជាងការរំពឹងទុក ។ ការលូតលាស់សេដ្ឋកិច្ចពិភពលោក វាមានផលប៉ះពាល់គួរឱ្យកត់សំគាល់មកលើសេដ្ឋកិច្ចកម្ពុជា ។ ឧទាហរណ៍ ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងវិស័យកម្មន្តសាលកម្ពុជា មានចំនងទាក់ទងយ៉ាងជិតស្និទ្ធនឹងទីផ្សារអន្តរជាតិ ហើយបានធ្វើឱ្យការងារបង្កើតបានក្នុងឆ្នាំនេះ មានចំនួន

តិចជាងឆ្នាំមុន ។ ប៉ុន្តែទិន្នន័យចុងក្រោយផ្សព្វផ្សាយនៅក្នុងត្រីមាសទី១ ឆ្នាំ២០០២ ហាក់ដូចបញ្ជាក់ឱ្យឃើញថា ប្រទេសមានសេដ្ឋកិច្ចចំបង១មួយចំនួនក្នុងពិភពលោក អាចកំពុងតែរើបពីការធ្លាក់ចុះនេះឡើងវិញហើយ ។

នៅឆ្នាំ២០០១ ស្ថានភាពនយោបាយ និងសង្គមកិច្ច មានស្ថិរភាព និងស្ងប់ស្ងាត់ល្អ ឯការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់បានដំណើរការដោយជោគជ័យនៅថ្ងៃទី៣ កុម្ភៈ ២០០២ ។ ដោយមានគោលដៅធ្វើវិមជ្ឈការលើដំណើរការសំរេចចិត្ត ការបោះឆ្នោតឃុំ-សង្កាត់ បាននាំចូលទៅដល់យុគសម័យថ្មីមួយនៃការអភិវឌ្ឍន៍មូលដ្ឋាន ។ ក្នុងរយៈពេលវែងនៃដំណើរការធ្វើវិមជ្ឈការរំពឹងថានឹងជួយជំរុញសេដ្ឋកិច្ចជាតិ តាមរយៈកំណើននៃលំហូរធនធាន និងសេវាកម្មដែលផ្តល់ទៅឱ្យទីជនបទ ។

## ២.២ ស្ថានភាពនយោបាយ និងសង្គមកិច្ចនៅកម្ពុជា

ស្ថិរភាពនយោបាយគឺជាកត្តាគន្លឹះសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។ តាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស អ្នកដឹកនាំនយោបាយកម្ពុជា បានប្តេជ្ញាញ៉ាំងឱ្យប្រទេសធ្វើចលនាឆ្ពោះទៅរកសន្តិភាព, ប្រជាធិបតេយ្យ និងភាពសំបូររុងរឿង ។ គេឃើញមានការរីកចំរើនខ្លះ១ហើយ ប៉ុន្តែនៅមានចំណុចដ៏ច្រើនទៀតដែលត្រូវដោះស្រាយ ។ កន្លងមក ការបោះឆ្នោតជាទូទៅចំនួនពីរលើកបានអនុវត្តរួចហើយ (ឧសភា ១៩៩៣ និង កក្កដា ១៩៩៨) ហើយការបោះឆ្នោតជាទូទៅលើកទីបី គ្រោងធ្វើនៅខែកក្កដា ២០០៣ ។ ទោះបីមានរបាយការណ៍ពីការបំភិតបំភ័យមួយចំនួនក្នុងរយៈពេលមុនការបោះឆ្នោតឃុំ-សង្កាត់នៅខែកុម្ភៈ ២០០២ ក្តី ក៏ការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយសន្តិភាព ហើយគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក៏បានទទួលយកលទ្ធផលនៃការបោះឆ្នោតនេះដែរ ។

ប៉ុន្តែនៅតំបន់ជនបទ ជំលោះដីធ្លី និងភាពក្រីក្រតោកយ៉ាក បានក្លាយជាបញ្ហាដែលគេមើលឃើញកាន់តែច្បាស់ ហើយអាចបណ្តាលឱ្យមានភាពរំជើបរំជួលនៅក្នុងសង្គម ប្រសិនបើគ្មានដំណោះស្រាយសមស្របណាមួយទេ ។ បញ្ហានេះគឺជាការព្រួយ

បារម្ភចំបងមួយរបស់ប្រទេសកម្ពុជា ។ ជំលោះខាងពលកម្ម ដែលកើតមានភាគច្រើននៅក្នុងឧស្សាហកម្មកាត់ដេរ នៅតែជាបញ្ហាដែលអាចបង្កការមិនស្រុះស្រួលគ្នាក្នុងសង្គម ។ ប៉ុន្តែបើធៀបនឹងឆ្នាំ២000 ជំលោះទាក់ទិននឹងវិស័យឧស្សាហកម្មហាក់ដូចជាបានធ្លាក់ចុះច្រើនហើយនៅឆ្នាំ២00១ ។ ការកែលំអអាចកើតមានឡើងដោយសារមានការយល់ដឹងកាន់តែប្រសើរពីច្បាប់ពលកម្មកម្ពុជា ទាំងពីសំណាក់ភាគីម្ចាស់រោងចក្រ និងសហជីពកម្មករ ហើយទោះជាមានបញ្ហារសើបទាំងនេះមួយចំនួនអាចក្លាយជាតឹងតែងខ្លាំងក្នុងពេលណាមួយនាអនាគតក្តី ក៏ហានិភ័យនៃការរំជើបរំជួលធ្ងន់ធ្ងរខាងនយោបាយនិងសង្គមកិច្ច ប្រហែលមានកំរិតតូច ហើយមិនអាចប៉ះពាល់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចទេ ជាពិសេសនៅក្នុងរយៈពេលខ្លី ។

## ២.៣ ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងពេលថ្មីៗ

ទោះបីមានការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកយ៉ាងធ្ងន់ធ្ងរក្តី សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅតែមានសន្ទុះគួរសម បើធៀបនឹងសេដ្ឋកិច្ចប្រទេសអាស៊ីជាច្រើនទៀត ។ ផសស កម្ពុជាមានកំនើនប្រហែល ៥,៣% ក្នុងឆ្នាំ២00១[១] ដែលទាបបន្តិចជាងកំរិត ៥,៥% ក្នុងឆ្នាំ២000 និង ៦,៨% ក្នុងឆ្នាំ១៩៩៩ (ការប៉ាន់ស្មានដោយ វបសអ) ។ ការធ្លាក់ចុះនេះ បណ្តាលជាសំខាន់មកពី ការថយល្បឿនលូតលាស់នៃឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ព្រមទាំងការធ្លាក់ចុះវិនិយោគផ្ទាល់ពីបរទេស (FDI) យ៉ាងខ្លាំង ។ ទោះបី មានទឹកជំនន់ក្នុងតំបន់ជាច្រើននាឆ្នាំ២00១ ក្តី ក៏ផលិតកម្មផលដំណាំ និងសត្វចិញ្ចឹម បានទទួលផលខ្ពស់គួរសមក្នុងឆ្នាំ២00១ (កំណើន ៣-៤%) ។ ប៉ុន្តែផលិតកម្ម កសិកម្មបានពីធនធានធម្មជាតិ ដូចជាត្រី និងព្រៃឈើ គឺស្ថិតនៅថេរ ឬក៏ធ្លាក់ចុះ ។ គិតជាតួលេខចារិក ការនាំចេញផលិតផលកាត់ដេរកើន ១៣% ក្នុងឆ្នាំ២00១ ធៀបនឹង ៧៨% ក្នុងឆ្នាំ២000 ។ សកម្មភាពក្នុងវិស័យកម្មន្តសាលផ្សេង

[១] ពេលរបាយការណ៍នេះកំពុងបោះពុម្ព រដ្ឋាភិបាលបានផ្សព្វផ្សាយទិន្នន័យមួយដែលបញ្ជាក់ថា ផសស ក្នុងឆ្នាំ២00១ មានអត្រាកំណើនលើសពី ៦% ។

ទៀត ក៏មានការធ្លាក់ចុះដូចគ្នា ។ ទោះបីជាមានការធ្លាក់ចុះ FDI ខ្លាំងក៏ដោយ ក៏សកម្មភាពសាងសង់កើនឡើងបន្តិច ដោយសារកម្មវិធីកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញរបស់រដ្ឋាភិបាល កាលពីមុនពេលបោះឆ្នោតឃុំ-សង្កាត់ ។ ឧស្សាហកម្មទេសចរណ៍ដែលមាននិន្នាការដូចគ្នានឹងឧស្សាហកម្មកាត់ដេរដែរ បានបន្តរីកធំធាត់ ប៉ុន្តែនៅក្នុងអត្រាយឺតជាងមុន ។ ចំនួនទេសចរអន្តរជាតិចូលមកទស្សនាកម្ពុជាតាមផ្លូវអាកាស បានកើនឡើងប្រហែល ១៤% ក្នុងឆ្នាំ២០០១ ធៀបនឹង ៣១% ក្នុងឆ្នាំ២០០០ ។ កំណើននេះ បានជំរុលឡើងដោយសារមានជើងហោះហើរផ្ទាល់ទៅខេត្តសៀមរាប ទោះបីមានភ្ញៀវទេសចរអន្តរជាតិ ក្នុងចំនួនប្រហែលគ្នាបានមកដល់តាមច្រកភ្នំពេញក្តី ។ សកម្មភាពក្នុងវិស័យសេវាផ្សេងទៀតក៏ធ្លាក់ចុះដែរ ។

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញធ្លាក់ចុះបន្តិចក្នុងឆ្នាំ២០០១ ដោយមានក៏រិតមធ្យមប្រចាំឆ្នាំ -០,៦% គិតជាប្រាក់រៀល និង -២,៥% គិតជាដុល្លារ ។ ថ្លៃម្ហូបអាហារក្នុងស្រុកធ្លាក់ចុះគួរឱ្យកត់សំគាល់ ទោះបីជាថ្លៃផ្គត់ផ្គង់សាធារណៈកើនឡើងយ៉ាងច្រើនក្តី ហើយទោះជាប្រាក់បញ្ញើរដ្ឋាភិបាលនៅធនាគារជាតិកើនឡើងគួរឱ្យកត់សំគាល់ក្តី ក៏ប្រាក់រៀលបានចុះថ្លៃ ១,៩% (មធ្យមប្រចាំឆ្នាំ) ធៀបនឹងដុល្លារ ដោយប្តូរបាន ៣.៩៣៥រៀល/ដុល្លារក្នុងឆ្នាំ២០០១ ធៀបទៅនឹង ៣.៨៥៩រៀល/ដុល្លារក្នុងឆ្នាំ២០០០ ។ ការធ្លាក់ថ្លៃនេះបណ្តាលមកពីកំណើនយ៉ាងច្រើន (+២៣%) នៃសាច់ប្រាក់រៀលធ្វើចរាចរនៅទីផ្សារក្នុងឆ្នាំ២០០១ ។ ទោះជាយ៉ាងនេះក្តី កំណើនការផ្គត់ផ្គង់ប្រាក់រៀលមិនប៉ះពាល់ដល់អតិផរណាទេ ពីព្រោះសេដ្ឋកិច្ចកម្ពុជាប្រើប្រាក់ដុល្លារច្រើនណាស់ ។ បញ្ញើជារូបិយវត្ថុបរទេសនៅធនាគារពាណិជ្ជ ក៏កើនឡើងក្នុងអត្រាប្រហាក់ប្រហែលគ្នាដែរ (+២៤%) ។ ដូច្នេះជាទូទៅ ការផ្គត់ផ្គង់សាច់ប្រាក់កើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០០១ ។ ចំពោះតំរូវការវិញ ឥណទានផ្តល់ឱ្យប្រជាជនកម្ពុជាបានធ្លាក់ចុះ ដូច្នេះបានន័យថា សញ្ជ័យកម្ពុជាបន្តហូរចេញទៅក្រៅប្រទេស ។

ការធ្លាក់ចុះឥណទានក្នុងស្រុក ជាសញ្ញាបង្ហាញពីភាពទន់ខ្សោយនៃវិនិយោគឯកជន ។ ក្នុងឆ្នាំ២០០១ វិនិយោគទិញសំភារៈបរិក្ខារថ្មីៗរបស់អាជីវកម្មនានាបានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ។ ទោះជាយ៉ាងនេះក្តី វិនិយោគលើអចលនទ្រព្យបន្តមានលំនឹងជាទូទៅ ដោយសារស្ថិរភាពខាងនយោបាយ និងសង្គមកិច្ចបានកែលំអឡើង ។ ពិនិត្យតាមតួលេខ FDI កសាងឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា FDI បន្តធ្លាក់ចុះក្នុងរយៈបីឆ្នាំជាប់គ្នា ដែលបញ្ជាក់ពីភាពមិនច្បាស់លាស់នៃយុទ្ធសាស្ត្ររបស់កម្ពុជាដើម្បីទាក់ទាញវិនិយោគបរទេស ។ ធៀបនឹងឆ្នាំ២០០០ គំរោង FDI ថ្មីអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងឆ្នាំ២០០១ បានធ្លាក់ចុះ ៥០% ហើយវិនិយោគឯកជនសរុបនៅកម្ពុជាធ្លាក់ចុះ ២៥% ។

ចំពោះហិរញ្ញវត្ថុសាធារណៈវិញ ស្ថិតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្ហាញពីការកែលំអចំណូលថវិការដ្ឋក្នុងឆ្នាំ២០០១ ។ គិតជាភាគរយនៃ ផសស ចារិក, ចំណូលក្នុងស្រុកកើន ០,៣% (ពី ១១,៧% នៅឆ្នាំ២០០០ ដល់ ១២% នៅឆ្នាំ២០០១) ដែលជាសំខាន់បានពីការពង្រឹងដំណើរការប្រមូលចំណូលមិនមែនពន្ធ ។ ចំពោះចំណាយសាធារណៈវិញ, ចំណាយលើសន្តិសុខ និងការពារជាតិធ្លាក់ចុះ ប៉ុន្តែចំណាយលើរដ្ឋបាលសាធារណៈកើនឡើងយ៉ាងខ្លាំង ដោយសារមានចំណាយលើការបោះឆ្នោតឃុំ-សង្កាត់ ។ វិនិយោគសាធារណៈផ្តល់ទុនតាមរយៈរតនាគារជាតិ ក៏ធ្លាក់ចុះដល់ ៩% នៅឆ្នាំ២០០១ ដែរ ។ ទោះយ៉ាងនេះក្តី វិនិយោគទុនសាធារណៈផ្តល់ទុនដោយជំនួយបរទេស ជាពិសេសកំចីពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានកើនឡើងយ៉ាងច្រើន (+១៧%) ។ ជាលទ្ធផល បំណុលអន្តរជាតិដែលរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ បានកើនយ៉ាងច្រើន (+២២%) ធៀបនឹងឆ្នាំ២០០០ គឺឡើងដល់ ៥២៥លានដុល្លារនៅចុងឆ្នាំ២០០១ ។

ខណៈដែលវិនិយោគឯកជនធ្លាក់ចុះយ៉ាងខ្លាំង ការបង្កើតការងារនៅក្នុងវិស័យផ្លូវការនានាមានកំរិតយ៉ាងទាបនៅឆ្នាំ២០០១ ។ ក្នុងវិស័យកាត់ដេរ រោងចក្រជាង

៣០បានបិទទ្វារ ប៉ុន្តែផលិតកម្មក្នុងវិស័យនេះនៅតែបន្តកើនឡើង ពីព្រោះរោងចក្រមួយចំនួន បានបង្កើនផលិតកម្មដោយបង្កើនវេណធ្វើការ ដើម្បីបំពេញតំរូវការពីបរទេស ។ តាមអង្កេតរបស់ វិបសអ ម្ចាស់រោងចក្របានជួលកម្មករបន្ថែមតាមកិច្ចសន្យាការងារបណ្ដោះអាសន្ន ដើម្បីដំណើរការផលិតសំលៀកបំពាក់នៅពេលយប់ ។ ជាលទ្ធផល ការងារមិនសូវជាប់លាប់ថ្មីប្រហែល ១០.០០០កន្លែងត្រូវបង្កើតឡើង ។ ក្នុងឧស្សាហកម្មទេសចរណ៍ កំណើនទេសចរអន្តរជាតិ ១៤% ក្នុងឆ្នាំ២០០១ ក៏បានបង្កើតការងារថ្មីជាង ៣.០០០កន្លែងដែរ ។ សរុបមក ការងារថ្មីជិតដល់ ២០.០០០ កន្លែងត្រូវបានបង្កើតក្នុងឆ្នាំ២០០១ ប៉ុន្តែមានយុវជនកម្ពុជាប្រមាណ ២០០.០០០នាក់បានចូលថ្មីទៅក្នុងទីផ្សារពលកម្ម[២] ។ ជាលទ្ធផល ចំនួនអ្នកធ្វើការងារមិនបានពេញលេញល្អបានកើនឡើងយ៉ាងខ្លាំង ពីព្រោះ វិស័យមិនផ្លូវការក្នុងកំរិតលូតលាស់ដូចសព្វថ្ងៃ គឺប្រហែលមិនអាចផ្ដល់ការងារមានផលិតភាពល្អសំរាប់ច្រើនគ្នាបានទេ ។ ចំពោះប្រាក់ចំណូលវិញ អង្កេត វិបសអ បង្ហាញថា ប្រាក់កំរៃក្នុងវិស័យផ្លូវការបន្តកើនឡើង ប៉ុន្តែប្រាក់កំរៃនៅក្នុងវិស័យមិនផ្លូវការបានធ្លាក់ចុះខ្លាំងនៅឆ្នាំ២០០១ ។

## ២.៤ សេចក្ដីសន្និដ្ឋានៈ និងទស្សនំខាងសេដ្ឋកិច្ច

ស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជាមិនរំពឹងថា នឹងមានការប្រែប្រួលច្រើនទេនៅឆ្នាំក្រោយ ពីព្រោះពុំឃើញមានការផ្លាស់ប្ដូរគោលនយោបាយអ្វីឱ្យបានខ្លាំងក្លា ។ នៅឆ្នាំ២០០២ និង ២០០៣ ផសស រំពឹងថានឹងកើនឡើងក្នុងកំរិតដូចពីមុនប្រមាណ ៥%

---

[២] ទោះជាគ្មាននិយមន័យណាចែងច្បាស់លាស់ពីវិស័យផ្លូវការ និងមិនផ្លូវការនៅកម្ពុជាក្ដី ក៏អ្នកស្រាវជ្រាវតែងសន្មតថា ក្រុមហ៊ុនធំៗ និងក្រុមហ៊ុនពហុជាតិ ដែលបានប្រកាសបង់ពន្ធ និងផ្សព្វផ្សាយបញ្ជីតុល្យការបានធ្វើសវនកម្ម គឺជាវិស័យផ្លូវការ (តួយ៉ាងដូចជា រោងចក្រកាត់ដេរ និងសណ្ឋាគារធំៗ) ។ កសិកម្មជីវព្រឹត្តិ (គ្រាន់តែមួយគ្រប់ហូប), ការលក់ដូរតូចតាច, ការផ្ដល់អាជីពដោយខ្លួនឯង (self-employment), និងការងារមានបៀវត្សរ៍ក្នុងសហគ្រាសធុនតូច ត្រូវបានចាត់ជាវិស័យមិនផ្លូវការ ។

ក្នុងមួយឆ្នាំ ។ ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ នឹងនៅតែជាក្បាលម៉ាស៊ីន សំរាប់ការពង្រីកសេដ្ឋកិច្ច ។ វិនិយោគឯកជនរំពឹងថា នឹងនៅតែខ្សោយដដែលក្នុងឆ្នាំ ២០០៣ ដោយសារតវិយាបទ "រង់ចាំមើលសិន" របស់មជ្ឈដ្ឋានភាគច្រើននៅក្នុងរយៈពេលមុនការបោះឆ្នោតជាតិក្នុងពេលខាងមុខ ។ ប៉ុន្តែវិនិយោគសាធារណៈអាចនឹងកើនឡើងដែរក្នុងពីរឆ្នាំខាងមុខនេះ ។

ស្របគ្នាទៅនឹងប្រទេសឯទៀតក្នុងតំបន់ អតិផរណារំពឹងថា នឹងមានកំរិតមធ្យមនៅក្នុងរយៈពីរឆ្នាំខាងមុខ ។ ទោះបីគេរំពឹងថា រដ្ឋាភិបាលនឹងបញ្ចេញសាច់ប្រាក់បន្ថែមទៀតសំរាប់បំពេញតំរូវការបោះឆ្នោតឆ្នាំក្រោយក្តី ក៏ប្រាក់រៀលនឹងមានលំនឹងគួរសម ធៀបនឹងដុល្លារក្នុងកំរិត ៣.៩០០-៤.០០០រៀល/ដុល្លារ ។ ប៉ុន្តែអត្រាប្តូរប្រាក់ជារឿងមួយពិបាកទស្សន៍ទាយណាស់ ហើយការប៉ាន់ស្មានត្រូវតែមានការបកស្រាយយ៉ាងប្រុងប្រយ័ត្ន ។ ប្រាក់បញ្ញើនៅធនាគារពាណិជ្ជ រំពឹងថានឹងកើនលឿនជាងផសស ចារិក ដែលឆ្លុះបញ្ចាំងពីកំណើនទំនុកចិត្តលើប្រព័ន្ធធនាគារ ។ ប៉ុន្តែឥណទានចំពោះពាណិជ្ជកម្មនៅកម្ពុជានឹងនៅតែមានកំរិតដដែល ដរាបណាគេមិនទាន់បានដោះស្រាយបញ្ហាមួយចំនួនដូចជា ការពង្រឹងក្របខ័ណ្ឌច្បាប់ស្តីពីការដាក់វត្ថុធានាជាដើម ។

ខាងហិរញ្ញវត្ថុសាធារណៈវិញ គំរោងថវិការជាតិសំរាប់ឆ្នាំ២០០២ ដែលរដ្ឋសភា និងព្រឹទ្ធសភាបានអនុម័ត គឺមានតុល្យភាពល្អ ។ ប៉ុន្តែការអនុវត្តន៍គំរោងថវិកាឆ្នាំ ២០០២ និង២០០៣ នឹងចោទការលំបាកដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសារការបោះឆ្នោតជាតិលើកក្រោយគ្រោងធ្វើនៅពាក់កណ្តាលឆ្នាំ២០០៣ ខាងមុខ ។ ជាលទ្ធផល ចំណាយថវិការំពឹងថានឹងកើនឡើង ។ ប៉ុន្តែ ចំណាយលើរដ្ឋបាលស៊ីវិលដែលរួមទាំងសោហ៊ុយធ្វើដំណើរ និងចំណាយផ្សេងទៀតរបស់មន្ត្រីរដ្ឋាភិបាលផង អាចនឹងកើនលើសផែនការក្នុងថវិកា ។

ស្របជាមួយនឹងកំណើនសេដ្ឋកិច្ច ៥% ក្នុងឆ្នាំ២០០២ និង២០០៣ ការងារក្នុងវិស័យផ្លូវការមួយចំនួនរំពឹងថានឹងត្រូវបង្កើតឡើង ប៉ុន្តែ មិនបានច្រើនតាមតំរូវការ

របស់ប្រទេសកម្ពុជាទេ ដោយសារសមាមាត្រយ៉ាងធំពលរដ្ឋមានអាយុ១៥-២៥ឆ្នាំ ជនចំណូលថ្មីទៅក្នុងទីផ្សារពលកម្មប្រហែលមានច្រើនជាង ២០០.០០០នាក់ក្នុងមួយឆ្នាំៗ ។ ប៉ុន្តែក្នុងមួយឆ្នាំៗ ការងារផ្លូវការថ្មីដែលបង្កើតបាន មានជាមធ្យមមិនលើសពី ២០.០០០នាក់ទេ ដូច្នេះសំរាប់ពលករចំណូលថ្មីប្រហែល ១៨០.០០០នាក់ទៀត ភាគច្រើននឹងត្រូវបង្ខំចិត្តធ្វើការងារកសិកម្មនៅជនបទ ឬទទួលយកការងារមានប្រាក់កំរៃ/ផលិតភាពទាបនៅទីក្រុង ។ ដើម្បីស្រូបយកកំលាំងពលកម្មថ្មីទាំងនេះ សេដ្ឋកិច្ចកម្ពុជាត្រូវមានអត្រាកំណើនជាលេខពីរខ្ទង់ ដូចប្រទេសអាស៊ីមួយចំនួនដែលធ្វើឧស្សាហតូបនីយកម្មថ្មីៗនៅកំឡុងឆ្នាំ១៩៨៥-៩៥ ។ ដើម្បីសំរេចកំណើននេះ វិនិយោគមានផលិតភាពនៅកម្ពុជា ត្រូវមានទំហំ ១០ដងធំជាងតួលេខដែលគេកំពុងរំពឹងទុកសំរាប់អនាគតដ៏ខ្លីខាងមុខ ។ ជោគជ័យនៅក្នុងកំណែទំរង់ស្ថាប័ន គឺជាកត្តាគន្លឹះដើម្បីជំរុញវិនិយោគនៅកម្ពុជា ។

ចំពោះចំណូលគ្រួសារ គេអាចរំពឹងពីការកែលំអគួរឱ្យកត់សំគាល់ តែនៅក្នុងវិស័យសេវាកម្មមួយមុខប៉ុណ្ណោះ ។ ប្រាក់កំរៃនៅក្នុងវិស័យបឋម (primary sectors) ប្រហែលមិនអាចកើនឡើងជាដុំកំភួនទេ ហើយកំណើនប្រាក់កំរៃក្នុងវិស័យកាត់ដេរក៏ប្រហែលមិនបានច្រើនទេបើធៀបនឹងឆ្នាំមុនៗ ។ ការធ្វើការងារមិនពេញលទ្ធភាព (underemployment) ដែលមានយ៉ាងច្រើននៅតាមជនបទ បានបង្កឧបសគ្គមួយទៀតដល់ការកាត់បន្ថយភាពក្រីក្រ ។ ស្ថានភាពប្រហាក់ប្រហែលនេះ ក៏អាចកើតមាននៅក្នុងវិស័យសេវាកម្មក្រៅផ្លូវការនៅទីក្រុងដែរ ដោយសារចំនួនជនចំណាកស្រុកពីជនបទមកទីក្រុងចេះតែបន្តកើនឡើង ។

# ជំពូកទី ៣
# របាយការណ៍លំអិតស្ដីពី
# លទ្ធផលប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា

## ៣.១ សេចក្ដីផ្ដើម: បរិយាកាសសេដ្ឋកិច្ចពិភពលោក

អត្រាកំណើនសេដ្ឋកិច្ចពិភពលោក ធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ២០០១។ ការធ្លាក់ចុះផ្នែកពតិមានវិទ្យា ទូរគមនាគមន៍ និងបច្ចេកវិទ្យា (Information, Communication and Technology: ICT) ដែលចាប់ផ្ដើមនៅអាមេរិកនៅពាក់កណ្ដាលឆ្នាំ២០០០ បានរាលដាលដល់វិស័យផ្សេងទៀតនៃសេដ្ឋកិច្ចនៅពាក់កណ្ដាលឆ្នាំ២០០១ និងធ្លាក់ធ្ងន់ធ្ងរក្លាយជាការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដោយសារតំរូវការបានចុះខ្សោយ ។ តារាង២.១ ដែលកសាងពីទិន្នន័យថ្មីបំផុតរបស់ IMF, ADB និង The Economist[៣] បង្ហាញថា ផលិតផលពិភពលោកកើនតែ ១,៧% ក្នុងឆ្នាំ២០០១ ធៀបនឹង ៤,៧% ក្នុងឆ្នាំ២០០០ ។ សេដ្ឋកិច្ចនានានៅអាស៊ីអគ្នេយ៍ មានកំណើន ផសស ពិត តែត្រឹម ២,៤% ក្នុងឆ្នាំ២០០១ ធៀបនឹង ៥,២% ក្នុងឆ្នាំមុន ។ ចំពោះបណ្ដាសេដ្ឋកិច្ចធ្វើឧស្សាហូបនីយកម្មថ្មីនៅក្នុងតំបន់ មានជាអាទិ៍ ហុងកុង តៃវ៉ាន់ សឹង្ហបុរី និងកូរ៉េខាង

---

[៣] សូមអាន IMF (2001), ABD (2002) និងច្បាប់ចេញផ្សាយផ្សេងៗនៅខែមីនា និងឧសភា ២០០២ របស់ The Economist ។

ត្បូង ទិន្នន័យថ្មីៗបំផុតបង្ហាញថា កំណើនសេដ្ឋកិច្ចជាមធ្យម មានកំរិតសូន្យក្នុងឆ្នាំ២០០១ ធៀបនឹងកំណើន ៨,២% ក្នុងឆ្នាំ២០០០ ។

ដើម្បីជំរុញសេដ្ឋកិច្ចអាមេរិក ធនាគារកណ្តាលអាមេរិក បានបញ្ចុះអត្រាការប្រាក់ចំនួន ១១ដង ក្នុងឆ្នាំ២០០១ (ឆ្នាំប្រតិទិនមានការបញ្ចុះការប្រាក់ច្រើនលើកបំផុត) ដែលធ្វើឱ្យអត្រាការប្រាក់នៅធនាគារកណ្តាលអាមេរិកចុះដល់ ១,៧៥% ដែលជាកំរិតទាបបំផុតក្នុងរយៈ ៤០ឆ្នាំកន្លងមក ។ អាំងឌីកាទ័រសេដ្ឋកិច្ចចុងក្រោយដែលផ្សព្វផ្សាយក្នុងត្រីមាសទី១ ឆ្នាំ២០០២, ហាក់ដូចជាបង្ហាញថា គោលនយោបាយរូបិយវត្ថុដ៏រឹងមាំបានចាប់ផ្តើមផ្តល់លទ្ធផលជាវិជ្ជមានខ្លះហើយៈ ទំនុកចិត្តរបស់អ្នកប្រើប្រាស់នៅអាមេរិកកើនឡើង, ស្តុកទំនិញរបស់អាជីវកម្មបានកើនឡើង, ទីផ្សារពលកម្មកំពុងមានលំនឹងវិញ ហើយការធ្លាក់ចុះក្នុងវិស័យកម្មន្តសាលក៏កំពុងបញ្ចប់ដែរ ។ ប្រទេសអាស៊ីមួយចំនួនកំពុងរៀបចំខ្លួនចាំទទួលការរើបសេដ្ឋកិច្ចឡើងវិញ ។ ប៉ុន្តែដើម្បីឱ្យការរើបឡើងវិញមានចីរភាព ទាំងការចំណាយរបស់អ្នកប្រើប្រាស់ ទាំងការវិនិយោគរបស់អាជីវកម្ម ត្រូវតែកើនឡើងជាចាំបាច់ ។ ប៉ុន្តែបញ្ហាចោទគឺនៅអាមេរិក ទាំងអ្នកប្រើប្រាស់ ទាំងក្រុមហ៊ុន មានជំពាក់បំណុលគេយ៉ាងច្រើន ។ ក្នុងករណីដែលសេដ្ឋកិច្ចអាមេរិកមិនបានរើបឡើងវិញយ៉ាងឆាប់រហ័ស ប្រហែលអាចកើតមានវិបត្តិតូចមួយចំពោះសេដ្ឋកិច្ចពិភពលោក ពីព្រោះទីផ្សារអាមេរិកនៅសំខាន់ខ្លាំងសំរាប់ការនាំចេញ ។ ជប៉ុនហាក់ដូចជាធ្លាក់ចុះកាន់តែជ្រៅទៅក្នុងបរិត្តផរណា ។ ក្រៅពីអាល្លឺម៉ង់ចេញ ជាទូទៅនៅអឺរ៉ុបគេបានគេចផុតពីការធ្លាក់ចុះសេដ្ឋកិច្ច ។ ប៉ុន្តែក្នុងពេលសព្វថ្ងៃ អឺរ៉ុបមានឥទ្ធិពលតិចតួចទៅលើកំណើនសេដ្ឋកិច្ចនៅកម្ពុជា និងអាស៊ីអគ្នេយ៍ ពីព្រោះមានចំណែកតូចក្នុងការស្រូបយកទំនិញនាំចេញពីតំបន់នេះ ។

## តារាង៣.១ កំណើន ផសស ពិភពលោក និងអត្រាអតិផរណា

| | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|
| | កំណើន ផសស | | | |
| **ពិភពលោក** | **4.7%** | **1.7%** | **2.0%** | **3.5%** |
| អាមេរិក | 4.9% | 1.2% | 1.7% | 3.6% |
| អឺរ៉ុប ១ | 3.4% | 1.2% | 1.9% | 2.8% |
| ជប៉ុន | 1.7% | -1.3% | -0.5% | 1.1% |
| អាស៊ីខាងជើង ២ | 8.0% | 4.0% | 5.1% | 6.8% |
| អាស៊ីអគ្នេយ៍ ៣ | 5.2% | 2.4% | 3.3% | 5.0% |
| | អត្រាអតិផរណា | | | |
| អាមេរិក | 3.4% | 2.9% | 1.5% | 2.1% |
| អឺរ៉ុប ១ | 2.3% | 2.6% | 2.0% | 2.3% |
| ជប៉ុន | -0.6% | -0.5% | -1.0% | -0.5% |
| អាស៊ីខាងជើង ២ | 0.6% | 1.4% | 1.0% | 1.3% |
| អាស៊ីអគ្នេយ៍ ៣ | 4.7% | 5.9% | 5.3% | 4.5% |

*ប្រភព: CDRI, ប្រមូលពី IMF, ADB Outlook និង The Economist Pools; ១. Euro Area; ២. រួមទាំង ចិន, ហុងកុង, តៃវ៉ាន់, និងកូរ៉េខាងត្បូង ៣. រួមទាំងឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ាឡេស៊ី សិង្ហបូរី ថៃ និងវៀតណាម ។*

ពតិមានត្រួសៗក្នុងតារាង៣.១ បង្ហាញថា សេដ្ឋកិច្ចអាមេរិករំពឹងថានឹងមានកំណើន ១,៧% ក្នុងឆ្នាំ២០០២ ធៀបនឹង ១,២% ក្នុងឆ្នាំ២០០១ និង ៤,៩% ក្នុងឆ្នាំ២០០០ ។ នៅតំបន់អឺរ៉ូ សេដ្ឋកិច្ចរំពឹងមានកំណើន ១,៩% ក្នុងឆ្នាំ២០០២ ធៀបនឹង ១,២% ក្នុងឆ្នាំ២០០១ និង ៣,៤% ក្នុងឆ្នាំ២០០០ ។ ប៉ុន្តែនៅជប៉ុន សេដ្ឋកិច្ចអាចបន្តធ្លាក់ចុះទៀត ដោយមានកំណើន -០,៥% ក្នុងឆ្នាំ២០០២ ធៀបនឹង -១,៣% ក្នុងឆ្នាំ២០០១ និង ១,៧% ក្នុងឆ្នាំ២០០០ ។ នៅអាស៊ី ស្ថានភាពសេដ្ឋកិច្ចនឹងមានលំនាំស្របតាមដំណើរងើបឡើងវិញនៃសេដ្ឋកិច្ចនៅអាមេរិក និងអឺរ៉ុប ។ នៅអាស៊ីខាងជើង សេដ្ឋកិច្ច រំពឹងថាមានកំណើន ៥,១% ក្នុងឆ្នាំ២០០២ ធៀបនឹង ៤,០% ក្នុងឆ្នាំ២០០១ និង ៨,០% ក្នុងឆ្នាំ២០០០ ។ នៅអាស៊ីអគ្នេយ៍ សេដ្ឋកិច្ចប្រហែលមានកំណើន ៣,៣%

ក្នុងឆ្នាំ២០០២ ធៀបនឹង ២,៤% ក្នុងឆ្នាំ២០០១ និង ៥,២% ក្នុងឆ្នាំ២០០០ ។ ក្បាលម៉ាស៊ីនដែលជំរុញកំណើនសេដ្ឋកិច្ចនៅអាស៊ីខាងជើង គឺសេដ្ឋកិច្ចចិន ។

អតិផរណាពិភពលោក ថយចុះដោយសារឥទ្ធិពលនៃការធ្លាក់ចុះសេដ្ឋកិច្ច ។ នៅអាមេរិក អតិផរណាថយចុះមកត្រឹម ១,៦% ក្នុងខែធ្នូ ឆ្នាំ២០០១ ធៀបនឹង ៣,៤% កាលពីមួយឆ្នាំមុន ។ នៅតំបន់អឺរ៉ូ អតិផរណាថយចុះមកត្រឹម ២,១% ក្នុងខែធ្នូ ឆ្នាំ២០០១ ធៀបនឹង ២,៦% កាលពីមួយឆ្នាំមុន ។ សេដ្ឋកិច្ចភាគច្រើននៅអាស៊ីក៏មាននិន្នាការប្រហាក់ប្រហែលគ្នាដែរ ។ ភាពមិនច្បាស់លាស់ពីអនាគតនៃសេដ្ឋកិច្ចបានធ្វើឱ្យអត្រាប្តូរប្រាក់ឡើងចុះយ៉ាងខ្លាំងនៅក្នុងទីផ្សារអន្តរជាតិ ។ ពីខែមករា-ធ្នូ ឆ្នាំ២០០១ ដុល្លារអាមេរិកឡើងថ្លៃគួរឱ្យកត់សំគាល់ធៀបនឹងប្រាក់អឺរ៉ូ និងយ៉េន ដោយមួយដុល្លារប្តូរបាន ១,១៣អឺរ៉ូ ឬ ១៣៣យ៉េន នៅខែធ្នូ ធៀបនឹង ១,០៦អឺរ៉ូ ឬ ១១៦យ៉េនកាលពីខែមករា ។ ដុល្លារអាមេរិកក៏ឡើងថ្លៃគួរសំគាល់ដែរ ធៀបនឹងរូបិយវត្ថុអាស៊ីឯទៀត ដូចជា ដុល្លារសិង្ហបុរី វ៉ុនកូរ៉េ ដុល្លារតៃវ៉ាន់ និងប្រាក់បាតថៃ ។

ថ្លៃទំនិញនៅទីផ្សារអន្តរជាតិបានធ្លាក់ចុះនៅឆ្នាំ២០០១ លើកលែងតែថ្លៃមាស ។ ថ្លៃអង្ករលេខ១នៅក្រុងបាងកក បានធ្លាក់ចុះ ៦% ដោយលក់បាន ១៧៣ដុល្លារ/តោននៅត្រីមាសទី១ ឆ្នាំ២០០១ ធៀបនឹង ១៨៥ដុល្លារ/តោនកាលពីមួយឆ្នាំមុន ។ ឈើ និងកៅស៊ូធ្លាក់ថ្លៃប្រហែល ២០% ឯសណ្តែកសៀងក៏ធ្លាក់ថ្លៃ ១០% ក្នុងរយៈពេលដូចគ្នាដែរ ។ លើសពីនេះទៀត គេបានកត់សំគាល់ថា ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បានប៉ះពាល់យ៉ាងខ្លាំងដល់ថ្លៃប្រេង ។ ប្រេងឆៅនៅឌុយបៃលក់ក្នុងថ្លៃ ២៧ដុល្លារ/ធុងនៅដើមឆ្នាំ២០០១ រួចចុះដល់ ២៥ដុល្លារ/ធុងនៅពាក់កណ្តាលឆ្នាំ២០០១ ហើយបន្តធ្លាក់ចុះរហូតដល់ ១៧ដុល្លារ/ធុងនៅចុងឆ្នាំ២០០១ ។ ប៉ុន្តែដោយគេរំពឹងថាមានការរើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក គួបផ្សំនឹងកិច្ចប្រឹងប្រែងរបស់ OPEC ដើម្បីទប់ទល់នឹងថ្លៃប្រេងឥន្ធនៈ, ប្រេងឆៅបានឡើងថ្លៃវិញដល់ ២៥ដុល្លារ/ធុងនៅខែមេសា ឆ្នាំ២០០២ ។

## ៣.២ ដំណើរការប្រតិបត្តិសេដ្ឋកិច្ចកម្ពុជា

### *៣.២.១ ដំណើរការប្រតិបត្តិទូទៅ*

សកម្មភាពសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០០១ បានដំណើរការល្អគួរសម បើធៀបនឹងសេដ្ឋកិច្ចប្រទេសអាស៊ីភាគច្រើន ។ ទោះបីជាមានផលប៉ះពាល់អវិជ្ជមានពីគ្រោះទឹកជំនន់នៅភាគខ្លះនៃប្រទេស ព្រមទាំងការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកយ៉ាងខ្លាំងក៏ដោយ ក៏គេប៉ាន់ថា កំណើន ផសស ពិតនៅឆ្នាំ២០០១ មានប្រមាណ ៥,៣% ធៀបនឹង ៥,៥% នៅឆ្នាំ២០០០ និង ៦,៨% នៅឆ្នាំ១៩៩៩ ។ ការធ្លាក់ចុះនេះបណ្តាលជាសំខាន់មកពីការរីកលូតលាស់មិនសូវច្រើននៃឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ និងការធ្លាក់ចុះនៃវិនិយោគទុនផ្ទាល់ពីបរទេស ។ បន្ទាប់ពីគ្រោះទឹកជំនន់នៅឆ្នាំ២០០០ ផលដំណាំបានរើបឡើងវិញយ៉ាងច្រើន ប៉ុន្តែផលិតកម្មទទួលពីធនធានធម្មជាតិ ដូចជាព្រៃឈើ និងនេសាទ នៅតែពុំមានការប្រែប្រួល ឬធ្លាក់ចុះ ។ ទោះជាយ៉ាងនេះក្តី ឧស្សាហកម្មនៅបន្តមាននិចលភាព ថ្វីបើទីផ្សារនាំចេញនៅក្នុងពិភពលោក បានរួញតូចក្តី ។ ការនាំចេញផលិតផលកាត់ដេរគឺជាកំលាំងដ៏សំខាន់ដែលរុញច្រានកំណើនសេដ្ឋកិច្ច ។ វិស័យសេវាកម្មក៏បានរីកធំដែរដោយសារការរីកចំរើននៃទេសចរណ៍ និងទូរគមនាគមន៍ ។

ចំពោះរចនាសម្ព័ន្ធវិញ ដោយសារការធ្លាក់ថ្លៃ និងការលូតលាស់យឺត ចំណែកវិស័យកសិកម្មនៅក្នុង ផសស ចារិកថយចុះយ៉ាងច្រើន គឺ ៣៣,៩% នៅឆ្នាំ១៩៩៩ មក ២៩,៥% នៅឆ្នាំ២០០០ និង ២៨,៤% នៅឆ្នាំ២០០១ ។ វិស័យឧស្សាហកម្មហាក់ដូចជាទទួលផលចំណេញយ៉ាងច្រើនបំផុតពីភាគហ៊ុន ។ ភាគហ៊ុនវិស័យឧស្សាហកម្ម (រួមទាំងផ្នែកសំណង់) បានកើនឡើងពី ២១,៨% នៅឆ្នាំ១៩៩៩ ដល់ ២៥,១% នៅឆ្នាំ២០០០ និង ២៥,៦% នៅឆ្នាំ២០០១ ។ វិស័យឧស្សាហកម្មកាត់ដេរមាននិចលភាពខ្លាំងជាងគេ ខណៈដែលចំណែកនៃអនុវិស័យឧស្សាហកម្មផ្សេងទៀតបានធ្លាក់ចុះ ។ វិស័យសេវាកម្ម ក៏កើនឡើងបន្តិចដែរគឺពី ៤៤,៣% នៅឆ្នាំ១៩៩៩ ដល់ ៤៥,៤% នៅ

ឆ្នាំ២០០០ និង ៤៦,០% នៅឆ្នាំ២០០១ ។ ទេសចរណ៍មាននិចលភាពខ្លាំងជាងគេនៅក្នុងវិស័យសេវាកម្ម ។

**តារាង៣.២ កំណើន ផសស ពិត តាមផ្នែក** (គិតជា%)

| | 1999 | 2000 | 2001 |
|---|---|---|---|
| **កសិកម្ម** | **1.4%** | **-2.4%** | **0.7%** |
| ដំណាំ និងសត្វចិញ្ចឹម | 6.5% | -0.9% | 3.3% |
| នេសាទ កៅស៊ូ និងព្រៃឈើ | -13.2% | -7.8% | -9.1% |
| **ឧស្សាហកម្ម** | **12.6%** | **16.7%** | **11.2%** |
| កាត់ដេរ | 40.4% | 59.5% | 24.6% |
| ឧស្សាហកម្មផ្សេងទៀត | 3.2% | -2.9% | 1.1% |
| **សេវាកម្ម** | **9.4%** | **7.5%** | **6.1%** |
| ទេសចរណ៍ | 16.0% | 13.4% | 8.8% |
| សេវាកម្មផ្សេងទៀត | 8.4% | 6.5% | 5.6% |
| **សរុប** | **6.8%** | **5.5%** | **5.3%** |

*ប្រភព: CDRI, កសាងចេញពីទិន្នន័យបឋមរបស់រដ្ឋាភិបាល ។*

**តារាង៣.៣ រចនាសម្ព័ន្ធនៃ ផសស ចារិក**(គិតជា%)

| | 1999 | 2000 | 2001 |
|---|---|---|---|
| **កសិកម្ម** | **33.9%** | **29.5%** | **28.4%** |
| ដំណាំ និងសត្វចិញ្ចឹម | 25.6% | 22.2% | 22.0% |
| នេសាទ កៅស៊ូ និងព្រៃឈើ | 8.3% | 7.3% | 6.4% |
| **ឧស្សាហកម្ម** | **21.8%** | **25.1%** | **25.6%** |
| កាត់ដេរ | 7.0% | 11.5% | 12.6% |
| ឧស្សាហកម្មផ្សេងទៀត | 14.7% | 13.5% | 13.0% |
| **សេវាកម្ម** | **44.3%** | **45.4%** | **46.0%** |
| ទេសចរណ៍ | 6.6% | 7.4% | 7.8% |
| សេវាកម្មផ្សេងទៀត | 37.7% | 38.0% | 38.1% |
| **សរុប** | **100.0%** | **100.0%** | **100.0%** |

*ប្រភព: CDRI, កសាងចេញពីទិន្នន័យបឋមរបស់រដ្ឋាភិបាល*

### ៣.២.២ វិស័យកសិកម្ម

វិស័យកសិកម្មដែលមានចំណែកប្រហែល ៣០% នៃ ផសស កម្ពុជា និងប្រើពលកម្ម ៧៧% នៃកំលាំងពលកម្មសសរុប, បានកើនឡើងបន្តិចប្រហែល +០,៣% នៅឆ្នាំ២០០១ ។ កំណើនមិនសូវច្រើននេះបង្ហាញអំពីការឈោងចាប់ទីផ្សារនាំចេញនៅខ្សោយ (និងទីផ្សារទូទៅ) សំរាប់កសិផល, ការវិនិយោគទុនមិនគ្រប់គ្រាន់ដើម្បីបង្កើនផលិតភាព (ដំណាំជាទូទៅ ជាពិសេសដំណាំកៅស៊ូ) និងការធ្វើអាជីវកម្មហួសហេតុលើធនធានធម្មជាតិកាលពីមុន ដូចជាព្រៃឈើ និងត្រីជាដើម ។ ផលកសិកម្មកម្ពុជា ត្រូវបានគ្របសង្កត់ដោយកត្តាអាកាសធាតុ ព្រមទាំងកត្តាផ្សេងទៀត ដូចជាកម្មសិទ្ធិដីធ្លីពុំមានសុវត្ថិភាពជាដើម ។

ផលិតកម្មស្រូវឡើងដល់កំរិតគ្រប់គ្រាន់ សំរាប់ការផ្គត់ផ្គង់ស្បៀងក្នុងប្រទេស គឺ ៣,៥លានតោននៅឆ្នាំ១៩៩៥ ធៀបនឹង ២,០លានតោននៅទសវត្សរ៍១៩៨០ ។ កំណើននេះទទួលបានតាមការពង្រីកផ្ទៃដីដាំដុះ និងការកែលំអផលិតភាព ។ ផលិតកម្មស្រូវបន្តកើនឡើងយ៉ាងទៀងទាត់ គឺឡើងដល់ ៤លានតោននៅឆ្នាំ១៩៩៩ ដែលនៅឆ្នាំនោះមានការនាំចេញអង្ករប្រមាណ ៣០០.០០០តោន ។ ផលិតភាពកើនពី ១,៣តោន/ហិកតានៅឆ្នាំ១៩៨៥ ដល់ ១,៨តោន/ហិកតានៅឆ្នាំ១៩៩៥ និង ២តោន/ហិកតានៅឆ្នាំ១៩៩៩ ទោះបីវានៅតែស្ថិតក្នុងចំណោមផលិតភាពទាបៗបំផុតនៅអាស៊ីក៏ដោយ ។ ម្យ៉ាងទៀត ទោះបីជាមានកិច្ចប្រឹងប្រែងកែលំអបច្ចេកទេសដាំដុះ និងជំរុញការប្រើពូជថ្មីៗ និងជីក៏ដោយ ក៏ពុំមានកំណើនអ្វីគួរកត់សំគាល់ទេតាំងពីឆ្នាំ១៩៩៩ មក ដោយសារមានទឹកជំនន់ ការរាំងស្ងួត និងកង្វះការអភិវឌ្ឍន៍ក្នុងប្រព័ន្ធស្រោចស្រព ។ នៅឆ្នាំ២០០១ ទឹកជំនន់ធ្ងន់ធ្ងរក្នុងអាងទន្លេមេគង្គ, ទឹកភ្លៀងមិនទៀងទាត់ (ផ្ទៃដីស្រែមានស្រោចស្រពមិនដល់ ១០% ទេ) បានធ្វើឱ្យខូចខាតស្រូវ

ប្រហែល ២៥០.០០០ហិកតា[៤] ។ ការពង្រីកប្រព័ន្ធស្រោចស្រព, ការបែងចែកដីធ្លីដែលយកមកធ្វើការដាំដុះឱ្យបានប្រសើរឡើង និងការកែលំអប្រព័ន្ធទីផ្សារ, អាចជួយបង្កើនផលិតកម្មស្រូវនៅកម្ពុជា[៥] បានយ៉ាងច្រើន ។

នៅកម្ពុជា បន្លែ និងដំណាំផ្សេងទៀត ដើរតួយ៉ាងសំខាន់សំរាប់ការហូបចុក និងការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ។ បន្លែមួយភាគធំដាំដុះនៅលើដីធ្លីតាមគ្រួសារ ហើយនៅកម្ពុជាគេចាត់ទុកវាជាផលិតកម្មធុនតូច ។ ផ្ទៃដីដាំដុះ និងផលិតកម្មប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារការបំផ្លាញពីសត្វចង្រៃ និងជំងឺ, គ្រោះធម្មជាតិ និងការឡើងចុះថ្លៃ ។ អង្គការស្បៀងអាហារកសិកម្ម (FAO) ផ្តល់មតិថា មនុស្សម្នាក់គួរបរិភោគបន្លែ ២០០ក្រ/ថ្ងៃ ប៉ុន្តែការបរិភោគជាមធ្យមនៅកម្ពុជាបានប្រហែលតែពាក់កណ្តាលនៃកំរិតនេះប៉ុណ្ណោះ ។ គេប៉ាន់ស្មានថា ការហូបបន្លែសរុបមានប្រមាណ ៦០០.០០០តោន/ឆ្នាំ ។ បន្លែបេះពីព្រៃតំណាងឱ្យប្រហែល ២៥% នៃបន្លែបរិភោគទាំងអស់, បន្លែដាំក្នុងស្រុកប្រហែល ២៥% ទៀត ហើយបន្លែប្រមាណ ៥០% ទៀតនាំចូលមកពីប្រទេសជិតខាង[៦] ។ មាន NGOs ជាង ៤០ ក្នុងស្រុក និងអន្តរជាតិ កំពុងធ្វើសកម្មភាពក្នុងការកែលំអសន្តិសុខស្បៀងនៃប្រជាជនជនបទ តាមរយៈការដាំបន្លែសំរាប់បរិភោគ និងបង្កើនប្រាក់ចំណូល ។ តាមរយៈសកម្មភាពនេះ ផលិតកម្ម និងផលិតភាពនៃតំបន់ខ្លះ បានកើនឡើងគួរឱ្យកត់សំគាល់ ជាពិសេសនៅឆ្នាំ២០០១ ។ លើសពីនេះ ផ្នែកសាកវប្បកម្ម និងការចិញ្ចឹមសត្វ គួរបានទទួលអត្ថប្រយោជន៍ពីតំរូវការខ្ពស់នៃវិស័យទេសចរណ៍ (សណ្ឋាគារ និងភោជនីយដ្ឋាន) ។ ប៉ុន្តែ ហេដ្ឋារចនា

---

[៤] តួលេខក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបង្ហាញថា ២០០.០០០ហ.ត (ក្នុងចំនោម ២,៥លានហ.តដែលមានសក្តានុពល) ត្រូវបានស្រោចស្រព ។ តួលេខនេះខុសពីផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច របស់រដ្ឋាភិបាលកម្ពុជា (SEDP II) ។

[៥] ការសិក្សាធ្វើដោយ វបសអ និងអង្គភាពដទៃទៀត បញ្ជាក់គាំទ្ររឿងនេះ ។ សូមអានឯកសារ Sok, Sik និង Chea (2001) និង So *et al.* (2001) ។

[៦] សូមអាន Helen Keller Int'l (2000) ។ ទិន្នន័យទទួលបានតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ។

សម្ព័ន្ធយ៉ាប់យ៉ឺននៅជនបទ និងលក្ខណៈប្រកួតប្រជែងកំរិតទាបខាងថ្លៃ និងគុណភាព ធៀបនឹងបន្លែនាំចូល បានបង្កបញ្ហាចំពោះអ្នកដាំបន្លែនៅក្នុងស្រុក ។ ម្យ៉ាងទៀត ការបែងចែកធនធានដី និងការកំណត់ពីសិទ្ធិ និងការទទួលខុសត្រូវលើដីទាំងនោះ វាមានសារៈសំខាន់ជាគ្រឹះសំរាប់ការអភិវឌ្ឍន៍នៅកម្ពុជា ។ ក្នុងពេលបច្ចុប្បន្ន កម្ពុជាពុំទាន់មានសិទ្ធិកាន់កាប់ដីធ្លីច្បាស់លាស់ទេ ហើយរឿងនេះបានរារាំងអ្នកជំនួញចំពោះការវិនិយោគទុនយូរអង្វែង ដើម្បីញ៉ាំងឱ្យផលិតកម្មកសិកម្មមានចីរភាព ។ ប៉ុន្តែការអនុម័តច្បាប់ដីធ្លីថ្មី កាលពីខែសីហា ឆ្នាំ២០០១ បានដៅគន្លង សំរាប់ការគ្រប់គ្រងដីធ្លីនៅកម្ពុជា ដោយឈរលើមូលដ្ឋានច្បាប់ ។

ផលនេសាទនៅកម្ពុជាដែលជាធនធានទ្រព្យរួមដ៏សំបូរបែប បានដើរតួយ៉ាងសំខាន់នៅជនបទ ដោយផ្តល់ជាតិប្រូតេអ៊ីនដល់គ្រួសារកម្ពុជានានា ។ ប្រមាណ ៨៥% នៃផ្ទៃដីកម្ពុជា ស្ថិតនៅក្នុងអាងទន្លេមេគង្គ ។ ដីលិចទឹកមានប្រមាណ ១លានហិកតា ត្រូវជា ៥.៥% នៃផ្ទៃដីសរុបក្នុងប្រទេស ។ កន្លងមក ស្ថិតិនៃការចាប់ត្រីមិនដែលបានកត់ត្រាច្បាស់លាស់ទេ ។ តាមការប៉ាន់ស្មានរបស់គណៈកម្មាធិការទន្លេមេគង្គ ការចាប់ត្រីទឹកសាបប្រចាំឆ្នាំ មានប្រហែលពី ២៩០.000 ដល់ ៤៣០.000តោន ដូច្នេះការនេសាទត្រីទឹកសាបនៅកម្ពុជាមានទិន្នផលខ្ពស់ជាងគេនៅក្នុងតំបន់ (Van Zalinge *et al.* 2000) ។ ការនេសាទធុនតូចជាលក្ខណៈគ្រួសារ បានរីកដុះដាលយ៉ាងលឿន ។ ប៉ុន្តែក្រៅពីការនេសាទតាមវាលស្រែ ការនេសាទជាលក្ខណៈពាណិជ្ជកម្ម ហាក់ដូចជាធ្លាក់ចុះបន្តិចពីឆ្នាំ១៩៩៩ ដល់ ២០០១ ដោយសារការធ្វើអាជីវកម្មហួសកំរិតកាលពីពេលមុន[៧] ។ ដើម្បីសំរួលដល់លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ (នៅក្រោមកំណែទំរង់ជលផល) នៅក្នុងឆ្នាំ២០០១ រដ្ឋាភិបាលបានរំលាយឡូត៍នេសាទប្រហែល ៥០% ដើម្បីប្រគល់ទៅឱ្យសហគមន៍តាមមូលដ្ឋាន ។ អនុក្រឹត្យរដ្ឋាភិបាលស្តីពី "សហគមន៍នេសាទ" ដែលមានគោលដៅផ្ទេរការធ្វើអាជីវកម្មធនធានជលផល ទៅឱ្យសហគមន៍

[៧] McKenney, B. & Prom, T. CDRI, (2002)

ក្នុងស្រុក បានចូលជាធរមានតាំងពីខែមិថុនា ឆ្នាំ២០០១ ។ យោងតាមអនុក្រឹត្យនេះ ឡូត៍នេសាទស្ថិតនៅក្រោមសម្បទានឯកជន ត្រូវបានកាត់បន្ថយពី ១៣៥ឡូត៍ (៩៥៤.០០០ហិកតា) មកត្រឹម ៨២ឡូត៍ (៤១៧.០០ហិកតា) ។ វបសអ បានរកឃើញ ១៨៧សហគមន៍នេសាទនៅកម្ពុជា ភាគច្រើនត្រូវបានបង្កើតឡើងនៅក្រោយឆ្នាំ១៩៩៨ ដែលមានការជួយឧបត្ថម្ភពី NGOs និងទាយកនានា ។ ប៉ុន្តែ ការគ្រប់គ្រងធនធានជលផលដោយសហគមន៍អ្នកភូមិ ចាំបាច់ត្រូវមានការកែលំអ[៨] ។

ផលិតកម្មកៅស៊ូធ្លាក់ចុះគួរឱ្យកត់សំគាល់ ពីព្រោះដើមកៅស៊ូភាគច្រើនលែងមានផលិតភាពសេដ្ឋកិច្ច ដោយវាមានអាយុចាស់ជាង ៤០ឆ្នាំ ។ នៅឆ្នាំ២០០១ ផលិតកម្មកៅស៊ូចុះដល់ ៣៩.៤០០តោន ធៀបនឹង ៤៦.២០០តោននៅឆ្នាំ១៩៩៩ ។ ទោះបីមានការិតទាបយ៉ាងនេះក្តី ក៏កម្ពុជាស្ថិតនៅចំណាត់ថ្នាក់លេខ៥ នៃប្រទេសនាំចេញកៅស៊ូច្រើនជាងគេនៅលើពិភពលោក ។ លក្ខណៈដីអំណោយផលក្នុងខេត្តមួយចំនួន អាចផ្តល់លទ្ធភាពពង្រីកផ្ទៃដីដាំដុះបច្ចុប្បន្ន ៦១.០០០ហិកតាថែមទៀត ដល់ ៣៣០.០០០ហិកតា ដែលអាចផ្តល់ផលកៅស៊ូស្ងួតប្រមាណ ៥០០.០០០តោន/ឆ្នាំ គឺច្រើនលើសពីផលកៅស៊ូបច្ចុប្បន្នប្រមាណជាង ១០ដង ។ រដ្ឋាភិបាលកំពុងខិតខំជំរុញអ្នកដាំកៅស៊ូទ្រង់ទ្រាយតូច និងមធ្យម ដោយផ្តល់កំចីរយៈពេលវែង តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងជំនួយពីទីភ្នាក់ងារផ្តល់ជំនួយបារាំង (AFD) ។ ប្រតិបត្តិការនេះនៅមិនទាន់មានដំណើរការល្អទេ ដោយសារមានបទប្បញ្ញត្តិច្បាប់តឹងតែងស្តីពីកំចី ។ ដើម្បីបានទទួលកំចី អ្នកខ្ចីចាំបាច់ត្រូវមានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់ ។

ព្រៃឈើដែលជាប្រភពចំណូលបន្ថែមដ៏ចំបងមួយ ក្នុងចំណោមប្រភពចំណូលសំខាន់ៗរបស់ប្រជាជនក្រីក្រនៅជនបទ បានធ្លាក់ចុះខ្លាំង នៅដើមទសវត្សរ៍២០០០ ដោយសារការកាប់ឈើខុសច្បាប់យ៉ាងធ្ងន់ធ្ងរ និងការធ្វើអាជីវកម្មច្រើនហួសហេតុ

[៨] របាយការណ៍លំអិតមួយស្តីពីការគ្រប់គ្រងការនេសាទ រៀបចំដោយ វបសអ ។ សូមអាន McKenney, B. & Prom, T. (2002) ។

ក្នុងទសវត្សរ៍១៩៩០ ។ នាយកដ្ឋានរុក្ខាប្រមាញ់ ប៉ាន់ស្មានថា ព្រៃឈើនៅគ្របដណ្តប់ប្រហែល ១០,៩លានហិកតា ឬ ៥៨% នៃផ្ទៃប្រទេសនៅចុងទសវត្សរ៍១៩៩០ ធៀបនឹង ៧៣% ក្នុងទសវត្សរ៍១៩៦០ ។ ក្រុមហ៊ុនឯកជនដែលមានកិច្ចសន្យាសម្បទានព្រៃឈើរយៈពេលវែង បានកាន់កាប់ប្រហែល ៤០% នៃដីព្រៃ ។ តាមរបាយការណ៍ពិគ្រោះយោបល់មួយផ្តល់ថវិកាដោយធនាគារពិភពលោក និងរៀបចំឡើងដោយ DAI, អត្រានៃការកាប់យកឈើនៅរដូវកាប់ឈើឆ្នាំ១៩៩៧ មានកំរិតខ្ពស់ស្មើនឹង ៧ដង នៃកំរិតប្រមូលផលមានចីរភាព (ប្រហែល ៥០០.០០០ម៣/ឆ្នាំ) ហើយវានឹងធ្វើឱ្យអស់ធនធានក្នុងរយៈ ៥-១០ឆ្នាំ ។ ម្យ៉ាងវិញទៀត គុណភាពព្រៃឈើដែលនៅសល់ ធ្លាក់ចុះយ៉ាងលឿន ពីព្រោះឈើមានតំលៃខ្ពស់ៗត្រូវកាប់អស់ ។ ដើម្បីការពារព្រៃឈើពីការខូចខាតថែមទៀត កំណែទំរង់ព្រៃឈើបានចាប់ផ្តើមឡើង ដោយមានការឧបត្ថម្ភពីទាយកជាច្រើន ហើយវិធានការដោះស្រាយមួយចំនួនត្រូវបានដាក់អនុវត្តនៅក្នុងរយៈ ២-៣ឆ្នាំចុងក្រោយ ។ ជាលទ្ធផល ផលិតកម្មឈើមូល បានធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ២០០០[៩] ។ នៅក្នុងកំណែទំរង់ព្រៃឈើ ដើម្បីជួយសំរួលលទ្ធភាពប្រើប្រាស់ធនធានទ្រព្យរួម រដ្ឋាភិបាលកំពុងពិចារណាពីការអនុញ្ញាតឱ្យប្រជាជនមានលទ្ធភាពប្រើប្រាស់ដីព្រៃមួយចំនួន ប៉ុន្តែសេចក្តីលំអិតពីរឿងនេះមិនទាន់ផ្សព្វផ្សាយជាសាធារណៈនៅឡើយទេ ។ ដោយមានជំនួយពី NGOs, ប្រហែល ២០០សហគមន៍ព្រៃឈើត្រូវបានបង្កើតឡើងក្នុង ១៦ខេត្ត នៅចុងឆ្នាំ២០០១ ។ ប៉ុន្តែ ការគ្រប់គ្រងព្រៃឈើដោយសហគមន៍អ្នកភូមិ ត្រូវមានការកែលំអថែមទៀត[១០] ។

ក្នុងការផ្តួចផ្តើមដំបូងមួយដើម្បីធានាសុវត្ថិភាពកម្មសិទ្ធិដីធ្លី និងធ្វើឱ្យមានការវិនិយោគលើដីធ្លី រដ្ឋាភិបាលបានដំណើរការការងារសុរិយោដី ដើម្បីផ្តល់ប័ណ្ណ

---

[៩] របាយការណ៍របស់រដ្ឋាភិបាល សំរាប់ក្រុមពិគ្រោះយោបល់នៅ តូក្យូ ខែមិថុនា ២០០១ ។

[១០] របាយការណ៍លំអិតស្តីពីការគ្រប់គ្រងព្រៃឈើ រៀបចំឡើងដោយ វិបសអ ។ សូមអាន McKenney, B. & Prom, T. (2002) ។

កម្មសិទ្ធិចំពោះដីធ្លីទាំងអស់ក្នុងទូទាំងប្រទេស ព្រមទាំងកំនត់ពីការប្រើប្រាស់ដីផង ។ ការងារស៊ុរិយោដីនេះចាប់ផ្តើមនៅឆ្នាំ២០០១ ហើយរំពឹងថា នឹងបញ្ចប់នៅក្នុងរយៈពេលមួយទសវត្សរ៍ខាងមុខ ។ ធនាគារពិភពលោក, GTZ និងរដ្ឋាភិបាលហ្វាំងឡង់ ជាអ្នកជួយឧបត្ថម្ភដល់ដំណើរការនេះ ។

### *៣.២.៣ ឧស្សាហកម្ម និងសំណង់*

ឧស្សាហកម្មដែលរួមចំណែក ២៥% ដល់ ផសស និងប្រើប្រាស់ប្រហែល ៨% នៃកំលាំងពលកម្មសរុបនៅឆ្នាំ២០០០ បានរីកចំរើនយ៉ាងរហ័សក្នុងកំឡុងឆ្នាំ១៩៩៥-២០០០ (អត្រាកំណើនពិតប្រចាំឆ្នាំប្រហែល ១០%) ទោះបីមានការវាយប្រយុទ្ធនៅថ្ងៃទី៥-៦ កក្កដា ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុអាស៊ានៅឆ្នាំ១៩៩៧-៩៨ ក្តី ។ ឧស្សាហកម្មកាត់ដេរ, អគ្គិសនី និងទឹក គឺជាអនុវិស័យដ៏មាននិចលភាព ប៉ុន្តែសកម្មភាពនៅក្នុងឧស្សាហកម្មផ្សេងទៀតមានកំណើនយឺតៗនៅឡើយ ។ នៅឆ្នាំ២០០១ ឧស្សាហកម្មកាត់ដេរស្ថិតនៅតែជាវិស័យចំបងគេនៅកម្ពុជា ទោះបីផលិតកម្មបានថយចុះដោយសារតំរូវការនាំចេញចុះខ្សោយក្តី ។ សកម្មភាពក្នុងវិស័យមិនមែនផលិតសំលៀកបំពាក់ពុំមានការប្រែប្រួលទេ ដោយសារការធ្លាក់ចុះជាទូទៅនៃការវិនិយោគធ្វើអាជីវកម្ម និងលក្ខណៈប្រកួតប្រជែងទន់ខ្សោយ ។ ផលិតកម្មក្នុងឧស្សាហកម្មម្ហូបអាហារ និងថ្នាំជក់ កើនឡើងបន្តិចនៅឆ្នាំ២០០១ ស្របគ្នានឹងកំណើនប្រជាជន ពីព្រោះឧស្សាហកម្មទាំងនេះផ្គត់ផ្គង់ភាគច្រើនឱ្យទីផ្សារក្នុងស្រុក ។ សកម្មភាពក្នុងវិស័យឈើ បានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារឥទ្ធិពលនៃយុទ្ធនាការធ្វើរួមគ្នាដោយរដ្ឋាភិបាល និងទាយក ដើម្បីបំបាត់ការកាប់ឈើខុសច្បាប់ ។ សហគ្រាសធុនតូច និងមធ្យមមួយចំនួន ព្រមទាំងរោងចក្រតំលើងទោចក្រយានយន្តមួយកន្លែងសំរាប់បំរើទីផ្សារក្នុងស្រុក ត្រូវបានបង្កើតឡើង ។

ការព្រួយបារម្ភដំបូងពីការធ្លាក់ចុះនៃការនាំចេញសំលៀកបំពាក់នៅឆ្នាំ២០០១ មិនបានក្លាយជាការពិតទេ ។ ឧស្សាហកម្មកាត់ដេរ ដែលជានិយោជកធំជាងគេក្នុង

វិស័យឧស្សាហកម្មនៅកម្ពុជា បានបន្តកើនឡើង ទោះបីសេដ្ឋកិច្ចធ្លាក់ចុះនៅអាមេរិកក្តី ។ ការនាំចេញសំលៀកបំពាក់ពីកម្ពុជា ឡើងដល់ ១.១០០លានដុល្លារនៅឆ្នាំ ២០០១ (កំណើន ១៣% ធៀបនឹងឆ្នាំ២០០០) ក្នុងនេះ ការនាំចេញទៅអាមេរិកមាន ៧៩៣លានដុល្លារ, ទៅសហភាពអឺរ៉ុប (EU) ៣០៥លានដុល្លារ និងទីផ្សារផ្សេងទៀត ១៤លានដុល្លារ ។ ធៀបនឹងឆ្នាំ២០០០ ការនាំចេញសំលៀកបំពាក់ទៅអាមេរិកកើន ៦% និងទៅ EU កើន ៣៨% ។ ទោះបីពុំមានកំណើនធំដុំក្នុងទីផ្សារផ្សេងទៀតក្តី ក៏តួលេខនេះបញ្ជាក់ពីកំណើនយ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗនៃការនាំចេញទៅទីផ្សារ EU ។ ដូចមានរាយការណ៍ក្នុងបទសម្ភាន៏ជាមួយវិស័យកាត់ដេរ កំណើននេះអាចជាលទ្ធផលនៃការយល់ដឹងកាន់តែច្រើនក្នុងចំណោមអ្នកនាំចេញកម្ពុជា អំពីទីផ្សារ EU និងក៏រិតស្តង់ដារបស់ EU ។ នៅខែមេសា ១៩៩៩ EU បានផ្តល់លក្ខខណ្ឌពាណិជ្ជកម្មអនុគ្រោះពិសេស (special preferential trading status) សំរាប់រយៈពេលបីឆ្នាំ ចំពោះប្រទេសកម្ពុជា ដែលអនុញ្ញាតឱ្យអ្នកនាំចេញកម្ពុជា អាចនាំទំនិញចូលទីផ្សារ EU ដោយគ្មានកូតា និងគ្មានពន្ធ ។ ទោះយ៉ាងនេះក្តី មានសំលៀកបំពាក់នាំចេញពីកម្ពុជាប្រហែលតែ ១០% ប៉ុណ្ណោះដែលចូលទៅទីផ្សារ EU ក្រោមកិច្ចព្រមព្រៀងនេះ ។ យោងតាមក្រសួងពាណិជ្ជកម្ម ការនាំចេញប្រមាណ ៩០% ទៀតគឺស្ថិតនៅក្រោមអត្រាពន្ធអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (Most Favoured Nation: MFN) ដែលមានក៏រិតជាមធ្យម ៩% ។ កត្តាផ្សេងទៀតដែលរាំងស្ទះដល់ការនាំចេញ គឺអសមត្ថភាពក្នុងការបំពេញតាមស្តង់ដាគុណភាព EU, និងការមិនប្រតិបត្តិតាមច្បាប់នៃប្រទេសនាំចូល[១១] ។ ដើម្បីរក្សានិងពង្រីកការនាំចេញ កម្ពុជាត្រូវស្វែងរកទីផ្សារសំលៀកបំពាក់ផ្សេងទៀតក្រៅពី EU និងអាមេរិក ព្រមទាំងកែលំអលក្ខណៈប្រកួតប្រជែងខាងថ្លៃដើម ។

[១១] ដើម្បីឱ្យទទួលប្រយោជន៍ដ៏ពេញលេញពីប្រពន្ធ័ GSP ឧស្សាហកម្មកាត់ដេរនៅកម្ពុជា ត្រូវតែប្រើយ៉ាងហោចណាស់ ៥០% នៃធាតុចូល (input) ក្នុងស្រុក ។

**តារាង៣.៤ រចនាសម្ព័ន្ធនៃការនាំចេញសំលៀកបំពាក់នៅកម្ពុជា (លានដុល្លារ)**

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|
| ការនាំចេញទំនិញសរុប | 848 | 723 | 873 | 912 | 1,048 | 1,393 | 1,502 |
| ការនាំចេញសំលៀកបំពាក់ | 27 | 79 | 227 | 378 | 553 | 985 | 1,112 |
| - ទៅអាមេរិក | - | 1 | 107 | 298 | 486 | 750 | 793 |
| - ទៅ EU | 26 | 75 | 112 | 76 | 58 | 221 | 305 |
| - ទីផ្សារឯទៀត | 1 | 4 | 8 | 4 | 9 | 14 | 14 |
| ការនាំចេញសំលៀកបំពាក់សរុបទៅអាមេរិក (%) | - | 1% | 47% | 79% | 88% | 76% | 71% |
| សំលៀកបំពាក់ជា % នៃការនាំចេញសរុប | 3% | 11% | 26% | 41% | 53% | 71% | 74% |

*ប្រភព: CDRI, ក្រសួងពាណិជ្ជកម្ម និងទីចាត់ការគយ*

រដ្ឋាភិបាលសហរដ្ឋអាមេរិក បានបន្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសំលៀកបំពាក់ឱ្យកម្ពុជាចំនួន ៣ឆ្នាំទៀត ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៤[១២] ។ កិច្ចព្រមព្រៀងនេះ អនុញ្ញាតឱ្យកម្ពុជានាំចេញផលិតផលកាត់ដេរទៅទីផ្សារអាមេរិកនៅក្រោមកូតាកំណត់មួយ ដោយមានអត្រាពន្ធគយ MFN ក៏រិត ១៧%[១៣] ។ រដ្ឋាភិបាលអាមេរិកបានបង្កើនកូតាសំរាប់ផលិតផលកាត់ដេររបស់កម្ពុជាចំនួន ៩% ក្នុងឆ្នាំ២០០១ និង ១៥% នៅក្នុងឆ្នាំ២០០០ ។ ចំពោះរដ្ឋាភិបាលកម្ពុជា កូតាបានបង្កើតឱកាសមួយសំរាប់រកចំណូលបន្ថែម ។ តាមការលក់កូតា រដ្ឋាភិបាល

១២ ការបង្កើន កូតាសំលៀកបំពាក់ វាផ្សារភ្ជាប់ទៅនឹងការគោរពបានល្អគួរសម "substantial compliance" ពីសំណាក់ភាគីកម្ពុជា ចំពោះលក្ខខណ្ឌធ្វើការងារល្អ ។ អង្គការពលកម្មអន្តរជាតិ (ILO) កំពុងតាមដានលក្ខខណ្ឌធ្វើពលកម្មនៅក្នុងរោងចក្រកាត់ដេរ ។

១៣ មានសំលៀកបំពាក់តែ ១២ប្រភេទប៉ុណ្ណោះ ដែលជាប់កូតា ។ សូមអាន Sok, Sik and Chea (2001) ។

កម្ពុជារកចំនួលបាន ១៧លានដុល្លារនៅឆ្នាំ២០០០ និង១៨លានដុល្លារឆ្នាំ២០០១ ។ ឧស្សាហកម្មកាត់ដេរ ដើរតួសំខាន់ក្នុងការបន្ថយភាពក្រីក្រនៅជនបទ ព្រោះប្រហែល ៨៥% នៃកម្មករកាត់ដេរកម្ពុជាជាស្ត្រីក្មេងៗ ហើយភាគច្រើនមកពីតំបន់ជនបទ ។

ជំរើសមួយដែលអាចជួយឧស្សាហកម្មកម្ពុជាកុំឱ្យធ្លាក់ចុះ គឺការចូលរួមនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) យ៉ាងឆាប់តាមអាចធ្វើបាន ។ សមាជិកភាពក្នុង WTO អាចជួយកម្ពុជាឱ្យពង្រីកទីផ្សារសំលៀកបំពាក់ទៅកន្លែងផ្សេងទៀតក្នុងពិភពលោក ។ ការលុបចោលកូតា សំរាប់អ្នកនាំចេញសំលៀកបំពាក់នៅឆ្នាំ២០០៥ ដែលនឹងអនុវត្តចំពោះគ្រប់សមាជិក WTO (លើកលែងតែចិនដែលត្រូវរង់ចាំដល់ឆ្នាំ ២០០៨) គឺជាឱកាសដ៏ល្អបំផុត ។ ទោះបីជាកម្ពុជាបានទទួលលក្ខខណ្ឌអនុគ្រោះ (preferential access) ចូលទីផ្សារអាមេរិក និង EU ក្នុង ២-៣ឆ្នាំចុងក្រោយនេះក្តី ប៉ុន្តែសមត្ថភាពដើម្បីពង្រីកការនាំចេញសំលៀកបំពាក់នៅអនាគត នឹងពឹងផ្អែកទៅលើលក្ខណៈប្រកួតប្រជែងខាងគុណភាព និងថ្លៃដើម ។ ការចូលជាសមាជិក WTO របស់ចិននៅខែធ្នូ ឆ្នាំ២០០១ និងកិច្ចព្រមព្រៀងទំនាក់ទំនងពាណិជ្ជកម្មរវាងអាមេរិក និងវៀតណាម នៅខែកញ្ញា ឆ្នាំ២០០១ រំពឹងថា នឹងបង្កើនការប្រកួតប្រជែងដណ្តើមទីផ្សារអន្តរជាតិ ចំពោះផលិតផលសំលៀកបំពាក់កម្ពុជា ។

**តារាង៣.៥ គំរោងវិនិយោគ និងការងារនៅក្នុងឧស្សាហកម្មកាត់ដេរ**

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|
| ចំនួនគំរោងដែលបានអនុម័ត | 120 | 144 | 48 | 83 | 45 | 51 | 19 |
| ចំនួនរោងចក្រ | 20 | 35 | 72 | 143 | 201 | 220 | 186 |
| ការងារ (ពាន់នាក់) | 48 | 58 | 90 | 120 | 150 | 200 | 210 |
| ការងារជាភាគរយនៃកំលាំងពលកម្មសរុប | 1.1% | 1.3% | 1.9% | 2.5% | 3.1% | 4.0% | 4.0% |
| ចំណូលរដ្ឋាភិបាលពីកូតា (លានដុល្លារ) | - | - | - | - | 30 | 17 | 18 |

*ប្រភព: CDRI, CDC និង GMAC*

ការរីកលូតលាស់ក្នុងវិស័យសំណង់ កើតចេញពីការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលទទួលហិរញ្ញប្បទានជាចំបងពីរដ្ឋាភិបាល តាមរយៈជំនួយទ្វេ និងពហុភាគី ។ សេដ្ឋកិច្ចទីផ្សារ គឺជាកត្តាចំបងមួយទៀតដែលរុញច្រានវិស័យសំណង់ទៅមុខក្នុងរយៈ ៧ឆ្នាំកន្លងមក ។ រោងចក្រកាត់ដេររាប់រយត្រូវបានសាងសង់ ហើយសំណង់សណ្ឋាគារ បានរីកដុះដាលយ៉ាងលឿននៅភ្នំពេញ សៀមរាប និងខេត្តដទៃទៀត ។ ប៉ុន្តែដោយ សារការធ្លាក់ចុះយ៉ាងខ្លាំងនៃវិនិយោគឯកជន ឧស្សាហកម្មសំណង់ បានធ្លាក់ចុះគួរឱ្យ កត់សំគាល់ក្នុងឆ្នាំ២០០០ ហើយនៅឆ្នាំ២០០១ ក៏មិនទាន់រើបពេញលេញវិញទេ ។ ការធ្លាក់ចុះវិនិយោគពាណិជ្ជកម្មយ៉ាងគំហុក នាំឱ្យមានការកាត់បន្ថយសំណង់អគារ ឃ្លាំង និងរោងចក្រយ៉ាងច្រើន ។ សំណង់លំនៅដ្ឋានក៏មិនសូវមានសកម្មភាពដែរ ដោយសារកង្វះតំរូវការផ្ទះសំបែង ។ ប៉ុន្តែកំណើនយ៉ាងខ្លាំងនៃវិនិយោគសាធារណៈ លើផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈតូចៗខ្លះទៀត (ផ្តួចផ្តើមដោយរដ្ឋាភិបាល ក្នុងរយៈពេលមុនការបោះឆ្នោតឃុំ-សង្កាត់) បានប៉ះប៉ូវយ៉ាងច្រើនដល់ការធ្លាក់ចុះនៃ សំណង់អគារ និងផ្ទះ ។ សង្ខេបមក ឧស្សាហកម្មសំណង់បានរើបចេញពីការរួញចុះ (contraction) ៨% នៅឆ្នាំ២០០០ មកជាការរីកលូតលាស់បាន ៣% នៅឆ្នាំ២០០១ ។

### *៣.២.៤ សេវាកម្ម*

វិស័យសេវាកម្មដែលរួមចំណែក ៤៥%នៃ ផសស ហើយដែលប្រើប្រាស់ ប្រហែល ១៥% នៃកំលាំងពលកម្ម មានវេទយិតភាព (sensitive) ជាមួយការវិវត្តន៍ ខាងនយោបាយ ។វិស័យនេះបានរីកចំរើនយ៉ាងលឿន (ប្រហែល ១០% ក្នុងមួយឆ្នាំ) ពីឆ្នាំ១៩៩២ ដល់ ១៩៩៦ ជាសំខាន់គឺដោយសារការរីកលូតលាស់ខាងការដឹកជញ្ជូន ទូរគមនាគមន៍ និងទេសចរណ៍ ។ ប៉ុន្តែការរីកចំរើនត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយ វិបត្តិនយោបាយផ្ទៃក្នុងនៅឆ្នាំ១៩៩៧ និង ១៩៩៨ ។ ក្រោយពីមានស្ថិរភាព នយោបាយវិញ សកម្មភាពក្នុងវិស័យសេវាកម្ម បានរីកចំរើនជាថ្មីនៅឆ្នាំ១៩៩៩ ។ នៅឆ្នាំ២០០១ វិស័យសេវាកម្មនៅតែមាននិចលភាព ទោះបីវាបានធ្លាក់ចុះខ្លះធៀប

ទៅនឹងឆ្នាំមុន១ក្តី ។ វិស័យដឹកជញ្ជូនកើន ៨,៧% នៅឆ្នាំ២០០១ ធៀបនឹង ១២,៣% នៅឆ្នាំ២០០០ ។ សកម្មភាព ជំនួញកើន ៥,៧% នៅឆ្នាំ២០០១ ធៀបនឹង ៦,៤% នៅឆ្នាំ២០០០ ។ វិស័យទេសចរណ៍បានធ្លាក់ចុះប្រហាក់ប្រហែលគ្នា: កំណើន ៨,៨% នៅឆ្នាំ២០០១ ធៀបនឹង ១៣,៤% នៅឆ្នាំ២០០០ ។ ជារួមវិស័យសេវាកម្មកើន ៦,១% នៅឆ្នាំ២០០១ ធៀបនឹង ៧,៥% នៅឆ្នាំ២០០០ ។

យោងតាមលទ្ធផលដំបូងផ្សព្វផ្សាយដោយ WTO ឆ្នាំ២០០១ មិនអំណោយផលដល់ទេសចរណ៍ពិភពលោកទេ ពីព្រោះមានការធ្លាក់ចុះជាទូទៅ ។ អ្នកដំណើរមកដល់ពីអន្តរជាតិធ្លាក់ចុះ ១,៣% ហើយតំបន់ដែលប៉ះពាល់ខ្លាំងជាងគេគឺ អាមេរិក មជ្ឈិមបូព៌ា និងអាស៊ីខាងត្បូង ។ នៅឆ្នាំ២០០១ អត្រាធ្លាក់ចុះ អ្នកដំណើរមកដល់គឺ អាមេរិក ៧,០% មជ្ឈិមបូព៌ា ៨,៨% និងអាស៊ីខាងត្បូង ៦,៤% (ធៀបនឹងឆ្នាំ ២០០០) ។ គេយល់ថាការធ្លាក់ចុះទាំងនេះ បណ្តាលមកពីការចុះខ្សោយសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០០១ គួបផ្សំនឹងការវាយប្រហារដោយភេរវជននៅថ្ងៃទី១១ កញ្ញា នៅអាមេរិក ព្រមទាំងអស្ថិរភាពនយោបាយ និងអំពើហិង្សានៅមជ្ឈិមបូព៌ា ។ អឺរ៉ុបហាក់ដូចជាមានការប៉ះពាល់តិចជាងគេ ហើយប្រទេសបារាំង រំពឹងថា នឹងនៅតែជាគោលដៅទេសចរណ៍លេខមួយក្នុងពិភពលោក ។

**តារាង៣.៦ ចំនួនភ្ញៀវមកដល់ប្រទេសអាស៊ានមួយចំនួន (គិតជាលាននាក់)**

| | 2000 | 2001[1] | ភាគរយប្រែប្រួល |
|---|---|---|---|
| ម៉ាឡេស៊ី | 10.22 | 13.13 | 28.5 |
| ថៃ | 9.58 | 10.15 | 6.0 |
| សឹង្ហបុរី | 6.26 | 6.09 | -2.7 |
| ឥណ្ឌូនេស៊ី | 5.06 | 5.36 | 6.0 |
| ហ្វីលីពីន | 2.17 | 1.94 | -10.4 |
| វៀតណាម | 1.38 | 1.52 | 10.2 |
| កម្ពុជា[2] | 0.52 | 0.66 | 28.5 |

*ប្រភព: អង្គការទេសចរណ៍ពិភពលោក ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃកម្ពុជា ។ [1] តួលេខបាន់ស្មានដោយអង្គការទេសចរណ៍ពិភពលោក [2] តួលេខពិត ។*

ទោះបីជាមានឧប្បត្តិហេតុជាច្រើន បានជះឥទ្ធិពលអវិជ្ជមានដល់ទេសចរណ៍ពិភពលោកនៅឆ្នាំ២០០១ ក្តី ប៉ុន្តែកម្ពុជាហាក់ដូចមិនប៉ះពាល់អ្វីទេ ។ ឧស្សាហកម្មទេសចរណ៍កម្ពុជា បន្តលូតលាស់ ដោយសារមានទេសចរអន្តរជាតិមកដល់សរុប ៦៦២.០០០នាក់ (កើនឡើងជិតដល់ ៣០% បើធៀបនឹងឆ្នាំ២០០០) ក្នុងនេះ ៤៦៥.០០០នាក់មកដល់ប្រទេសកម្ពុជាតាមផ្លូវអាកាស, (២៩% តាមជើងហោះហើរអន្តរជាតិផ្ទាល់ទៅសៀមរាប) ។ ទេសចរអន្តរជាតិមកតាមយន្តហោះកើន ១៦% នៅឆ្នាំ២០០១ បើធៀបនឹងឆ្នាំ២០០០ ។ ចំនួនទេសចរចូលតាមផ្លូវទឹក ឬផ្លូវគោក ក៏កើនឡើងដែរ ។ តួលេខផ្តល់ដោយក្រសួងទេសចរណ៍កម្ពុជា បង្ហាញថា ចំនួនទេសចរមកដល់តាមរថយន្ត និងនាវា ឡើងដល់ ១៩៧.០០០នាក់ (កើនពី ១១៥.០០០នាក់ នៅឆ្នាំ២០០០) ។ តំបន់ប៉ោយប៉ែតនៅតាមព្រំដែនកម្ពុជា-ថៃ គឺជាច្រកចេញចូលផ្លូវគោកមមាញឹកជាងគេ ។

**តារាង៣.៧ ចំនួនភ្ញៀវអន្តរជាតិមកដល់កម្ពុជា (ពាន់នាក់)**

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|
| ភ្នំពេញ | 213 | 297 | 225 | 213 | 279 | 313 | 331 |
| សៀមរាប | - | - | - | 10 | 28 | 87 | 134 |
| សរុបតាមផ្លូវអាកាស | 213 | 297 | 225 | 223 | 307 | 400 | 465 |
| តាមផ្លូវគោក និងទឹក | - | - | - | 100 | 105 | 115 | 197 |
| ដំណើរមកដល់សរុប | - | - | - | 323 | 412 | 515 | 662 |

*ប្រភព: CDRI, ក្រសួងមហាផ្ទៃ និងទេសចរណ៍*

តាមអង្កេតថ្មីមួយរបស់ វិបសអ នៅសៀមរាប, ម្ចាស់សណ្ឋាគារភាគច្រើន និងប្រតិបត្តិករក្រុមហ៊ុនទេសចរណ៍ផ្សេងទៀត មានសុទិដ្ឋិនិយម និងសេចក្តីសង្ឃឹមយ៉ាងច្រើនសំរាប់អនាគត (Sok, Sik and Chea 2001) ។ ចំនួនសណ្ឋាគារនៅសៀមរាបកើនពី ៣៦ ក្នុងឆ្នាំ២០០០ ដល់ ៤៧ (ភាគច្រើនសណ្ឋាគារមានគុណភាពខ្ពស់) នៅចុងឆ្នាំ២០០១ ។ ផ្ទះសំណាក់ក៏កើនឡើងដែរ គឺពី ៧០ នៅឆ្នាំ២០០០ ដល់

១១២ នៅចុងឆ្នាំ២០០១ ។ អត្រាជួលបន្ទប់កើនពី ៦៥% នៅឆ្នាំ២០០០ ដល់ ៨០% នៅឆ្នាំ២០០១ ប៉ុន្តែរយៈពេលនៃការស្នាក់នៅគឺដូចមុនដដែល ប្រហែល ៣ថ្ងៃក្នុងមួយទស្សនកិច្ចនៅខេត្តសៀមរាប និង ៥ថ្ងៃក្នុងមួយទស្សនកិច្ចនៅភ្នំពេញ ។ ដោយសារកំណើនសណ្ឋាគារ និងផ្ទះសំណាក់ ម្ចាស់គ្រឹះស្ថានទាំងនេះបានកាត់បន្ថយថ្លៃបន្ទប់ពី ៥-១៥% ដើម្បីឆ្លើយតបនឹងកំណើនការប្រកួតប្រជែង ។

**ក្រាហ្វិក៣.១ ចំនួនទេសចរអន្តរជាតិចូលទស្សនាប្រាសាទអង្គរ (ពាន់នាក់)**




*ប្រភព: អាជ្ញាធរអប្សរា*

កំនើនទេសចរមកដល់នៅឆ្នាំ២០០១ មិនបានបង្កឱ្យកើនចំនួលក្នុងសមាមាត្រប៉ុនគ្នាទេ ។ ការប៉ាន់ស្មានដំបូងដោយ វបសអ បង្ហាញថា ប្រហែល ៣៥-៤៥% នៃចំណាយសរុបរបស់ទេសចរនៅសៀមរាប (អ្នកចូលមកតាមជើងហោះហើរអន្តរជាតិផ្ទាល់) បានស្ថិតនៅក្នុងប្រទេសកម្ពុជា ឯក្រៅពីនេះគឺបានទៅដល់ក្រុមហ៊ុនឯកជនបរទេស (Sok, Sik and Chea 2001) ។ ហើយទោះបីមានប្រាក់ ទេសចរតែមួយភាគតូចដែលធ្លាក់ទៅដល់ដៃប្រជាជនក្នុងស្រុកក៏ដោយ ក៏ម្ចាស់សណ្ឋាគារ និងក្រុមហ៊ុនទេសចរណ៍នានា រីករាយនឹងកំណើនអ្នកដើរកំសាន្ត ព្រមទាំងគោលនយោបាយបើកចំហជើងមេឃដែលរដ្ឋាភិបាលដាក់ឱ្យប្រើនៅចុងឆ្នាំ១៩៩៧ ។ ពួកគេមានសុទិដ្ឋិនិយមពីកំណើនលំហូរចូលនៃទេសចរក្នុងឆ្នាំខាងមុខ ដែលជាលទ្ធផលនៃការកែលំអហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ និងសេវាកម្ម) និងការហៀរចូលនៃទេសចរអន្តរជាតិមកពីប្រទេសជិតខាង ។ តាមការអង្កេតរបស់ វបសអ ប្រហែល ៩-១២% នៃទេសចរ

អន្តរជាតិ ដែលចូលមកតាមជើងហោះហើរផ្ទាល់ទៅខេត្តសៀមរាប បានបន្តដំណើរមកក្រុងភ្នំពេញទៀត ។

## ៣.៣ ថ្លៃ និងរូបិយវត្ថុ

### *៣.៣.១ ថ្លៃ និងអត្រាប្តូរប្រាក់*

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅក្រុងភ្នំពេញ ចងក្រងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ជាទូទៅមិនប្រែប្រួលទេនៅឆ្នាំ២០០១ គឺធ្លាក់ចុះតែបន្តិចប្រហែល 0,៦% នៅចុងឆ្នាំ (RGC 2001) ។ CPI នៅតាមខេត្តចងក្រងដោយ វបសអ ក៏បញ្ជាក់ពីការធ្លាក់ចុះអតិផរណានៅកម្ពុជាដែរ (-១,៦%នៅតាមខេត្ត) ។ តួលេខ NIS បង្ហាញថា ចាប់ពីខែធ្នូ ឆ្នាំ២000 ដល់ខែធ្នូ ឆ្នាំ២០០១ ថ្លៃម្ហូបអាហារនៅភ្នំពេញធ្លាក់ចុះ ៣% ដែលឆ្លុះបញ្ចាំងពីការធ្លាក់ថ្លៃយ៉ាងខ្លាំងនៃផលិតផលកសិកម្ម ។ ឧទាហរណ៍ ថ្លៃអង្ករនៅទីផ្សារក្រុងភ្នំពេញធ្លាក់១៩%, និងថ្លៃសាច់ជ្រូក និងសាច់មាន់ធ្លាក់ ៧% និង ១៥% ។ ថ្លៃទំនិញកសិកម្មកម្ពុជា វាផ្សារភ្ជាប់ទៅនឹងថ្លៃទំនិញអន្តរជាតិ ពីព្រោះកម្ពុជាបានបើកចំហព្រំដែនទាក់ទងពិភពខាងក្រៅ ។ តាំងពីពេលបើកច្រកព្រំដែនមកមានការហូរចូលនូវទំនិញកសិកម្មពីបណ្តាប្រទេសជិតខាង ។ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ថ្លៃទំនិញនៅទីផ្សារអន្តរជាតិ ធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ២០០១ ដែលនាំឱ្យមានការធ្លាក់ចុះថ្លៃទំនិញកសិកម្មកម្ពុជាផងដែរ ។ ទិន្នន័យ NIS បង្ហាញទៀតថា ថ្លៃផ្គត់ផ្គង់សាធារណៈ (utilities) កើនយ៉ាងខ្លាំងនៅឆ្នាំ២០០១ (ដូចជា ទឹកឡើងថ្លៃ ៨៨%, អគ្គិសនីឡើង ២៣%) ចំណែកឯប្រេងសាំង ឡើងថ្លៃក៏វិតមធ្យមប្រហែល ៣% ។ កំណើនយ៉ាងខ្លាំងនៃថ្លៃផ្គត់ផ្គង់សាធារណៈ ឆ្លុះបញ្ចាំងពីវិធានការរបស់រដ្ឋាភិបាល ដើម្បីកែតំរូវថ្លៃទំនិញប្រើប្រាស់ ឱ្យបានសមស្របតាមចំណាយផលិតកម្ម ។

**តារាង៣.៨ អតិផរណា និងអត្រាប្តូរប្រាក់នៅភ្នំពេញ**

| | 1999 | 2000 | 2001 |
|---|---|---|---|
| អត្រាអតិផរណាជារៀល (មធ្យមប្រចាំឆ្នាំ) | 4.0% | -0.8% | -0.6% |
| អត្រាអតិផរណាជារៀល (Q4/Q4) | 0.0% | 0.5% | -1.3% |
| អត្រាអតិផរណាជាដុល្លារ (មធ្យមប្រចាំឆ្នាំ) | 3.5% | -1.8% | -2.5% |
| អត្រាប្តូរប្រាក់ រៀល/ដុល្លារ (មធ្យមប្រចាំឆ្នាំ) | 3,820 | 3,859 | 3,950 |
| អត្រាប្តូរប្រាក់ រៀល/ដុល្លារ (ចុងគ្រា) | 3,775 | 3,895 | 3,930 |

*ប្រភព: ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា*

ចំពោះអត្រាប្តូរប្រាក់វិញ កម្ពុជាបានអនុវត្តគោលនយោបាយអត្រាប្តូរប្រាក់បណ្តែតចាប់តាំងពីឆ្នាំ១៩៩៣ និងពឹងផ្អែកលើគោលនយោបាយហិរញ្ញវត្ថុមួយដ៏តឹងរ៉ឹងដើម្បីធានាឱ្យមានស្ថិរភាពមួយក៏រិត នៅក្នុងទីផ្សារប្តូរប្រាក់អន្តរជាតិ ។ ធនបំរុងជាដុល្លារ ត្រូវបានធនាគារជាតិនៃកម្ពុជា (NBC) ប្រើប្រាស់ម្តងម្កាលដើម្បីធ្វើអន្តរាគមន៍ និងទប់ឱ្យនឹងវិញនូវការឡើងចុះអត្រាប្តូរប្រាក់ ។ ប្រព័ន្ធរូបិយវត្ថុកម្ពុជា មានប្រតិបត្តិការប្រើសាច់ប្រាក់ និងដុល្លារូបនីយកម្ម ក៏រិតខ្ពស់ ដែលបានកាត់បន្ថយលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការប្រើប្រាស់គោលនយោបាយរូបិយវត្ថុឱ្យបានសកម្ម និងសក្តិសិទ្ធិ ។ គេប្រើប្រាក់រៀលក្នុងប្រតិបត្តិការតូចៗ និងការទូទាត់ប្រាក់បៀវត្សរ៍ ជាពិសេសចំពោះរដ្ឋាភិបាល រីឯប្រតិបត្តិការហិរញ្ញវត្ថុធំៗបានធ្វើឡើងដោយប្រើរូបិយវត្ថុបរទេសដូចជាដុល្លារអាមេរិក និងប្រាក់បាតថៃ ។ បន្ទាប់ពីមានស្ថិរភាពជាទូទៅនៅក្នុងអត្រាប្តូរប្រាក់នៅឆ្នាំ១៩៩៨-២០០០ សាច់ប្រាក់រៀលបានកើនយ៉ាងច្រើន (+២៣%) នៅឆ្នាំ២០០១ ប្រហែលដោយសារកំនើនថវិកាដែលត្រូវផ្តល់សំរាប់ការបោះឆ្នោតឃុំ-សង្កាត់ ។ គួរកត់សំគាល់ថា ការបោះឆ្នោតឃុំ-សង្កាត់ គឺជាការបោះឆ្នោតបែបនេះលើកទី១ដែលត្រូវការថវិកាយ៉ាងច្រើនសំរាប់ការរៀបចំផ្សេងៗមុនពេលបោះឆ្នោត ។ ជាលទ្ធផលប្រាក់រៀលបានធ្លាក់ថ្លៃ ធៀបនឹងប្រាក់ដុល្លារនៅក្នុង ៣ត្រីមាសដំបូង ប៉ុន្តែវាវើបឡើងវិញនៅក្នុងត្រីមាសទី៤ ។ នៅក្នុងមួយឆ្នាំពេញ ប្រាក់រៀលបានធ្លាក់ថ្លៃ ១,៩% ធៀបនឹងដុល្លារ (ពី ៣.៨៥៩ ដល់ ៣.៩៣៥រៀល/ដុល្លារ គិតជាមធ្យម

ប្រចាំឆ្នាំ) ។ ប្រាក់រៀលធ្លាក់ថ្លៃក្នុងកំរិតប្រហែលគ្នា ធៀបនឹងប្រាក់ដុងវៀតណាម ប៉ុន្តែវាមានលំនឹងធៀបនឹងប្រាក់បាតថៃ ដោយប្តូរបាន៨៩រៀល/បាតនៅឆ្នាំ២០០១ ។

### ៣.៣.២ ការផ្គត់ផ្គង់រូបិយវត្ថុ និងឥណទាន

សាច់ប្រាក់សរុបកត់ត្រាដោយ ធនាគារជាតិនៃកម្ពុជា មានប្រហែល ១៨% នៃ ផសស នៅចុងឆ្នាំ២០០១ ដែលស្មើនឹងពីរដងនៃកំរិតក្នុងឆ្នាំ១៩៩៥ ។ សាច់ប្រាក់ជារៀលមានប្រហែល ៥% នៃ ផសស ចំណែកឯប្រាក់ដុល្លារធ្វើចរាចរឆ្លងកាត់ប្រព័ន្ធធនាគារមានប្រហែល ១៣% នៃសាច់ប្រាក់សរុប[១៤] ។

ប្រាក់បញ្ញើជារូបិយវត្ថុបរទេស ដែលនិវាសជនបានដាក់ផ្ញើនៅតាមធនាគារពាណិជ្ជ បានកើន ២៤% នៅឆ្នាំ២០០១ ធៀបនឹង ៤២% នៅឆ្នាំ២០០០ និង ៣២% នៅឆ្នាំ១៩៩៩ ។ ប៉ុន្តែសញ្ញ័យកម្ពុជាបន្តហូរចេញទៅក្រៅប្រទេស ដោយសារឥណទានក្នុងស្រុកធ្លាក់ចុះ (-៥%) នៅឆ្នាំ២០០១ ។ វិធានការពីធនាគារកណ្តាលដើម្បីទប់ស្កាត់ការហូរចេញមូលធន មិនទាន់មានផ្លែផ្កានៅឡើយ ដោយសារគោលនយោបាយជាក់លាក់សំរាប់ការពារផលប្រយោជន៏របស់អ្នកឱ្យខ្ចីប្រាក់ និងអ្នកផ្ញើប្រាក់ មិនទាន់កសាងត្រឹមត្រូវទេ ។ ដូចក្នុងឆ្នាំ២០០០ ដែរ លំហូរនៃប្រាក់បញ្ញើថ្មីៗ និងបំណុលផ្សេងៗរបស់ធនាគារពាណិជ្ជកម្ម មានទំហំគួរឱ្យកត់សំគាល់ឡើងដល់ ១១០លានដុល្លារនៅឆ្នាំ២០០១ ឯធនបំរុងបរទេសនៅធនាគារកណ្តាលបានកើនដល់ប្រហែល ៦០លានដុល្លារ ។ ប៉ុន្តែភាគច្រើននៃកំណើនទាំងអស់នេះ បានហូរចេញទៅក្រៅប្រទេស ។ យោងតាមតួលេខដែលចងក្រងដោយធនាគារកណ្តាល បរិមាណនៃសញ្ញ័យកម្ពុជា[១៥] ដែលឆ្លងកាត់ប្រព័ន្ធធនាគារ មានប្រហែល ១.៣៥០លានដុល្លារនៅ

---

[១៤] ប្រព័ន្ធធនាគារកម្ពុជានៅខ្សោយ រូបិយវត្ថុបរទេសចរាចរក្រៅធនាគារមានបរិមាណខ្ពស់ ។

[១៥] ប្រាក់សញ្ញ័យសរុបកម្ពុជា ត្រូវគេកំណត់និយមន័យថា ជាបរិមាណសរុបនៃទ្រព្យសកម្មកាន់កាប់ដោយធនាគារពាណិជ្ជកម្ម និងធនាគារកណ្តាល ។ ធនបំរុងនៃធនាគារពាណិជ្ជដែលផ្ញើទុកនៅធនាគារកណ្តាល មិនត្រូវបានគណនាបញ្ចូលទេ ។

ចុងឆ្នាំ២០០១ ក្នុងនេះ ៥៤% (៧៣០លានដុល្លារ) ត្រូវបានឱ្យវិនិយោគិននៅក្រៅប្រទេសខ្ចី ។ គំឃើញនេះអាចធ្វើឱ្យអ្នកខ្លះភ្ញាក់ផ្អើល ពីព្រោះអត្រាការប្រាក់នៅកម្ពុជា ខ្ពស់ជាងនៅប្រទេសឯទៀត ។ ប៉ុន្តែ ធនាគារបានពិចារណាលើកត្តាមួយចំនួនទៀត ក្រៅពីរឿងចំណូលការប្រាក់មួយមុខនេះ មានដូចជាកង្វះកិច្ចគាំពារគ្រប់គ្រាន់ចំពោះអ្នកឱ្យខ្ចីប្រាក់ និងកង្វះយន្តការ ដោះស្រាយក្នុងករណីមានទំនាស់ ។

**ក្រាហ្វិក៣.២ ការប្រើប្រាស់សញ្ញ័យកម្ពុជាតាមរយៈប្រព័ន្ធធនាគារ (ចុងឆ្នាំ២០០១)**




*ប្រភព:ការគណនារបស់ វិបសអ ដោយផ្អែកលើតួលេខរបស់ NBC ។*

បច្ចុប្បន្ននៅកម្ពុជាមាន ១៩ធនាគារកំពុងដំណើរការ ។ ធនាគារពីរជាកម្មសិទ្ធិរដ្ឋ គឺធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា និងធនាគារអភិវឌ្ឍន៍ជនបទ ។ នៅឆ្នាំ១៩៩៨ គេឃើញមាន ៣០ធនាគារចុះបញ្ជី គឺធនាគារពាណិជ្ជកម្មក្រៅប្រទេសមួយជារបស់រដ្ឋ, ២២ធនាគារជារបស់វិនិយោគិនក្នុងស្រុក, និង ៧ធនាគារទៀតជាសាខារបស់ធនាគារបរទេស ។ NBC បានផ្តល់ពត៌មានថា តាមការអនុវត្តន៍ច្បាប់ថ្មីស្តីពីស្ថាប័នហិរញ្ញវត្ថុ និងធនាគារ, ១១ធនាគារដែលមិនអាចដំណើរការរស់បាន គឺបានបិទទ្វារ ពីព្រោះមិនអាចបំពេញលក្ខខណ្ឌមូលធនចុះបញ្ជីតាមការតំរូវក្នុងច្បាប់[១៦] ។

[១៦] ច្បាប់ធនាគារថ្មី តំរូវឱ្យបង្កើនមូលធនកាន់កាប់ដោយធនាគារពី ៥លានដុល្លារ ទៅ ១៣លានដុល្លារ ។

## ៣.៤ ហិរញ្ញវត្ថុសាធារណៈ

### *៣.៤.១ ហិរញ្ញវត្ថុសាធារណៈទូទៅ*

យោងតាមតួលេខជាផ្លូវការ ផ្សព្វផ្សាយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណូលថវិកាកម្ពុជាឆ្នាំ២០០១ ឡើងដល់ ៣៨៩លានដុល្លារ ប៉ុន្តែថវិកាចំណាយមាន ដល់ ៥៩៣លានដុល្លារ ។ ឱនភាព ២០៤លានដុល្លារ ត្រូវបានធ្វើហិរញ្ញប្បទានដោយ ជំនួយបរទេស (១៩៤លានដុល្លារ) និងដោយដកសាច់ប្រាក់ពីរតនាគារជាតិ (១០ លានដុល្លារ) ។ ប៉ុន្តែ តួលេខទាំងនេះហាក់ដូចជាមិនបានឆ្លុះបញ្ចាំងពីភាពជាក់ស្តែង នៃចំណាយសាធារណៈទេ ។ តាមពិត បើតាមទិន្នន័យបណ្តោះអាសន្នរបស់ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រទេសកម្ពុជាទទួលជំនួយបរទេស ប្រហែល ៥២៨លានដុល្លារនៅឆ្នាំ២០០១ ក្នុងនេះ អំណោយមាន ៤៣៧លានដុល្លារ និងកំចីមាន ៩១លានដុល្លារ ។ ដូច្នេះ ចំនួនសរុបនៃចំណាយក្នុងវិស័យសាធារណៈ (ចំនាយអភិវឌ្ឍន៍ និងមិនមែនអភិវឌ្ឍន៍) មាន ៩១៧លានដុល្លារនៅឆ្នាំ២០០១[១៧] ។

រចនាសម្ព័ន្ធនៃខ្ទង់ចំនាយសរុបក្នុងវិស័យសាធារណៈ ប្រែប្រួលបន្តិចនៅឆ្នាំ ២០០១ ធៀបនឹងឆ្នាំ២០០០ ។ គិតជាភាគរយនៃ ផសស ចារិក វាកើន ១,៤% (ឡើងដល់ ២៨,៣%នៅឆ្នាំ២០០១ ធៀបនឹង ២៦,៩%នៅឆ្នាំ២០០០) ។ ក្នុងកំនើន នេះ ជំនួយបរទេសមាន ១,១% ឯចំនូលក្នុងស្រុកមាន ០,៣% ហើយធៀបនឹងចំនាយ សរុបក្នុងវិស័យសាធារណៈ ជំនួយបរទេសតំនាងឱ្យ ៥៧,៦% នៅឆ្នាំ២០០១ (កើនពី ៥៦,៤%នៅឆ្នាំ២០០០) បានន័យថា កម្ពុជាបានបង្កើនការពឹងផ្អែកលើជំនួយបរទេស ។

---

[១៧] ជំនួយបរទេសកត់ត្រាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (១៩៤លានដុល្លារ) នៅក្នុង ឯកសារថវិកា បង្ហាញតែបរិមាណដែលប្រើលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (១៨០លានដុល្លារ) និងជំនួយទ្រទ្រង់ដល់ថវិការដ្ឋាភិបាល (១៤លានដុល្លារ) ។ ទឹកប្រាក់ នេះមិនបានគណនាចូលនូវជំនួយបរទេសគ្រប់គ្រងផ្ទាល់ដោយ NGOs និងទាយកខ្លួនឯង ដែលមានសរុបប្រហែល ៣៣៤លានដុល្លារនៅឆ្នាំ២០០១ ។

**តារាង៣.៩ ថវិកាសរុបរបស់ប្រទេសកម្ពុជាសំរាប់ឆ្នាំ ២០០០ និង ២០០១**

| | លានដុល្លារ | | ភាគរយនៃចំណូលសរុប | | ភាគរយនៃ ផសស | |
|---|---|---|---|---|---|---|
| | **2000** | **2001** | **2000** | **2001** | **2000** | **2001** |
| **ចំណូលថវិកាសរុប** | **846** | **917** | **100.0%** | **100.0%** | **26.9%** | **28.3%** |
| ចំណូលក្នុងស្រុក | 369 | 389 | 43.6% | 42.4% | 11.7% | 12.0% |
| ពន្ធ | 270 | 279 | 31.8% | 30.4% | 8.6% | 8.6% |
| មិនមែនពន្ធ | 99 | 110 | 11.7% | 12.0% | 3.1% | 3.4% |
| ជំនួយបរទេស | 478 | 528 | 56.4% | 57.6% | 15.2% | 16.3% |
| អំណោយ | 390 | 437 | 46.1% | 47.7% | 12.4% | 13.5% |
| កំចី | 88 | 91 | 10.4% | 9.9% | 2.8% | 2.8% |
| **ចំណាយសរុប** | **839** | **927** | **99.1%** | **101.2%** | **26.6%** | **28.7%** |
| ពីចំណូលក្នុងស្រុក | 369 | 389 | 43.6% | 42.4% | 11.7% | 12.0% |
| ការវិនិយោគ | 49 | 58 | 5.8% | 6.3% | 1.6% | 1.8% |
| ចរន្ត | 319 | 331 | 37.7% | 36.1% | 10.1% | 10.2% |
| ពីជំនួយបរទេស | 478 | 528 | 56.4% | 57.6% | 15.2% | 16.3% |
| ការវិនិយោគ | 183 | 194 | 21.7% | 21.2% | 5.8% | 6.0% |
| ចរន្ត | 294 | 334 | 34.8% | 36.4% | 9.3% | 10.3% |
| **បំរែបំរួលនៅរតនាគារ** | **7** | **-10** | **0.9%** | **-1.2%** | **0.3%** | **-0.3%** |

*ប្រភព: ចងក្រងពីទិន្នន័យដើមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង CDC ។*

### *៣.៤.២ ថវិកាក្នុងស្រុក*

ដូចឆ្នាំមុនៗដែរ ប្រតិបត្តិការថវិការដ្ឋឆ្នាំ២០០១ បង្ហាញពីកង្វះចំណូល និងការបើកផ្តល់ថវិកាបានតិចជាងការរំពឹងទុកទៅឱ្យវិស័យនានាខាងសង្គមកិច្ច ។

យោងតាមច្បាប់ថវិកាឆ្នាំ២០០១, ផែនការចំណូលក្នុងស្រុកសរុបគឺ ៤១៨ លានដុល្លារ ដែលបង្ហាញនូវកំណើន ១៣,៦% ធៀបនឹងឆ្នាំ២០០០ ។ ដើម្បីសំរេចគោលដៅនេះ រដ្ឋាភិបាលបានដាក់អនុវត្តយុទ្ធសាស្ត្រជាច្រើន ដើម្បីបង្កើនចំណូល ដូចជា ពន្ធលើបារី, VAT លើការលក់ប្រេងម៉ាស៊ូត, កំរៃបន្ថែមលើទិដ្ឋាការ, ហើយខ្ទង់ចំណូលទាំងអស់នេះបានប្រមូលតាំងពីពាក់កណ្តាលឆ្នាំ២០០១ ។ ប៉ុន្តែតាមស្ថិតិចងក្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, កង្វះចំណូលក្នុងស្រុកសរុបមានប្រហែល

៧% នៃថវិកាដែលបានគ្រោងទុក ។ កង្វះចំណូលថវិការដ្ឋ បណ្តាលជាសំខាន់ពីភាពទន់ខ្សោយនៃការអនុវត្តនីតិវិធានការប្រមូលអាករពិសេស ដែលសំដៅយកមកប៉ះប៉ូវការកាត់បន្ថយពន្ធគយដែលត្រូវធ្វើជាចាំបាច់ ដោយសារសមាជិកភាពរបស់កម្ពុជានៅក្នុង ASEAN/AFTA ។

ទោះជាយ៉ាងនេះក្តី ចំណូលថវិការដ្ឋសរុបបានឡើងដល់ ១២% នៃ ផសស នៅឆ្នាំ២០០១ ធៀបទៅនឹង ១១,៧% នៅឆ្នាំ២០០០ ។ កំណើនចំណូលក្នុងស្រុកនៅឆ្នាំ២០០១ ទទួលបានជាសំខាន់មកពីជោគជ័យរបស់រដ្ឋាភិបាលក្នុងការពង្រីកមូលដ្ឋានប្រមូលចំណូល (ចំណូលសំខាន់ជាងគេគឺ VAT និងពន្ធលើប្រាក់បៀវត្សរ៍), និងបានមកពីចំនូលក្នុងវិស័យទូរគមនាគមន៍ និងទេសចរណ៍ (កំរៃទិដ្ឋាការ, ចំនូលអាកាសចរណ៍ស៊ីវិល, និងប្រាក់កំរៃចូលទស្សនាប្រាសាទអង្គរវត្ត) ។ ពីឆ្នាំសារពើពន្ធ ២០០០-២០០១ អាករពិសេសកើនយ៉ាងច្រើន (៣៩លានដុល្លារក្នុងឆ្នាំ២០០១ ធៀបនឹង ២៩លានដុល្លារក្នុងឆ្នាំ២០០០) ប៉ុន្តែបានតែ ៦២% នៃផែនការក្នុងច្បាប់ថវិកា (៦៤លានដុល្លារ) ។ ឯការប្រមូលពន្ធប្រយោល និងពន្ធផ្ទាល់ផ្សេងៗទៀត បានលើសផែនការបន្តិចបន្តួច ។ ដូចបានរំពឹងទុក និងបញ្ជាក់ជូនពីខាងដើម ពន្ធគយធ្លាក់ចុះជាលំដាប់ក្នុងរយៈបីឆ្នាំចុងក្រោយ គឺបាន ១១៣លានដុល្លារក្នុងឆ្នាំ១៩៩៩, ១០១លានដុល្លារក្នុងឆ្នាំ២០០០ និងត្រឹមតែ ៩៥លានដុល្លារក្នុងឆ្នាំ២០០១ ។

ពិនិត្យតាមបរិបទអន្តរជាតិ ចំណូលថវិកាកម្ពុជានៅទាប បើធៀបនឹងប្រទេសជិតខាង ។ ឧទាហរណ៍ ប្រជាជនកម្ពុជាផ្តល់ឱ្យថវិការដ្ឋតែ ៣០ដុល្លារក្នុងមួយនាក់ ធៀបនឹងប្រទេសថៃដែលប្រជាជនម្នាក់ផ្តល់ឱ្យរដ្ឋប្រហែល ៦០០ដុល្លារ ។ មូលហេតុនៃគំលាតនេះ គឺនៅក្នុងប្រទេសកម្ពុជា ចំណូលជាតិមានកំរិតទាប ហើយប្រព័ន្ធសារពើពន្ធក៏នៅខ្សោយ ។

តួលេខក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បង្ហាញថា ក្នុងឆ្នាំ២០០១ ចំណាយរដ្ឋាភិបាលសរុបតាមរយៈធនាគារជាតិ ឡើងដល់ ៤១៣លានដុល្លារ ឬ ៣% ទាប

ជាងផែនការ[១៨] ។ ប្រភពថវិកាទាំងនេះ គឺ ៣៨៩លានដុល្លារទទួលពីចំណូលក្នុងស្រុក, ១៤លានដុល្លារជាកំចីទ្រទ្រង់ថវិកាផ្តល់ដោយទាយកអន្តរជាតិ[១៩] និង ១០លានដុល្លារដកពីធនបំរុងនៅរតនាគារជាតិ ។ ឯកសារថវិកាបានបង្ហាញនូវការធ្លាក់ចុះជាបន្តក្នុងចំណាយយោធា និងកំណើនបន្តិចបន្តួចទៅលើសកម្មភាពដែលបានកំណត់ជាអាទិភាពមានជាអាទិ៍ អប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ។

## តារាង៣.១០ ចំណូលថវិកាក្នុងស្រុក នៅឆ្នាំ ២០០០ និង ២០០១

| | លានដុល្លារ | | %នៃចំណូលសរុប | | %នៃ ផសស | |
|---|---|---|---|---|---|---|
| | **2000** | **2001** | **2000** | **2001** | **2000** | **2001** |
| **ចំណូលក្នុងស្រុកសរុប** | **368** | **389** | **100.0%** | **100.0%** | **11.7%** | **12.0%** |
| **ចំណូលពន្ធ** | **269** | **279** | **73.1%** | **71.7%** | **8.6%** | **8.6%** |
| ពន្ធផ្ទាល់ | 35 | 36 | 9.5% | 9.2% | 1.1% | 1.1% |
| ពន្ធប្រយោល | 133 | 148 | 36.1% | 38.0% | 4.2% | 4.6% |
| ពន្ធគយ | 101 | 95 | 27.4% | 24.6% | 3.2% | 3.0% |
| **ចំណូលមិនមែនពន្ធ** | **99** | **110** | **26.9%** | **28.3%** | **3.1%** | **3.4%** |
| ព្រៃឈើ និងនេសាទ | 13 | 9 | 3.6% | 2.3% | 0.4% | 0.3% |
| ទាក់ទិននឹងទេសចរណ៍ | 13 | 21 | 3.5% | 5.4% | 0.4% | 0.6% |
| កូតាកាត់ដេរ និងអាជ្ញាប័ណ្ណ | 17 | 18 | 4.6% | 4.6% | 0.5% | 0.6% |
| ទូរគមនាគមន៍ | 24 | 31 | 6.5% | 8.0% | 0.8% | 1.0% |
| ចំណូលផ្សេងទៀត | 32 | 31 | 8.7% | 8.0% | 1.0% | 1.0% |

*ប្រភព: វិបសអ ចងក្រងពីទិន្នន័យដើមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ចំណាយតាមរយៈរតនាគារជាតិ មាន ១២,៨% នៃ ផសស ចារិក ក្នុងឆ្នាំ ២០០១ គឺកើនពី ១២,៤% ក្នុងឆ្នាំ២០០០ ។ គិតជាភាគរយនៃ ផសស ចំណាយលើ

---

[១៨] តួលេខនេះមិនគណនាគំរោងហេដ្ឋារចនាសម្ព័ន្ធប្រើថវិកាជំនួយបរទេស និងគ្រប់គ្រងផ្ទាល់ដោយទីភ្នាក់ងារផ្តល់ជំនួយចូលទេ ។ សកម្មភាពទាំងនេះ បំពេញបន្ថែមលើការអភិវឌ្ឍន៍ជាតិ ប៉ុន្តែមិនឆ្លុះបញ្ចាំងក្នុងថវិការដ្ឋទេ ។

[១៩] ចំនួននេះរួមទាំងកំចី ៤,៦លានដុល្លារពីទីភ្នាក់ងារពហុភាគី, និងអំណោយ ៩លានដុល្លារពីទីភ្នាក់ងារទ្វេភាគី ។

ការពារនិងសន្តិសុខជាតិ ធ្លាក់ចុះ ០,៣% ពី ៣,៦% ក្នុងឆ្នាំ២០០០ ដល់ ៣,៣% ក្នុងឆ្នាំ២០០១, ចំណែកខាងអប់រំ និងសុខាភិបាល កើន ០,៥% ពី ២,២% នៅឆ្នាំ២០០០ ដល់ ២,៧% នៅឆ្នាំ២០០១ ។ ចំណាយលើការអភិវឌ្ឍន៍សេដ្ឋកិច្ច (ចំណាយចរន្តលើក្រសួងសេដ្ឋកិច្ចនានា បូកនឹងចំណាយវិនិយោគសាធារណៈ) នៅនឹងត្រឹម ៣,៤% នៃ ផសស ក្នុងឆ្នាំ២០០១ ប៉ុន្តែចំណាយលើស្ថាប័នរដ្ឋផ្សេងទៀតមានកំណើនបន្តិចបន្តួចឡើងដល់ ៣,៤% នៃ ផសស ក្នុងឆ្នាំ២០០១ ដោយកើនពី ៣,៣% ក្នុងឆ្នាំ២០០០ ។ កំណើននេះបណ្តាលជាសំខាន់ពីចំណាយបន្ថែមទាក់ទិននឹងការបោះឆ្នោតឃុំ-សង្កាត់ ។

**តារាង៣.១១ ថវិកាចំណាយតាមរយៈរតនាគារជាតិ**

| | លាន US$ | | សរុបជាភាគរយ | | ភាគរយ GDP | |
|---|---|---|---|---|---|---|
| | 2000 | 2001 | 2000 | 2001 | 2000 | 2001 |
| **ចំណាយសរុប** | **390** | **413** | **100.0%** | **100.0%** | **12.4%** | **12.8%** |
| **ចំណាយចរន្ត** | **311** | **341** | **79.8%** | **82.6%** | **9.9%** | **10.6%** |
| ការពារជាតិ និងសន្តិសុខ | 114 | 106 | 29.2% | 25.7% | 3.6% | 3.3% |
| អប់រំ និងសុខាភិបាល | 68 | 87 | 17.4% | 21.0% | 2.2% | 2.7% |
| ក្រសួងសេដ្ឋកិច្ច | 27 | 38 | 6.9% | 9.2% | 0.9% | 1.2% |
| ស្ថាប័នរដ្ឋផ្សេងៗ | 102 | 110 | 26.2% | 26.7% | 3.3% | 3.4% |
| **វិនិយោគ** | **79** | **72** | **20.2%** | **17.4%** | **2.5%** | **2.2%** |

*ប្រភព: វិបសអ ចងក្រងពីទិន្នន័យដំបូងទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

*សំគាល់: ចំណាយនៅក្នុងតារាង៣.១១ ខុសពីតារាង៤.១ បន្តិចបន្តួច ព្រោះបានបញ្ចូលចំណាយដែលផ្តល់ដោយបំរែបំរួល និងឧបត្ថម្ភថវិការបស់បរទេសនៅរតនាគារជាតិក្នុងស្រុក ។*

តួលេខផ្សព្វផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីថវិកាចំណាយសំរាប់ខែធ្នូ ២០០១ បានធ្វើឱ្យគេព្រួយបារម្ភ ពីព្រោះវាខ្ពស់ខ្លាំងណាស់ធៀបនឹងកំរិតមធ្យមប្រចាំខែ ។ ចំណាយនៅក្រសួងសុខាភិបាល ជាឧទាហរណ៍ល្អមួយដែលគួរលើកយកមកបង្ហាញ ។ ចំណាយលើសុខាភិបាល នៅខែធ្នូ ២០០១ តែមួយខែ វាធំជិតដល់ពីរដងនៃចំណាយសរុបលើវិស័យនេះក្នុង ១១ខែមុន និងស្មើនឹង ២០% នៃចំណាយសរុបនៅខែធ្នូ ឆ្នាំ២០០១ (សំរាប់មួយឆ្នាំពេញ ចំណាយសុខាភិបាលតំណាងឱ្យតែ

៩.១% នៃចំណាយសរុបប៉ុណ្ណោះ) ។ ប៉ុន្តែមានករណីជាច្រើនដែលការកំណត់ក៏រិតចំណាយនេះ មិនអាចអនុវត្តបានដោយសារកង្វះខាតសាច់ប្រាក់ ។

**ក្រាហ្វិក៣.៣ ថវិកាកំណត់ផ្តល់ឱ្យក្រសួងសុខាភិបាលនៅឆ្នាំ២០០១**




*ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

វិន័យសារពើពន្ធ គឺជាឧបករណ៍ដ៏សំខាន់សំរាប់ធ្វើឱ្យស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចមានចីរភាព ។ ខាងកងទ័ព និងស្ថាប័នកំពូល៧មួយចំនួន ដូចជា ក្រុមប្រឹក្សារដ្ឋមន្ត្រីសភាជាតិ និងព្រះបរមរាជវាំង នៅតែមានចំណែកដ៏ធំនៃចំណាយសរុប (ប្រហែល ៤០%) ហើយរឿងនេះអាចជាហេតុផលមួយដែលរដ្ឋាភិបាល មិនអាចផ្តល់ថវិកាច្រើនថែមទៀតសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។ ប្រជាជនកម្ពុជាទទួលពីរដ្ឋាភិបាលប្រហែល ៧ដុល្លារក្នុងមួយនាក់ក្នុងមួយឆ្នាំ សំរាប់ការថែទាំសុខភាព និងអប់រំ (ធៀបនឹង ១៥០ដុល្លារក្នុងមួយនាក់នៅថៃ) ។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (៦ដុល្លារក្នុងមួយនាក់ ធៀបនឹង ១៨០ដុល្លារក្នុងមួយនាក់នៅថៃ) ពឹងផ្អែកលើជំនួយបរទេសស្ទើរតែទាំងស្រុង ។ តាមការសិក្សាឆ្នាំ១៩៩៩ របស់ធនាគារពិភពលោក, ទាយក និង NGOs ឧបត្ថម្ភថវិកាប្រហែល ៤៦% លើចំណាយអប់រំសរុប ឯគ្រួសារឯកជន និងរដ្ឋាភិបាល ឧបត្ថម្ភ ២៧% ស្មើគ្នា ។ សំរាប់ការថែទាំសុខភាពគ្រួសារឯកជនផ្តល់ដល់ទៅ ៨២% នៃចំណាយសរុប, NGOs និងទាយកគួប

គ្នាផ្តល់ ១៤%, ឯរដ្ឋាភិបាលផ្តល់តែ ៤% ប៉ុណ្ណោះ។ កង្វះថវិកាគឺជាមូលហេតុចំបងនៃគុណភាពអន់ក្នុងប្រព័ន្ធសុខាភិបាលសាធារណៈ និងអប់រំនៅកម្ពុជា ដែលពុំអាចមានផលប៉ះពាល់ច្រើនទេដល់ការកាត់បន្ថយភាពក្រីក្រ ។ ដោយសារប្រព័ន្ធសុខាភិបាលសាធារណៈនៅខ្សោយ គ្រួសារកម្ពុជាតែងលក់ដីធ្លីខ្លះរបស់ខ្លួន ដើម្បីបង់ថ្លៃព្យាបាលសុខភាព ហើយតាមនេះក៏ក្លាយជាអ្នកគ្មានដីធ្លី ឬគ្មានទ្រព្យ[២០] ។

### *៣.៤.៣ ជំនួយបរទេស និងបំណុលក្រៅប្រទេស*

តាមការប៉ាន់ស្មានដំបូងៗរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការបើកផ្តល់ជំនួយបរទេសកើនយ៉ាងខ្លាំងដល់ ៥២៨លានដុល្លារនៅឆ្នាំ២០០១ គឺកើន ១០,៥% ធៀបនឹងឆ្នាំ២០០០ (៤៧៨លានដុល្លារ) ។ កំចីតំណាងឱ្យ ១៧,២% នៃជំនួយបរទេសសរុបបើកផ្តល់ក្នុងឆ្នាំ២០០១ ធៀបនឹង ១៨,៤% ក្នុងឆ្នាំ២០០០ ។ បន្ទាប់ពីកំណើនដ៏ខ្ពស់ក្នុងឆ្នាំ២០០០ ការបើកផ្តល់កំចីកើនថែមទៀតក្នុងឆ្នាំ២០០១ ។ តាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការបើកផ្តល់កំចីដោយធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី មានសរុប ៩១លានដុល្លារក្នុងឆ្នាំ២០០១ គឺកើនពី ៨៨លានដុល្លារក្នុងឆ្នាំ២០០០ និង ៤៥លានដុល្លារក្នុងឆ្នាំ១៩៩៩ ។ កំណើនដ៏ខ្ពស់នៅឆ្នាំ២០០០ គឺដោយសារការកំនត់កំចីដែលត្រូវបើកផ្តល់បន្ទាន់សំរាប់ការទ្រទ្រង់ថវិកា (២៣លានដុល្លារ) និងមូលនិធិសង្គម (២០លានដុល្លារ) ។ ទោះបីជាមានការបើកផ្តល់បែបនេះក្តី ក៏ការផ្តល់កំចីដល់កម្ពុជា នៅតែទាបជាងកំរិតដែលស្ថាប័នកំចីបានសន្យា (១៥០លានដុល្លារ/ឆ្នាំ) ។ ក្នុងបីឆ្នាំចុងក្រោយ កំចីបើកផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី មានច្រើនជាងកំចីបើកផ្តល់ដោយធនាគារពិភពលោក ។

ដោយមានការបើកផ្តល់កំចីដ៏លឿន បំណុលបរទេសដែលកម្ពុជានៅជំពាក់ ហើយរដ្ឋាភិបាលបានទទួលស្គាល់ (ជំពាក់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍

[២០] ឯកសារ វិបសអ ស្តីពីការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា មានពិភាក្សាលំអិតពីចំណុចនេះ (So *et al.* 2001) ។

អាស៊ី តាំងពីឆ្នាំ១៩៩៣ និងជំនួយទ្វេភាគីមួយចំនួនដែលទទួលមុនឆ្នាំ១៩៧០) បាន កើនយ៉ាងខ្លាំងដល់ ៥៥៨លានដុល្លារនៅចុងឆ្នាំ២០០១ ។ ប៉ុន្តែបំណុលជំពាក់សហរដ្ឋអាមេរិកនៅឆ្នាំ១៩៧០-៧៥ (ប្រហែល ៣០០លានដុល្លារ) និងជំពាក់រុស្ស៊ីនៅឆ្នាំ១៩៨០-៩០ ប្រហែល ១.៤០០លានដុល្លារ) រដ្ឋាភិបាលមិនបានទទួលស្គាល់ទេ ។ ដោយហេតុថា កំចីពីទីភ្នាក់ងារកំចីពហុភាគីទាំងពីរ គឺជាកំចីសម្បទាន មានរយៈពេលអនុគ្រោះ ១០ឆ្នាំ, ដូច្នេះរដ្ឋាភិបាលកម្ពុជានឹងចាប់ផ្តើមសងលើកទី១ នៅឆ្នាំ២០០៣ ហើយនៅឆ្នាំនោះសងតែការប្រាក់ចំនួនតូចប៉ុណ្ណោះ (តិចជាង ៥០០.០០០ដុល្លារ) ។

**តារាង៣.១២ ការបើកផ្តល់កំចី (លានដុល្លារ)**

| | 1999 | 2000 | 2001 |
|---|---|---|---|
| កំចីសរុប | 45.4 | 87.7 | 90.7 |
| *កំចីបែងចែកតាមអ្នកឱ្យខ្ចី* | | | |
| World Bank | 19.9 | 36.4 | 41.7 |
| ADB | 25.5 | 51.3 | 49.0 |
| *កំចីបែងចែកតាមប្រភេទ* | | | |
| កំចីទ្រទ្រង់ថវិកា | - | 23.1 | 4.6 |
| មូលនិធិសង្គម | - | 19.7 | 31.7 |
| ហេដ្ឋារចនាសម្ព័ន្ធ | 43.8 | 43.4 | 53.5 |
| ជំនួយបច្ចេកទេស | 1.6 | 1.5 | 0.9 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**ក្រាហ្វិក៣.៤ បំនុលបរទេសនៅជំពាក់ និង រដ្ឋាភិបាលទទួលស្គាល់ (លានដុល្លារ)**




*ប្រភព: វិបសអ ចងក្រងពីទិន្នន័យដើមរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ៣.៥ ជញ្ជីងទូទាត់

## *៣.៥.១ គណនីចរន្ត*

ថ្វីបើមានការធ្លាក់ចុះការនាំចេញសំលៀកបំពាក់ និងឈើក្តី ពាណិជ្ជកម្មក្រៅប្រទេសបន្តរីកចំរើនយ៉ាងទៀងទាត់ឡើងដល់ ៣.៣៤៣លានដុល្លារនៅឆ្នាំ២០០១ គឺធំជាង ផសស ចារិកជាលើកទីមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ការនាំចេញកើនតែ ៨% នៅឆ្នាំ២០០១ ធៀបនឹង ៣៣% នៅឆ្នាំ២០០០ ចំណែកឯការនាំចូលទំនិញ កើន ៧%

**តារាង៣.១៣ គណនីចរន្តកម្ពុជា**

| | លានដុល្លារ | | | ភាគរយនៃ ផសស | | |
|---|---|---|---|---|---|---|
| | 1999 | 2000 | 2001 | 1999 | 2000 | 2001 |
| **ការនាំចេញទំនិញ** | **1048** | **1393** | **1502** | **33.9%** | **44.2%** | **46.4%** |
| **ការនាំចូលទំនិញ** | **1488** | **1714** | **1841** | **48.2%** | **54.4%** | **56.9%** |
| សមតុល្យពាណិជ្ជកម្ម | -441 | -322 | -339 | -14.3% | -10.2% | -10.5% |
| កសិកម្ម | 169 | 119 | 97 | 5.5% | 3.8% | 3.0% |
| កាត់ដេរ | 124 | 285 | 309 | 4.0% | 9.1% | 9.6% |
| ថាមពល[១] | -139 | -157 | -167 | -4.5% | -5.0% | -5.2% |
| ទំនិញផ្សេងៗ | -594 | -569 | -578 | -19.2% | -18.1% | -17.9% |
| សមតុល្យសេវា | 68 | 100 | 119 | 2.2% | 3.2% | 3.7% |
| ចំណូល និងការផ្ទេរឯកជន (សុទ្ធ)[២] | 15 | -6 | 4 | 0.5% | -0.2% | 0.1% |
| **សមតុល្យគណនីចរន្ត** | **-357** | **-227** | **-216** | **-11.6%** | **-7.2%** | **-6.7%** |

*ប្រភព: ចងក្រងពីទិន្នន័យដើមរបស់រដ្ឋាភិបាល ។ [១] តួលេខនេះមានគិតចូលតែការនាំចូលជាផ្លូវការនូវសាំង ម៉ាស៊ូត និងផលិតផលប្រេងផ្សេងទៀត ដែលកត់ត្រាដោយទីចាត់ការគយ ហើយត្រូវតិចជាងការប្រើប្រាស់ក្នុងស្រុកពិតខ្លាំង ។ [២] តួលេខនេះគឺជាការប៉ាន់ស្មានត្រួសៗ ។ អង្កេតរបស់ វបសអ ជាមួយម្ចាស់ធនាគារពាណិជ្ជមួយចំនួន បង្ហាញថាប្រទេសកម្ពុជាទទួលយ៉ាងហោចណាស់ ១០០លានដុល្លារក្នុងមួយឆ្នាំ ដែលជាការផ្ទេរប្រាក់ឯកជនពីជនកម្ពុជានៅក្រៅប្រទេស ប៉ុន្តែមានប្រាក់ប្រហែលគ្នានេះ ត្រូវផ្ញើចេញទៅក្រៅប្រទេសវិញដោយអ្នកជំនួញ និងឯកជន ។*

ក្នុងឆ្នាំ២០០១ ធៀបនឹង ១៤% ក្នុងឆ្នាំ២០០០ ។ ចំពោះជញ្ជីងពាណិជ្ជកម្មវិញ កៅស៊ូនាំចេញមានថ្លៃទាប គួបផ្សំនឹងការថយចុះយ៉ាងខ្លាំងនៃឈើនាំចេញ គឺជាហេតុផលដែលធ្វើឱ្យថយចុះ អតិរេកពាណិជ្ជកម្មសំរាប់ផលិតផលកសិកម្ម ។ អតិរេកពាណិជ្ជ

កម្មក្នុងវិស័យកាត់ដេរបន្តកើនឡើង ។ ក្នុងវិស័យថាមពល និងវិស័យមិនមែនកាត់ដេរ ឱនភាពពាណិជ្ជកម្មកើនបន្តិច ដោយសារការពង្រីកសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ។ ជាលទ្ធផល ឱនភាពពាណិជ្ជកម្មសរុប កើនបន្តិចនៅឆ្នាំ២០០១ ឡើងដល់ ៣៣៩លានដុល្លារជាតំលៃចារិក ដែលតំនាងឱ្យ ១០,៩% នៃ ផសស ចារិក ។ សមតុល្យក្នុងវិស័យសេវាកម្មបន្តកែលំអយ៉ាងច្រើននៅឆ្នាំ២០០១ (+១៩%) ដោយសារមានការរីកចំរើនវិស័យទេសចរណ៍ ។ លំហូរចេញនូវប្រាក់ចំណូលរបស់ជនបរទេស (រួមទាំងបៀវត្សរ៍ និងប្រាក់ចំណេញកើតចេញពី FDI) ជាទូទៅអាចទូទាត់បានដោយសារលំហូរចូលនៃប្រាក់ផ្ញើមកស្រុកវិញពីសំណាក់ជនកម្ពុជាដែលរស់នៅក្រៅប្រទេស ។ ជាទូទៅ ឱនភាពគណនីចរន្តកម្ពុជាត្រូវបានកែលំអបន្តិចបន្តួច ដោយថយចុះមកត្រឹម ៦,៧% នៃ ផសស នៅឆ្នាំ២០០១ ធៀបនឹង ៧,២% នៅឆ្នាំ២០០០ ។

### *៣.៩.២ គណនីមូលធន*

ថ្វីបើជំនួយបរទេសបានកើនឡើងគួរឱ្យកត់សំគាល់ក្តី ប៉ុន្តែមូលធនសរុបដែលហូរចូលកម្ពុជាបានធ្លាក់ចុះ ៩% នៅឆ្នាំ២០០១ ធៀបនឹងឆ្នាំ២០០០ ដោយសារ FDI បានធ្លាក់ចុះយ៉ាងច្រើន ។ FDI ក្នុងអាជីវកម្មឯកជន ដូចជា រោងចក្រ និងសណ្ឋាគារ មានតែ ៦៣លានដុល្លារនៅឆ្នាំ២០០១ ធៀបនឹង ១០១លានដុល្លារនៅឆ្នាំ២០០០ និង ១៧៤លានដុល្លារនៅឆ្នាំ១៩៩៩ ។ ក្នុងបីឆ្នាំចុងក្រោយ ការផ្ទេរជាផ្លូវការ (ជំនួយបរទេសជាអំណោយ) ស្ថិតនៅថេរដដែលប្រហែល ២៥០លានដុល្លារ/ឆ្នាំ ប៉ុន្តែកំចីផ្លូវការបានកើនឡើងបន្តិច ។ ជំនួយបរទេសមកកម្ពុជាកើនបន្តិចដល់ ៣៤០លានដុល្លារនៅឆ្នាំ២០០១ ធៀបនឹង ៣៣៣លានដុល្លារនៅឆ្នាំ២០០០[២១] ។ ជាលទ្ធផល

[២១] ជំនួយបរទេសនៅក្នុងគណនីជញ្ជីងទូទាត់ មិនគិតទឹកប្រាក់ចំណាយនៅក្រៅប្រទេសចូលទេ ដូចជា ប្រាក់ខែរបស់ជំនាញការបរទេសជាដើម ។ ដូច្នេះហើយបានជាទំហំជំនួយបរទេសខាងលើ ទាបជាងតួលេខគណនាដោយ CDC ដែលគ្មានកាត់អ្វីចោលទេ ។

សមតុល្យគណនីមូលធនកម្ពុជា មានតែ ៤០៣លានដុល្លារនៅឆ្នាំ២០០១ គឺចុះពី ៤៣៤លានដុល្លារនៅឆ្នាំ២០០០ និង ៤៦៩លានដុល្លារនៅឆ្នាំ១៩៩៩ ។

**តារាង៣.១៤ គណនីមូលធនរបស់កម្ពុជា**

| | លានដុល្លារ | | | % នៃ ផសស | | |
|---|---|---|---|---|---|---|
| | **1999** | **2000** | **2001** | **1999** | **2000** | **2001** |
| **សមតុល្យគណនីចរន្ត** | **-357** | **-227** | **-216** | **-11.6%** | **-7.2%** | **-6.7%** |
| **សមតុល្យគណនីមូលធន** | **469** | **434** | **403** | **15.2%** | **13.8%** | **12.5%** |
| ការផ្ទេរផ្សំវការ (អំណោយ)[១] | 251 | 246 | 250 | 8.1% | 7.8% | 7.7% |
| កំចីផ្លូវការ (សុទ្ធ)[២] | 44 | 87 | 90 | 1.4% | 2.8% | 2.8% |
| វិនិយោគផ្ទាល់ពីបរទេស | 174 | 101 | 63 | 5.6% | 3.2% | 2.0% |
| **បំរែបំរួលធនបំរុងបរទេស**[៣] | **112** | **207** | **187** | **3.6%** | **6.6%** | **5.8%** |
| នៅ NBC | 26 | 63 | 58 | 0.8% | 2.0% | 1.8% |
| នៅក្រៅ NBC | 86 | 144 | 129 | 2.8% | 4.6% | 4.0% |

*ប្រភព: ចងក្រងពីទិន្នន័យដើមរបស់រដ្ឋាភិបាល ។ [១] តួលេខនេះ គិតចូលតែជំនួយបរទេសជាអំណោយផ្ទេរចូលកម្ពុជា ។ ឧទាហរណ៍: ប្រាក់ខែជំនាញការបរទេសបើកនៅក្រៅប្រទេស មិនគិតចូលក្នុងជញ្ជីងទូទាត់ទេ ។ [២] ចំនួនសុទ្ធនៃសំណងបំណុល [៣] សមតុល្យទូទៅបង្ហាញពីបំរែបំរួលនៅក្នុងធនបំរុងបរទេស ។ កម្ពុជាមានសេដ្ឋកិច្ចដុល្លារូបនីយកម្ម ហើយបុគ្គលនិងស្ថាប័ននានាអាចប្រើរូបិយវត្ថុបរទេសបាន ដូច្នេះបំរែបំរួលក្នុងជញ្ជីងទូទាត់មិនត្រឹមតែប៉ះពាល់ដល់ធនបំរុងបរទេសនៅធនាគារជាតិទេ ប៉ុន្តែប៉ះពាល់ដល់ភ្នាក់ងារសេដ្ឋកិច្ចផ្សេងៗ (ស្ថាប័នហិរញ្ញវត្ថុឯកជន អាជីវកម្ម គ្រួសារ) ។*

ទោះបីជា FDI ធ្លាក់ចុះក្តី ជញ្ជីងទូទាត់កម្ពុជាទូទៅស្ថិតនៅវិជ្ជមាន ក្នុងកំរិត ១៨៧លានដុល្លារនៅឆ្នាំ២០០១ ធៀបនឹង ២០៧លានដុល្លារនៅឆ្នាំ២០០០ និង ១១២ លានដុល្លារនៅឆ្នាំ១៩៩៩ ។ អតិរេកជាទូទៅនេះ បានជួយកែលំអដល់ធនបំរុងបរទេសរបស់ជាតិ ។ មួយភាគនៃអតិរេកនេះ (៥៨លានដុល្លារ) ដាក់ចូលធនាគារជាតិនៃកម្ពុជា ឯចំនួននៅសល់ (១២៩លានដុល្លារ) ស្ថិតនៅក្នុងសេដ្ឋកិច្ចនៅកម្ពុជា ។

## ៣.៦ វិនិយោគ និងការប្រមូលផ្តុំមូលធន

### *៣.៦.១ ការវិនិយោគឯកជន*

ការហូរចេញមូលធន គឺជាសញ្ញាណមួយនៃការធ្លាក់ចុះវិនិយោគឯកជន ។ នៅឆ្នាំ២០០១ ចំនួនគំរោងវិនិយោគអនុម័តដោយ CDC និងតំលៃគិតតាមទ្រព្យសកម្ម

ជាប់លាប់ បានបន្តធ្លាក់ចុះក្នុងបីឆ្នាំជាប់គ្នា និងបានប៉ះពាល់ដល់គ្រប់វិស័យ ។ ទោះបីរដ្ឋាភិបាលបានប្រឹងប្រែងគ្រប់មធ្យោបាយ ដើម្បីជំរុញកំណើនក្នុងវិស័យទេសចរណ៍ (ដូចជាគោលនយោបាយបើកចំហជើងមេឃ) ក្តី ក៏គំរោងសាងសង់សណ្ឋាគារថ្មី និងមណ្ឌលទេសចរណ៍ផ្សេងទៀត (លើកលែងតែកាស៊ីណូ) នៅតែមានតិចដដែល ។ តាមការប៉ាន់ស្មានរបស់ វបសអ ដោយផ្អែកលើប្រភពរដ្ឋាភិបាលផ្សេងៗ និងអង្កេតផ្ទាល់ខ្លួន, FDI បានអនុវត្តពិតនៅឆ្នាំ២001 ធ្លាក់ចុះប្រហែលពាក់កណ្តាល បើធៀបនឹងឆ្នាំ២000 ។ វិនិយោគនៅកម្ពុជាក្នុង២ឆ្នាំចុងក្រោយ ផ្តោតជាសំខាន់តែលើសំណង់សណ្ឋាគារនៅសៀមរាប ។ វិស័យកាត់ដេរមានស្ថានភាពគួរឱ្យបារម្ភ ដោយមាន ៣៤រោងចក្របានបិទទ្វារនៅឆ្នាំ២001 ។ម្យ៉ាងទៀត នៅឆ្នាំ២000 គេឃើញមានសាងសង់ថ្មីតែ ១៩រោងចក្រប៉ុណ្ណោះ ធៀបនឹង ៥៨រោងចក្រនៅឆ្នាំ១៩៩៩ និង ៧១រោងចក្រនៅឆ្នាំ១៩៩៨ ។

**ក្រាហ្វិក៣.៥ គំរោងអនុម័តដោយ CDC គិតជាទ្រព្យសកម្មជាប់លាប់ (លានដុល្លារ)**




*ប្រភព:* CDC

### ៣.៦.២ ស្តុកនៃមូលធន

ស្តុកនៃ FDI នៅកម្ពុជាកើនយ៉ាងច្រើនពីឆ្នាំ១៩៩៥-១៩៩៩ ដោយឡើងដល់ប្រហែល ១.០០០លានដុល្លារនៅចុងឆ្នាំ១៩៩៩ ក្នុងនេះ រោងចក្រកាត់ដេរ និងសណ្ឋាគារ តំណាងឱ្យប្រហែលពាក់កណ្តាលនៃចំនួនសរុប ។ ប៉ុន្តែសន្ទុះហាក់ដូចជាត្រូវបានបញ្ឈប់នៅឆ្នាំ២០០០ ។ តាមការបិទរោងចក្រកាត់ដេរ ៣៤ នៅឆ្នាំ២០០១, ស្តុក FDI ក្នុងវិស័យកាត់ដេរបានធ្លាក់ចុះយ៉ាងខ្លាំង ។ នៅឆ្នាំ២០០១ ចំនួនសណ្ឋាគារដែលមានដំណើរការនៅភ្នំពេញក៏ធ្លាក់ចុះដែរ ប៉ុន្តែនៅសៀមរាប និងខេត្តខ្លះទៀតមានសង់សណ្ឋាគារថ្មីមួយចំនួន ។ ស្តុកមូលធនក្នុងវិស័យទេសចរណ៍ បន្តកើនឡើង ឯស្តុក FDI ក្នុងវិស័យផ្សេងទៀត រួមទាំងវិស័យមិនមែនសំលៀកបំពាក់ ដូចជាឧស្សាហកម្មម្ហូបអាហារ រោងចក្រប្លាស្ទិក និងរោងចក្រតំលើងទោចក្រយានយន្តជាដើម ពុំមានប្រែប្រួលទេ ប៉ុន្តែវិនិយោគខាងកាស៊ីណូបានកើនឡើងគួរឱ្យកត់សំគាល់ ។

**ក្រាហ្វិក៣.៦ ស្តុកនៃការវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ)**




*ប្រភព: ចងក្រងតាមទិន្នន័យរដ្ឋាភិបាល និងអង្កេតរបស់ វិបសអ*

ការធ្លាក់ចុះនាពេលសព្វថ្ងៃនៃស្តុកមូលធនក្នុងឧស្សាហកម្មកាត់ដេរ មិនទាន់ប៉ះពាល់ដល់ផលិតកម្មនៅឡើយទេ ។ ម្ចាស់រោងចក្រកាត់ដេរខ្លះៗ បានចាប់ផ្តើមដំណើរការរោងចក្រដោយប្រើកម្មករពីរវេន ដើម្បីបំពេញកំណើនតំរូវការ និងបំពេញ

ជំនួសការបិទរោងចក្រដទៃទៀត។ អនាគតវិស័យកាត់ដេរ ពឹងផ្អែកលើសមត្ថភាពរបស់ឧស្សាហកម្មនេះ ក្នុងការក្តោបក្តាប់ទីផ្សារអន្តរជាតិ ។ លក្ខខណ្ឌផ្សេងទៀតដែលត្រូវបំពេញឱ្យបានជាមុន គឺការលៃលំអបច្ចេកវិទ្យា និងការចូលជាសមាជិក WTO ។

## ៣.៧ ការងារ និង ប្រាក់កំរៃ

### *៣.៧.១ កំលាំងពលកម្ម*

ផ្អែកតាមស្ថិតិកែតំរូវរបស់រដ្ឋាភិបាល[២២] ប្រទេសកម្ពុជាមានប្រជាជនប្រមាណ ១៣,១លាននាក់នៅឆ្នាំ២០០១ ។ ផ្អែកលើសេចក្តីសន្និដ្ឋានរបស់វិជ្ជាស្ថានជាតិស្ថិតិ (NIS) កំលាំងពលកម្មនៅកម្ពុជាឡើងដល់ ៥,៦លាននាក់គឺត្រូវជា ៤៣% នៃប្រជាជនសរុបនៅឆ្នាំ២០០១ ។ ផ្អែកលើទិន្នន័យជំរឿនឆ្នាំ១៩៩៨ និងអង្កេតរបស់ វបសអ កំលាំងពលកម្មក្នុងវិស័យផ្លូវការ (វិស័យបឋម កាត់ដេរ និងទេសចរណ៍) មានប្រហែល ៥% នៃកំលាំងពលម្មសរុប។ កំលាំងពលកម្ម ៩៥% ទៀត ស្ថិតក្នុងកសិកម្ម (៧៧%) វិស័យមិនមែនរោងចក្រកាត់ដេរ (៤%) និងវិស័យសេវាកម្មផ្សេងទៀត (១៤%) ។វិស័យផ្លូវការមានតែនៅក្រុងភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ ។

ធៀបនឹងឆ្នាំ២000 ប្រជាជនកម្ពុជាសរុបកើនប្រហែល ៣៣0.000នាក់នៅឆ្នាំ២០០១ ក្នុងនេះកំលាំងពលកម្មកើន ២00.000នាក់ ។ គេប៉ាន់ស្មានថា វិស័យផ្លូវការស្រូបយកកំលាំងពលកម្មថ្មីបានតែ ១៥.000នាក់ ចំណែក ១៨៥.000នាក់ទៀតត្រូវចូលទៅក្នុងវិស័យមិនផ្លូវការ ភាគច្រើនក្នុងវិស័យកសិកម្ម ។ វិស័យកាត់ដេរបង្កើតការងារថ្មីបានប្រហែល ១០.000កន្លែងនៅឆ្នាំ២០០១ ទោះបីចំនួនរោងចក្រកាត់ដេរមានដំណើរការ បានថយចុះក្តី ។ រោងចក្រកាត់ដេរជាច្រើន បានដំណើរការពីរវេន និងជួលកម្មករថ្មីតាមកិច្ចសន្យារយៈពេលខ្លី ហើយសភាពការណ៍នេះអាចបង្កទំនាស់ក្នុងទំនាក់ទំនងធ្វើឧស្សាហកម្មក្នុងពេលអនាគត ។ វិស័យទេសចរណ៍បង្កើត

---

[២២] ក្រសួងផែនការៈ ការព្យាករណ៍ពីប្រជាជន សំរាប់ឆ្នាំ២០០១-២០២១ ។

ការងារថ្មីបានប្រហែល ៥.០០០កន្លែង នៅឆ្នាំ២០០១ ។ ដូចបានបញ្ជាក់ខាងលើ ចំណូលកំលាំងពលកម្មថ្មីប្រហែល ១៨៥.០០០នាក់ត្រូវស្ថិតនៅក្នុងវិស័យកសិកម្ម និងវិស័យមិនមែនកសិកម្មនិងមិនផ្លូវការផ្សេងទៀត ។ អ្នកទាំងនេះអាចក្លាយជាជនចំណាកស្រុកទៅកាន់ទីក្រុងធំៗ ដូចជាភ្នំពេញជាដើម ឬក៏ទៅកាន់ប្រទេសជិតខាង ។

**តារាង៣.១៥ កំលាំងពលកម្មនៅកម្ពុជា (ពាន់នាក់)**

| | **2000** | **2001** | **បំរែបំរួល** |
|---|---:|---:|---:|
| **ប្រជាជន** | **12,770** | **13,100** | **330** |
| **កំលាំងពលកម្ម** | **5,430** | **5,630** | **200** |
| **វិស័យផ្លូវការ**[១] | **260** | **275** | **15** |
| កាត់ដេរ | 200 | 210 | 10 |
| ទេសចរណ៍ | 60 | 65 | 5 |
| **វិស័យមិនផ្លូវការ** | **5,170** | **5,355** | **185** |
| កសិកម្ម | 4,196 | 4,352 | 156 |
| ឧស្សាហកម្ម[២] | 217 | 224 | 7 |
| សេវាកម្ម[៣] | 757 | 779 | 22 |

*ប្រភព: វបសអ ចងក្រងពីទិន្នន័យដើមរបស់រដ្ឋាភិបាល និងអង្កេតរបស់ វបសអ ។ [១] ដោយសារកង្វះពត៌មានមិនបានគិតក្រុមហ៊ុនមួយចំនួននៅក្នុងឧស្សាហកម្មស្បៀងអាហារ និងថ្នាំជក់ចូលទេ, គមនាគមន៍, លក់ដុំ, និងហិរញ្ញវត្ថុ, ដែលផ្តល់ការងារផ្លូវការប្រហែលពី ៥.០០០ ទៅ ១០.០០០កន្លែង ។ [២] ភាគច្រើនសិប្បកម្មធុនតូច [៣] ភាគច្រើនរួមមានពាណិជ្ជកម្ម ដឹកជញ្ជូន, និងសេវាកម្មមិនផ្លូវការផ្សេងៗ ។*

## *៣.៧.២ ប្រាក់ចំណូលរបស់អ្នកក្រ*

តាមការប៉ាន់ស្មានរបស់ វបសអ ផសស ចារិក របស់កម្ពុជានៅឆ្នាំ២០០១ កើន ៨៥លានដុល្លារ លើសពីឆ្នាំ២០០០[២៣] ហើយទឹកប្រាក់នេះត្រូវបានចាត់ទុកជា

---

[២៣] តួលេខបណ្តោះអាសន្ននៃក្រសួងផែនការ បង្ហាញថា ផសស ចារិករបស់កម្ពុជា កើនតែ ៥៣លានដុល្លារនៅឆ្នាំ២០០១ ទោះបីមានកំណើនគួរឱ្យកត់សំគាល់នៃ ផសស ពិតក្តី ។ ការធ្លាក់ចុះយ៉ាងខ្លាំងនៃសន្ទស្សន៍បរិត្តផរណា ផសស (GDP deflator) ប៉ាន់ស្មានដោយក្រសួងផែនការអាចជាមូលហេតុចំបងនៃភាពខុសគ្នានេះ ។

អាំងឌីកាទ័រ សរុបដែលបង្ហាញពីចំណូលរកបានជាបន្ថែមដោយជាតិទាំងមូល ។ តើចំណូលនេះត្រូវបានបែងចែកយ៉ាងដូចម្តេច? តារាង៣.១៦ បង្ហាញថា វិស័យផ្លូវការទទួលបាន ៦៤លានដុល្លារ ត្រូវជា ៧៥% នៃទ្រព្យថ្មីរបស់ជាតិ ទោះបីវាប្រើតែ ៥% នៃកំលាំងពលកម្មសរុបក្តី ។ ក្នុងលក្ខណៈជាវិស័យដែលរួមចំណែកចំបងគេនៅក្នុងកំណើនសេដ្ឋកិច្ច វិស័យកាត់ដេរទទួលផលបានមួយចំណែកយ៉ាងធំពីកំណើនសេដ្ឋកិច្ច (៤៤លានដុល្លារ) ឯវិស័យទេសចរណ៍ស្ថិតក្នុងលំដាប់ទីពីរដោយទទួលបាន ២០លានដុល្លារ ។ វិស័យកសិកម្មដែលប្រើប្រាស់ដល់ទៅ ៧៧% នៃកំលាំងពលកម្មសរុបបានទទួលការខាតបង់ បើគិតជាតួលេខពិតនៅឆ្នាំ២០០១ (-៩លានដុល្លារ) ។ សិប្បកម្ម និងឧស្សាហកម្មខាងក្រណាត់ធុនតូចមួយចំនួន ក៏បានបាត់បង់ចំនូលប្រហែល

**តារាង៣.១៦ ផសស ចារិក តាមអនុវិស័យ (លានដុល្លារ)**

| | 2000 | 2001 | បំរែបំរួល | បំរែបំរួល/ពលករ (US$) |
|---|---|---|---|---|
| **សរុបគ្រប់វិស័យ** | **3,149** | **3,234** | **85** | **15** |
| **វិស័យផ្លូវការ**[១] | **596** | **660** | **64** | **233** |
| កាត់ដេរ | 363 | 407 | 44 | 209 |
| ទេសចរណ៍ | 233 | 253 | 20 | 311 |
| **វិស័យមិនផ្លូវការ** | **2,552** | **2,573** | **21** | **4** |
| កសិកម្ម | 928 | 919 | -9 | -2 |
| មិនមែនកាត់ដេរ[២] | 426 | 421 | -5 | -22 |
| សេវាមិនមែនទេសចរណ៍[៣] | 1,198 | 1,233 | 35 | 45 |

*ប្រភព: វបសអ ចងក្រងពីទិន្នន័យដើមរបស់រដ្ឋាភិបាលកម្ពុជា ។ [១] ដោយខ្វះពត៌មាន មិនបានគិតក្រុមហ៊ុនមួយចំនួននៅក្នុងឧស្សាហកម្មស្បៀងអាហារ និងថ្នាំជក់ចូលទេ, គមនាគមន៏, លក់ដុំ, និងហិរញ្ញវត្ថុ, ដែលផ្តល់ការងារផ្លូវការ ។ [២] ភាគច្រើនជាសិប្បកម្ម និងតំបាញធុនតូច [៣] ភាគច្រើនមានពាណិជ្ជកម្ម ដឹកជញ្ជូន, និងសេវាកម្មមិនផ្លូវការផ្សេងៗ ។*

៥លានដុល្លារដែរ ។ ទ្រព្យបន្ថែមរបស់ជាតិ ដែលរកបាននៅឆ្នាំ២០០១ ឡើងដល់ជាមធ្យម ១៥ដុល្លារក្នុងពលករម្នាក់ ។ វិស័យទេសចរណ៍ទទួលបានច្រើនជាងគេ (៣១១ដុល្លារ/ពលករម្នាក់) បន្ទាប់មកគឺ វិស័យកាត់ដេរ (២០៩ដុល្លារ/ពលករ

ម្នាក់) ចំណែកឯវិស័យសេវាកម្មមិនផ្លូវការ និងពាណិជ្ជកម្មផ្សេងទៀត ក៏នៅមានចំណេញដដែល ។

ដើម្បីតាមដានចលនាប្រាក់ចំណូលនៃពលករជ្រើសរើស ក្នុងប្រភេទងាយរងគ្រោះមួយចំនួន, វិបសអ បានធ្វើអង្កេតប្រចាំត្រីមាសតាំងពីឆ្នាំ១៩៩៧ លើគំរូតាងមួយមានពលករប្រហែល ៥០០នាក់នៅភ្នំពេញ និងនៅតាមខេត្តជុំវិញភ្នំពេញ[២៤] ។ លទ្ធផលនៃអង្កេតនេះ (តារាង៣.១៧) បង្ហាញថា ចំណូលប្រចាំថ្ងៃនៃអ្នកបំរើតាមភោជនីយដ្ឋាន កម្មករកាត់ដេរ និងអ្នករត់ម៉ូតូឌុប បានកើនយ៉ាងច្រើន ប៉ុន្តែចំណូលរបស់ក្រុមផ្សេងទៀតបានធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ២០០១ បើធៀបនឹងឆ្នាំ២០០០ ។

**តារាង៣.១៧ ប្រាក់ចំណូលដុលប្រចាំថ្ងៃរបស់កម្មករ (ជារៀល)**

| | 2000 | 2001 | ភាគរយប្រែប្រួល |
|---|---|---|---|
| អ្នកបំរើតាមភោជនីយដ្ឋាន | 2,122 | 2,560 | 21% |
| កម្មករកាត់ដេរ | 7,866 | 8,483 | 8% |
| អ្នករត់ម៉ូតូឌុប | 10,467 | 10,600 | 1% |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4,057 | 3,958 | -2% |
| អ្នកលក់ដូរតូចតាច | 6,889 | 6,388 | -7% |
| អ្នកធាក់ស៊ីក្លូ | 9,321 | 8,272 | -11% |
| កម្មករសំណង់គ្មានជំនាញ | 7,571 | 6,557 | -13% |
| អ្នកលីសែង | 7,809 | 6,637 | -15% |
| អ្នករើសអេតចាយ | 4,228 | 3,162 | -25% |
| កម្មករសំណង់មានជំនាញ | 15,220 | 10,937 | -28% |

*ប្រភព: អង្កេតរបស់ វិបសអ*

ជនចំណាកស្រុកតាមរដូវមកពីខេត្ត ដែលមករកស៊ីជាអ្នកធាក់ស៊ីក្លូ, កម្មករសំណង់គ្មានជំនាញ និងអ្នកលីសែង បានធ្លាក់ចុះប្រាក់ចំណូលដុល ១១%, ១៣% និង ១៥%

[២៤] សំណាកគំរូនៃអង្កេតមាន ៤០នាក់តាមក្រុមនីមួយៗ លើកលែងតែវិស័យកាត់ដេរ ដែលមានកម្មករ ១២០នាក់ ។

រៀង១គ្នា ។ អ្នករើសអេតចាយ[២៥] និងកម្មករសំណង់មានជំនាញ គឺជាក្រុមយ៉ាប់ជាងគេ ដោយប្រាក់ចំណូលបានធ្លាក់ចុះ ២៥% និង ២៨% ។ តាមអង្កេតនេះ ការធ្លាក់ចុះនៃប្រាក់ចំណូលអ្នករើសអេតចាយ បណ្តាលជាសំខាន់ដោយសារកំណើនចំនួនអ្នករើសអេតចាយមកពីខេត្តក្រីក្រនៅភាគអគ្នេយ៍នៃប្រទេស (ស្វាយរៀង ព្រៃវែង និង តាកែវ) ។ ចំពោះកម្មករសំណង់ ចំណូលធ្លាក់ចុះដោយសារមិនសូវមានសកម្មភាពសាងសង់, កំនើនកម្មករចំនាកស្រុក, និងការប្រកួតប្រជែងតឹងតែងពីសំណាក់កម្មករបរទេសដែលគេយល់ថាមានជំនាញ និងសមត្ថភាពខ្ពស់ជាង ។

## ៣.៨ ភាពក្រីក្រ និងការអភិវឌ្ឍន៍វិមជ្ឈការ

គេពុំទាន់ឃើញមានការប៉ាន់ស្មានពីភាពក្រីក្រថ្មីទៀតទេ ក្រៅតែពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ ។ យោងតាមអង្កេតនេះ ប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រមានសរុបប្រមាណ ៣៦-៣៧% ។ នៅឆ្នាំ២០០១ ក្រសួងផែនការបានផ្សព្វផ្សាយរបាយការណ៍មួយ ដែលបញ្ជាក់ជាផ្លូវការថា អ្នករស់នៅក្រោមបន្ទាត់ក្រីក្រមានប្រហែល ៣៦% ។ ៩០%នៃប្រជាជនក្រីក្រ រស់នៅតាមជនបទ និងប្រកបរបរកសិកម្ម ។ ទិន្នន័យស្តីពីប្រាក់ចំណូលប្រចាំថ្ងៃដែលបានបង្ហាញពីខាងដើម បំផុសឱ្យដឹងថា ស្ថានភាពក្រីក្រអាចគ្មានការប្រែប្រួល ។ អ្នកក្រីក្រភាគច្រើនគឺជាអនក្ខរជន ឬជាអ្នកចេះអក្សរតិច ។ ពួកគេជាកសិករមានដីតិច ឬកម្មករគ្មានជំនាញនិងគ្មានដី (លក្ខខណ្ឌការងារមិនសុវត្ថិភាព) និងជាគ្រួសារមានស្ត្រីជាមេគ្រួសារ ។ ចំពោះសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្ម ភាពអត់ការងារធ្វើដោយចំហ (open unemployment)[២៦] មានតិចតួចណាស់ ។ ប៉ុន្តែភាពមានការងារមិនពេញលេញ (underemployment) ដែលបង្កប់ខ្លួនក្នុងរូបភាពជាពលករមានផលិតភាព/ចំណូលទាប គឺមានយ៉ាងច្រើន

---

[២៥] ពាក្យនេះសំដៅដល់ពលករដែលប្រមូល និងកែច្នៃ កាកសំណល់ ។

[២៦] ភាពអត់ការងារចំហខុសពីភាពអត់ការងារបង្កប់ខ្លួន (disguished unemployment) និង ភាពមានការងារមិនពេញលេញ ។

ទាំងនៅជនបទ និងទីក្រុង ។ ដោយទទួលស្គាល់ភាពក្រីក្រនៅក្នុងប្រទេស រដ្ឋាភិបាល បានផ្ដួចផ្ដើមដំណើរការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRS) ។ ជំហាន ដំបូងនៃដំនើរការនេះគឺការរៀបចំផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSP) ដែលគ្រោងបញ្ចប់នៅខែតុលា ឆ្នាំ២០០២ ។ ផែនការនេះសំដៅតាមដានយ៉ាងជិតដល់ នូវគោលដៅនានាដែលចែងនៅក្នុងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដែលកំណត់ឡើង ដោយអង្គការសហប្រជាជាតិ និងដែលកម្ពុជាជាហត្ថលេខី ។ នៅក្នុងក្របខ័ណ្ឌ និង ជាបន្ថែម លើ PRS, រដ្ឋាភិបាលបានបង្កើតប្រព័ន្ធតាមដាននិងវិភាគភាពក្រីក្រ ដែល មានទីតាំងនៅក្នុងក្រសួងផែនការ ដើម្បីតាមដានការប្រែប្រួលនៃភាពក្រីក្រ និងផ្ដល់ យោបល់ជូនរដ្ឋាភិបាលពីវិធានការកែតំរូវផ្សេងៗដើម្បីកាត់បន្ថយភាពក្រីក្រ ។

ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ជាលើកដំបូង នៅខែកុម្ភៈ ២០០២ ហើយការបោះឆ្នោតនេះជាផលសំរេចនៃដំណើរការមួយដែល បានចាប់ផ្ដើមនៅឆ្នាំ១៩៩៤ ដើម្បីធ្វើវិមជ្ឈការអភិបាលកិច្ច និងការអភិវឌ្ឍន៍ ក្នុង គោលដៅជំរុញការអភិវឌ្ឍន៍កសិកម្ម និងជនបទ និងលើកកំពស់របបប្រជាធិបតេយ្យ នៅតាមមូលដ្ឋាន ។ គេជឿថា នៅឆ្នាំខាងមុខ រដ្ឋាភិបាលនឹងកសាងច្បាប់ និងផែនការ សកម្មភាព ដើម្បីធ្វើវិមជ្ឈការអភិបាលកិច្ច និងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុទៅ ឱ្យថ្នាក់ក្រោមនៅក្នុងប្រព័ន្ធអភិបាលកិច្ច ។

## ៣.៩ សេចក្ដីសន្និដ្ឋាន និងសេចក្ដីសង្ឃឹមទៅអនាគត

គេឃើញមានចំណុច ៤ ដែលអាចបង្កការជជែកវែកញែកពីអ្វីដែលនឹងអាច កើតមានក្នុងអនាគត ជាពិសេសក្នុងរយៈពេលខ្លីមួយឆ្នាំឬពីរឆ្នាំខាងមុខ ។ *ទីមួយ* គឺ កំណើនចំណូលជាតិ *ទីពីរ* អតិផរណានិងអត្រាប្ដូរប្រាក់, *ទីបី* ថវិការដ្ឋ, និង*ទីបួន* ការ បែងចែកនៃផលចំណេញដល់សង្គមជាតិ ។ សេចក្ដីអធិប្បាយខ្លីៗពីចំណុចនីមួយៗ មានដូចខាងក្រោម ។

កំណើនចំណូលជាតិ ជាប់ទាក់ទិននឹងប្រភពកំណើន ។ ក្នុងពេលកន្លងមក ក្បាលម៉ាស៊ីនសំខាន់នៃកំណើនគឺ ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ។ មូលហេតុមួយដែលធ្វើឱ្យកំណើនក្នុងវិស័យទាំងនេះមានកំរិតខ្ពស់ក្នុងទសវត្សរ៍១៩៩០ គឺកាលនោះឧស្សាហកម្មមានទ្រង់ទ្រាយតូចនៅឡើយ ។ បច្ចុប្បន្ន ដោយមានរោងចក្រប្រហែល ២០០ និងការនាំចេញផលិតផលវាយនភណ្ឌតំលៃ ១.០០០លានដុល្លារ, ឧស្សាហកម្មនេះធំជាងមុនច្រើនណាស់ ។ វិស័យទេសចរណ៍មានដំណើរប្រហែលគ្នា ។ ឥទ្ធិពលគួបផ្សំមួយទៀត គឺការរើបឃឹត១ ចេញពីការធ្លាក់ចុះសេដ្ឋកិច្ចជាសាកលពីព្រោះឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ជាប់ទាក់ទិននឹងតំរូវការអន្តរជាតិ និង FDI ដូច្នេះហើយក៏ត្រូវទទួលរងការប៉ះពាល់ ។ វិស័យកសិកម្មដែលប្រើប្រាស់ពលករច្រើនបំផុត មិនទាន់បង្ហាញសមត្ថភាពក្នុងការធ្វើឱ្យមានកំណើនលឿន និងមានចីរភាពបានទេ ។ ដូច្នេះក្នុងមួយឆ្នាំ ទៅពីរឆ្នាំខាងមុខ ប្រទេសកម្ពុជាមិនអាចប្រែប្រួលអ្វីច្រើនពីអត្រាកំណើនប្រចាំឆ្នាំ ៥% នោះទេ ។

អត្រាអតិផរណានៅកម្ពុជា មានកំរិតទាបឬស្មើសូន្យ ដោយសារដុល្លារូបនីយកម្មនៃសេដ្ឋកិច្ច ។ ដូចបានបញ្ជាក់ពីខាងដើម ប្រហែល ៧០% នៃស្តុករូបិយវត្ថុនៅក្នុងប្រទេស គឺជារូបិយវត្ថុបរទេស ហើយក្នុងប្រតិបត្តិការធំ១ភាគច្រើនគេប្រើប្រាស់រូបិយវត្ថុបរទេស ។ ដុល្លារូបនីយកម្ម មិនអាចបំបាត់បានក្នុងពេលឆាប់១ទេ ពីព្រោះទីផ្សារបានសំរបខ្លួនតាមប្រព័ន្ធនេះហើយ ហើយក៏ពុំឃើញមានការប្រឹងប្រែងប្រើប្រាស់គោលនយោបាយសាធារណៈអ្វី ដើម្បីបំបាត់រឿងនេះដែរ។ ដូច្នេះ អតិផរណានៅកម្ពុជាសំរាប់មួយឬពីរឆ្នាំក្រោយ រំពឹងថានឹងមានកំរិតទាប ពីព្រោះប្រតិបត្តិការភាគច្រើនធ្វើជារូបិយវត្ថុបរទេស ហើយតំលៃប្រាក់រៀលត្រូវចងភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងប្រាក់ដុល្លារ។ ដូចគ្នាដែរ អត្រាប្តូរប្រាក់រៀល-ដុល្លារ រំពឹងថាស្ថិតនៅថេរក្នុងរង្វង់ ៣.៩០០-៣.៩៥០រៀល/ដុល្លារ ទោះមានការបញ្ចេញសាច់ប្រាក់រៀលប្រើ

ច្រើននៅក្នុងការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០០២ និងការបោះឆ្នោតសភាជាតិនៅឆ្នាំ ២០០៣ ក្តី ។

ថវិការដ្ឋាភិបាលកម្ពុជាមានឱនភាពយ៉ាងធ្ងន់ធ្ងរ ដោយសារភាពទន់ខ្សោយក្នុងការប្រមូលចំណូល ។ កន្លងមក ឱនភាពថវិកាត្រូវបានបំពេញដោយជំនួយអន្តរជាតិ ។ ដោយហេតុថា ទាយកសន្យាផ្តល់ជំនួយឱ្យកម្ពុជាយ៉ាងហោចណាស់ក្នុងរយៈពេលខ្លីដែរ ដូច្នេះវាសមហេតុផលហើយដែលគេមានជំនឿថា ការផ្តល់មូលនិធិទ្រទ្រង់ឱនភាពថវិកា នឹងមានបន្តសំរាប់មួយឬពីរឆ្នាំទៀត ។ ចំពោះការប្រមូលចំណូលវិញ វាលូតលាស់យឺតជាងផែនការបានកំណត់សំរាប់ឆ្នាំនីមួយៗ ។ ឆ្នាំ២០០២ និង ២០០៣ ជាឆ្នាំបោះឆ្នោត ហើយរដ្ឋាភិបាលក៏ស្ថិតក្នុងសម្ព័ន្ធភាព ដូច្នេះប្រហែលជាគ្មានវិធានការតឹងរ៉ឹងអ្វីដើម្បីបង្កើនការប្រមូលពន្ធទេ ។ ក្នុងពេលដូចគ្នា តំរូវការចំណាយប្រហែលជានឹងមានកំរិតខ្ពស់ ពីព្រោះ ដំណើរការកែទំរង់ទាមទារនូវការផ្តល់ថវិកាបៀវត្សរ៍ឱ្យបានប្រសើរជាងមុន, ការអភិវឌ្ឍន៍ និងការធ្វើសមាហរណកម្មទៅក្នុងអាស៊ានត្រូវមានចំណាយច្រើនលើហេដ្ឋារចនាសម្ព័ន្ធ, កម្មវិធីកាត់បន្ថយភាពក្រីក្រត្រូវពង្រឹងថែមទៀត, ហើយការបោះឆ្នោតខាងមុខនឹងត្រូវការសាច់ប្រាក់ច្រើន ។ គំលាតរវាងចំណូល និងចំណាយក្នុងស្រុក ប្រហែលជានឹងកាន់តែរីកធំ ហើយនឹងត្រូវបំពេញដោយជំនួយបរទេស ។

ការបែងចែកផលចំណេញត្រូវផ្សារភ្ជាប់នឹងប្រភពកំណើន ចំណាយថវិការដ្ឋ និងកម្មវិធីជំនួយអន្តជាតិ ។ ដោយសារប្រភពកំណើនប្រហែលមិនប្រែប្រួលទេក្នុងរយៈមួយឬពីរឆ្នាំខាងមុខ ដូច្នេះនឹងមានការប្រែប្រួលតែតិចតួចនៅក្នុងការបែងចែកចំណូលដែលកើតចេញពីដំណើរការកើនឡើង ។ រដ្ឋាភិបាលប្រហែលបង្កើនចំណាយលើវិស័យសង្គមកិច្ច និងបន្ថយចំណាយខាងការពារជាតិ និងរដ្ឋបាល ហើយទង្វើនេះអាចមានផលល្អដល់អ្នកក្រីក្រ និងជនបទ ។ ដូចគ្នានេះដែរ ជំនួយបរទេសសំរាប់កាត់បន្ថយភាពក្រីក្រអាចកើនឡើង ហើយអាចជួយឱ្យបង្កើនប្រាក់ចំណូលរបស់អ្នកក្រីក្រ

(តាមរយៈការវិនិយោគខាងកសិកម្ម អភិវឌ្ឍន៍ជនបទ និងធនធានមនុស្ស) ។ ប៉ុន្តែ ផលប៉ះពាល់ក្នុងរយៈពេលខ្លីនៃជំនួយទាំងនេះ ប្រហែលមិនសូវលេចធ្លោប៉ុន្មានទេ ។

# ជំពូកទី ៤
# ការអភិវឌ្ឍន៍វិស័យឯកជន នៅក្នុងប្រទេសកម្ពុជា: ការសិក្សាដំបូង

## ៤.១ សេចក្តីផ្តើម

ជោគជ័យខាងសេដ្ឋកិច្ចនៅអាស៊ីខាងកើត និងអាស៊ីអគ្នេយ៍ គឺជាភស្តុតាង ចំពោះរឿងពិតមួយដែលថា ការអភិវឌ្ឍន៍វិស័យឯកជន អាចជាសញ្ញាមួយប្រាប់មុន ពីកំណើនសេដ្ឋកិច្ចយ៉ាងលឿននៅអាស៊ី ។ រដ្ឋាភិបាលភាគច្រើននៅក្នុងប្រទេសកំពុង អភិវឌ្ឍន៍ ព្រមទាំងទីភ្នាក់ងារអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី កំពុងខិតខំដោះស្រាយ បញ្ហាថា តើត្រូវធ្វើយ៉ាងណាដើម្បីជំរុញវិស័យឯកជន ។ គេបានគិតគូរទាំងការទាក់ ទាញមូលធនបរទេស និងការជំរុញមូលធនជាតិ ដើម្បីញ៉ាំងឱ្យសេដ្ឋកិច្ចដែលមាន ចំណូលទាប និងលក្ខណៈអន្តរកាល បានស្ថិតនៅលើផ្លូវដែលមានកំណើនខ្ពស់ ។

ក្នុងការពិចារណាពីការអភិវឌ្ឍន៍វិស័យឯកជននៅកម្ពុជា គួរបញ្ជាក់ពីដំបូងថា កម្ពុជាចាប់ផ្តើមការអភិវឌ្ឍន៍ពីកំរិតសឹងស្មើសូន្យ ។ រឿងនេះ វាពិតជាក់ស្តែងទាំង សំរាប់ការលូតលាស់វិស័យឯកជន និងឧស្សាហូបនីយកម្មនៅដើមទសវត្សរ៍១៩៩០ ដែលជាដំណាក់កាលសេដ្ឋកិច្ចទើបបើកចំហ ។ ៣០ឆ្នាំនៃសង្គ្រាមនិងការរើករេ បាន បំផ្លាញហេដ្ឋារចនាសម្ព័ន្ធកម្ពុជាអស់ បានធ្វើឱ្យបាត់បង់អ្នកមានកំរិតអប់រំ ការបណ្តុះ បណ្តាលនិងជំនាញ, ហើយនៅពេលនោះជាសកម្មភាពសេដ្ឋកិច្ច គឺមានតែកសិកម្ម

ជីវព្រឹត្ត ជំនួញតូចតាច និងឧស្សាហកម្មផលិតផលតូចរបស់រដ្ឋក្នុងរដ្ឋធានីប៉ុណ្ណោះ ។ ហេដ្ឋារចនាសម្ព័ន្ធសឹងតែគ្មានសោះ បើសិនវាយតំលៃតាមស្តង់ដានាសម័យនោះ ។ អង្កេតពីគ្រឹះស្ថាននៅឆ្នាំ១៩៩៥ (RGC 1997) បង្ហាញថា នៅកម្ពុជាគ្រឹះស្ថានអាជីវកម្មដែលមានបុគ្គលិកចាប់ពី១០នាក់ឡើងទៅ មានសរុប ៨២៩, ក្នុងនេះមាន ១២៧កន្លែងតាំងនៅភ្នំពេញ និង ៧០២កន្លែងទៀតនៅតាមបណ្តាខេត្ត ហើយ ៩៤% ជាសហគ្រាសផលិត និង ៦% សហគ្រាសសេវាកម្ម[២៧] ។ សកម្មភាពដែលកើតមាននៅដំណាក់កាលដំបូង (ដើមទសវត្សរ៍១៩៩០) ភាគច្រើនមានទ្រង់ទ្រាយជាវិនិយោគបរទេសឯកជនខាងសម្បទានព្រៃឈើ កសិកម្មពាណិជ្ជកម្ម និងក្រោយមកទៀតមានឧស្សាហកម្មកាត់ដេរ ។ គេឃើញមានវិនិយោគក្នុងផ្នែកទេសចរណ៍ និងសណ្ឋាគារប្រណិតផងដែរ ជាបន្ថែមទៅលើវិនិយោគដ៏តូចខាងផ្នែកទូរគមនាគមន៍ ។ វិស័យឯកជនគ្រប់គ្រងដោយអ្នកនៅក្នុងស្រុក វាស្ថិតនៅក្នុងដំណាក់កាលដំបូងបំផុតនៃការលូតលាស់ គឺមានតែសេវាកម្មខ្លះៗ ដូចជា ពាណិជ្ជកម្មលក់រាយ និងការលក់អចលនវត្ថុ និងការធ្វើជាដៃគូមានភាគហ៊ុនតិច ជាមួយនឹងមូលធនបរទេស ដើម្បីបំពេញតាមការតំរូវនៃច្បាប់ ។ គឺនៅក្នុងបរិបទនេះហើយ ដែលគេត្រូវពិនិត្យ និងវាយតំលៃពីការអភិវឌ្ឍន៍វិស័យឯកជននៅកម្ពុជា ។

ក្នុងលក្ខណៈជាសេដ្ឋកិច្ចអន្តរកាល និងធ្វើឧស្សាហូបនីយកម្មក្រោយគេ កម្ពុជាកន្លងមកបានបង្ហាញនូវសមត្ថភាពមានកំរិតដើម្បីអភិវឌ្ឍន៍ និងទាញផលចំណេញពីឧត្តមភាពប្រៀបធៀបរបស់ខ្លួននៅក្នុងវិស័យផ្សេងៗទៀត ក្រៅពីការធ្វើអាជីវកម្មបម្លិនព្រៃឈើដ៏សំបូរក្នុងរយៈពេលដ៏ខ្លី (Chan 2000) ។ ប្រទេសកម្ពុជាត្រូវជួបបញ្ហាប្រឈមយ៉ាងធំក្នុងការដាក់លក្ខខណ្ឌលើការរីកលូតលាស់វិស័យឯកជន ដើម្បីដោះ

[២៧] តួលេខនេះមានលំអៀងយ៉ាងច្បាស់ ដោយអង្កេតពីគ្រឹះស្ថាននៅកម្ពុជា កន្លងមកមិនបានបូកបញ្ចូលសហគ្រាសធុនតូច ឬលក្ខណៈគ្រួសារទេ ។ ប៉ុន្តែទោះយ៉ាងដូច្នេះក្តី ក៏មូលដ្ឋានឧស្សាហកម្មនៅតែតូចដដែល ។

ស្រាយបញ្ហាទាក់ទិននឹងភាពក្រីក្រ ភាពគ្មានការងារធ្វើ និងប្រាក់ចំណូលទាប ។ ដោយទទួលស្គាល់ពីបញ្ហាប្រឈមនេះ រដ្ឋាភិបាល ទើបបញ្ចប់ក្នុងពេលថ្មីៗនូវការសិក្សាមួយខ្សែ ដែលពិនិត្យអំពីបញ្ហានៃការលូតលាស់វិស័យឯកជននៅក្នុងបរិបទពាណិជ្ជកម្មអំនោយផលដល់អ្នកក្រីក្រខ្សត់ខ្សោយ (គិតតាមវិស័យ/ឧស្សាហកម្ម) ។ ឧទាហរណ៍ ដើម្បីជួយឱ្យមានកំណើន ការសិក្សាបានពិចារណាទៅលើវិស័យណាដែលអាចអភិវឌ្ឍទៅបាន និងជំហានណាខ្លះ ដែលត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌច្បាប់ ដើម្បីជំរុញកំណើននេះ (MoC 2001a, b, c, d) ។ ប៉ុន្តែនៅមានសំនួរសំខាន់ៗមួយចំនួនទៀត ឧទាហរណ៍ តើយុទ្ធសាស្ត្រធ្វើអាជីវកម្មអ្វីខ្លះដែលកន្លងមកធ្លាប់បានទទួលជោគជ័យ? តើនៅកំរិតមីក្រូ ពួកអាជីវករជាបុគ្គលបានជួបការរាំងស្ទះ និងការបារម្ភអ្វីខ្លះ? តើសហគ្រិនអាចលើកសំណើយ៉ាងដូចម្តេចចំពោះគោលនយោបាយសាធារណៈ? សំណួរទាំងនេះសំខាន់បំផុតចំពោះការចាក់ឫសរឹងមាំនៃវិស័យឯកជន ប៉ុន្តែមិនទាន់មានចម្លើយពេញលេញនៅឡើយទេ[២៨] ។ ជំពូកនេះបង្ហាញនូវការប្រឹងប្រែងដ៏តូចមួយ ដើម្បីផ្តល់ចម្លើយចំពោះសំនួរខ្លះៗ ។

ជំពូកបួន លើកត្រួសៗពីការសិក្សាពីដំបូង ដែលផ្អែកលើគំរូតាងតូចមួយនៃក្រុមសហគ្រាសគ្រប់គ្រងដោយអ្នកក្នុងស្រុកដែលបានទទួលជោគជ័យ ។ ការងារនេះមានគោលដៅពិនិត្យពីការលូតលាស់ និងចារិកនៃវិស័យឯកជននៅកម្ពុជា ដែលចាំបាច់បំផុតសំរាប់ឧស្សាហូបនីយកម្មនៃកម្ពុជា ។ ការស្រាវជ្រាវក្នុងជំពូកនេះ ផ្អែកលើករណីសិក្សាអំពីសហគ្រាសឯកជនធុនតូច និងធំ, ទាំងនៅក្រៅ និងក្នុងក្រុងភ្នំពេញ ។ មានការស្រាវជ្រាវពតិមានអំពីការបង្កើតសហគ្រាស, ការលូតលាស់, បញ្ហាដែលត្រូវប្រឈម និងយុទ្ធសាស្ត្រដោះស្រាយរបស់ពួកគេ ។ បន្ទាប់មក មានបង្ហាញពី

[២៨] កន្លងមកប្រហែលជាមានការសិក្សាតែមួយទេដែលធ្វើឡើងដោយ Webster និង Boring (2000) ដែលផ្តោតទៅលើចម្លើយរបស់អាជីវករ ។

អនុសាសន៍មួយចំនួន សំរាប់គោលនយោបាយសាធារណៈ ផ្អែកតាមសំណូមពរពីពួកសហគ្រិន ។

ផ្នែកទី២ នៃជំពូកនេះបង្ហាញពីសនិទានភាព (rationale) នៃការអភិវឌ្ឍន៍វិស័យឯកជនមួយដែលគ្រប់គ្រង និងកាន់កាប់ដោយអ្នកក្នុងស្រុក ។ ផ្នែកទី៣ បង្ហាញពីការលូតលាស់សេដ្ឋកិច្ចកម្ពុជា និងវិស័យឯកជននៅក្នុងឆ្នាំកន្លងទៅថ្មីៗ ។ ផ្នែកទី៤ បង្ហាញពីសេចក្តីសង្ខេបតាមបញ្ហានៃករណីសិក្សា ដែលជាទិន្នន័យគ្រឹះសំរាប់ការសិក្សានេះ ។ ផ្នែកទី៥ ផ្តល់អនុសាសន៍ដែលទាក់ទងនឹងបរិយាកាសម៉ាក្រូសេដ្ឋកិច្ច, អភិបាលកិច្ច, ហិរញ្ញវត្ថុ, ធនធានមនុស្សនិងបច្ចេកវិទ្យា, និងការពង្រឹងផ្នែកផ្គត់ផ្គង់ ។ នៅផ្នែកចុងក្រោយនឹងមានបង្ហាញនូវសេចក្តីសន្និដ្ឋានលើការសិក្សានេះ ។

## ៤.២ សនិទានភាព និងខ្វះខាតនៃវិស័យឯកជនកាន់កាប់ និង/ឬ គ្រប់គ្រងដោយអ្នកក្នុងស្រុក

### *៤.២.១ តំរូវការ*

ការប្រើប្រាស់គំរូអភិវឌ្ឍន៍តាមបែបបទរៀបរយ (conventional development models) ដែលពឹងផ្អែកទាំងស្រុងលើផែនការមជ្ឈការ ឬសេដ្ឋកិច្ចប្រមូលផ្តុំ ត្រូវប្រឈមមុខនឹងតំរូវការបង្កើតការងារមានចីរភាព ដើម្បីស្រូបយកកំណើនកំលាំងពលកម្ម ។ រឿងនេះជាការចាំបាច់ ពីព្រោះប្រជាជនកើនឡើងយ៉ាងច្រើនក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនៅអាស៊ី ។ សព្វថ្ងៃមានការយល់ស្របគ្នាកាន់តែច្រើនឡើងថា វិស័យឯកជន ឬវិនិយោគបរទេស ក៏វិស័យកសិកម្មតែមួយមុខៗមិនដែល និងមិនអាចបង្កើតការងារបានពេញលេញទៅតាមល្បឿននៃកំណើនតំរូវការការងារឡើយ ។ ភាពយឺតក៏រិតទាបនៃការប្រើប្រាស់កំលាំងពលកម្ម ធៀបជាមួយនឹងកំណើននៅក្នុងវិស័យទាំងនេះ ព្រមទាំងលទ្ធផលមិនគួរឱ្យកត់សំគាល់នៃការកាត់បន្ថយភាពក្រីក្រ គឺជាភស្តុតាងបញ្ជាក់ពីរឿងនេះ ។

បទពិសោធន៍ជាសាកល ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ បានបង្ហាញថា វិស័យឯកជនដែលបានធ្វើចំរុះកម្ម (diversified private sector) ហើយមានដំណើរការនៅក្នុងបរិស្ថានប្រកួតប្រជែងគ្នា វាមានសក្តានុពលយ៉ាងធំនៅក្នុងការរួមចំនែកជំរុញកំណើនមានចីរភាព និងកាត់បន្ថយភាពក្រីក្រ (World Bank 2001a) ។

### *៤.២.២ បទពិសោធន៍ពីកន្លែងផ្សេងៗ*

ចាប់តាំងពីសង្គ្រាមលោកលើកទីពីរមក មានការប្រមូលផ្តុំមូលធនយ៉ាងស្តុកស្តម និងការកែលំអគុណភាពជីវិតសឹងតែគ្រប់ប្រទេសនៅអាស៊ី (ដូចជានៅកូរ៉េ ជប៉ុន និងតៃវ៉ាន់) ។ ថ្មីៗនេះ ប្រទេសចិនក៏បានអភិវឌ្ឍតាមលំនាំខាងលើដែរ ។ ប្រទេសទាំងនេះអាចបង្កើតការងារបានយ៉ាងច្រើនសំរាប់ពលករក្នុងស្រុក[២៩] និងបានទទួលជោគជ័យតាមរយៈគំនិតផ្តួចផ្តើមរបស់វិស័យឯកជន ។ ជាលទ្ធផល ពលករបានចាកចេញពីតំបន់/វិស័យមានផលិតភាពទាប (វិស័យជីវព្រឹត្តិ, វិស័យបឋម) ទៅកាន់តំបន់/វិស័យមានផលិតភាពខ្ពស់ ហើយតាមនេះភាពក្រីក្រក៏ត្រូវបានកាត់បន្ថយ[៣០] ។ ក្នុងករណីនីមួយៗខាងលើ ទាំងឧស្សាហកម្មធុនធំ ធុនមធ្យម និងធុនតូច នៅជនបទក៏ដូចជានៅទីក្រុង គឺមានតួនាទីយ៉ាងសំខាន់[៣១] ។ នៅឆ្នាំដំបូងៗនៃឧស្សាហូបនីយកម្មនៅជប៉ុន និងកូរ៉េ ច្បាប់បានហាមឃាត់បរទេសក្នុងការកាន់កាប់ភាគហ៊ុន លើសពី

---

[២៩] ច្បាប់ចេញផ្សាយថ្មីៗនៃ WB Observers (2001) បានសំគាល់ថា ការប្រមូលផ្តុំ និងការបណ្តាក់មូលធនក្នុងប្រទេស ជាកត្តាកំនត់ពីការអភិវឌ្ឍន៍ល្អជាងអត្រាកំនើនតែឯកឯង ។

[៣០] ចំពោះពតិមានលំអិត សូមអាន Islam (1997), Johansson និង Ronnas (1996), World Bank (1991) និង World Bank (2001b) ។

[៣១] ពាក្យ "ឧស្សាហកម្មធុនតូច ឧស្សាហកម្មជនបទ សកម្មភាពក្រៅកសិដ្ឋាន និងសកម្មភាពក្នុងវិស័យមិនប្រមូលផ្តុំ" មានន័យដូចគ្នានៅក្នុងអត្ថបទនេះ និងសំដៅដល់សកម្មភាពសេដ្ឋកិច្ចនានាដែលនៅក្រៅកសិកម្ម/ឧស្សាហកម្មធុនធំទំនើបៗ ឬក្រៅឧស្សាហកម្មដែលប្រើកំលាំងពលកម្មច្រើន ។ តាមទស្សនៈវិស័យពីអាស៊ីរបស់ ILO បានផ្តល់មតិឱ្យបង្កើតការងារយ៉ាងច្រើនតាមរយៈសហគ្រាសនៅមូលដ្ឋាន ។ សូមអាន ILO-SAAT (2000) ។

សមាមាត្រតូចមួយ ក្នុងគោលដៅរក្សាទុកតំលៃបន្ថែមនៅក្នុងប្រទេសឱ្យបានច្រើនជាអតិបរមា ដើម្បីញ៉ាំងឱ្យមានវិនិយោគបន្ត និងការធ្វើឧស្សាហូបនីយកម្មថែមទៀត ។

### *៤.២.៣ ផលចំណេញពីវិស័យឯកជនដើមកំណើតក្នុងស្រុក*[៣២]

គេមានហេតុផល និងអត្ថប្រយោជន៍យ៉ាងច្រើន ក្នុងការជំរុញវិស័យឯកជនដែលជាកម្មសិទ្ធិនៃអ្នកនៅក្នុងស្រុក ទោះបីជាក្នុងទ្រង់ទ្រាយជាឧស្សាហកម្មធុនធំប្រមូលផ្តុំ និងធ្វើសមាហរណកម្មបញ្ឈរ ឬក៏សកម្មភាពចំរុះធុនតូច ទាំងនៅទីក្រុង និងជនបទក្តី ហើយបន្សំនៃទ្រង់ទ្រាយទាំងពីរនេះ គឺប្រសើរបំផុត ។ អត្ថប្រយោជន៍មួយចំនួនមានដូចខាងក្រោម:

*ក. ការបង្កើតការងារថ្មីមានចីរភាព*

ហេតុផលចំបងគេគឺការបង្កើតការងារ សំរាប់រ៉ាប់រងកំលាំងពលកម្មនៅសល់ដែលបច្ចុប្បន្នស្ថិតនៅក្នុងកសិកម្មជីវព្រឹត្តិ និងសកម្មភាពមានផលិតភាពទាបផ្សេងទៀត ។ ការបែងចែកឡើងវិញនូវកំលាំងពលកម្មនេះ ឱ្យទៅធ្វើការងារផ្សេងទៀត ដែលមានប្រាក់កំរៃខ្ពស់ អាចជួយកាត់បន្ថយភាពក្រីក្រភ្លាមៗ ។ ដោយសារលក្ខណៈសំបូរបែបនៃសកម្មភាពក្រៅពីកសិកម្មជីវព្រឹត្ត ចំណូលទទួលបានពីសកម្មភាពទាំងនេះ ប្រហែលមិនធ្លាក់ចុះទេ ដូច្នេះក្នុងអនាគតដ៏ខ្លី ពលករប្រហែលជាអាចមានការងារមានចីរភាព ។

*ខ. ការលើកកំពស់ការបែងចែកទ្រព្យសម្បត្តិ និងចំណូល*

សន្ទុះខ្លាំងក្លាដូចគ្នាមួយទៀត ផុសចេញពីតំរូវការបែងចែកទ្រព្យសម្បត្តិ និងចំណូល ។ គេឃើញមានកំណើនប្រជាជនយ៉ាងច្រើនដែលជាពលករគ្មានទ្រព្យ ឬគ្មានដី ។ ដំណោះស្រាយបាននូវបញ្ហាទ្រព្យសម្បត្តិ និង/ឬតំរូវការចាំ

[៣២] ផ្នែកនេះ មិនបានបង្អាប់តួនាទីនៃវិនិយោគផ្ទាល់ពីបរទេសទេ ។ ការគួបផ្សំនៃវិនិយោគពីក្រៅប្រទេស និងវិនិយោគក្នុងប្រទេស នឹងមានឥទ្ធិពលរីតតែទ្វេឡើង (synergy) ។

បាច់ផ្សេងៗរបស់អ្នកទាំងនេះ គឺមានន័យថា បើកចំហលទ្ធភាពផ្តល់អាជីព ដោយខ្លួនឯងឱ្យដល់ពួកគេ ។ ការប្រឹងប្រែងធ្វើឱ្យសំបូរបែបនូវការងារ នឹងជួយបង្កើនសមត្ថភាពមនុស្ស និងធនធានរូបវ័ន្តនៅក្នុងប្រទេស ។ ការលូតលាស់វិស័យឯកជនសំបូរបែប និងប្រកបដោយភាពប្រកួតប្រជែង ជាញឹកញាយណាស់តែងនាំឱ្យមានការបែងចែកដោយផ្ទាល់ និងជាប្រយោលនូវចំណូល និងធនធាននៅក្នុងចំណោមប្រជាជនកាត់តែច្រើនថែមទៀត ។

*គ. លើកទឹកចិត្តដល់ការអភិវឌ្ឍន៍មានតុល្យភាពល្អនៅក្នុងតំបន់*

អសមត្ថភាពក្នុងការគ្រប់គ្រងចំនាកស្រុកទៅកាន់ទីក្រុងធំៗ ឬការបង្កើតបរិវេណឧស្សាហកម្មតាមទីក្រុងដែលមានតំបន់ស្នូលច្រើន ហើយដែលអាចប្រើប្រាស់ ដោយមានផលិតភាពនូវប្រជាជនជនបទ និងប្រជាជនពាក់កណ្តាលជនបទ បានបង្កការប្រមូលផ្តុំប្រជាជន និងការចង្អៀតចង្អល់ហួសហេតុនៅក្នុងទីក្រុងធំៗ ។ ម្យ៉ាងទៀត ប្រជាជននៅរាជធានីភ្នំពេញមានច្រើនហួសក៏វិត បើធៀបនឹងប្រជាជននៃទី ក្រុងផ្សេងទៀតដែលតូចជាងៈ ទីក្រុងធំជាងគេបន្ទាប់ពីភ្នំពេញ គឺតូចជាងភ្នំពេញដល់ទៅ ១០ដង ។ សកម្មភាពតូចតាចនៅក្នុងវិស័យមិនផ្លូវការនៅទីក្រុង (ពិសេសពាណិជ្ជកម្មលក់រាយ និងវិស័យសេវាកម្ម ដែលជនចំណាកស្រុកតែងរកស៊ីចិញ្ចឹមជីវិត) កាន់តែពិបាករីកលូតលាស់ថែមទៀតហើយ នៅក្រោមគោលនយោបាយបច្ចុប្បន្ន ។ កំណើនសកម្មភាពនៃវិស័យឯកជនបានធ្វើវិមជ្ឈការ នឹងជួយបំពេញបាននូវគោលដៅនៃឧស្សាហូបនីយកម្មមានតុល្យភាពនៅក្នុងតំបន់ ហើយតាមនេះ វាបំពេញគោលដៅនៃការអភិវឌ្ឍន៍មានតុល្យភាពបាន ដែលឧស្សាហូបនីយកម្មតាមផែនការប្រមូលផ្តុំ អាចត្រូវប្រើពេលយូរណាស់ទើបសំរេចបាន ។

*ឃ. លើកកំពស់សហគ្រិនភាព ការអភិវឌ្ឍន៍ជំនាញ និងការផ្ទេរបច្ចេកវិទ្យា*

វិស័យឯកជន (គឺសហគ្រាសធុនតូច និងមធ្យម ក្នុងភាគច្រើន ប៉ុន្តែមិនមែនទាំងអស់ទេ) មានសមត្ថភាពយ៉ាងធំធេងក្នុងការផ្សព្វផ្សាយជំនាញ និងបច្ចេកវិទ្យាដល់ក្រុមពលករផ្សេងៗ ។ មួយចំណែកទៀត មិនមែនមានត្រឹមតែជំនាញគ្រប់គ្រង និងបច្ចេកទេសទេដែលអាចសាយភាយបានយ៉ាងឆ្ងាយនោះ ប៉ុន្តែពលករម្នាក់ៗក៏អាចកើនទំនុកចិត្តដើម្បីក្លាយជាសហគ្រិនផងដែរ ។ គេមានភស្តុតាងច្រើនគ្រប់គ្រាន់នូវអាជីវករតូចតាច ដែលបានរីកលូតលាស់នៅក្នុងបរិស្ថានទីផ្សារខុសៗគ្នា ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ (Saith 2000) ។

*ង. បង្កើនតំលៃបន្ថែមនៅក្នុងប្រទេស*

តាមនិយមន័យរបស់វា វិស័យឯកជនក្នុងស្រុកត្រូវរក្សាទុកតំលៃបន្ថែមភាគច្រើនរបស់ខ្លួននៅក្នុងប្រទេស ហើយប្រការនេះបានអនុញ្ញាតឱ្យមានសញ្ជ័យនិងការបង្កបង្កើតមូលធនបានកាន់តែច្រើន ។ ផ្ទុយទៅវិញចំណូលលើមូលធនបរទេស នឹង ត្រូវនាំយកទៅប្រទេសដើមវិញ (Hach *at al.* 2001) ។

*ច. បង្កើតចំណងទាក់ទងនៅក្នុងសេដ្ឋកិច្ចក្នុងស្រុក*

ជាញឹកញយណាស់ ក្នុងដំណាក់កាលដំបូងៗនៃឧស្សាហូបនីយកម្ម សកម្មភាពនិងឧស្សាហកម្មរបស់វិស័យឯកជនក្នុងស្រុក តែងប្រើប្រាស់ធនធានដែលអាចរកបានក្នុងស្រុកយ៉ាងច្រើន ព្រមទាំងធ្វើការផ្គត់ផ្គង់ទៅទីផ្សារក្នុងស្រុកវិញ ។ របៀបរបបនេះបានជួយជំរុញខ្សែរយៈផលិតកម្មនៅខាងក្រោយ និងនៅឯដើមទីដែលអាចបង្កើតឱ្យមានសកម្មភាពសេដ្ឋកិច្ច និងជួយផ្សព្វផ្សាយបច្ចេកវិទ្យា ។ ឧស្សាហកម្មកែច្នៃ កសិផលដែលធ្វើកិច្ចសន្យាលើការដាំដុះសំរាប់ខ្សែរយៈផលិតកម្មកសិកម្មនៅឯដើម ទីដូចមានអនុវត្តនៅប្រទេសស៊ីរីលង្កា គឺជាឧទាហរណ៍ដ៏ល្អមួយ (Dunham 1994) ។ ប្រទេសភាគច្រើននៅ

អាស៊ីអគ្នេយ៍ រួមទាំងកម្ពុជាផង មានសក្តានុពលសំរាប់កំណើនកសិកម្មយ៉ាងល្អប្រសើរ ដែលអាចជួយបង្កើតចំណងទាក់ទងជាមួយទីផ្សារ និងសកម្មភាពកែច្នៃកសិផលយ៉ាងឆាប់រហ័សបាន ។

*ឆ. ធ្វើឱ្យមានស្ថិរភាព និងរបាយនៅក្នុងតំបន់*

ការអភិវឌ្ឍន៍វិស័យឯកជន អាចនាំឱ្យមានរបាយមូលធនទៅកាន់តំបន់ផ្សេងៗក្នុងទូទាំងប្រទេស ហើយប្រការនេះបង្កើតឱ្យមានការបែងចែកធនធានកាន់តែច្រើនដល់ប្រជាជនគ្រប់ស្រទាប់ ។ ក្នុងដំណើរការនេះ ប្រជាជនក៏ក្លាយជាអ្នកមានភាគហ៊ុន ហើយគេមានផលប្រយោជន៍ក្នុងកិច្ចការពារទ្រព្យសម្បត្តិរបស់ខ្លួន ។ អភិបាលកិច្ចល្អ ប្រសើរដែលមានសារៈសំខាន់ជាអាយុជីវិតចំពោះសេដ្ឋកិច្ច ក៏ដូចជាការអភិវឌ្ឍន៍សង្គម អាចកកើតបានងាយស្រួល បើសិនជាប្រជាជនភាគច្រើន ជាអ្នកមានកម្មសិទ្ធិ មានការត្រួតត្រា និង/ឬស្គាល់ពីតំលៃទ្រព្យសកម្មនានា ហើយមានភាគហ៊ុននៅក្នុងទ្រព្យទាំងនោះ ។

### *៤.២.៤ សមភាពយេនឌ័រ*

នៅកម្ពុជា ក៏ដូចប្រទេសអាស៊ីភាគច្រើនដែរ ការងារដែលស្ត្រីកាន់កាប់តែងមានឋានៈតូចតាច និងកំរៃតិចតួច ។ ស្ត្រីមានលទ្ធភាពចាប់យកធនធានសមត្ថភាព និងធនធានរូបវ័ន្តតិចជាងបុរស ។ ប៉ុន្តែ ដោយសារនៅដំណាក់កាលដំបូងៗ មូលដ្ឋានធនធានក្នុងវិស័យឯកជនដែលគ្រប់គ្រងដោយអ្នកក្នុងស្រុក មិនទាន់ធំដុំ ឬស្មុគស្មាញច្រើននៅឡើយទេ ដូច្នេះវិស័យនេះ ពិសេសឧស្សាហកម្មធុនតូច និងតូចបំផុត អាចផ្តល់ឱកាសស្មើភាពមួយដល់ស្ត្រី ។ នៅក្នុងប្រទេសភាគច្រើនគេបានសង្កេតឃើញថា ការចូលរួមរបស់ស្ត្រីនៅក្នុងសហគ្រាលធុនតូច មានច្រើនលើសលុបជាងនៅក្នុងគ្រឹះ

ស្ថានធំៗ[៣៣] ។ ពេលបានចូលធ្វើការ ស្ត្រីមានឱកាសចាប់យកជំនាញ និងទាមទារការកែលំអមុខតំណែងនៅក្នុងទីផ្សារពលកម្ម ។

## *៤.២.៥ ឧស្សាហកម្មនៃវិស័យឯកជន នៅក្នុងដំណាក់កាលដំបូងៗនៃការអភិវឌ្ឍន៍*

ដើម្បីបង្ហាញជាឧទាហរណ៍ខ្លះៗ, នៅក្នុងដំណាក់កាលដំបូងៗនៃការអភិវឌ្ឍន៍ សហគ្រាសក្នុងវិស័យឯកជន (ភាគច្រើន ប៉ុន្តែមិនមែនទាំងអស់ទេ គឺជាសហគ្រាសធុនតូច និងមធ្យម) ដែលទទួលជោគជ័យក្នុងសកម្មភាពផលិត/ជួយទ្រទ្រង់ អាចជាសាខា អ្នកម៉ៅការ ផលិតករផ្ទាល់ និងឧស្សាហកម្មតាមផ្ទះ/គ្រួសារ ។ សហគ្រាសក្នុងវិស័យសេវា ក៏បានទទួលជោគជ័យដែរក្នុងការងារដឹកជញ្ជូន លក់រាយ សេវាផ្ទាល់ខ្លួន និងសេវាបច្ចេកទេសជាដើម ។ លក្ខណៈវិនិច្ឆ័យដ៏សំខាន់សំរាប់ជោគជ័យ គឺកំរិតស្មុគស្មាញនៃបច្ចេកវិទ្យាដែលអាចសំរេចបាន នៅក្នុងដំណើរការផលិត ឬផ្តល់សេវា ។ នៅឯប្រទេសអភិវឌ្ឍន៍ សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យខ្លះ គឺជាអ្នកឈានមុខខាងផ្នែកបច្ចេកវិទ្យាទំនើប (ដូចជា អ្នកប្រើប្រាស់ "បច្ចេកវិទ្យាទន់ភ្លន់", អ្នកច្នៃបង្កើតគ្រឿងម៉ាស៊ីន និងកម្មវិធីកំព្យូទ័រ-Piori and Sabel 1984) ។ នៅក្នុងសេដ្ឋកិច្ចទើបផុសខ្ពស់ឡើង តួនាទីវិស័យឯកជនមានសារៈសំខាន់បំផុត។ ឧស្សាហកម្មវិស្វកម្មធុនស្រាល ផលិតផលល្បែងក្មេងលេង និងគ្រឿងបន្ទាប់បន្សំផ្សេងទៀត នៅក្នុងបណ្តាប្រទេសនៅអាស៊ីខាងកើត គឺជាឧទាហរណ៍បញ្ជាក់យ៉ាងល្អ ។

ក្នុងប្រទេសមានចំណូលទាបដូចជាកម្ពុជា ឧស្សាហកម្មវិស័យឯកជនធុនតូច និងធុនតូចបំផុត អាចបំពេញតួនាទីដ៏មានប្រយោជន៍ នៅក្នុងផលិតកម្មវិមជ្ឈការនូវទំនិញប្រើប្រាស់មួយចំនួន (ការរៀបចំនិងកែច្នៃម្ហូបអាហារ និងការកែច្នៃស្បែក គឺជាឧទាហរណ៍យ៉ាងល្អ) ។ ជាទូទៅ ឧស្សាហកម្មទាំងនេះពីដំបូងប្រើប្រាស់បច្ចេកវិទ្យា

[៣៣] សូមអាន Horton (1995) ចំពោះតួលេខស្តីពីប្រទេសអាស៊ីជ្រើសរើសមួយចំនួន ។ ប៉ុន្តែមតិនេះមានករណីលើកលែងមួយ គឺឧស្សាហកម្មកាត់ដេរនៅកម្ពុជា ដែលមានទ្រង់ទ្រាយធំ ប៉ុន្តែប្រើប្រាស់កំលាំងពលកម្មស្ត្រីច្រើនណាស់ ។

ធុនមធ្យម មុននឹងឈានទៅដល់ដំណើរការផលិតបែបស្មុគស្មាញ នៅពេលសមត្ថភាពកើនឡើង[៣៤] ។ កម្ពុជាមានប្រពៃណីយូរមកហើយ ក្នុងការផលិតវត្ថុសិប្បកម្ម ហើយជាមួយគ្នានឹងការកែលំអគុណភាពផលិតផល នឹងមានឱកាសល្អទ្វេឡើង (syner-gistic opportunity) សំរាប់ឧស្សាហកម្មសិប្បកម្ម និងទេសចរណ៍ ។ វិស័យផ្សេងទៀតដែលសហគ្រាសធុនតូច ឬសកម្មភាពវិមជ្ឈការ អាចឈានមុខ គឺវិស័យសំណង់ ជួសជុល និងការផ្លាស់គ្រឿងបំលាស់ ។ ដោយហេតុថា កម្ពុជាមានជំនាញស្ទួលខ្លះៗក្នុងវិស័យកម្មន្តសាល ដូច្នេះគេអាចសិក្សាស្រាវជ្រាវពីលទ្ធភាពនៃការពង្រីកសកម្មភាព និងការបង្កើតតំលៃថែមទៀតក្នុងមួយឯកតាទិន្នផល (product deepening) ។

សេចក្តីអះអាងផ្សេងៗទាំងនេះផ្តល់គំនិតថា សហគ្រាសវិស័យឯកជនធុនតូច និងមធ្យម មានសក្តានុពលយ៉ាងធំក្នុងការដើរតួជាមធ្យោបាយជួយបែងចែកចំណូល ព្រមទាំងជួយដោះស្រាយនូវបញ្ហាប្រឈមនៃការបង្កើតការងារ និងបែងចែក ឧស្សាហកម្មនៅក្នុងតំបន់ទៀតផង ។ ការសិក្សាពីជោគជ័យ យុទ្ធសាស្ត្រ បញ្ហាប្រឈម និងជំរើសរបស់សហគ្រាសឯកជនធុនតូច និងមធ្យមសំរាប់ដោះស្រាយបញ្ហាទាំងនេះ អាចផ្តល់នូវពត៌មានជាមូលដ្ឋានសំរាប់ការវិភាគពីបរិយាកាសគោលនយោបាយ ដែលជួយឱ្យឧស្សាហូបនីយកម្មរីកលូតលាស់នៅក្នុងសេដ្ឋកិច្ចអន្តរកាល ។ ការសិក្សាបែបនេះអាចនឹងមានប្រយោជន៍នៅក្នុងការសំគាល់អនុវិស័យនីមួយៗ ដែលមានសន្ទុះល្អជាង ហើយមានសក្តានុពលផ្តល់កំនើនលឿន នៅក្នុងបរិស្ថានមួយដែលអំណោយផលជាងនេះបន្តិច ។

[៣៤] វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងតំរូវការខាងសមត្ថភាពស្ថាប័នដើម្បីបង្កើតឧស្សាហកម្មធុនតូចនៅក្នុងបរិបទអាស៊ី មានដាក់បញ្ចូលយ៉ាងសង្ខេបក្នុង ESCAP (1998) ។

## ៤.៣ ការពិនិត្យគ្រួសៗខាងម៉ាក្រូសេដ្ឋកិច្ចនៃការអភិវឌ្ឍន៍ឧស្សាហកម្ម នៅក្នុងប្រទេសកម្ពុជា

តាំងពីដើមទសវត្សរ៍១៩៩០ ប្រតិបត្តិការសេដ្ឋកិច្ចនៅកម្ពុជាបង្ហាញលទ្ធផល ជាការលូតលាស់យ៉ាងលឿននូវឧស្សាហកម្មថ្មីៗមួយចំនួន ជាពិសេស ឧស្សាហកម្ម កាត់ដេរ និងទេសចរណ៍ ។ ប៉ុន្តែ សកម្មភាពសេដ្ឋកិច្ចកើតឡើងក្នុងវិស័យតែមួយចំនួន តូច និងប្រមូលផ្តុំភាគច្រើននៅតាមទីក្រុង ។ សេចក្តីសង្ខេបពីការរីកចំរើនដែលទទួល បាន មានចុះនៅក្នុងតារាង៤.១ ។

**តារាង៤.១ កំណើនសេដ្ឋកិច្ច និងផលិតភាពពីឆ្នាំ១៩៩៣-២០០០ (កំណើនមធ្យម ប្រចាំឆ្នាំជាភាគរយ)**

| | ផលិតកម្ម | ផលិតភាព/ពលករម្នាក់ | សមាមាត្រមូលធន-ទិន្នផល [១] |
|---|---|---|---|
| កសិកម្ម | 2.6 | 0.4 | 14 |
| ឧស្សាហកម្ម | 10.4 | 1.9 | 48 |
| សេវាកម្ម | 4.2 | 3.2 | 76 |
| **សរុប** | **4.6** | **2.1** | **50** |

*ប្រភព: មូលដ្ឋានទិន្នន័យរបស់ វិបសអ ចងក្រងចេញពីប្រភពរដ្ឋាភិបាល និងអង្កេតរបស់ វិបសអ ។ តួលេខនៅក្នុង តារាងនេះគណនាចេញពីទិន្នន័យដើមបានពីរដ្ឋាភិបាល និងអាចមិនដូចគ្នានឹងតួលេខផ្សព្វផ្សាយនៅក្នុងឯកសារផ្សេង ទេ ។ [១] ស្តុកនៃមូលធនគិតជាភាគរយនៃតំលៃបន្ថែម ។*

### *៤.៣.១ កំណើនសេដ្ឋកិច្ច*

នៅឆ្នាំ១៩៩៥-៩៦ សេដ្ឋកិច្ចកម្ពុជាមានកំនើនខ្ពស់ដល់ ៧-៨% ក្នុងមួយឆ្នាំ ។ ការវាយប្រយុទ្ធគ្នានៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ រួមទាំងវិបត្តិហិរញ្ញវត្ថុអាស៊ីក្នុង ពេលជាមួយគ្នា នាំឱ្យសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង រួមទាំងសេដ្ឋកិច្ចកម្ពុជាផងដែរ គឺ មានកំណើនប្រចាំឆ្នាំតែ ១% ប៉ុណ្ណោះ ។ មកដល់ឆ្នាំ១៩៩៩-២០០០ សកម្មភាព សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមមានកំណើនវិជ្ជមានឡើងវិញ ហើយទោះបីមានផលប៉ះ ពាល់អាក្រក់ពីទឹកជំនន់ ព្រមទាំងការបន្តមានវិបត្តិហិរញ្ញវត្ថុនៅក្នុងតំបន់ក៏ដោយ ក៏

កម្ពុជា មានកំណើន ផសស ពិត ក្នុងឆ្នាំ១៩៩៩ និង ២០០០ ប្រហែល ៥% និង ៦% ក្នុងមួយឆ្នាំៗ ។ សរុបមក កំណើនសេដ្ឋកិច្ចពីឆ្នាំ១៩៩៣-២០០០ មានប្រហែល ៤,៦% គិតជាមធ្យមប្រចាំឆ្នាំ ហើយបានពីវិស័យមួយចំនួនដូចជា ឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ ។ កសិកម្មមានកំណើនយឺតជាងវិស័យផ្សេងទៀត ហើយចំណែករបស់វាក្នុង ផសស ធ្លាក់ចុះយ៉ាងខ្លាំង ។

វិស័យកសិកម្មដែលរួមចំណែកប្រហែល ៣០% ក្នុង ផសស កម្ពុជា និងប្រើប្រហែល ៧៧% នៃកំលាំងពលកម្មសរុបនៅឆ្នាំ២០០០, មានកំនើនប្រចាំឆ្នាំពិតតែ ២,៦% ពីឆ្នាំ១៩៩៣-២០០០ ។ កសិកម្មកម្ពុជារងឥទ្ធិពលគួរឱ្យកត់សំគាល់ពីកត្តាធាតុអាកាស ដោយសារវិនិយោគក្នុងប្រព័ន្ធស្រោចស្រព និងប្រព័ន្ធគ្រប់គ្រងទឹកជំនន់មានកំរិតទាបណាស់ ។ ទោះជាយ៉ាងនេះក្តី ផលិតកម្មស្រូវឡើងដល់កំរិតផ្គត់ផ្គង់ក្នុងប្រទេសបាននៅឆ្នាំ១៩៩៥ គឺប្រហែល ៣,៥លានតោន ធៀបនឹងកំរិត ២លានតោននៅពាក់កណ្តាលទសវត្សរ៍១៩៨០ ។ កំណើននេះសំរេចបានតាមការពង្រីកផ្ទៃដីដាំដុះ និងកំណើនទិន្នផលពី ១,២តោន/ហិកតា នៅដើមទសវត្សរ៍១៩៩០ ដល់ ២តោន/ហិកតានៅឆ្នាំ២០០០ ។ ដំណាំផ្សេងទៀត និងសត្វចិញ្ចឹម មានកំណើនយឺត (តិចជាង ២%/ឆ្នាំ) ។ ម្យ៉ាងវិញទៀត ដំណាំមួយចំនួន ជាពិសេស ស្រូវ សណ្តែកសៀង និងថ្នាំជក់ ជួបការលំបាកយ៉ាងធ្ងន់ធ្ងរ ដោយសារការធ្លាក់ថ្លៃ ក្នុងរយៈបីឆ្នាំចុងក្រោយ ។ ផលិតកម្មនេសាទ និងព្រៃឈើ ធ្លាក់ចុះយ៉ាងខ្លាំងដែរតាំងពីឆ្នាំ១៩៩៩ ដោយសារការធ្វើអាជីវកម្មហួសហេតុលើធនធានធម្មជាតិក្នុងទសវត្សរ៍១៩៩០ ។

ឧស្សាហកម្មដែលរួមចំណែក ២៥% នៃ ផសស នៅឆ្នាំ ២០០១ និងប្រើប្រាស់ប្រហែល ៨%នៃកំលាំងពលកម្មសរុប បានកើនយ៉ាងលឿនពីឆ្នាំ១៩៩៣-២០០០ ដល់ ១០,៤%/ឆ្នាំ (កំណើនពិត) ទោះបីជាមានការវាយប្រយុទ្ធនៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុអាស៊ីក៏ដោយ ។ ឧស្សាហកម្មកាត់ដេរ អគ្គិសនី និងទឹកស្អាត គឺជាអនុវិស័យមានទិចលភាពខ្ពស់ជាងគេ ឯផ្នែកសំណង់ និងទូរគមនាគមន៍

ក៏មានកំណើនគួរឱ្យពេញចិត្តខ្លះដែរ ។ ចំពោះឧស្សាហកម្មផ្សេងទៀតជាទូទៅមិនមែនជាកំលាំងជំរុញទេ ។ ឧស្សាហកម្មកាត់ដេរនៅកម្ពុជា ចាប់ផ្តើមកសាងក្នុងឆ្នាំ១៩៩៣ ក្នុងគោលដៅបំរើការនាំចេញ ដែលត្រូវបានជួយសំរួលដោយការចូលរួមក្នុងកិច្ចព្រមព្រៀងពហុវាយនភ័ណ្ឌ (Multi-Fibre Agreement) ។ តាំងពីឆ្នាំ១៩៩៧ ការនាំចេញភាគច្រើនតំរង់ទៅទីផ្សារអាមេរិក និងមាន ១/៤ ត្រូវនាំចេញទៅអឺរ៉ុប ។ ទោះបីជាមានការដាក់កូតាលើសំលៀកបំពាក់នាំចេញទៅអាមេរិកក្នុងឆ្នាំ១៩៩៩ក្តី ក៏ការនាំចេញសំលៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌផ្សេងទៀត ឡើងដល់ ១.០០០លានដុល្លារនៅឆ្នាំ២០០០ ដោយកើនពី ៤លានដុល្លារនៅឆ្នាំ១៩៩៣ ។ ក្នុងទសវត្សរ៍ចុងក្រោយ មានរោងចក្រកាត់ដេរ២០០ ត្រូវបានបង្កើតឡើង ។ ដើមឡើយសំណង់សណ្ឋាគារបានលូតលាស់យ៉ាងលឿននៅភ្នំពេញ សៀមរាប និងទីរួមខេត្តមួយចំនួនទៀត ។ វិបត្តិទ្វេនៅឆ្នាំ១៩៩៧ និងកំណើនយ៉ាងលឿននៃថ្លៃឈើ បានធ្វើឱ្យវិស័យសំណង់ធ្លាក់ចុះក្នុងប៉ុន្មានឆ្នាំថ្មីៗ ។

វិស័យសេវាកម្មដែលតំណាងឱ្យប្រហែល ៤៥% នៃ ផសស និងប្រើប្រហែល ១៥% នៃកំលាំងពលកម្មសរុប បានលូតលាស់យ៉ាងលឿនពីឆ្នាំ១៩៩២-១៩៩៦ (ប្រហែល ១០% ក្នុងមួយឆ្នាំ) ដោយសារការរីកចំរើននៃការដឹកជញ្ជូន, ទូរគមនាគមន៍ និងទេសចរណ៍ ។ ប៉ុន្តែ សកម្មភាពទាំងនេះត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការវាយប្រយុទ្ធនៅថ្ងៃ៥-៦ កក្កដា ១៩៩៧ ។ ដោយមានស្ថិរភាពនយោបាយឡើងវិញ វិស័យនេះក៏មានសន្ទុះជាថ្មី ដោយមានកំនើនប្រហែល ៩% ក្នុងមួយឆ្នាំនៅឆ្នាំ១៩៩៩ និង ២០០០ ។ សរុបមក វិស័យសេវាកម្មកើន ៤,២%/ឆ្នាំ ពីឆ្នាំ១៩៩៣ ដល់ ២០០០ ដែលមានកំរិតទាបជាងអត្រាកំណើនសរុបនៃចំណូលជាតិ ។

រចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជាបង្ហាញថា មានអតុល្យភាពយ៉ាងធំធេងរវាងវិស័យនានានៅក្នុងផលិតកម្ម, ផលិតភាព និងការបែងចែកកំលាំងពលកម្ម ។ មានហេតុផលជាច្រើនចំពោះអតុល្យភាពនេះគឺ *ទី១* សេដ្ឋកិច្ចផ្សំឡើងជាសំខាន់ដោយ

កសិកម្មជីវព្រឹត្ត *ទី២* មូលធនបរទេសមានផលប៉ះពាល់យ៉ាងខ្លាំងលើសេដ្ឋកិច្ចនេះ និង *ទី៣* មានសល់កើ្តរដីណែលពីវិស័យដែលក្តោបក្តាប់ដោយរដ្ឋកន្លងមក ។ លើសពីនេះទៀត គេឃើញមានតិចតួចទេនូវគំនិតផ្តួចផ្តើមផ្សេងៗដើម្បីធ្វើការប្រកួតប្រជែងតាមកំលាំងទីផ្សារដើម្បីធានានូវការបែងចែកធនធានបានប្រសើរបំផុត ។

### *៤.៣.២ ផលិតភាព និងផលចំណេញ*

គិតតាមក៏រិតថ្លៃឆ្នាំ១៩៩៣ ផលិតភាពក្នុងកម្មករម្នាក់ៗ កើនយ៉ាងលឿនពីឆ្នាំ ១៩៩៣-១៩៩៦ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៤%, សំរាប់សេដ្ឋកិច្ចទាំងមូល ។ ប៉ុន្តែកំណើនផលិតភាពធ្លាក់ចុះនៅឆ្នាំ១៩៩៧ និង ១៩៩៨ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចជាទូទៅ ប៉ុន្តែវាកើនឡើងវិញនៅឆ្នាំ១៩៩៩ និង ២០០០ នៅក្នុងវិស័យមួយចំនួន ។ គិតជាសរុប ផលិតភាពក្នុងកម្មករម្នាក់កើនប្រហែល ២,១% ក្នុងមួយឆ្នាំចាប់តាំងពីឆ្នាំ១៩៩៣-២០០០ ។ ផលិតភាពក្នុងវិស័យកសិកម្ម មានកំណើនទាបក្នុងក៏រិតប្រហែល ០,៤% ក្នុងមួយឆ្នាំ ប៉ុន្តែផលិតភាពក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មកើនយ៉ាងលឿនក្នុងក៏រិត ១,៩% ក្នុងមួយឆ្នាំ និង ៣,២% ក្នុងមួយឆ្នាំរៀងៗគ្នា ។ អត្រាកំណើនខ្ពស់នៃផលិតភាពក្នុងកម្មករម្នាក់នៃវិស័យសេវាកម្ម អាចផុសចេញពីសមាភាគមូលធន-ធាតុចេញ (capital-output ratio) ដែលកាន់តែកើនខ្ពស់ឡើងក្នុងវិស័យទាំងនេះ ។ ក្នុងវិស័យកសិកម្មផលិតភាពក្នុងពលករម្នាក់ បន្តធ្លាក់ចុះតាំងពីឆ្នាំ១៩៩៧ ដោយសារចំនួនយ៉ាងច្រើននៃប្រជាជននៅជនបទដែលគ្មានការងារធ្វើពេញលេញ (underemployed) និងការស្ងៀមស្ងំក់នៃផលិតកម្មកសិកម្ម ។ ក្នុងវិស័យឧស្សាហកម្ម ផលិតភាពក្នុងពលករម្នាក់រើបបានបន្តិចបន្តួចនៅឆ្នាំ១៩៩៩ និង ២០០០ ដោយសារលទ្ធផលល្អក្នុង ប្រតិបត្តិការនៃវិស័យកាត់ដេរ ។ ជាទូទៅ វិស័យសេវាកម្មមានលទ្ធផលប្រតិបត្តិការល្អចាប់តាំងពីឆ្នាំ១៩៩៥[៣៥] ប៉ុន្តែ ក្នុងវិស័យឧស្សាហកម្មផ្សេងទៀត ស្ថានការណ៍បន្តធ្លាក់យ៉ាប់យ៉ឺន ។

[៣៥] កំណើនផលិតភាពខ្ពស់នៅប្រទេសជិតខាង ជាពិសេស ក្នុងវិស័យកសិកម្ម ។

ថ្លៃដើមកំលាំងពលកម្មមានកំរិតទាបនៅក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម (១៣% នៃចំណូលនៅឆ្នាំ២០០០) ប៉ុន្តែបើគិតតាម សមាភាគផលិតភាព-ប្រាក់កំរៃ គេពិបាកនិយាយថា កម្ពុជាជាសេដ្ឋកិច្ចមានកំរិតប្រាក់កំរៃទាប ពីព្រោះផលិតភាពនៅកម្ពុជា មានកំរិតទាបជាង ដូចជានៅវៀតណាមជាដើម ។ កសិកម្មគឺជាករណីដោយឡែកមួយ ពីព្រោះប្រើពលករច្រើន, ប្រើមូលធន និងធាតុចូល (input) តិចតួច, និងបង្កើតបានតំលៃបន្ថែមតិច ។ វិស័យឧស្សាហកម្មប្រើប្រាស់ធាតុចូលច្រើនជាអតិបរមា (៦៦% នៃចំណូលលក់) ប៉ុន្តែវាបង់ពន្ធតិចតួច ដូច្នេះហើយចំណេញដុលនៅមានកំរិតខ្ពស់ (២០% នៃចំណូលលក់) ។ វិស័យសេវាកម្មហាក់ដូចជាមានចំណេញច្រើនជាងគេនៅកម្ពុជា ទោះបីវារួមចំណែកបានតិចនៅក្នុងចំណូលជាតិក៏ដោយ (៨% នៃចំនូលលក់ក្នុងឆ្នាំ២០០០) ។ ចំណេញលដុលក្នុងវិស័យនេះបានប្រហែល ៣២% នៃចំណូលលក់ (Hach *et al.* 2001) ។

### *៤.៣.៣ វិស័យឯកជននៅក្នុងអន្តរកាល*

ប្រទេសកម្ពុជាមានបទពិសោធន៍យ៉ាងយូរនៅក្នុងការប្រែប្រួល តាំងពីពេលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ។ នៅទសវត្សរ៍១៩៥០ ការសម្លឹងមើលពីការអភិវឌ្ឍន៍សេដ្ឋកិច្ច ហាក់ដូចជាផ្តល់សេចក្តីសង្ឃឹមច្រើន ។ អាំងឌីកាទ័រម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗមានលក្ខណៈល្អ សេដ្ឋកិច្ចមានកំណើនខ្លាំងប្រហែល ៧% ជាមធ្យមពីឆ្នាំ១៩៥៤-១៩៦៣ ហើយនៅពេលនោះកម្ពុជាជាប្រទេសដ៏រុងរឿងមួយនៅក្នុងតំបន់ ។ ប៉ុន្តែកំណែទំរង់បែបរដ្ឋនិយមដែលចាប់ផ្តើមនៅឆ្នាំ១៩៦៤ តាមការធ្វើជាតូបនីយកម្មវិស័យសេដ្ឋកិច្ចសំខាន់ៗ ដូចជា ធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស បានរុញច្រានប្រទេសចូលទៅក្នុងការធ្លាក់ចុះសេដ្ឋកិច្ច និងវិបត្តិសង្គម ។ បន្ទាប់មក ក៏មានកើតពាណិជ្ជកម្មផ្សារងងឹតក្រៅផ្លូវការជាមួយប្រទេសជិតខាង ។ នៅឆ្នាំ១៩៧០ ទីផ្សារសេរី ត្រូវបានបង្កើតឡើងវិញនៅក្រោយព្រឹត្តិការណ៍រដ្ឋប្រហារយោធា ។ ប៉ុន្តែសេដ្ឋកិច្ចមិនបានរើបឡើងវិញលឿនទេ ពីព្រោះមានភាពរីករវខ្លាំងខាងនយោបាយ ។

ខ្មែរក្រហមដណ្តើមអំណាចបាននៅខែមេសា ឆ្នាំ១៩៧៥ ហើយរំលាយចោលកម្មសិទ្ធិឯកជនទាំងអស់ ។ ក្រោយខ្មែរក្រហមទទួលបរាជ័យនៅឆ្នាំ១៩៧៩ កសិករត្រូវបានលើកទឹកចិត្តឱ្យផ្តុំគ្នាជាក្រុមផលិតកម្មតូចៗ ហៅថា ក្រុមសាមគ្គី ដោយក្រុមនីមួយៗមានពី ១០-១៥គ្រួសារ ។ ដីធ្លីស្ថិតនៅជាសម្បត្តិរដ្ឋ ហើយការដាំដុះធ្វើជាសមូហភាព ប៉ុន្តែគ្រួសារនីមួយៗទទួលចំនែកជាដីឡូតិ៍តូចសំរាប់កាន់កាប់ជាឯកជន ។

មកដល់ឆ្នាំ១៩៨៥ នៅក្នុងរលកនៃសេរីភាវូបនីយកម្មនយោបាយគណបក្សកាន់អំណាចនៅកម្ពុជា បានទទួលស្គាល់ការលក់ដូរតូចតាច និងបានចេញច្បាប់ទទួលស្គាល់វិស័យឯកជន ដើម្បីបើកលទ្ធភាពដល់ផលិតកម្មទំនិញប្រើប្រាស់ធុនស្រាល ។ កំណែទំរង់សេដ្ឋកិច្ចបានបង្កើនល្បឿនតាំងពីឆ្នាំ១៩៨៩ ។ ក្រុមសាមគ្គីប្រហែល ៩០% ត្រូវបានរំលាយ ។ ការដឹកជញ្ជូន, ការថែទាំសុខភាព និងការអប់រំ ក៏បានធ្វើឯកជននីយកម្មមួយកំរិត ហើយភាគច្រើននៃទីផ្សាររបស់រដ្ឋក៏ដូចគ្នាដែរ ។ ការបន្ធូរបន្ថយការត្រួតត្រាលើសេដ្ឋកិច្ច បានផ្តល់សន្ទុះយ៉ាងខ្លាំង ដល់ការលូតលាស់វិស័យឯកជនតូចតាច ជាពិសេសនៅភ្នំពេញ ។ តំលៃបន្ថែមបង្កើតឡើងដោយវិស័យឯកជន បានកើនយ៉ាងលឿនលើសតំលៃបន្ថែមរបស់រដ្ឋ ប៉ុន្តែភាគច្រើននៃវិនិយោគឯកជនប្រមូលផ្តុំលើផ្នែកពាណិជ្ជកម្ម ។

ពីឆ្នាំ១៩៩១-៩៣ សេដ្ឋកិច្ចឯកជននៅទីក្រុងបន្តកើនឡើង ហើយសកម្មភាពសាងសង់ និងជួសជុលលំនៅដ្ឋាន សឹងតែរត់មិនទាន់កំណើនតំរូវការរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) ផង ។ ស្ថិរភាព និងទំនុកចិត្តលើសេដ្ឋកិច្ច បានកើតមានមួយកំរិតឡើងវិញ នៅក្រោយការបោះឆ្នោត និងការបង្កើតរដ្ឋាភិបាលចំរុះនៅឆ្នាំ១៩៩៣ ។ បន្ទាប់ពី UNTAC ដកចេញពីកម្ពុជានៅចុងឆ្នាំ១៩៩៣ វិនិយោគបរទេសខាងផ្នែកសណ្ឋាគារ (ដែលជាវិនិយោគឯកជនតែមួយនៅពេលនោះ) បានធ្លាក់ចុះយ៉ាងខ្លាំង ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៩៥ មក កម្ពុជាទាក់ទាញវិនិយោគផ្ទាល់ពីបរទេស (FDI) បានច្រើនគួរឱ្យកត់សំគាល់ ជាចំបងមកពីប្រទេស

អាស៊ី ។ ក្នុងឆ្នាំ១៩៩៦ FDI មានជិតដល់ ៣០០លានដុល្លារ (ប្រហែល ១០% នៃ ផសស) ។ ប៉ុន្តែការប្រយុទ្ធនៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុអាស៊ី បានប៉ះពាល់ខ្លាំងដល់វិនិយោគនេះ[៣៦] ។ ប៉ុន្តែការកាត់ដេរនៅតែមាននិចលភាព ហើយកំណើនរោងចក្រសាងសង់ថ្មីបានធ្វើឱ្យ FDI កើនយ៉ាងខ្លាំងនៅឆ្នាំ១៩៩៨ ។ ប៉ុន្តែ តួលេខជញ្ជីញទូទាត់ដែលឆ្លុះបញ្ចាំងពីការអនុវត្តន៍ពិតនូវវិនិយោគ បង្ហាញថា FDI បានធ្លាក់ចុះពី ២៥០លានដុល្លារនៅឆ្នាំ១៩៩៨ មកតិចជាង ១០០លានដុល្លារនៅឆ្នាំ២០០១ ។ តួលេខនេះ ទាបជាងក៏វិត ៥០០លានដុល្លារក្នុងមួយឆ្នាំខ្លាំងណាស់ ដែល

**ក្រាហ្វិក៤.១ ការចុះបញ្ជីក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា**




*ប្រភព: ក្រសួងពាណិជ្ជកម្ម*

កម្ពុជាត្រូវការ ដើម្បីផ្តល់ការងារដល់អ្នកចំនូលថ្មីក្នុងកំលាំងពលកម្ម (RGC 1996) ។ យោងតាមសមាគមផលិតករកាត់ដេរកម្ពុជា (GMAC) ចំនួនរោងចក្រកាត់ដេរកំពុង

[៣៦] សេចក្តីលំអិតរបៀបដែលសេដ្ឋកិច្ចក្នុងប្រទេស រួមទាំងវិស័យឯកជនដែលរងឥទ្ធិពលដោយការវាយប្រហាគ្នានៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ មានចែងក្នុងរបាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំ២០០១ របស់ វិបសអ (Sok, Sik និង Chea 2001) ។

ដំណើរការនៅកម្ពុជាធ្លាក់ពី ២២០ នៅឆ្នាំ២០០០ ដល់ ១៨០ នៅឆ្នាំ២០០១ ។ ទោះបីធ្លាក់ចុះបែបនេះក្តី FDI នៅតែមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដោយវាតំណាងឱ្យ ៦៧% នៃស្តុកមូលធនសរុបនៅក្នុងប្រទេសក្នុងវិស័យទំនើប ។

វិស័យឯកជនកម្ពុជានៅក្មេងខ្ចីនៅឡើយ ។ វិនិយោគក្នុងស្រុកទើបចាប់ផ្តើមនៅក្រោយឆ្នាំ១៩៩៣ ជាពិសេសលើវិស័យសំណង់ និងពាណិជ្ជកម្ម ។ ដូចបង្ហាញក្នុងក្រាហ្វិក៤.១ ចំនួនក្រុមហ៊ុនចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម កើនយ៉ាងខ្លាំងពីឆ្នាំ ១៩៩៤-៩៦ ប៉ុន្តែចុះវិញក្នុងឆ្នាំ១៩៩៧ ហើយបន្តធ្លាក់ចុះចាប់តាំងពីពេលនោះមក ។ ជាងពាក់កណ្តាលនៃក្រុមហ៊ុនដែលមានស្រាប់បានចុះបញ្ជីក្នុង ៥ឆ្នាំចុងក្រោយ ។ម្យ៉ាងវិញទៀត ក្រុមហ៊ុនភាគច្រើនដែលចុះបញ្ជីពីឆ្នាំ១៩៩៨-២០០១ គឺជាក្រុមហ៊ុនមានម្ចាស់ច្រើន (multi-proprietor) គឺក្នុងចំណោម ៧.៨០០ក្រុមហ៊ុនចុះបញ្ជី មានតែ ១៦% ប៉ុណ្ណោះជាក្រុមហ៊ុនមានម្ចាស់តែមួយ ។ ក្រុមហ៊ុនទាំងនេះភាគច្រើន (ប្រហែល ៩០%) ជាក្រុមហ៊ុនតូចៗ ។ ក្រុមហ៊ុនប្រហែល ១.០០០ មានប្រព័ន្ធគណនេយ្យ និងការគ្រប់គ្រងទំនើប ។ គួរបញ្ជាក់ថា រដ្ឋាភិបាលឱ្យនិយមន័យក្រុមហ៊ុនទំនើបជាក្រុមហ៊ុនមានបង់ពន្ធ, ធ្វើសវនកម្មគណនេយ្យ, ផ្សព្វផ្សាយតារាងតុល្យការ, និងចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ។

## ៤.៤ លទ្ធផលរកឃើញក្នុងករណីសិក្សា

### *៤.៤.១ គំរូតាង*

វិបសអ បានជ្រើសរើសនិងអនុវត្តករណីសិក្សាមួយចំនួន លើសហគ្រិនមានជោគជ័យ ដើម្បីស្រាវជ្រាវពីហេតុផលនៃជោគជ័យ ក្នុងការបង្កើតនិងដំណើរការពាណិជ្ជកម្មនៅកម្ពុជា[៣៧] ។ ទោះបីការស្រាវជ្រាវ គឺជាការសិក្សាលើគំរូតាងតូចមួយ

[៣៧] អាជីវករទាំងអស់មិនមែនសុទ្ធតែបានជោគជ័យដូចៗគ្នាទេ ។ ប៉ុន្តែ ភាគច្រើនបានរីកចំរើនក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយ ។ មានអ្នកខ្លះអះអាងថា អ្នកមានលទ្ធភាពដំណើរការរហូតដល់សព្វថ្ងៃ អាចចាត់ទុកជាអ្នកមានជោគជ័យហើយ ។

លើពាណិជ្ជករតែ ១០នាក់ក្តី ក៏បទសម្ភាន៍មានលក្ខណៈស៊ីជំរៅ និងបានផ្តល់ពតិមាន ពីប្រវត្តិនៃការលូតលាស់អាជីវកម្មក្នុងទសវត្សរ៍១៩៩០ និងក្នុងឆ្នាំជាបន្តមកទៀត ។ ប្រវត្តិដើមអាជីវកម្មមិនដូចគ្នាទាំងអស់ទេ ។ អាជីវកម្មខ្លះ ចាប់ផ្តើមនៅទសវត្សរ៍ ១៩៨០ គឺភ្លាមៗបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ខ្លះទៀតបានចាប់ផ្តើមនៅឆ្នាំ ១៩៩៣-៩៤ និងខ្លះទៀតចាប់ផ្តើមថ្មីៗនៅចុងទសវត្សរ៍១៩៩០ ។

ការសិក្សានេះជាជំហានដំបូង ហើយវាជួយកំណត់ក្របខ័ណ្ឌសំរាប់ការសិក្សាលើកក្រោយៗទៀត ។ ការសិក្សាបានធ្វើឡើងដោយគ្មានបញ្ជីសហគ្រាសទេ[៣៨] ។ លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសសហគ្រាសអាជីវកម្មគឺ ១. សហគ្រាសអាជីវកម្មនៅក្នុងវិស័យបឋម, វិស័យទីពីរ និងវិស័យទីបី, ដែលត្រូវមានតំណាងនៅក្នុងគំរូតាង ។ ២. តំណាងសហគ្រាសទាំងតូច ទាំងធំ ត្រូវបានសម្ភាស ។ ៣. អង្គភាពអាជីវកម្មទាំងទំនើប និងបុរាណ ដែលបញ្ចូលក្នុងករណីសិក្សា ។ បានប្រឹងប្រែងជ្រើសយកអង្គភាពអាជីវកម្មទាំងនៅក្រៅ និងក្នុងក្រុងភ្នំពេញ ។ គួរបញ្ជាក់បន្ថែមថា នៅកម្ពុជាពុំមាននិយមន័យនៃអាជីវកម្មតូច និងអាជីវកម្មធំទេ ។ មួយចំណែកទៀត វាអាចមានន័យគ្រប់គ្រាន់ជាង បើមានកំណត់ពីប្រភេទសហគ្រាសធុនមធ្យមផង ។ ប៉ុន្តែ គំរូតាងមានទំហំតូច ដូច្នេះគេមិនអាចបែងចែកប្រភេទមធ្យមមួយទៀតបានទេ ។ សហគ្រាសមានចំណូលចាប់ពី ៥០០.០០០ដុល្លារឡើងទៅ អាចចាត់ជាសហគ្រាសធុនធំ ហើយក្រៅពីនេះគឺជាសហគ្រាសធុនតូច ។ បន្ទាប់ពីការកាត់ចោលលើបញ្ជីវែង គំរូតាងសំរេចរួមមាន ធនាគារ សណ្ឋាគារ ក្រុមហ៊ុនសំនង់-ពាណិជ្ជកម្ម-ចំការដំណាំ (C-T-P) ផលិតកម្មឥដ្ឋ ផលិតកម្មទឹកត្រី ផលិតកម្មគ្រឿងប្លាស្ទិក ហាងទំនិញ សិប្បកម្មផលិតវត្ថុសិល្បៈ កសិដ្ឋានចិញ្ចឹមមាន់ និងកសិដ្ឋានដាំបន្លែពាណិជ្ជកម្ម ។ ចំណាត់ថ្នាក់នៃសហគ្រាសក្នុងគំរូតាងមានចុះក្នុងតារាង៤.២ ។ ថ្វីបើគេមិនអាចអះអាងថា គំរូតាងនេះតំណាងឱ្យគ្រប់វិស័យនៃពាណិជ្ជកម្ម និងកម្មន្តសាលនៅកម្ពុជាក្តី ក៏ផ្អែកលើទិន្នន័យ

[៣៨] ការសិក្សានេះប្រើប្រាស់បញ្ជីឈ្មោះសហគ្រិនផ្តល់ដោយ Webster និង Boring (2000) ។

បានពីករណីសិក្សាទាំងនេះ គេអាចមានគំនិតខ្លះ អំពីមូលហេតុដែលសហគ្រាសបានទទួលជោគជ័យ ឬបរាជ័យ ។

ដូចបានបញ្ជាក់រួចហើយ អង្គភាពអាជីវកម្មនៅក្នុងករណីសិក្សា ទោះបីមិនមែនជ្រើសឡើងដោយចុចឈ្មោះយកត្រង់ៗ (a priori handpicked) ក៏ដោយ (ពោលគឺមានលក្ខណៈចៃដន្យមួយក៏រិតដែរ) ប៉ុន្តែតាមពិតទៅ នៅកម្ពុជាគេមិនអាចមានជំរើសចៃដន្យពេញលេញលើសហគ្រាសអាជីវកម្មកម្មបានទេ ដោយសារភាពមិនសំបូរបែបនៃក្រុមសកម្មភាពពាណិជ្ជកម្ម និងឧស្សាហកម្មទាំងនោះ ។ ដោយហេតុនេះហើយ គំរូតាងដែលជ្រើសរើសឡើងដោយមានគោលដៅ វាមិនខុសគ្នាអ្វីច្រើនទេពីគំរូតាងដែលគេជ្រើសរើសបាន បើសិនប្រើបច្ចេកទេសចៃដន្យយ៉ាងតឹងរ៉ឹង[៣៩] ។

**តារាង៤.២ ការបែងចែកសហគ្រាសអាជីវកម្មនៅក្នុងគំរូតាង**

| ប្រភេទ | ទីតាំង | ទំហំធំ | ទំហំតូច |
|---|---|---|---|
| ទំនើប | ភ្នំពេញ | ធនាគារ, សណ្ឋាគារ | ប្លាស្ទិក ទឹកត្រី នំប៉័ង |
| | តាមខេត្ត | ធនាគារ | - |
| បុរាណ | ភ្នំពេញ | C-T-P | កសិដ្ឋានចិញ្ចឹមមាន់ |
| | តាមខេត្ត | C-T-P | ឥដ្ឋ, សិប្បកម្ម, កសិដ្ឋានពាណិជកម្ម |

*សំគាល់: ធនាគារ និងC-T-P មាននៅក្នុងទីតាំងទាំងពីរ ពីព្រោះធ្វើប្រតិបត្តិការនៅក្រៅ និងក្នុងក្រុងភ្នំពេញ ។*

### *៤.៤.២ ការពិពណ៌នាពីសហគ្រាសអាជីវកម្មក្នុងគំរូតាង*

ឧស្សាហកម្មនីមួយៗ មានលក្ខណៈពិសេសដោយឡែករបស់វា (industry-specificity) គឺមានន័យថាជំរើសរបស់យើងមានលំអៀងបង្កប់នៅខាងក្នុង ហើយរឿងនេះវាពិតសំរាប់ស្ទើរតែគ្រប់សកម្មភាពដែលកំពុងសិក្សា ។ អាជីវករជាច្រើនទាំងនៅក្នុង និងក្រៅគំរូតាងបានលើកថា វិនិយោគនានាពីដំបូងផ្តោតតែលើសកម្មភាពណា

[៣៩] ទាំងជំរឿនឆ្នាំ១៩៩៨ និងការសិក្សារបស់ MPDF អំពីសហគ្រិនភាព ជាភស្តុតាងបញ្ជាក់គាំទ្រក្នុងរឿងនេះ ។ សូមអាន RGC (1999) និង Webster and Boring (2000) ។

ដែលផ្តល់ចំណូលឆាប់ និងមិនបាច់ប្រើទុនច្រើន ។ ទោះជារឿងនេះមិនអាចត្រឹមត្រូវសំរាប់គ្រប់ឯកតានៅក្នុងគំរូតាងក៏ដោយ ក៏មានកក្តាបីដែលអាចបង្ហាញពីលក្ខណៈដោយឡែកនៃអាជីវកម្មនៅក្នុងបរិបទកម្ពុជា និងដែលមានដូចខាងក្រោម៖

១) ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងកត្តានានានៃការផ្គត់ផ្គង់នៅខ្វះខាត
២) គំរូវការតូច ទាំងកាលពីមុន និងក្នុងពេលសព្វថ្ងៃ
៣) អ្នកវិនិយោគជាច្រើន នៅស្ទាក់ស្ទើរក្នុងការបណ្តាក់ទុនពេញលេញ និងរយៈពេលវែងនៅកម្ពុជា ។

ការរៀបរាប់ត្រួសៗ អំពីលក្ខណៈដោយឡែកៗពីគ្នា នៃសហគ្រាសអាជីវកម្មទាំង១០ មានដូចតទៅ៖

ជាទូទៅ ធនាគារស្ថិតក្នុងចំណោមសហគ្រាសដែលបើកដំណើរការពីដំបូងៗ បន្ទាប់ពីមានការផ្សះផ្សារខាងនយោបាយ ។ សកម្មភាពនានាដូចជា ប្រតិបត្តិការនៃរតនាគារជាតិ ដែលជាអ្នកថែរក្សាប្រាក់សន្សំ និងទ្រព្យសម្បត្តិរបស់ប្រជាជន ព្រមទាំងទទួលបញ្ញើ និងបើកផ្តល់នូវប្រាក់កាសរបស់ភ្នាក់ងារជំនួយអន្តរជាតិ ត្រូវតែបង្កើតឡើង ។ នៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ ប្រជាជនកម្ពុជាជាច្រើនបានធ្វើអន្តោប្រវេសន៍ទៅប្រទេសបារាំង អាមេរិកខាងជើង និងអូស្ត្រាលី ដើម្បីគេចខ្លួនពីភាពវឹកវរខាងនយោបាយនៅក្នុងស្រុក ។ ដោយមានសន្តិភាពមួយកើតឡើងវិញនៅទសវត្សរ៍ ១៩៩០ ជនកម្ពុជាដែលត្រឡប់មកមាតុភូមិវិញបានជួយបង្កើតតំរូវការសេវាធនាគារ ហើយធនាគារយ៉ាងច្រើន ក៏រួសរាន់ចូលមកកម្ពុជាដើម្បីធ្វើអាជីវកម្ម ។ នៅក្នុងសេដ្ឋកិច្ចកម្ពុជាដ៏តូច ក្រីក្រ និងពឹងផ្អែកលើកសិកម្ម គេឃើញមានធនាគារ២៩ នៅ

ឆ្នាំ១៩៩៩ ហើយមកដល់សព្វថ្ងៃនេះនៅសល់តែ ២១ធនាគារទេ បន្ទាប់ពីការដាក់អនុវត្តន៍ច្បាប់ហិរញ្ញវត្ថុដ៏តឹងរ៉ឹងមក[៤០] ។

សណ្ឋាគារ ក៏បានទទួលអត្ថប្រយោជន៍ពីឱកាសល្អក្នុងទសវត្សរ៍ចុងក្រោយនេះដែរ ។ ក្រោយពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ មក កងកំលាំងរក្សាសន្តិភាព ក៏ដូចជាទីភ្នាក់ងារផ្តល់ជំនួយ និង NGOs បានចូលមកកម្ពុជា ដើម្បីផ្តល់ជំនួយអភិវឌ្ឍន៍ ហើយនៅចំពោះមុខលំហូរចូលមនុស្សយ៉ាងច្រើនបែបនេះ សណ្ឋាគារនានាក៏បានចាប់ផ្តើមផុសឡើង ។

ម្យ៉ាងទៀត ដោយសារកម្ពុជាមានធនធានព្រៃឈើយ៉ាងច្រើន ការអភិវឌ្ឍន៍ចំការដំណាំធំៗ និងពាណិជ្ជកម្មលើផលិតផលនៃចំការទាំងនេះ គឺជាជំរើសជាធម្មតាមួយសំរាប់ពួកសហគ្រិន ពីព្រោះវាជាប្រតិបត្តិការងាយស្រួល ចំណាយដើមទុនតិច និងមានហានិភ័យទាប ។ គួររំលឹកថា មុនពេលវិនិយោគបរទេសហូរចូលទៅក្នុងឧស្សាហកម្មកាត់ដេរ ការធ្វើចំការដំណាំធំៗគឺជាសកម្មភាពមួយទៀតដែលមានក្រៅពីកសិកម្មជីវព្រឹត្តិ ។ ឧស្សាហកម្មផលិតឥដ្ឋ អាចចាត់ទុកជាលទ្ធភាពវិនិយោគដំបូងគេមួយទៀត ពីព្រោះក្រោយពីមានសង្គ្រាមស៊ីវិលដ៏យូរអង្វែង ប្រជាជនតែងមានបំណងសាងសង់លំនៅដ្ឋានឡើងវិញជាអាទិភាព ។ ម្យ៉ាងទៀត ផលិតកម្មឥដ្ឋ គឺជាឧស្សាហកម្មជាប្រពៃណី ដែលមានឫសគល់កប់ក្នុងប្រវត្តិសាស្ត្រដ៏យូរលង់ ដូច្នេះ គេអាចចាត់ទុកជាការរស់ឡើងវិញ មិនមែនគំនិតផ្តួចផ្តើមថ្មីទេ ហើយចំពោះសិប្បកម្ម និងការកែច្នៃម្ហូបអាហារ (នំប៉ុង និងទឹកត្រី) ក៏ដូចគ្នាដែរ ។ កសិករដែលមានគំនិតច្នៃប្រឌិតចេះរកស៊ី បានមើលឃើញសក្តានុពលថ្មីក្នុងការដាំ និងអភិវឌ្ឍន៍បន្លែ/ស្បៀងក្រៅពីដំណាំស្រូវតាមប្រពៃណី (ដែលគ្របដណ្តប់លើ ៩០% នៃកសិដ្ឋានតូចៗ

[៤០] ក្នុងដំណាក់កាលដំបូងពីឆ្នាំ១៩៩២-៩៥ ធនាគារត្រូវធ្វើជាដៃគូជាមួយ NBC ដើម្បីធានាហានិភ័យ ។

ឬវិស័យជីវព្រឹត្តិផ្សេងទៀត) ហើយចំពោះកសិដ្ឋានចិញ្ចឹមមាន់ក៏ដូចគ្នាដែរ ។ ឯការផលិតគ្រឿងប្លាស្ទិកជាសកម្មភាពវិនិយោគមួយដែលអាចបញ្ចប់ក្នុងពេលយ៉ាងឆាប់ ។

ក្រៅពីធនាគារចេញ គ្មានឧស្សាហកម្មដូចខាងលើមួយណាដែលស្ថិតនៅក្នុងវិស័យបច្ចេកវិទ្យាខ្ពស់ស្មុគស្មាញ ឬក៏ទាមទារការវិនិយោគហិរញ្ញវត្ថុធំដុំនោះទេ ។ អាជីវកម្មប្រភេទនេះ មានដំនើរការដែរនៅក្នុងបរិស្ថានមួយដែលខ្វះខាតធនធាន ជាពិសេស ធនធានមនុស្ស ការជួយទ្រទ្រង់ខាងហេដ្ឋារចនាសម្ព័ន្ធ និងតំរូវការ ។

### *៤.៤.៣ ឫលគល់នៃសហគមន៍អាជីវករនៅកម្ពុជា*

ដូចប្រទេសផ្សេងទៀតនៅអាស៊ីអគ្នេយ៍ដែរ កម្ពុជាលេចចេញមកពីប្រភពកសិកម្ម ។ ក្រៅពីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួន កម្ពុជានៅតែជាប្រទេសធ្វើកសិកម្មជាសំខាន់ ។ តាំងពីដើមរៀងមក ជីធ្លីគឺជារបស់សហគមន៍ក្នុងស្រុក ចំណែកឯក្រុមជនភាគតិចដែលភាគច្រើនជាពាណិជ្ជករចំណាកស្រុកមកពីប្រទេសចិន បានត្រួតត្រាលើពាណិជ្ជកម្ម ។ ក្នុងរឿងនេះគេគួររំលឹកថា ប្រទេសចិនដែលមានអារ្យធម៌យូរអង្វែងណាស់មកហើយនៅក្នុងតំបន់ និងក្នុងពិភពលោក បានបង្កើតនូវបច្ចេកវិទ្យា និងមធ្យោបាយដឹកជញ្ជូនជាច្រើនប្រភេទ ហើយដោយប្រើលទ្ធភាពទាំងនេះ ចិនក៏មានវត្តមានលេចធ្លោនៅក្នុងពាណិជ្ជកម្មក្នុងតំបន់ តាំងពីសម័យដំបូងៗម្លេះ ។ ដើមឡើយពួកគេជាពាណិជ្ជករធ្វើដំនើរចុះឡើង ប៉ុន្តែដល់យូរៗទៅ ក៏បង្កើតបានជាសហគមន៍តូចមួយ ដែលតាំងលំនៅជាប់លាប់ និងមានចំណងអាពាហ៍ពិពាហ៍ជាមួយអ្នកនៅក្នុងស្រុក ។ ដូច្នេះហើយ ក៏មានសហគមន៍ថ្មីៗនៃខ្មែរកាត់ចិន ថៃកាត់ចិន ម៉ាឡេស៊ីកាត់ចិន នៅក្នុងតំបន់ជាច្រើននៅអាស៊ីអគ្នេយ៍ ។ រយៈពេលក្រោយមកពួកគេក៏ក្លាយជាតួអង្គមានឥទ្ធិពលខ្លាំងនៅក្នុងវិស័យមិនមែនកសិកម្ម ។

នៅកម្ពុជា ឯកសារនិពន្ធក្នុងសតវត្សរ៍ទី១៩ និង ២០ បង្ហាញថា តំបន់ទីក្រុងជាពិសេសភ្នំពេញ មានពាណិជ្ជករដើមកំណើតចិនរស់នៅ ហើយពួកគេមានកិរិត

ជីវភាពខ្ពស់ជាងប្រជាជនឯទៀត ។ ការពិតទៅពួកគេគឺជាប្រជាជនតែមួយក្រុមគត់ដែលរស់នៅក្នុងទីក្រុងជាមួយនឹងវណ្ណៈអ្នកដឹកនាំ មន្ត្រីរាជការ និងកងទ័ព[៤១] ។

ខ្មែរកាត់ចិនដែលនៅក្នុងប្រវត្តិសាស្ត្រ តែងមានមុខរបរជាសំខាន់នៅក្នុងជំនួញជួញដូរ បានកាន់កាប់មួយភាគធំនៃពាណិជ្ជកម្មនៅកម្ពុជា ។ មនុស្សភាគច្រើនក្នុងសហគមន៍នេះ គេមានចំណេះដឹងពីអាជីវកម្ម និងពាណិជ្ជកម្ម ដែលផ្ទេរបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ទៀត[៤២] ។ អ្នកឆ្លើយសម្ភាន៍ភាគច្រើនបានសារភាពថា ពួកគេនៅរក្សាបណ្តាញសាច់ញាតិរបស់ខ្លួន ។ ពេលមានតំរូវការ ឬមានឱកាសល្អ ពួកគេតែងឃើញថា អ្នកដែលចេញពីសហគមន៍របស់ពួកគេ គឺមានលក្ខណៈប្រសើរបំផុតដើម្បីធ្វើជាដៃគូនឹងគ្នា ឯអ្នកដទៃទៀត ឬមួយមានធនធានតិច ឬមួយមានបទពិសោធន៍តិច ដោយសារហេតុផលខាងប្រវត្តិសាស្ត្រដូចបានបញ្ជាក់ខាងលើ ។ គួរបញ្ជាក់ដែរថា សហគមន៍នេះមិនមែនឯកោដាច់ពីគេទេ ប៉ុន្តែបានបន្សុីខ្លួនចូលយ៉ាងពេញលេញទៅក្នុងសង្គមធំ ដោយមានសមាសភាពចំរុះគ្នាច្រើនក្នុងសហគមន៍ទៀតផង ។ ដូចលើករួចហើយ ធនធាន និងបទពិសោធន៍ ជាកត្តាដែលចងភ្ជាប់មនុស្សឱ្យស្ថិតក្នុងសហគមន៍ជាមួយគ្នា ។ ដូច្នេះ វាមិនមែនជារឿងគាប់ជួនទេ ដែលសហគ្រិនធ្វើសម្ភាន៍ទាំង ១០នាក់នៅក្នុងការសិក្សា គឺជាអ្នកមានប្រភពដើមជាខ្មែរកាត់ចិន ។

### *៤.៤.៤ ការលូតលាស់អាជីវកម្ម*

ទោះបី សកម្មភាព និងឫសគល់នៃអង្គភាពអាជីវកម្មទាំងនេះខុសគ្នាខ្លាំង មិនអាចប្រៀបធៀបគ្នាបានសមស្របក៏ដោយ ក៏គេអាចធ្វើការសង្កេតទូទៅខ្លះៗដែរ ។ អាជីវករ ៩នាក់ក្នុងចំណោម ១០នាក់ចេញពីប្រភពសាមញ្ញនៅកម្ពុជា គឺមានតែម្នាក់

---

[៤១] Tarling (1999) (pg. 127-189), and Chandler (1993) ស្ថិតក្នុងចំនោមឯកសារស្តីពីប្រវត្តិសាស្ត្រកម្ពុជាដែលគេស្គាល់ច្រើនជាងគេ ។ ឯកសារទាំងនេះបង្ហាញនូវពតិមានខាងលើ ។

[៤២] ឥរិយាបទនេះគ្មានអ្វីពិសេសទេ ។ ឧទាហរណ៍ សហគមន៍ Marwadi និង Parsi នៅអាស៊ីខាងត្បូងបង្ហាញនូវលំនាំប្រហាក់ប្រហែលគ្នា (សូមអាន Piramal 1998) ។

គត់ដែលមកពីបរទេស និងចេញពីប្រភពអ្នកមានធនធានគួរសម ។ សហគ្រិនទាំងអស់រៀនសូត្រជំនាញធ្វើអាជីវកម្មពីការងារផ្ទាល់ និងបានរីកចំរើនស្របគ្នានឹងការរីកលូតលាស់សេដ្ឋកិច្ច ប៉ុន្តែអ្នកខ្លះរីកចំរើនលឿនណាស់ ឯខ្លះទៀតរីកចំរើនយឺតៗ ។

ធនាគារក្នុងគំរូតាង បានរីកចំរើនយ៉ាងលឿនពីទ្រព្យដើមប្រហែល ៨លានដុល្លារនៅឆ្នាំ១៩៩៣ ដល់ ១២៤លានដុល្លារនៅឆ្នាំ២០០១ ។ ធនាគារសំរេចបាននូវកំណើនយ៉ាងសំបើមប្រហែល ៤០%ក្នុងមួយឆ្នាំ និងមានជោគជ័យក្នុងការបើកសាខាជាច្រើននៅតាមខេត្ត ដោយសារកត្តាធំៗពីរ ។ *កត្តាទីមួយ.* ធនាគារបានកេណ្ឌប្រមូលប្រាក់កាសពីសហគមន៍កម្ពុជានៅក្រៅប្រទេស (the Diaspora) ក្រោយពីបានធ្វើឱ្យគេជឿទុកចិត្ត ពីលទ្ធភាពអាចរកស៊ីរស់ និងផលចំណេញនៃការវិនិយោគទុននៅកម្ពុជា ។ *កត្តាទីពីរ.* ធនាគារបង្កើតច្រករកស៊ីរបស់ខ្លួនមួយបាន គឺការឱ្យខ្ចីប្រាក់ដល់អាជីវករកម្ពុជាថ្នាក់កណ្តាល និងថ្នាក់ខ្ពស់យ៉ាងច្រើន ដែលមិនអាចរកបានដោយស្រួលនូវឥណទានស្ថាប័នមកវិនិយោគ ។ ចំណុចគន្លឹះនៅក្នុងការរីកចំរើនធនាគារ គឺការមិនសូវរារែកក្នុងការធ្វើជំនួញជាមួយពាណិជ្ជករ និងផលិតករក្នុងស្រុកធុនតូច និងមធ្យម ជាបន្ថែមទៅលើការវិនិយោគលើសកម្មភាពច្រើនមុខទាក់ទិននឹងអចលនទ្រព្យ ។

ក្នុងលំនាំប្រហែលគ្នាដែរ សណ្ឋាគាររីកចំរើនយ៉ាងរហ័សសណ្ឋាគារធុនតូចមាន ២៧បន្ទប់ ដល់ខ្នាត ១៥៧បន្ទប់បំពាក់ដោយសំភារៈផ្តល់ផាសុកភាពច្រើនមុខ និងមានបន្ថែមសណ្ឋាគារពាក់កណ្តាលទំនើបនៅឯទីក្រុងផ្សេងមួយទៀតផង ។ សព្វថ្ងៃអាជីវកម្មនេះមានចំណូលប្រហែល ១លានដុល្លារក្នុងមួយឆ្នាំ ។ កំណើនទ្វេច្រើនដងនៃខ្ទង់ទ្រព្យសកម្ម និងចំណូល បង្ហាញពីជោគជ័យជាប់បន្តរបស់ម្ចាស់សណ្ឋាគារ និងក្រុមគ្រួសារ នៅមុនពេលពួកគេចាប់ធ្វើអាជីវកម្មខាងសណ្ឋាគារនៅឆ្នាំ១៩៩៣ ។ មុនឆ្នាំ ១៩៩៣ ម្ចាស់សណ្ឋាគារប្រមូលបានធនធានមួយចំនួនតូចហើយនៅក្នុងជំនួញរបស់ខ្លួនហើយក៏មើលឃើញសក្តានុពលក្នុងវិស័យសណ្ឋាគារ ។ នៅពេលចាប់ផ្តើមដំបូងសណ្ឋាគាររកចំណូលបានពីអ៊ុនតាក់ និងបុគ្គលិកអ៊ុនតាក់ ដែលត្រូវការកន្លែងយ៉ាងច្រើននៅ

ភ្នំពេញ ។ ក្រោយមក សណ្ឋាគារបង្កើតបានច្រករកស៊ីមួយជាមួយអ្នកទេសចរអន្តរជាតិប្រភេទខ្លះដែលមកទស្សនាកម្ពុជា ដោយបានប្រឹងប្រែងយ៉ាងខ្លាំង និងចាប់បន្តធ្វើការឃោសនាទាក់ទាញ NGOs អន្តជាតិ និងភ្ញៀវទេសចរនៅឯព្រលានយន្តហោះ ។ ចំនុចគន្លឹះនៃជោគជ័យ គឺការរំពៃរកមើលយ៉ាងពិនិត្យពិច័យនូវចំណែកទីផ្សារប្រភេទ NGO /អ្នកទេសចរ/អ្នកធ្វើទស្សនកិច្ចជាផ្លូវការ នានាដែលត្រូវការកន្លែងហូបចុក/ស្នាក់នៅដែលមិនថ្លៃពេក និងមានផាសុកភាពតាមបែបបស្ចឹមប្រទេស ។

ក្រុម C-T-P ដែលជាបណ្តុំយ៉ាងជិតស្និទ្ធនៃក្រុមហ៊ុន៧ផ្សេងគ្នា បានរីកចំរើនសឹងតែពីគ្មានអ្វីសោះ រហូតដល់មានមូលដ្ឋានទ្រព្យសកម្ម ៣០លានដុល្លារ តាមរយៈយុទ្ធសាស្ត្រមួយចំនួននៃការគ្រប់គ្រងទីផ្សារ និងការធ្វើចំរុះកម្ម (diversification) ផលិតផល ។ ប្រវត្តិក្រុមហ៊ុននេះចាប់ផ្តើមនៅទសវត្សរ៍១៩៨០ នៅពេលបរិយាកាសពាណិជ្ជកម្មមិនទាន់ផុសចេញនៅឡើយទេនៅកម្ពុជា។ នៅពេលនោះគេត្រូវការយ៉ាងខ្លាំងនូវរូបិយប័ណ្ណ ហើយការស្តារឡើងវិញនូវចំការធំៗនិងការនាំចេញផលិតផលចំការគឺជាជំរើសមួយក្នុងចំនោមជំរើសដ៏តិចតួចដែលអាចអនុវត្តបាននៅពេលនោះ ។ ដោយទទួលបានចំនូលខ្លះៗពីការនាំចេញផលិតផលចំការ ម្ចាស់ចំការបានចាប់ផ្តើមធ្វើចំរុះកម្មមុខរបរ ដោយធ្វើមុខដំណាំចំការផ្សេងៗ ធ្វើសំនង់ និងធ្វើសមាហរណកម្មបញ្ឈរលើសកម្មភាពទាំងឡាយនៃចំការដំណាំ (ឧទាហរណ៍ ការកែច្នៃស្បៀងអាហារ) ។

ក្នុងចំណោមអាជីវកម្ម និងក្រុមហ៊ុនតូចៗដែលបានសិក្សា ក្រុមហ៊ុនមួយដែលមានកំណើនដប់ដងនៅក្នុងមូលធនពី ១០.០០០ដុល្លារ ដល់ ១០០.០០០ដុល្លារ ពីឆ្នាំ ១៩៩៤-២០០១ គឺកសិដ្ឋានចិញ្ចឹមមាន់ ។ ការធានាគុណភាព និងការបង្កើតច្រកទីផ្សាររបស់ខ្លួនផ្ទាល់ គឺជាកត្តាជោគជ័យនៃកសិដ្ឋាននេះ ។ ហាងនំប៉័ងចាប់ដំណើរមុនគេខ្លាំងណាស់តាំពីឆ្នាំ១៩៧៩ និងស្ថិតក្នុងចំណោមហាងដ៏តិចតួចដែលត្រឡប់មកវិញភ្លាមៗបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ។ នៅដំណាក់កាលដំបូង ហាងនេះផលិតសំរាប់លក់ឱ្យអ្នកជិតខាងនៅម្តុំនោះ គឺទើបតែនៅក្រោយឆ្នាំ១៩៩៤ ប៉ុណ្ណោះ ដែល

អាជីវកម្មចាប់មានកំណើនខ្ពស់ ដោយមានទាំងការនាំចេញទំច្រើនប្រភេទទៅប្រទេសជិតខាងទៀតផង ប៉ុន្តែទំហំនៃកំណើនមិនអាចឱ្យដឹងប្រាកដឡើយ ។ កសិដ្ឋានបន្លែពាណិជ្ជកម្មចាប់ផ្តើមសកម្មភាពលើដី ០,៥ហិកតានៅឆ្នាំ២០០០ ហើយផលបន្លែអាចលក់បាន ៤,៧លានរៀល (១.២០០ដុល្លារ) ក្នុងមួយឆ្នាំ ។ ផលិតកម្មទឹកត្រីមានកំណើនលឿនដែរ តាំងពីពេលចាប់ដំណើរការនៅឆ្នាំ១៩៨៦ ។ ហេតុផលនៃជោគជ័យក្នុងបណ្តាអាជីវកម្ម មានសកម្មភាពទាក់ទិននឹងម្ហូបអាហារ គឺការរកមើលទីផ្សារគ្រឿងបរិភោគក្រៅពីអង្ករ នៅពេលដែលប្រជាជនក្នុងទីក្រុងកើនឡើង ហើយតំរូវការគ្រឿងបរិភោគក្រៅពីអង្ករ ក៏ដូចជាផលិតផលអាហារកែច្នៃផ្សេងៗ បានកើនឡើងយ៉ាងលឿន ។ អាជីវករជាច្រើនប្រើប្រាស់បណ្តាញសង្គមកិច្ចរបស់ខ្លួន ដើម្បីពង្រីកចំណែកទីផ្សាររបស់គេ ។ សហគ្រាសសិប្បកម្ម ចាប់ដំណើរការជាអង្គភាពតូចមួយនៅឆ្នាំ១៩៩៧ ហើយនៅឆ្នាំ២០០១ អាចលក់ផលិតផលបានដល់ទៅ ២០.០០០ដុល្លារ ដែលអាចចាត់ទុកជាជោគជ័យដ៏សមរម្យមួយហើយ ។ អង្គភាពផលិតឥដ្ឋបានចាប់ដំណើរការនៅឆ្នាំ១៩៩១ ប៉ុន្តែលក្ខខណ្ឌពាណិជ្ជកម្មមិនស្មើភាពគ្នាជាមួយប្រទេសជិតខាង និងការប្រកួតប្រជែងគ្នាយ៉ាងតឹងតែង បានរំខានដល់ការរីកលូតលាស់នៃអាជីវកម្មនេះ ។ ក្រុមហ៊ុនផលិតគ្រឿងប្លាស្ទិកចាប់ដំណើរការនៅឆ្នាំ១៩៩៣ ប៉ុន្តែបានជួបការលំបាកសឹងតែត្រូវបិទទ្វារជាច្រើនដង ដោយសារត្រូវប្រឈមមុខនឹងផលិតផលនាំចូលមានតំលៃថោក ។ អាជីវកម្មនេះមានដំណើរការមិនដូចគ្នានឹងសហគ្រាស ឯទៀតក្នុងគំរូតាងនេះទេ[៤៣] ។

[៤៣] ក្រុមហ៊ុនដទៃប្រឈមមុខនឹងការប្រកួតប្រជែងមិនស្មើភាព គឺរួមទាំងការប្រកួតប្រជែងពីទំនិញរត់ពន្ធ និងទំនិញលក់បង្ខូចថ្លៃ (dumping) ។ ប៉ុន្តែផលិតករទទួលរងផលប៉ះពាល់កំរិតណាៗ វាអាស្រ័យលើទំហំនៃការពាក់ព័ន្ធនឹងទីផ្សារ និងយុទ្ធសាស្ត្រដោះស្រាយដែលយកមកអនុវត្ត ។

ដោយផ្អែកលើពតិមានដែលបានលើកមកពិភាក្សារួចហើយ គេអាចសំគាល់បាននូវកត្តាជោគជ័យជាទូទៅមួយចំនួន ប៉ុន្តែនៅមានកត្តាជោគជ័យជាច្រើនទៀតដែលនឹងលើកយកមកពិភាក្សាជាក្រោយក្នុងជំពូកនេះ ។ អាជីវកម្មនានាដែលបានរីកចំរើនមានកត្តាជោគជ័យដូចតទៅ:

- បានចូលកាន់កាប់ទីផ្សារក្នុងវិស័យសំខាន់ៗដែលមានតំរូវការពីដំបូងដៃ ។ ដំនើរការបែបនេះ អាជីវកម្មបានបង្កើតកន្លែងមួយសំរាប់ខ្លួនឯងរួចហើយ ខំថែរក្សាទីផ្សារនោះយ៉ាងប្រុងប្រយ័ត្ននៅពេលវារីកធំជាបន្តបន្ទាប់ ។
- បានធ្វើអាជីវកម្មក្នុងមុខរបរណា ដែលមានការប្រកួតប្រជែងពីអន្តរជាតិក៏រិតទាប ពីព្រោះភាគច្រើនស្ថិតនៅក្នុងចំណែកទីផ្សារដែលមិនអាចដោះដូរបាន (non-tradable segments of the market)[៤៤] ។
- ក្នុងសំនាកគំរូនេះ អាជីវកម្មមានជោគជ័យខ្ពស់សំរាប់សកម្មភាពក្នុងវិស័យបឋម និងវិស័យទីបី ឯក្នុងវិស័យទីពីរ កំនើនមិនសូវលេចធ្លោទេ[៤៥] ។

## *៤.៤.៥ បច្ចេកវិទ្យា និងការគ្រប់គ្រង*

ដូចបានលើកឡើងពីខាងដើមរួចហើយ គ្មានសហគ្រិនណាមួយបានទទួលការបណ្តុះបណ្តាលបច្ចេកទេសជាផ្លូវការនៅក្នុងវិស័យដែលគេធ្វើអាជីវកម្មទេ ។ សហគ្រិនម្នាក់ៗ បានរៀន និងចាប់យកជំនាញបណ្តើរៗ ហើយជាច្រើននាក់បានជួលបុគ្គលិកមានការបណ្តុះបណ្តាល ដើម្បីឱ្យជួយបំពេញកង្វះជំនាញរបស់ខ្លួន ។

ធនាគារដែលលើកយកមកពិភាក្សានៅក្នុងឯកសារនេះ បានចាប់ដំណើរការនៅឆ្នាំ១៩៩៣ ដោយមានបុគ្គលិកតែ ១៩នាក់ដែលភាគច្រើនជាសមាជិកគ្រួសារម្ចាស់ធនាគារ ។ នៅឆ្នាំ២០០២ បុគ្គលិកកើនដល់ ២៥០នាក់ ហើយជាច្រើននាក់បានទទួល

---

[៤៤] មានន័យថា មានការប្រកួតប្រជែងតិច ឬគ្មានសោះនៅក្នុងវិស័យទាំងនេះ ។

[៤៥] រឿងនេះអាចនិយាយជាទូទៅបានសំរាប់ទូទាំងប្រទេស ។

ការបណ្តុះបណ្តាលទាំងតាមបែបផ្លូវការ ទាំងតាមបែបភ្ជាប់នឹងការងារ (formal and on-the-job training) ខាងផ្នែកហិរញ្ញវត្ថុ ធនាគារ និងអេឡិចត្រូនិក ។ នៅពេលខ្លះ ធនាគារខ្លួនឯងបានជំរុញការបណ្តុះបណ្តាល ។ ថ្នាក់គ្រប់គ្រងដឹងច្បាស់ថា សំរាប់អាជីវកម្មធំៗ និងមានរបរច្រើនមុខ ម្ចាស់កម្មសិទ្ធិ និងថ្នាក់គ្រប់គ្រង គឺជារឿងពីរដាច់ពីគ្នា ហើយតួនាទីរបស់គេម្នាក់ៗត្រូវតែយល់ឱ្យបានច្បាស់ ។ ថ្នាក់គ្រប់គ្រងបានចាប់យកបច្ចេកវិទ្យាក្នុងវិស័យធនាគារ តាមរយៈសម្ព័ន្ធភាពជាយុទ្ធសាស្ត្រជាមួយក្រុមហ៊ុនអន្តរជាតិ ដូចជា Swift ដែលជំនាញខាងផ្ទេរប្រាក់, MasterCard និង Visa ដែលជំនាញខាងប័ណ្ណឥណទាន និង Cirrus ដែលធ្វើអាជីវកម្មក្នុងផ្នែកម៉ាស៊ីនបើកប្រាក់ស្វ័យប្រវត្តិ ។ ទាំងនេះគ្រាន់តែជាការបង្ហាញខ្លះៗប៉ុណ្ណោះ ហើយធនាគារមានមធ្យោបាយច្រើនទៀតដើម្បីចាប់យកបច្ចេកវិទ្យា និងធ្វើអាជីវកម្មតាមបែបទំនើប ។ ថ្នាក់គ្រប់គ្រងបានសារភាពថា បច្ចេកវិទ្យាទំនើបមិនមែនអាចរកបានដោយថោកៗនោះទេ ប៉ុន្តែផលចំណេញខាងផលិតភាព អាចទូទាត់បានហើយចំពោះចំណាយក្នុងពេលកន្លងមក ។ ធនាគារពឹងផ្អែកយ៉ាងខ្លាំងដែរលើទូរគមនាគមន៍ និងបច្ចេកវិទ្យាកំព្យូទ័រដ៏ទំនើប ដើម្បីធ្វើប្រតិបត្តិការប្រចាំថ្ងៃ ។

សណ្ឋាគារក៏ចាប់ផ្តើមធ្វើអាជីវកម្មជាលក្ខណៈគ្រួសារដែរ ដូច្នេះដំណើរការរៀនសូត្រជួបការលំបាកច្រើនជាង ។ អាជីវកម្មបែបនេះ ទាមទារនូវជំនាញពិសេសសំរាប់សកម្មភាពដែលជាប់ទាក់ទិនជាច្រើន ដូចជា ទំនាក់ទំនងជាមួយភ្ញៀវ, ការថែទាំបន្ទប់ ការជួសជុលគ្រឿងអគ្គីសនី និងទឹក ការផ្គត់ផ្គង់ក្នុងពិធី (catering), ភោជ-នីយដ្ឋាន និងការបោកអ៊ុត ។ ជាក់ស្តែងកន្លងមក សណ្ឋាគារមិនមែនបានសុខស្រួលរហូតទេនៅក្នុងសកម្មភាពទាំងនេះ ហើយជំនាញធ្វើអាជីវកម្មមួយចំនួនអាចរៀនសូត្របានដោយលំបាកណាស់ ។ សមាជិកគ្រួសារជាច្រើននាក់ហាត់រៀនជំនាញតាមរយៈការអនុវត្តន៍ការងារផ្ទាល់ នៅក្នុងវិស័យដែលពួកគេមិនធ្លាប់ជួបប្រទះពីមុនមកសោះ ។ សមាជិកខ្លះទៅធ្វើការជាមួយសណ្ឋាគារផ្សេងទៀតនៅកម្ពុជា និងនៅថៃ

ដើម្បីហាត់រៀនពីការធ្វើអាជីវកម្ម អ្នកខ្លះរៀនពីបច្ចេកទេសពតិមានវិទ្យា ឯខ្លះទៀត រៀនខាងគណនេយ្យ ។ រហូតដល់សព្វថ្ងៃ គ្រួសារនេះគ្មានរបបថ្ងៃឈប់សំរាកទេ ។ ម៉ោងធ្វើការមានកំរិតវែង ហើយការភ្លាំងភ្លាត់នីមួយៗ (ជាពិសេសកាលពីដំបូង) ត្រូវបានកត់ត្រាចំណាំទុកជាមេរៀន[៨៦] ។ ក្រៅពីសមាជិកគ្រួសារ សណ្ឋាគារបានជួលបុគ្គលិកបួននាក់សំរាប់ទំនាក់ទំនងភ្ញៀវ ។ ចំពោះបុគ្គលិកប្រតិបត្តិការដែលភាគច្រើនមានជំនាញទាប គឺសុទ្ធតែជួលទាំងអស់ ។ ម្ចាស់សណ្ឋាគារ និងភរិយាគាត់ ត្រូវបានប្រកាសជាផ្លូវការថាជា "ម្ចាស់" ឯកូនក្មួយដែលចូលរួមពេញកំលាំងនៅក្នុងអាជីវកម្ម គឺជា "បុគ្គលិកមានប្រាក់ខែ" ។ ទោះបីមានការបែងចែកយ៉ាងនេះក្តី សណ្ឋាគារមិនបានប្រឹងប្រែងណាស់ណាទេ ដើម្បីកាត់ផ្តាច់កម្មសិទ្ធិ ឱ្យដាច់ពីការគ្រប់គ្រង ហើយទង្វើនេះអាចនឹងរាំងស្ទះដល់ការរីកចំរើនថែមទៀតតទៅអនាគត ។ រហូតមកទល់សព្វថ្ងៃ ការប្រមូលផ្តុំជំនាញ និងការងារគ្រប់គ្រង នៅក្នុងរង្វង់គ្រួសារ បានធានាឱ្យមានការសន្សំសំចៃយ៉ាងសំបើម ពីព្រោះការបាត់បង់ថវិកា និងភាពរយីករយៀកក្នុងការងារ គឺសឹងតែគ្មានសោះ ។

ចំពោះក្រុមហ៊ុន C-T-P គេបានហាត់រៀនយ៉ាងច្រើនពីវិធីគ្រប់គ្រង និងបច្ចេកវិជ្ជារបស់បណ្តាក្រុមហ៊ុនពហុជាតិដែលជាដៃគូរបស់ខ្លួន ។ នៅពេលខ្លះ C-T-P បាននាំចូលម៉ាស៊ីន និងគ្រឿងចក្រទាំងមូល (ដូចជា សំរាប់កែច្នៃកសិផល) ដែលជាមធ្យោបាយមួយទៀតដើម្បីចាប់យកបច្ចេកវិទ្យា ។ នៅពេលខ្លះទៀត ក្រុមហ៊ុនបានជួលបុគ្គលិកបរទេសដែលមានការបណ្តុះបណ្តាលខ្ពស់ ។ ដោយសារមានក្រុមហ៊ុនច្រើននៅក្នុងក្រុមអាជីវកម្មធំរុះនេះ វិធីចាប់យកបច្ចេកវិទ្យាមានភាពខុសគ្នាពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ។ ពីដំបូងដៃ គេពឹងផ្អែកលើពួកពូមាមីង និងបងប្អូនជីដូនមួយនៅក្នុងការងារគ្រប់គ្រង ប៉ុន្តែបន្តិចម្តងៗរបៀបរបបនេះក៏ត្រូវបានជំរុះចោល ហើយ

---

[៨៦] ភស្តុតាងចោះៗបង្ហាញថា កំហុសធ្ងន់ៗជាងគេកាលពីដំបូងគឺ ទំនាក់ទំនងភ្ញៀវ ដោយសារកង្វះបទពិសោធន៍ ហើយគេបានកែតំរូវវាវិញយ៉ាងលឿន ។

បែរទៅជួលបុគ្គលិកវិជ្ជាជីវៈមកជំនួសវិញ ។ អ្នកបង្កើតក្រុមហ៊ុននៅតែគ្រប់គ្រងអាជីវកម្មសឹងតែទាំងស្រុងដដែល ហើយជាលទ្ធផល គាត់ត្រូវរវល់ពេញៗមួយសប្តាហ៍ និងពេញៗមួយឆ្នាំ ។ ដូចក្នុងករណីមុនដែរ ទង្វើនេះ អាចរាំងស្ទះដល់ការរីកចំរើនអាជីវកម្មនៅបណ្តាឆ្នាំខាងមុខ ។

កសិករចិញ្ចឹមមាន់ទទួលបានបច្ចេកទេសចំណេះធ្វើ តាមរយៈទំនាក់ទំនងជាមួយក្រុមហ៊ុនថៃដ៏ធំមួយដែលមានវត្តមាននៅកម្ពុជា ។ ពីដំបូងបំផុត សាច់ញាតិម្នាក់របស់ម្ចាស់ក្រុមហ៊ុនសព្វថ្ងៃ បានជួយណែនាំគាត់អំពីអាជីវកម្មនេះ បានបញ្ជូនគាត់ទៅធ្វើការរយៈបីខែជាមួយសហគ្រាសចិញ្ចឹមមាន់ដ៏មាំទាំមួយនៅថៃ ដើម្បីរៀនសូត្រពីអាជីវកម្ម និងបច្ចេកទេសលំអិតផ្សេងៗ ។ ដើម្បីរក្សាគុណភាពធាតុចូល (input) ម្ចាស់កសិដ្ឋានតែងនាំចូលពូជមាន់ពីក្រុមហ៊ុនថៃនោះ ។ គាត់អះអាងថា នៅបរទេស ឬក្នុងក្រុមហ៊ុនបរទេស គេចិញ្ចឹមមាន់មានលក្ខណៈវិទ្យាសាស្ត្រជាង ។ មេមាន់យកមកពីបរទេសផ្តល់ស៊ុតតាមទំហំស្តង់ដាឬធំជាង ហើយអត្រាទិន្នផលក៏មានកំរិតខ្ពស់ ។ ចំណីមាន់ក៏នាំចូលពីក្រុមហ៊ុនថៃនេះដែរ ដែលគេកិនលាយនៅកម្ពុជា ប៉ុន្តែវត្ថុធាតុដើមមួយចំណែកយកពីថៃ ។ កសិដ្ឋានទទួលបានជំនាញក្នុងការលាយចំណីមាន់ និងចំណីសត្វផ្សេងទៀតឱ្យបានសមស្រប ដើម្បីបានលទ្ធផលប្រសើរបំផុត ។ ម្ចាស់ក្រុមហ៊ុនបានព្យាយាមកែច្នៃប្រើប្រាស់បច្ចេកវិទ្យាក្នុងស្រុក ប៉ុន្តែមិនបានទទួលជោគជ័យទេ ។ ដូច្នេះហើយ គាត់នៅតែត្រូវពឹងផ្អែកលើក្រុមហ៊ុនថៃជាបន្តទៀត ។

ចំពោះសិប្បកម្មផលិតវត្ថុសិល្បៈ បច្ចេកវិទ្យារបស់គេ គឺទីមួយមាន សិល្បៈ និងជំនាញ ខាងឆ្លាក់ថ្មដោយដៃ, និងទីពីរមានមធ្យោបាយសំរាប់កាត់និងខាត់ថ្ម, កាត់បន្ថយថ្មដែលត្រូវដាប់ចោល និងធ្វើស្តង់ដានីយកម្មផលិតផល ។ សហគ្រាសនេះមិនបានធ្វើវិនិយោគលើការអភិវឌ្ឍន៍ ឬការចាប់យកបច្ចេកវិទ្យាទំនើបសំរាប់ថ្ងៃក្រោយទេ ។ ដូច្នេះហើយទើបមានការខាតថ្មចោលយ៉ាងច្រើន នៅក្នុងវិធីដាប់ ឬឆ្លាក់ថ្មក្នុងពេលសព្វថ្ងៃ ។ ការខាតបង់នេះបានបង្កើននូវចំណាយលើធាតុចូល និងជាពិសេស

ចំណាយលើការដឹកជញ្ជូន ។ ម្ចាស់សិប្បកម្មបានចាប់អារម្មណ៍ពីការបង់ខាតដែរ ប៉ុន្តែបញ្ជាក់ថា គាត់ពុំមានលទ្ធភាពធ្វើការកែលំអទេ ពីព្រោះនៅក្នុងខេត្តគាត់ គាត់មិនអាចរកធនធានសំរាប់ទិញម៉ាស៊ីនល្អៗជាងនេះបាន ។ គាត់មិនបានអភិវឌ្ឍន៍ក្រុមកម្មកររបស់គាត់ទេ ដោយយល់ឃើញថា គាត់បានចំណេញច្រើនជាងតាមការជួលកម្មករមានជំនាញខ្ពស់ៗឱ្យមើការផលិតឱ្យគាត់ ។ តាមវិធីនេះ គាត់អាចរក្សាចំណាយឱ្យនៅទាប ។ គាត់អះអាងថា ជំនាញខាងសិល្បៈគឺមានមនុស្សជាច្រើនចេះធ្វើ ដូច្នេះមិនចាំបាច់ប្រឹងប្រែងអ្វីជាពិសេសទេ ដើម្បីថែរក្សាវា (នេះជាជំនាញពីបរមបុរាណ ហើយប្រជាជននឹងថែរក្សាឱ្យវាឋិតឋេរតទៅមុខទៀត ដោយឆន្ទៈរបស់គេផ្ទាល់) ។ ម្ចាស់សិប្បកម្មជឿថា គឺទឹកដៃសិល្បៈមិនមែនបច្ចេកវិទ្យាទំនើបទេដែលផ្តល់ឧត្តមភាពដាច់ណាត់ ហើយនេះជាហេតុផលមួយដែលនាំឱ្យគាត់ប្រកាន់យកវិធីធ្វើប្រតិបត្តិការដូចសព្វថ្ងៃ ។

ម្ចាស់ហាងនំប៉័ងចេះធ្វើរបរនេះតាំងពីមុនឆ្នាំ១៩៧៩ មកម្ល៉េះ ដូច្នេះគាត់មានប្រៀប ពីព្រោះស្ថិតក្នុងចំណោមអ្នកបើកហាងមុនគេបង្អស់ ដោយប្រើសមាជិកគ្រួសារជាកម្មករ ។ បច្ចុប្បន្ន អាជីវកម្មនេះប្រើម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ ដើម្បីលាយម្សៅ និងដុតនំ និងមានសំភារៈជំនួយការងារមួយចំនួនទៀត ។ ម៉ាស៊ីន និងសំភារៈទាំងអស់ផលិតនៅប្រទេសចិន ។ សំភារៈវេចខ្ចប់មកពីចិន និងថៃ ហើយរឿងនេះបង្កការយឺតយ៉ាវជារឿយៗ និងឡើងថ្លៃខ្ពស់ និងមានតំលៃខ្ពស់ ដោយសារសំភារៈដឹកជញ្ជូនយ៉ាប់យ៉ឺន និងចំណាយក្រៅផ្លូវការច្រើន ។ ការប្រឹងប្រែងចុះកិច្ចសន្យាឱ្យក្រុមហ៊ុនក្នុងស្រុក ផ្គត់ផ្គង់សំភារៈវេចខ្ចប់ឱ្យមិនបានជោគជ័យទេ ដោយសារបញ្ហាគុណភាព និងតំលៃ ។ សំភារៈផលិតក្នុងស្រុកថ្លៃជិតស្មើរបស់នាំចូល ប៉ុន្តែគុណភាពខុសគ្នាឆ្ងាយ ។

កសិករដាំបន្លែ បានទទួលការបណ្តុះបណ្តាលជាដំបូងពី NGO មួយ ។ ប៉ុន្តែគាត់មានអារម្មណ៍ថា បច្ចេកវិទ្យាកសិកម្មដែលរួមមាន ជី ពូជ និងថ្នាំសំលាប់សត្វ

ចង្រៃ គួរចេញមកពីប្រភពស្ថាប័នណាមួយនៅក្នុងប្រទេស និងបន្តផ្សព្វផ្សាយជាប់រហូតទៅដល់កសិករ ។ កសិករនេះបានដឹងពីភាពជឿនលឿនក្នុងសម័យថ្មីនេះ ខាងផ្នែកបច្ចេកវិទ្យាដែលផ្តល់ទិន្នផលខ្ពស់ ប៉ុន្តែគាត់ជួបឧបសគ្គមិនអាចប្រើប្រាស់វាទាំងអស់បានទេ គឺត្រូវប្រើប្រាស់ដោយមានការជ្រើសរើស ។

ផលិតករឥដ្ឋ ប្រើបច្ចេកវិទ្យាបុរាណដើម្បីធ្វើឥដ្ឋ ។ ឥន្ធនៈចំបងគឺអង្កាម មិនមែនធ្យូងថ្មទេ ។ គាត់មិនបានធ្វើទំនើបភាវូបនីយកម្មអាជីវកម្មរបស់គាត់ទេ ពីព្រោះខ្វះខាតធាតុចូល និងបច្ចេកវិទ្យា ។ ក្នុងរយៈពេលខ្លី សំភារៈទំនើបនឹងបង្កើនបន្ទុកចំណាយដែលកាត់បន្ថយសមត្ថភាពប្រកួតប្រជែង ។ ម្យ៉ាងទៀតនៅកម្ពុជាគ្មានធ្យូងថ្មក្នុងករិតឧស្សាហកម្មទេ ដែលជាគ្រឿងជំរុញឱ្យមានការកែលំអបច្ចេកវិទ្យានោះ ។

ទឹកត្រី គឺជាគ្រឿងហូបពីបរមបុរាណនៅអាស៊ីអគ្នេយ៍ ហើយដើម្បីផលិតវា បច្ចេកវិទ្យាក្នុងស្រុកគឺមានគ្រប់គ្រាន់ ។ សំភារៈសំរាប់ផលិតជាទ្រង់ទ្រាយធំ ក៏មាននៅក្នុងប្រទេសដែរ ។ កត្តាមួយដែលរារាំងដល់ការពង្រីកអាជីវកម្ម គឺសមត្ថភាពច្រកដប ។ បច្ចេកវិទ្យាបែបនេះមិនអាចរកបានងាយៗទេនៅកម្ពុជា ។ ដោយមូលហេតុនេះ ផលិតករមិនអាចជ្រៀតចូលបានទេទៅក្នុងចំណែកទីផ្សារនៃអ្នកមានធនធាន ។

រោងចក្រប្លាស្ទិកបានទិញបរិក្ខារប្រើបច្ចេកវិទ្យាចាស់ឆ្នាំ១៩៩១ ពីពាណិជ្ជករតៃវ៉ាន់ម្នាក់ ដែលផ្តល់ចំណេះដឹងប្រើប្រាស់ និងជួសជុលម៉ាស៊ីនឱ្យម្ចាស់សិប្បកម្មផងដែរ ។ ក្នុងពេលសព្វថ្ងៃបច្ចេកវិទ្យានេះហួសសម័យហើយ ។ ទោះបីផលិតករមិនសូវគិតគូរពីបញ្ហាបច្ចេកទេស ឱ្យបានច្រើនដូចគាត់គិតពីរឿងពាណិជ្ជកម្ម និងទីផ្សារក៏ដោយ ក៏ជាក់ស្តែងរឿងបច្ចេកវិទ្យា ទំហំផលិតកម្ម និងការថែទាំបរិក្ខារ បានបង្កើនបន្ទុកចំណាយខ្ពស់ពេក ធ្វើឱ្យអាជីវកម្មមានសមត្ថភាពប្រកួតប្រជែងទាបនៅក្នុងទីផ្សារ ។ កាលពីមុន គាត់នាំវត្ថុធាតុដើមពីសឹង្ហបុរី និងកូរ៉េ ក្រោយមកគាត់ចាប់ផ្តើមកែច្នៃកាកសំណល់ប្លាស្ទិកនៅក្នុងស្រុក ។ វិធីនេះជួយកាត់បន្ថយតំលៃ ប៉ុន្តែផលិតផលពុំមានគុណភាពល្អដូចមុនទេ ។ អាជីវករបានកាត់បន្ថយចំនួនកម្មករផងដែរ

ហើយសព្វថ្ងៃប្រើតែកម្មករអណ្តែត គឺបានន័យថាគាត់ទូទាត់ប្រាក់កំរៃឱ្យកម្មករតែនៅពេលមានការងារធ្វើ ដូច្នេះអាចកាត់បន្ថយចំណាយមួយក៏រិតទៀត ហើយអាចរក្សាឱ្យអាជីវកម្មនៅបន្តដំណើរការបាន ។

ក្នុងចំណោមករណីសិក្សា១០ខាងលើ មានករណីសិក្សា៨ ដែលគ្រប់គ្រងដោយបុគ្គលម្នាក់ ឬគ្រួសារមួយ ។ មានករណី៣ យ៉ាងតិច គឺផលិតកម្មឥដ្ឋ សិប្បកម្មផលិតវត្ថុសិល្បៈ និងរោងចក្រប្លាស្ទិក គេមានការលំបាកក្នុងការរកឱ្យឃើញពីហេតុផលពិតនៃការបាត់បង់ ក៏កង្វះកំណើនទីផ្សារ ។

តាមការអធិប្បាយខាងលើ គេឃើញមានលក្ខណៈទូទៅមួយចំនួនដូចតទៅ:

- គេហាក់ដូចជាឃើញច្បាស់ថា អ្នកជ្រើសយកបច្ចេកវិទ្យាទំនើប គឺបានរីកចំរើនល្អជាងអ្នកដែលមិនបានជ្រើសយកវា ។ តាមពិតនៅក្នុងដំណើរការអាជីវកម្ម អ្នកប្រើប្រាស់វិធីចាស់ៗ ជួនកាលមិនបានទាំងចាប់អារម្មណ៍ថាខ្លួនកំពុងចាញ់គេផង ។
- ក្នុងគ្រប់ករណីសិក្សា ឬមួយគេទទួលបច្ចេកវិទ្យាស្ទើរទាំងអស់ពីក្រុមហ៊ុនបរទេស ឬមួយគេគ្មានប្រើបច្ចេកវិទ្យាទំនើបតែម្តង ពីព្រោះឃើញមានបច្ចេកវិទ្យាទំនើបក្នុងស្រុក ឬក៏មធ្យោបាយខាងស្ថាប័នតិចតួចណាស់សំរាប់ទាក់ទងស្វែងរកពីកន្លែងផ្សេង ។ សហគ្រិនជាច្រើនបានកាត់បន្ថយចំណាយពលកម្ម ដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងជាជាងទាញផលចំណេញពីបច្ចេកវិទ្យាទំនើប ហើយទង្វើបែបនេះធ្វើឱ្យខូចផលប្រយោជន៍របស់កម្មករ ។ គួររំលឹកដែរថា ក្នុងករណីសិក្សាជាច្រើន ចំណូលកម្មករមានក៏រិតទាបណាស់ ។
- ស្ទើរគ្រប់អាជីវកម្មដែលបានសិក្សា មានការត្រួតត្រាជារបៀបគ្រួសារយ៉ាងតឹងតែង ។ ថ្វីបើក្នុងដំណាក់កាលដំបូង វាជាការចាំបាច់ និងមាន

ប្រយោជន៍ក្តី ក៏នេះមិនមែនជាជំរើសដ៏ប្រសើរបំផុតទេ នៅពេលទំហំប្រតិបត្តិការកើនឡើង ។

### *៤.៤.៦ ប្រភពហិរញ្ញវត្ថុ*

លទ្ធភាពមានប្រើប្រាស់ហិរញ្ញវត្ថុស្ថាបន័ គឺជាបញ្ហាដ៏ធំមួយនៅកម្ពុជា ។ ធនាគារពាណិជ្ជភាគច្រើនមានប្រភពពីបរទេស និងច្រើនធ្វើប្រតិបត្តិការសំរាប់ពួកក្រុមហ៊ុនមកពីក្រុមហ៊ុនមេ ឬក្រុមហ៊ុនបរទេសធំៗប៉ុណ្ណោះ ។ សំរាប់ប្រជាជនក្នុងស្រុក អ្នករកស៊ីចងការប្រាក់ឯកជនគឺជាប្រភពកំចីចំបង ដែលមានការប្រាក់ខ្ពស់ហួសហេតុគឺពី ៥% ទៅ ១០% ក្នុងមួយខែ ។

ក្នុងបរិបទធនាគារ គេគួរជជែកពីការប្រើប្រាស់ និងចរាចរប្រាក់កាស មិនមែនពីប្រភពប្រាក់កាសតែមួយមុខនោះទេ ។ ធនាគារកំពុងសិក្សានេះ ទទួលមូលធនដើមទាំងអស់ពីអាណិកជនខ្មែរនៅបរទេស តាមរយៈក្រុមហ៊ុនវិនិយោគចំរុះមួយ ហើយធនាគារនេះគឺជាសាខានៅខាងក្រោមមួយ ។ ក្រោយមកទៀត ធនាគារទទួលប្រាក់បញ្ញើពីបណ្តាអាជីវកម្មនៅកម្ពុជា និងប្រជាពលរដ្ឋជាឯកជន ។ ធនាគារនេះបានធ្វើវិនិយោគចំរុះ ដោយមានច្រើនមុខជាងវិនិយោគរបស់ធនាគារធម្មតានៅកម្ពុជា[៤៧] ។ ធនាគារផ្តល់កំចីឱ្យអង្គភាពធុនតូច មធ្យម និងធំមួយចំនួន ជាពិសេស ជនកម្ពុជា និងអ្នកដែលមានសមត្ថភាពជាក់ស្តែង ក្នុងការប្រើប្រាស់ប្រាក់កាសមានប្រសិទ្ធភាព ។ ដោយសារនៅកម្ពុជា អភិបាលកិច្ច និងប្រព័ន្ធច្បាប់នៅទន់ខ្សោយ ធនាគារទាមទារឱ្យមានដាក់ទ្រព្យធានាធំៗ នៅពេលខ្លះធំជាងទឹកប្រាក់កំចីជាច្រើនដង ដើម្បីការពារផលប្រយោជន៍របស់ធនាគារ[៤៨] ។ ធនាគារផ្តល់ការប្រាក់ ៦%/ឆ្នាំ ចំពោះបញ្ញើមានកាលកំណត់ ដែលជាអត្រាដ៏ខ្ពស់បើធៀបនឹងស្តង់ដាអន្តរជាតិ ប៉ុន្តែតាមធម្មតាអត្រាការប្រាក់នៅកម្ពុជាតែងតែខ្ពស់ ពីព្រោះពួកអាជីវករវាយតំលៃទាបពីគំរិតសុវត្ថិភាព

[៤៧] មានវិនិយោគច្រើនលើអចលនទ្រព្យ ប៉ុន្តែក៏មានក្នុងសកម្មភាពផ្សេងទៀតដែរ ។

[៤៨] ទង្វើនេះ ក៏ដោយសារតែកម្ពុជាមិនមានសេវាកម្មកំនត់តំលៃទ្រព្យសម្បត្តិ និងសេវា ។

មូលធន ។ ហានិភ័យខ្ពស់ដែលធនាគារជួបប្រទះ ត្រូវបានទប់ទល់មួយកំរិតដោយសារចំណងទាក់ទងផ្ទាល់ខ្លួន និងកត្តាសាច់ញាតិ ។ សហគមន៍ខាងអាជីវកម្មជាច្រើនចងភ្ជាប់គ្នាយ៉ាងជិតស្និទ្ធតាមរយៈសាច់ញាតិ និងបណ្តាញផ្សេងទៀត ហើយសំពាធលើកូនបំណុលមិនឱ្យរត់ចោលប្រាក់គេគឺមានកំរិតខ្ពស់ ។ បច្ចុប្បន្ននេះ នៅកម្ពុជាសឹងតែគ្មានប្រតិបត្តិការអន្តរ-ធនាគារ ឬអន្តរ-ស្ថាប័នហិរញ្ញវត្ថុទេ ។ ការពិត សហប្រតិបត្តិការរវាងស្ថាប័នហិរញ្ញវត្ថុពុំទាន់លូតលាស់នៅឡើយទេ ។ ហេតុផលមួយគឺធនាគារភាគច្រើនមានមុខសេវាមិនច្រើនទេ ហើយហេតុផលមួយទៀត គឺកង្វះខាតក្នុងការដាក់អនុវត្តន៍ច្បាប់ ។ ដូច្នេះហើយ ធនាគារនេះមិនអាចមានលទ្ធភាពធ្វើប្រតិបត្តិការដូចខាងលើនេះទេ ។

ទោះបីក្នុងទំហំបច្ចុប្បន្នក្តី សណ្ឋាគារពឹងផ្អែកសុទ្ធសាធលើថវិកាផ្ទាល់ខ្លួន ។ ដំបូងម្ចាស់សណ្ឋាគាររកចំណូលមួយចំនួនបានពីរបរលក់មាសក្នុងទសវត្សរ៍១៩៨០ នៅពេលដែលមាសជាមធ្យោបាយតែមួយគត់សំរាប់សន្សំ និងផ្តល់សុវត្ថិភាពនៅកម្ពុជា ។ ដោយប្រើប្រាស់ទុននោះ គាត់ចាប់របរលក់យានយន្តនៅដើមទសវត្សរ៍១៩៩០ ហើយរកប្រាក់បានកាន់តែច្រើនថែមទៀត ។ នៅពេលបង្កើតសណ្ឋាគារបាន និងរហូតដល់ពាក់កណ្តាលទសវត្សរ៍១៩៩០ គាត់បានចាត់តាំងឱ្យសមាជិកគ្រួសារ កាន់ដំណែងសំខាន់ៗតាមដែលអាចធ្វើបាន ហើយបានកាត់បន្ថយចំណាយ និងធានាមិនឱ្យមានការលេចធ្លាយហិរញ្ញវត្ថុ ។ ធ្វើដូច្នេះ ម្ចាស់សណ្ឋាគារបានចំណេញកាន់តែច្រើនថែមទៀត[៤៩] ។ ការធ្វើសមាហរណកម្មបញ្ឈរ (vertical integration) នូវសកម្មភាពនានាដូចជាមានម៉ាស៊ីនភ្លើង កន្លែងបោកអ៊ុត រថយន្តដឹកភ្ញៀវ និងមានសេវាចាត់ចែងសំបុត្រធ្វើដំណើររបស់ភ្ញៀវដោយផ្ទាល់ ក៏ជួយកាត់បន្ថយចំនាយដែរ ។ ប្រាក់ចំនេញមួយភាគទុកប្រើជាទុនសំរាប់ដំណើរការ ឯមួយភាគទៀតសន្សំទុក សំរាប់ពង្រីកអាជីវកម្ម ។ សណ្ឋាគារទីពីរបានសង់ដោយប្រើប្រាក់សន្សំរបស់គ្រួសារសុទ្ធសាធ ។

[៤៩] ចំណាយធំៗមានពីរគឺ ប្រាក់ខែ និងពន្ធ ។ ក្នុងករណីនេះ ចំណាយទាំងពីរមានកំរិតទាប ។

វាហាក់ដូចជាមិនសមសោះ ដែលអាជីវកម្មមួយមានចំណូលប្រចាំឆ្នាំជាង ១លាន ដុល្លារ បានដំណើរការដោយប្រើទុនផ្ទាល់ខ្លួនទាំងស្រុង ។ នៅក្នុងប្រទេសផ្សេង បើសិនជាមានទុនផ្ទាល់ខ្លួនមួយចំនួន ជាញឹកញយ គេអាចទាក់ទាញទុនបន្ថែមច្រើនណាស់ ពីទីផ្សារហិរញ្ញវត្ថុដែលអាចជំរុញអាជីវកម្មឱ្យលូតលាស់លឿនច្រើនដងថែមទៀត ។ និយាយដូច្នេះពុំមែនមានន័យថា អាជីវកម្មនេះមិនបានរីកចំរើនគួរឱ្យរំភើបនោះទេ ។ ជាក់ស្តែងអាជីវកម្មបានរីកចំរើនដោយគ្មានជំនួយទុនពីទីផ្សារហិរញ្ញវត្ថុ មិនមែនដោយសារបានទទួលទុននេះទេ ។

ក្រុមហ៊ុន C-T-P ពីដំបូងរកចំនួលបានភាគច្រើនតាមរយៈការធ្វើជំនួញ ហើយបន្ទាប់មកចាប់ផ្តើមពង្រីកទៅខាងចំការ និងសំណង់ ។ ម្ចាស់ក្រុមហ៊ុនបានកសាងសម្ព័ន្ធយុទ្ធសាស្ត្រ ជាមួយអ្នកមានឥទ្ធិពលដែលកាន់ដំណែងសំខាន់ៗ (របៀបរបបអនុវត្តន៍ជាទូទៅនៅក្នុងប្រទេសភាគច្រើនលើសកលលោក) ដើម្បីទទួលបានសិទ្ធិធ្វើពាណិជ្ជកម្មលើផលិតផលចំបងៗ ដែលជាសកម្មភាពផ្តល់ចំណេញច្រើន ។ ប្រាក់ដែលប្រមូលបានពីដំបូង ត្រូវបានប្រើដើម្បីទាក់ទាញទុនថែមទៀតពីទីផ្សារ, ធនាគារ និងក្រុមហ៊ុនបរទេស ។ ក្នុងគំរូតាងមានតែ C-T-P និងធនាគារទេ ដែលបានធ្វើតាមរបៀបរបបអន្តរជាតិខ្លះៗក្នុងការកេណ្ឌប្រមូលទុន ។ បច្ចុប្បន្ន បើគិតតាមទំហំកេរ្តិ៍ឈ្មោះ និងប្រាក់ចំណូល C-T-P ប្រហែលមិនពិបាកក្នុងការស្វែងរកហិរញ្ញវត្ថុពីប្រភពស្ថាប័នច្រើនទេ ទោះបីក្នុងចំណោមក្រុមហ៊ុនជាសមាជិកទាំង៧ មានក្រុមហ៊ុនខ្លះដំណើរការមិនសូវបានល្អដូចគេក៏ដោយ ។

នៅឆ្នាំ១៩៩៧ កសិដ្ឋានចិញ្ចឹមមាន់រកទុនបានប្រហែល ៥០% នៃទុនសរុប ពីធនាគារមួយក្នុងអត្រាការប្រាក់ ២៤% ក្នុងមួយឆ្នាំ ។ នេះជាហិរញ្ញវត្ថុពីស្ថាប័នតែមួយគត់ដែលកសិដ្ឋានបានទទួល ហើយតំរូវការបន្ថែមទៀតលើទុនបង្វិល និងទុនអចល័តកសិដ្ឋានរកបានពីប្រភពផ្ទាល់ខ្លួន ឬតាមរយៈការចាត់ចែងជាមួយក្រុមហ៊ុនថៃដែលផ្គត់ផ្គង់ធាតុចូល និងចំណេះធ្វើខាងបច្ចេកទេសដល់កសិដ្ឋាននេះ ។

សិប្បកម្មផលិតវត្ថុសិល្បៈមានទីតាំងនៅក្រៅក្រុងភ្នំពេញ ។ នៅទីនោះមានលទ្ធភាពតិចតួចទេក្នុងការរកឥណទានស្ថាប័ន ហើយម្ចាស់សិប្បកម្មត្រូវប្រើធនធាន និងប្រាក់សន្សំផ្ទាល់ខ្លួន រួមទាំងកំចីពីសាច់ញាតិផង ។ ម្ចាស់ហាងនំប៉័ងបានឱ្យដឹងថា ជួនកាលគាត់ទទួលបានការបញ្ជាទិញធំៗ ហើយគេទូទាត់ថ្លៃទិញក្រោយពេលប្រគល់នំប៉័ងរួច ។ ដូច្នេះដើម្បីបានទុនបង្វិល ជារឿយៗគាត់ត្រូវបង្ខំចិត្តខ្ចីពីធនាគារមួយក្នុងអត្រាការប្រាក់ ២២%/ឆ្នាំ[៥០] ។ បញ្ហាចោទមួយនៃកំចីនេះ គឺចំណាយផលិតកម្មវាកើនឡើង ។ ទំនិញថោកៗផលិតនៅថៃ បានចាប់ផ្ដើមប្រកួតប្រជែងជាមួយផលិតផលរបស់គាត់ ហើយរឿងនេះកាន់តែយ៉ាប់យ៉ឺនថែម ដោយសារការបញ្ចុះតំលៃប្រាក់បាតថៃ និងដុល្លារូនីយកម្មនៃសេដ្ឋកិច្ចកម្ពុជា ។ កសិករដាំបន្លែ មានឥរិយាបថប្រហែលគ្នាដែរ ដោយលើកថា តំរូវការទុនអចល័តគួរបំពេញដោយធនធានផ្ទាល់ខ្លួន ចំណែកឯទុនបង្វិលអាចខ្ចីគេម្ដងម្កាលបាន បើសិនអត្រាការប្រាក់ថោក ។ កសិករនេះក៏ធ្លាប់ខ្ចីទុនពីស្ថាប័នមីក្រូឥណទានដែរ ។ ម្ចាស់ផលិតកម្មទឹកត្រី ពឹងផ្អែកលើប្រាក់សន្សំផ្ទាល់ខ្លួន និងធនធានក្នុងគ្រួសារ (ប្រហែល ៧0%) និងអ្នករកស៊ីចងការប្រាក់ (៣0% ក្នុងអត្រាការប្រាក់ ២៤%/ឆ្នាំ) ដើម្បីកសាង និងពង្រីកអាជីវកម្ម ។ ចំពោះទុនបង្វិល គាត់យកទុនផ្ទៃក្នុងមកដាក់បញ្ចូលប្រើវិញ ។ គាត់បានព្យាយាមខ្ចីពីធនាគារម្ដងដែរ ប៉ុន្តែនីតិវិធី, ការយឺតយ៉ាវ និងកំរៃក្រៅផ្លូវការផ្សេងៗ បានរាំងស្ទះកិច្ចប្រឹងប្រែងរបស់គាត់[៥១] ។ អ្នកផលិតឥដ្ឋបានប្រាប់រឿងប្រហែលគ្នា គឺសាច់ញាតិ និងមិត្តភ័ក្តិ ជាប្រភពតែមួយគត់ដែលអាចទុកចិត្តបាន ។ គាត់បានទទួលការបណ្ដុះបណ្ដាលមួយលើកនៅឯធនាគារមីក្រូឥណទាន ACELEDA ប៉ុន្តែមិនអាចខ្ចីប្រាក់ពី

---

[៥០] ឥរិយាបទបែបនេះចំពោះឥណទាន គឺចាស់គំរិលហើយនៅក្នុងពិភពលោកសព្វថ្ងៃ (ទោះបីក្នុងករណីសិក្សារនេះ វាធ្វើឱ្យចំនាយផលិតកម្មកើនឡើងក៏ដោយ) ។ ឥរិយាបទនេះបង្ហាញថា តំលៃឱកាសត្រូវបាត់បង់ (opportuinity cost) លើធនធានផ្ទាល់ខ្លួន គឺស្មើសូន្យ ។

[៥១] គួរបញ្ជាក់ថា អវត្តមានឯកសារកម្មសិទ្ធិដីធ្លីផ្លូវការ គឺជាឧបសគ្គចំបងចំពោះការទទួលបានកំចីពីធនាគារនៅកម្ពុជា ។ កម្មសិទ្ធិដីធ្លីចាំបាច់បំផុតសំរាប់ធានាកំចី ។

ធនាគារនេះបាន ដោយសារកំរិតកំចីអតិបរមា តិចជាងតំរូវការរបស់គាត់ ។ ម្ចាស់ក្រុមហ៊ុនប្លាស្ទិក បានចូលហ៊ុនជាមួយសាច់ញាតិដើម្បីប្រមូលទុនទិញទ្រព្យសកម្មជាប់លាប់ ។ ចំពោះទុនបង្វិល គាត់យកចំណូលផ្ទៃក្នុងទៅដាក់បញ្ចូលប្រើប្រាស់វិញ ។

ចំណុចដូចខាងក្រោម បានមកពីការពិភាក្សានៅក្នុងជំពូកនេះ :

- ហិរញ្ញវត្ថុស្ថាប័ន សឹងតែគ្មានសោះ ក្នុងអាជីវកម្មនៅកម្ពុជា ។ ទោះបីអាជីវករធំៗក្តី ក៏មិនសូវហ៊ានប្រើហិរញ្ញវត្ថុនេះដែរ ។ ដូច្នេះហើយនៅក្នុងការខំប្រឹងលូតលាស់អាជីវកម្មនានា ក៏មិនបានទទួលកំលាំងគំនាស់ពីហិរញ្ញវត្ថុស្ថាប័ន និងទីផ្សារដែរ ។
- បញ្ហាមិនមែនមានតែការផ្គត់ផ្គង់មិនគ្រប់គ្រាន់នោះទេ ប៉ុន្តែគឺពួកអ្នកត្រូវការឥណទាន ដែលចង់ចៀសវាងការខ្ចីបុល ។ អាកប្បកិរិយាបែបនេះប្រហែលផុសចេញពីអត្រាការប្រាក់ខ្ពស់ (ទាំងអ្នករកស៊ីចងការប្រាក់ និងហិរញ្ញវត្ថុស្ថាប័ន) ព្រមទាំងការលំបាក នៅក្នុងការរកទ្រព្យដាក់ធានាហិរញ្ញវត្ថុស្ថាប័ន ពីព្រោះគ្មានឯកសារកម្មសិទ្ធិដីធ្លី ហើយបទប្បញ្ញត្តិខាងច្បាប់ ក៏មិនទាន់មានគ្រប់គ្រាន់ ។
- ចំពោះផ្នែកផ្គត់ផ្គង់វិញ ទីភ្នាក់ងារហិរញ្ញវត្ថុស្ថាប័នភាគច្រើន គឺតឹងរ៉ឹងណាស់ និងផ្តល់សេវាមានកំណត់ ។ ជារឿយៗគេលើកឡើងថា ប្រព័ន្ធហិរញ្ញវត្ថុស្ថាប័ន និងច្បាប់ពុំមានប្រសិទ្ធិភាព វាជាមូលហេតុដែលបង្កបញ្ហានេះ ។ បញ្ហាផ្គត់ផ្គង់ឥណទានស្ថាប័ន កាន់តែចោទខ្លាំងនៅក្រៅរាជធានី ពីព្រោះនៅទីនោះមានស្ថាប័នហិរញ្ញវត្ថុតិចតួចណាស់ ឬគ្មានសោះ ។

### *៤.៤.៧ យុទ្ធសាស្ត្រ និងបញ្ហាចោទខាងទីផ្សារ*

ប្រជាជននៅក្នុងស្រុកមានអំនាចទិញទាប គួបផ្សំនឹងទីផ្សារដែលចំហយ៉ាងទូលាយចំពោះការប្រកួតប្រជែងពីអន្តរជាតិ គឺជាមូលហេតុធ្វើឱ្យសហគ្រិនក្នុងស្រុក

ជួបការលំបាក[៥២] ។ ការបើកចំហទីផ្សារ ក៏ជាមូលហេតុនាំឱ្យមានកង្វះទំនិញលក់ដូរផលិតនៅកម្ពុជា ពីព្រោះផលិតផលក្នុងស្រុក មិនអាចប្រកួតប្រជែងជាមួយនឹងទំនិញផលិតនៅប្រទេសជិតខាងបាន ។

ដូចបានបញ្ជាក់ពីខាងដើមរួចហើយ ធនាគារដែលបានសិក្សា បានផ្តល់ឥណទានដល់ប្រភេទអាជីកម្មដែលមិនអាចទទួលសេវាពីធនាគារផ្សេង ។ ធនាគារនេះផ្តល់សេវាយ៉ាងមានប្រសិទ្ធិភាព ទោះបីស្ថិតក្នុងចំណោមតែពីរ-បីធនាគារដែលជាកម្មសិទ្ធិអ្នកក្នុងស្រុកក្តី ។ ធនាគារបានបង្កើតសេវាថ្មីៗបំរើដល់សហគ្រាសធុនតូច និងមធ្យមៈ ផ្តល់កំចីរហូតដល់ ៩០% នៃអចលនទ្រព្យរបស់សហគ្រាសទាំងនេះ ព្រមទាំងមានបែបបទបែងចែកគ្នានូវប្រាក់ចំណេញ និងការជួយពិគ្រោះយោបល់ខាងអាជីវកម្ម ។ អ្នកវិភាគជាច្រើននាក់គិតថា ធនាគារនេះអនុវត្តគំលាតការប្រាក់ចេញ-ចូលតូចពេក ដូច្នេះ ត្រូវប្រឈមមុខនឹងហានិភ័យខ្ពស់ ។ ប៉ុន្តែម្ចាស់ធនាគារគិតថា ចំណូលលើមូលធនមានកំរិតខ្ពស់ (ហេតុនេះបានជាកូនបំណុលបង់ការប្រាក់ខ្ពស់នៅក្នុងទីផ្សារចំហ) ដូច្នេះវាជាបច្ច័យល្អក្នុងការអនុវត្តគំលាតការប្រាក់តូច ជាពិសេសកាលណាកំចីមានដាក់វត្ថុធានាគ្រប់គ្រាន់ ។ ធនាគារមានលក្ខណៈទាក់ទាញអតិថិជន ពីព្រោះពិនិត្យសំណើសុំខ្ចីប្រាក់បានរហ័សណាស់ ។ លើសពីនេះទៀត ធនាគារមានផ្តល់សេវាប្រើប្រាស់ប័ណ្ណឥណទាន, ម៉ាស៊ីនបើកប្រាក់ស្វ័យប្រវត្តិ (ATM) និងសេវាផ្សេងៗមួយចំនួនដល់អ្នកផ្ញើប្រាក់ថ្នាក់កណ្តាល ។

សណ្ឋាគារបានបង្កើតចំនែកទីផ្សាររបស់ខ្លួនមួយក្នុងចំនោម NGOs អន្តរជាតិ ទេសចរអន្តរជាតិថ្នាក់កណ្តាល តាមរយៈការសាកសួរស្រង់យោបល់ និងការមានផ្តល់សេវានានាដែលអ្នកដំណើរអន្តរជាតិចូលចិត្ត ជាអាទិ៍ អាហារបែបបស្ចឹមប្រទេស, ទឹក

[៥២] ទំនិញស្ទើរតែទាំងអស់អាចជាកម្មវត្ថុនាំចូល ចំពោះពន្ធនាំចូល ។ ការគេចពន្ធ គឺមិនមែនជារឿងប្លែកទេ បើតាមសេចក្តីរាយការណ៍ពីសារពត៌មាន។

ក្តៅ/ត្រជាក់សំរាប់ងូត, និងព្រមទទួលយកការបង់ប្រាក់ជាប័ណ្ណឥណទាន[៥៣] ។ ទីតាំងយុទ្ធសាស្ត្ររបស់សណ្ឋាគារនៅក្នុងតំបន់ដែលមានការិយាល័យរបស់ NGOs អន្តរជាតិយ៉ាងច្រើន បានជួយជំរុញដំនើរការអាជីវកម្មមួយកំរិតទៀត ។ ប៉ុន្តែម្ចាស់សណ្ឋាគារគិតថា ដំណើរការអាជីវកម្មមិនអាចបានស្រួលដូច្នេះរហូតទេ ពីព្រោះមានដៃគូប្រកួតប្រជែងផុសឡើងដោយមានផ្តល់កញ្ចប់សេវាទាក់ទាញផង ។

យុទ្ធសាស្ត្រម៉ាឃីទីងពីដំបូងរបស់ក្រុមហ៊ុន C-T-P គឺចង់ក្លាយជាអ្នកនាំចេញផ្ទាល់មុខ ដើម្បីឱ្យមានទីផ្សារមួយសំរាប់ខ្លួនផ្ទាល់ ។ យុទ្ធសាស្ត្រនេះបានអនុវត្តតាំងពីសម័យដំបូង គឺមុនពេលបើកចំហទីផ្សារ ហើយដោយបានចូលក្នុងទីផ្សារមុនគេបែបនេះបានផ្តល់អត្ថប្រយោជន៍មួយកំរិតមែន ។ ក្រោយមកនៅពេលចាប់ធ្វើចំរុះកម្មមុខរបរ ក្រុមហ៊ុនបានប្រើប្រាស់វិធីសាស្ត្រមួយចំនួន ដូចជាចងសម្ព័ន្ធជាមួយដៃគូអន្តរជាតិ និងពង្រីកមុខរបរទៅខាងផលិតផល និងសេវាផ្សេងៗ ដែលមិនសូវមានការប្រកួតប្រជែងពីអន្តរជាតិ ។ ប៉ុន្តែទោះបានធ្វើដូច្នេះក្តី ក៏ជោគជ័យមិនបានកើតមានចំពោះគ្រប់សហគ្រាសជាសមាជិករបស់ C-T-P ទេ ។

កសិករចិញ្ចឹមមាន់បានផ្គត់ផ្គង់ដល់ទៅ ៨០% នៃផលិតផលផ្ទាល់ខ្លួន ទៅឱ្យភោជនីយដ្ឋាន សណ្ឋាគារ និងផ្សារទំនើបៗនៅក្នុងក្រុងភ្នំពេញ ។ មូលហេតុមួយដែលផលិតផលគាត់លក់បានថ្លៃជាងគេក្នុងទីផ្សារ គឺស៊ុតមានទំហំធំ ដោយសារការផ្ទេរបច្ចេកវិទ្យាពីបរទេស ។ ប៉ុន្តែទីផ្សារវាជាប់ទាក់ទងនឹងថ្លៃផលិតផល និងមានការប្រកួតប្រជែងយ៉ាងតឹងតែងពីផលិតផលក្នុងស្រុកឯទៀត និងពីផលិតផលនាំចូលថោកៗ ។ ការប្រកួតប្រជែងដោយយុត្តិធម៌មិនជាប្រការមួយដ៏ល្អ ប៉ុន្តែគេទទួលបានរបាយការណ៍ថាមានការលក់បង្ខូចថ្លៃ[៥៤] និងការរត់ពន្ធស៊ុត/ផលិតផលមាន់ផ្សេង

---

[៥៣] កត្តាមួយដែលទាក់ទាញភ្ញៀវ គឺការចៀសវាងភ្ញៀវដែលប្រើប្រាស់កន្លែងស្នាក់នៅ ដើម្បីប្រព្រឹត្តអំពើពេស្យាចារ និងល្បែងស៊ីសងជាដើម ។

[៥៤] ថ្លៃដែលលក់ដោយគ្មានបានចំណេញ ។

ទៀតមកពីវៀតណាម និងថៃ ដែលបានជះឥទ្ធិពលអាក្រក់ ។ ថ្មីៗនេះ រដ្ឋាភិបាលបាន ប្រឹងប្រែងទប់ស្កាត់សកម្មភាពរត់ពន្ធ ប៉ុន្តែ ដោយការអនុវត្តន៍ទន់ខ្សោយនៅតែជា បញ្ហាមួយគួរបារម្ភ ។ ម្យ៉ាងទៀត អ្នកលក់ជុំបានគ្រប់គ្រងថ្លៃផលិតផល ហើយពួកគេ អាចទំលាក់ថ្លៃទិញចូលយ៉ាងទាបបាន ។ នៅពេលថ្លៃស៊ុតចុះទាបពេក (ជួនកាល ទាបជាង ១៧០រៀល/ស៊ុត) វាពិបាករកចំណេញណាស់ ។ គ្រាមួយ គេបានប៉ុនប៉ង បង្កើតសមាគមនីកសិករចិញ្ចឹមមាន់ ដើម្បីទប់ស្កាត់ថ្លៃឱ្យនៅថេរ ប៉ុន្តែដោយសារខ្វះ ចំណេះដឹង និងបទពិសោធន៍ បានរាំងស្ទះដល់គោលបំនងនេះ ។ ដូចគ្នាដែរ សេដ្ឋកិច្ច ដុល្លារូបនីយកម្មនៅកម្ពុជា ធ្វើឱ្យផលិតផលបរទេសមានតំលៃថោកៈ ការធ្លាក់ថ្លៃ ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម បានធ្វើឱ្យទំនិញនាំចូលដែលគិតជាដុល្លារមាន តំលៃកាន់តែថោក ហើយវាបានជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្មនៅកម្ពុជា ។

ទីផ្សារសិប្បកម្មមានភាពឃើតយ៉ាងខ្លាំងទៅតាមគុណភាព គឺថាអតិថិជនមិន ទិញផលិតផលដែលមានគុណភាពអន់ទេ ។ ម្យ៉ាងទៀត មានការប្រកួតប្រជែងមួយ ចំនួនពីថៃ គឺវត្ថុចំលាក់ថ្មចំលងតាមរចនាបថសិល្បៈខ្មែរ ក៏មានផលិតនៅថៃដែរ ព្រម ទាំងមានគុណភាពល្អជាងទៀតផង ។ ដូច្នេះសហគ្រិនដែលយើងសិក្សា មិនស្ថិតនៅ ក្នុងទីផ្សារទេសចរទេ ។ គាត់លក់ផលិតផលឱ្យទៅអ្នកទិញសន្សំក្នុងស្រុក, ប្រជាជន ស្រទាប់ខ្ពស់, និងជនកម្ពុជានៅបរទេស, ព្រមទាំងផលិតលក់តាមការបញ្ជាទិញ ។ ដោយទីតាំងសិប្បកម្មនៅជិតកន្លែងយកថ្ម វាបានជួយឱ្យចំនាយដឹកជញ្ជូនស្ថិតនៅកំរិត មួយសមរម្យ (តែអាចបញ្ចុះបានថែមទៀត) ។ ប៉ុន្តែនៅពេលខាងមុខ គាត់រំពឹងថា ដំនើរការមិនបានងាយស្រួលទៀតទេ ពីព្រោះ ទីផ្សារផលិតផលរបស់គាត់មិនមាំទាំ សោះ ។ *មូលហេតុទីមួយ* គឺគាត់គ្មានគ្រឿងចក្រដើម្បីផលិតឱ្យមានគុណភាព និង តាមស្តង់ដា ។ *មូលហេតុទីពីរ* គឺកម្មកររបស់គាត់មិនជំនាញគ្រប់គ្រាន់ដើម្បីបំពេញ តាមស្តង់ដាគុណភាពអន្តរជាតិ ។ *មូលហេតុទីបី* ការមានទីតាំងនៅក្រៅក្រុងភ្នំពេញ គឺជាការចាញ់ប្រៀបមួយ ពីព្រោះទីផ្សារចំបងៗស្ថិតនៅក្នុងទីក្រុងធំៗ ។ ចំណាយដឹក

ជញ្ជូនខ្ពស់ និងការបង់ប្រាក់ក្រៅផ្លូវការមួយចំនួន បានបង្កើនបន្ទុកចំនាយរបស់គាត់ ។ ម្យ៉ាងវិញទៀត ការងារម៉ាឃីទឹងមានថ្លៃខ្ពស់ និងទាមទារបទពិសោធន៍ ហើយគាត់មានការខ្វះខាតលើចំណុចទាំងពីរនេះ ។

ម្ចាស់ហាងនំប៉័ងបាននិយាយថា ចំពោះសេដ្ឋកិច្ចដែលទើបកកើតឡើងដូចនៅកម្ពុជា គឺបានប៉ះទង្គិចច្រើនពេកហើយ ដូចជា ការរំជើបរំជួលខាងនយោបាយនៅឆ្នាំ១៩៩៧ វិបត្តិហិរញ្ញវត្ថុក្នុងតំបន់ ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ទាំងអស់នេះហើយបានប៉ះពាល់ដល់តំរូវការនំប៉័ង ។ ចំនូលលក់របស់គាត់ចុះ-ឡើងពី ៣០-៥០% ដោយសារការប៉ះទង្គិចនានា ។ អតិថិជនរបស់គាត់ជាច្រើនគឺ ខ្មែរនៅក្រៅប្រទេសដែលមកលេងស្រុកខ្មែរមិនញឹកញាប់ទេ ដោយសារតែការប៉ះទង្គិចនេះ ។ ម្ចាស់ហាងនំប៉័ងបានបញ្ជាក់ពីហេតុផលដូចគ្នានឹងកសិករចិញ្ចឹមមាន់ដែរ ពោលគឺការរត់ពន្ធផលិតផលថោកៗពីក្រៅប្រទេស បានកាត់យកទីផ្សាររបស់គាត់អស់មួយចំនួន ។ ក្នុងបរិបទដូចគ្នានេះ ម្ចាស់ហាងនំប៉័ងបានលើកថា សេដ្ឋកិច្ចកម្ពុជាមានបន្ទុកចំណាយខ្ពស់ ដោយសារថ្លៃអគ្គិសនីខ្ពស់ ដឹកជញ្ជូនខ្ពស់ និងការបង់ប្រាក់ក្រៅផ្លូវការ ។ កត្តាទាំងនេះបានបង្កើនតំលៃផលិតផល និងកាត់បន្ថយភាពប្រកួតប្រជែង ។ បញ្ហាទាក់ទងនឹងទីផ្សារមួយទៀត គឺការយឺតយ៉ាវ និងការមិនព្រមសងប្រាក់ពីសំណាក់ម៉ូយជាច្រើន ដែលនាំឱ្យមានការបង់ខាតគួរឱ្យកត់សំគាល់ ។

កសិករដាំបន្លែពាណិជ្ជកម្ម លក់កសិផលរបស់គាត់តាមរយៈម៉ូយ និងការលក់ផ្ទាល់ទៅទីផ្សារ ។ នៅរដូវប្រាំង គាត់ប្រឈមមុខនឹងការឡើងចុះថ្លៃ ។ ដើម្បីទប់ទល់បញ្ហានេះ គាត់ធ្វើជ្រក់ និង/ឬសំងួតបន្លែ (តាមរយៈបច្ចេកទេសកែច្នៃក្នុងស្រុក) ទុកសំរាប់លក់នៅពេលក្រោយ ។ គាត់បញ្ជាក់ថា ការរក្សាចំណងទាក់ទងល្អជាមួយម៉ូយ និងម៉ូតូឌុប មានសារៈសំខាន់ខ្លាំងណាស់សំរាប់ម៉ាឃីទីងកសិផលរបស់គាត់ ។ គាត់ត្អូញត្អែរថា គាត់ត្រូវបង់ប្រាក់ក្រៅផ្លូវការ ដើម្បីឱ្យទំនិញរបស់គាត់ចូលទីផ្សារបាន ។ ផលិតករទឹកត្រីមើលឃើញថា ភោជនីយដ្ឋាននៅភ្នំពេញ និងនៅបីខេត្តទៀតយ៉ាង

តិច គឺជាទីផ្សាររបស់គាត់ ។ ការកំណត់គោលដៅផលិតផលបំរើភោជនីយដ្ឋានខ្មែរថ្នាក់កណ្តាល និងកំណត់ថ្លៃឱ្យប្រកួតប្រជែង គឺជាកត្តាគន្លឹះ សំរាប់ជោគជ័យខាងម៉ាឃីទីង ។ គាត់យល់ច្បាស់ថា បើចង់លូតលាស់ និងធ្វើចំរុះកម្មមុខរបរលើសពីសព្វថ្ងៃ គាត់ត្រូវតំរង់យកទីផ្សារធូធារជាងនេះ (ភោជនីយដ្ឋានធំៗ សណ្ឋាគារធំៗ អតិថិជនអន្តរជាតិ...) ដែលមានទំនិញនាំចូលជាច្រើនកំពុងប្រជែងគ្នាជាស្រេច ហើយគាត់អាចនឹងដណ្តើមទីផ្សារមិនបាន ។ ឯការផ្សាយពាណិជ្ជកម្ម គឺមិនធ្វើមិនកើតទេ ពីព្រោះមានបន្ទុកចំណាយខ្ពស់ និងផលប៉ះពាល់មិនច្បាស់លាស់ ។

ម្ចាស់អាជីវកម្មឥដ្ឋ បានបែងចែកទីផ្សាររបស់គាត់តាមលំដាប់ទំហំ: សាលារៀន ឃ្លាំង និងអ្នកលក់រាយតូចៗ ។ គាត់ចង់ទាក់ទងពួកគេដាច់ៗពីគ្នា ។ នៅពេលក្រោយៗនេះ មានផលិតករក្នុងស្រុកជាច្រើនមកប្រជ្រៀតចូលទីផ្សារ និងបានប៉ះពាល់ដល់ការលក់ដូររបស់គាត់មួយក៏រិត ។ ក្នុងរបរនេះ ការមានទីតាំងនៅក្រៅក្រុងភ្នំពេញ និងការមិនអាចបំរើទីផ្សារមានចំណេញច្រើនបែបនេះ វាជាការខាតបង់មួយយ៉ាងធំ ។ម្យ៉ាងទៀត ថ្វីបើគាត់មានលទ្ធភាពលក់ផលិតផលនៅកម្ពុជា (៣ខេត្ត) ក្តី ក៏ការប្រឹងប្រែងនាំចេញឥដ្ឋទៅថៃមិនបានសំរេចទេ ទោះបីមានប្រៀបខាងថ្លៃដល់ទៅមួយទល់នឹងបីក៏ដោយ ពីព្រោះមានរបាំងខាងពាណិជ្ជកម្ម និងគុណភាព បង្កើតឡើងដោយភាគីថៃ ជាឧបសគ្គរាំងស្ទះ ។ បន្ថែមលើបញ្ហានេះ គឺការមិនសងប្រាក់ និងការទូទាត់យឺតយ៉ាវពីសំណាក់អ្នកទិញ ។

អ្នកផលិតគ្រឿងប្លាស្ទិក លើកពីចំណុចជាច្រើនដូចខាងលើដែរ ដូចជាការប៉ះទង្គិចសេដ្ឋកិច្ចម្តងហើយម្តងទៀត, ការបញ្ចុះថ្លៃរូបិយវត្ថុនៃប្រទេសជិតខាង, ការរត់ពន្ធគ្រឿងប្លាស្ទិកថោកៗឆ្លងកាត់ព្រំដែន ដែលមានចន្លោះប្រហោងជាច្រើន និងបន្ទុកចំណាយខ្ពស់ (ពិសេសចរន្តអគ្គីសនី) ដែលសឹងតែបានសំលាប់ឧស្សាហកម្មប្លាស្ទិកដ៏ក្មេងខ្ចីនេះហើយ ។ ម្យ៉ាងទៀត ផលិតករធុនតូចមានផលិតផលគុណភាពអន់ បាន

ក្លែងបន្លំផ្លាកសញ្ញារបស់ក្រុមហ៊ុនល្បីឈ្មោះ (ដូចជាក្រុមហ៊ុនគាត់) ដើម្បីបានចំណែកទីផ្សារសំរាប់ខ្លួនគេ ហើយទង្វើនេះបានប៉ះពាល់កាន់តែខ្លាំងដល់ផលិតករពិតប្រាកដ ។

ចំណុចសំខាន់ៗនៅក្នុងការពិភាក្សាខាងលើ មានដូចតទៅ:

- អ្នកខ្លះដែលមានវត្តមាននៅក្នុងទីផ្សារ ឬមានផ្លាកសញ្ញារបស់ខ្លួនតាំងពីដំណាក់កាលដំបូង គឺអាចរក្សាស្ថានភាពនេះបានរហូតមកដល់សព្វថ្ងៃ ។
- កត្តាម៉ាក្រូសេដ្ឋកិច្ចដូចជា ដុល្លារូបនីយកម្ម និងការប៉ះទង្គិចពីក្រៅ ជាទូទៅតែងធ្វើឱ្យខូចខាតដល់ឧស្សាហកម្មក្មេងខ្ចីនៅកម្ពុជា ជាពិសេសបើសិនត្រូវប្រឈមមុខនឹងទំនិញនាំចូលថោកៗ ។
- បច្ចេកវិទ្យាចាស់ហួសសម័យ/សាមញ្ញហួសពេក, កម្មករបណ្តុះបណ្តាលអន់ និងបន្ទុកចំនាយខ្ពស់, និងហេដ្ឋារចនាសម្ព័ន្ធមានផលិតភាពទាប បានរុញច្រានឧស្សាហកម្មកម្ពុជា ឱ្យស្ថិតក្នុងសភាពមិនសូវអភិវឌ្ឍន៍ ។
- ទីផ្សារបើកចំហខ្លាំង និងអវត្តមាននៃយុទ្ធសាស្រ្តពង្រឹងការផ្គត់ផ្គង់ មិនអនុញ្ញាតឱ្យសហគ្រិនក្នុងស្រុករីកចំរើនលឿននៅក្នុងទីផ្សារនៃទំនិញ សំរាប់លក់ដូរទេ ។
- កង្វះអភិបាលកិច្ចដ៏សក្តិសិទ្ធិ វាជាកត្តារាំងស្ទះ ។ ឧទាហរណ៍ ព្រំប្រទល់បិទមិនជិត បានធ្វើឱ្យមានការរត់ពន្ធជាទូទៅ, ការបង់ប្រាក់កំរៃក្រៅផ្លូវការច្រើន និងកង្វះលទ្ធភាពក្នុងការផ្តល់ ឬទទួលឥណទាន ។

### *៤.៤.៨ សហគ្រិនភាព*

នៅក្នុងឯកសារគោលនយោបាយ និងការពិភាក្សានានា គេតែងលើកជារឿយៗថា ភាពក្រីក្រ និងកង្វះការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា កើតចេញពីហេដ្ឋារចនាសម្ព័ន្ធយ៉ាប់យ៉ឺន ប្រព័ន្ធអភិបាលកិច្ចមិនសមស្រប និងធនធានមនុស្សគុណភាពទាប ។ ប៉ុន្តែ តើពាណិជ្ជកម្មមួយចំនួនធ្វើយ៉ាងណា ដើម្បីអាចរីកចំរើនខ្លាំងបានក្នុងរយៈពេលខ្លីប្រហែលតែមួយទសវត្សរ៍? តើពួកនេះខុសប្លែកពីគេត្រង់ណា? ថ្វីបើមួយ

ភាគធំនៃរឿងរកទ្រព្យធនបានឬមិនបាន បានលើកមកពិភាក្សារួចហើយក្តី ប៉ុន្តែនៅសល់បញ្ហាសហគ្រិនភាព ដែលមានធ្វើសំយោគដូចខាងក្រោម ។

មិនចាំបាច់បញ្ជាក់អ្វីច្រើនទេថា នៅដើមទសវត្សរ៍១៩៩០ កម្ពុជាសឹងតែនៅទទេស្អាតចំពោះវិស័យអាជីវកម្មជាច្រើនប្រភេទ ។ ទោះជាដូច្នេះក្តី ក៏មិនមែនគ្រប់អាជីវកម្ម សុទ្ធតែអាចរស់រានបាននោះទេ (មានបរាជ័យច្រើនណាស់) ប៉ុន្តែមួយចំនួនអាចដណ្តើមកន្លែងឈរជើងបានពិតមែន ។ អ្នកចាប់ដំណើរការអាជីវកម្មមុនគេកសាងបាននូវស្ថានភាពសឹងតែផ្តាច់មុខ (near-monopoly) ឬក៏កាន់កាប់បានកន្លែងសំខាន់ៗ សំរាប់ធ្វើអាជីវកម្មរបស់ខ្លួន ហើយថែមទាំងបានបោះជំហានទៅមុខយ៉ាងធំៗទៀតផង ។ ពេលពួកគេផ្សងនឹងហានិភ័យដោយបានថ្លឹងថ្លែងច្បាស់លាស់ និងបានអនុវត្តចំពេល ហើយព្រមទាំងប្រមូលយកផលបានជាបន្តបន្ទាប់ ។ អាជីវករខ្លះបានសំរេចចិត្តបង្កើនមុខអាជីវកម្ម ខ្លះចូលរកស៊ីក្នុងវិស័យថ្មីៗ រីឯខ្លះទៀតពង្រីកអាជីវកម្មក្នុងសកម្មភាពដែលខ្លួនធ្លាប់មានស្រាប់ ។ បើមានភាពវៃឆ្លាតកាន់តែខ្លាំងក្នុងការរកស៊ី (ទាំងការរើសផលិតផលនិងទីផ្សារ) អាជីវកម្មក៏រីកកាន់តែលឿន ។

ការបង្កើត និងរក្សាចំណងសម្ព័ន្ធភាពជាយុទ្ធសាស្រ្តបានផ្តល់ផលល្អពិតមែន ។ នៅក្នុងករណីសិក្សានានាដូចបានពិភាក្សាកន្លងមក គឺមានចំណងទាក់ទងតាមបណ្តាញសាច់ញាតិ, សម្ព័ន្ធភាពអាជីវកម្មជាមួយក្រុមហ៊ុនអន្តរជាតិ, និងចំណងទាក់ទងជាមួយបុគ្គលមានឥទ្ធិពល, ដែលបានជួយបំរើគោលដៅអាជីវកម្ម។ នៅក្នុងគំនិតបែបក្លាស៊ិក គេអាចចង់ចៀសវាងមិនរាប់បញ្ចូលនូវរបៀបធ្វើអាជីវកម្មដូច្នេះ ដោយសារហេតុផលខាងសីលធម៌ និងសមភាព ប៉ុន្តែនៅទសវត្សរ៍១៩៨០ និង ១៩៩០ កម្ពុជាមិនមែនជាទីផ្សារក្លាស៊ិកដែលគេអាចធ្វើអាជីវកម្មដោយស្មើភាពនោះទេ ។ កម្ពុជាបានផុសចេញពីផេះផង់ គឺត្រូវកសាងច្បាប់ និងវិធាននានា, បង្កើតប្រព័ន្ធអាជីវកម្ម, កសាងសមត្ថភាព, ដាក់អនុវត្តនូវដំណើរការអភិបាលកិច្ច, និងកសាងទំនុកចិត្តរបស់

ប្រជាជន ។ វាជារឿងធម្មតាទេដែលអាជីវករមួយចំនួនបានជ្រើសយកផ្លូវដើរដែលមានការស្វែងរកការគាំពារយោគយល់ពីសំណាក់អ្នកមានអំណាច[៥៥] ។

អ្នកអាចពុះពារតាំងពីឆ្នាំដំបូង១បាន គឺជាអ្នកដែលខំតស៊ូព្យាយាមធ្វើឱ្យសំរេចនូវចក្ខុវិស័យរបស់ខ្លួន ។ ពួកគេមានគំនិតច្បាស់លាស់ពីគោលដៅរបស់ខ្លួន និងបានប្រឹងប្រែងជាខ្លាំងដើម្បីធ្វើឱ្យសំរេច ។ ពួកគេឈប់ទ្រឹងម្តង១នៅពេលមួយសមគួរដើម្បីវាយតំលៃពីការលូតលាស់ និងធ្វើការកែតំរូវនៅពាក់កណ្តាលទី និង/ឬផ្លាស់ប្តូរទិសដៅ ។ បទសម្ភាសន៍លំអិតបានផ្តល់គំនិតថា សហគ្រិនទាំងនោះប្រឹងប្រែងធ្វើការខ្លាំងណាស់ គឺ ៧ថ្ងៃ/សប្តាហ៍ ហើយជាញឹកញយពេញ១មួយឆ្នាំតែម្តង ។ គេប្រើប្រាស់សមាជិកគ្រួសារ និងសាច់ញាតិ ឱ្យធ្វើការច្រើនម៉ោងណាស់ក្នុងមួយសប្តាហ៍១ និងគ្មានសប្តាហ៍ណាឈប់សំរាកទេ ។ ប៉ុន្តែការងារខ្លាំងបានហុចលទ្ធផលល្អមែន ។ វិធីសាស្ត្រនេះបានកាត់បន្ថយបន្ទុកចំណាយ និងជួយឱ្យពួកគេរក្សាសមត្ថភាពប្រកួតប្រជែង ។ សហគ្រិនជាច្រើនមានកូនចៅទៅរៀនសាលាពាណិជ្ជសាស្ត្រ ដូច្នេះជំនាន់ក្រោយនឹងអាចធ្វើពាណិជ្ជកម្មតាមរបៀបទំនើបបាន ។

សំនួរដែលផុសឡើងជារឿយ១គឺ ហេតុអ្វីបានជាសហគ្រិនខ្លះចាប់យកឱកាសពីដំបូងដៃ ឯខ្លះទៀតរង់ចាំរហូតដល់មានឱកាលល្អ ឬកាលៈទេសៈងាយស្រួល? សំរាប់សំនួរនេះ គ្មានចម្លើយតែមួយនោះទេ ប៉ុន្តែគេអាចសន្និដ្ឋានបានខ្លះ១ ថ្វីបើមានទិន្នន័យបញ្ជាក់មិនសព្វគ្រប់ក្តី ។ ករណីសិក្សាបានផ្តល់គំនិតថា មានអាជីវករពីរប្រភេទយ៉ាងតិច ។ *ប្រភេទទីមួយ* គឺ "ពួកសហគ្រិនដែលហ៊ានប្រថុយនឹងហានិភ័យដោយបាន

---

[៥៥] ការអនុវត្តរបៀបនេះ មាននៅគ្រប់កន្លែងក្នុងពិភពលោកនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍ ។ ដោយឡែក សូម្បីតែរដ្ឋាភិបាលអាមេរិក ក៏មានផ្តល់ជំនួយហិរញ្ញវត្ថុដើម្បីសង្គ្រោះក្រុមហ៊ុន Chrysler Motor ក្នុងឆ្នាំ១៩៧0 នៅពេលក្រុមហ៊ុនជួបវិបត្តិហិរញ្ញវត្ថុ (Iacocca and Novak 1986) ។ ប៉ុន្តែ គេមិនបានប្រឹងប្រែងរកឱ្យឃើញនូវគុណប្រយោជន៍នៃការអនុវត្តន៍របៀបនេះទេ ។

មើលឃើញវែងឆ្ងាយ" ។ ពួកគេមានជំរើសផ្សេងទៀត ភាគច្រើននៅក្រៅប្រទេសកម្ពុជា ប៉ុន្តែគេមើលឃើញពីការប្រែប្រួលល្អទៅអនាគត ហើយហ៊ានប្រថុយបណ្តាក់ទុន ដើម្បីក្លាយជាអ្នកដើរមុនគេ ។ *ប្រភេទទីពីរ* "អ្នកគ្មានជំរើសផ្សេងតែបានរួចរស់ជីវិត" ដែលបានដំណើរការអាជីវកម្មរបស់ខ្លួននេះ ពីព្រោះគ្មានជំរើសអ្វីផ្សេងច្រើន ។ ក្នុងករណីទាំងពីរ ការប៉ិនប្រសព្វរបស់ពួកគេបានហុចផលល្អ ។ មានអ្នកឆ្លើយសម្ភាន៍ម្នាក់យ៉ាងតិចបានលើកពីស្មារតីជាតិនិយម និងទំនុកចិត្តចំពោះអនាគតប្រទេសជាតិៈ បើសិនគ្មានគំនិតបែបនេះទេ ការអភិវឌ្ឍន៍គឺមិនងាយស្រួលឡើយ[៥៦] ។ ម្ចាស់អាជីវកម្ម ភាគច្រើនបានបង្ហាញទឹកចិត្តថា ខ្លួនមានជំនឿចំពោះ "អនាគតសង្គម" និងមានអារម្មណ៍ថា ខ្លួនមានតួនាទីត្រូវធ្វើការងារដើម្បីកែលំអវាឡើង ។ ម្ចាស់ធនាគារបានបន្ថែមថា ការផ្តល់កំចីទាំងអស់មិនមែនសុទ្ធដើម្បីបានចំណេញនោះទេ គឺមានមួយចំនួនសំរាប់ផលប្រយោជន៍សង្គមធំទូលាយ ។ ម្ចាស់ក្រុមហ៊ុន C-T-P បញ្ចេញយោបល់ប្រហាក់ប្រហែលគ្នាថា សកម្មភាពទាំងអស់មិនមែនសុទ្ធសំរាប់បានចំណេញទេ គឺមានការងារមួយចំនួនបានធ្វើឡើងតាមការពេញចិត្តរបស់បុគ្គល និងដើម្បីផលប្រយោជន៍ជាតិ ។ ពិតហើយ សំរាប់សំនួរខាងលើគ្មានចម្លើយត្រឹមត្រូវតែមួយទេ ប៉ុន្តែគេអាចនិយាយថា ការហ៊ានប្រថុយនឹងហានិភ័យ និងការប្តេជ្ញាចិត្តតែងផ្តល់ផលល្អ ។

ក្រៅពីកត្តានានាដូចខាងលើ នៅមានកត្តាជាច្រើនទៀតដែលនាំឱ្យមានជោគជ័យ ដូច្នេះត្រូវតែបំផុសវាឡើង និងស្វែងរកវិធីដាក់បញ្ចូលវាទៅក្នុងក្របខ័ណ្ឌច្បាប់នៅក្នុងដំណើរការកែទំរង់សេដ្ឋកិច្ច ។ ខ្លឹមសារសង្ខេបមានដូចតទៅៈ

---

[៥៦] ចំណុចនេះហាក់ដូចប្រទាំងប្រទើសបន្តិច ប៉ុន្តែគំនិតជាតិនិយមក៏ឃើញថាមានសារៈសំខាន់នៅតំបន់ឯទៀតៗនៃពិភពលោកដែរ ។ មានពេលមួយ នៅខាងក្រៅហាង Marks and Spencer នៅអង់គ្លេស គេបានដាក់ផ្ទាំងផ្សាយពាណិជ្ជកម្មសរសេរធំៗថាៈ ទិញទំនិញអង់គ្លេស គឺផ្តល់ការងារច្រើនទៀតឱ្យប្រជាជនអង់គ្លេស ។ ដូចគ្នាដែរ ពួកអាល្លឺម៉ង់ទិញតែទំនិញអាល្លឺម៉ង់, ជប៉ុនចូលចិត្តទំនិញជប៉ុន, កូរ៉េបើករថយន្តផលិតនៅកូរ៉េ... ។

- សហគ្រិនភាព ផុសឡើងក្នុងរូបភាពជាការហ៊ានប្រថុយនឹងហានិភ័យនៅចំពេលល្អ និងការប្រើគ្រប់វិធីសាស្ត្រ/មធ្យោបាយដែលមាន ដើម្បីជំរុញអាជីវកម្មៈ ការងារចាប់ផ្តើមពីការប្រយុទ្ធតស៊ូដើម្បីរស់ ដែលប្រែក្លាយទៅជាជ័យជំនះ នៅពេលមានស្ថិរភាព និងកាលៈទេសៈល្អប្រសើរឡើង ។
- ការងារខ្លាំង និងការប្តេជ្ញាចិត្ត តែងផ្តល់ផលល្អ ។
- សហគ្រិនម្នាក់ៗតែងតែមានជំនឿចិត្តក្នុងកំរិតណាមួយថា កម្ពុជានឹងមានស្ថិរភាព និងសន្តិភាព ហើយជំនឿនេះវាជួយពួកគេឱ្យហ៊ានសំរេចចិត្តយ៉ាងរឹងប៉ឹង និងហ៊ានប្រថុយនឹងហានិភ័យ ។

### *៤.៤.៩ ផែនការសហគ្រាសទៅអនាគត*

សហគ្រាសភាគច្រើន មានផែនការបោះទីតាំងឱ្យរឹងមាំ និងពង្រីកអាជីវកម្មនៅកម្ពុជា ទោះបីមួយចំនួនតូចបានជួប ឬកំពុងជួបបញ្ហាក៏ដោយ ។ ជំហរសុទិដ្ឋិនិយមនេះ គឺជាប្រភពនៃសេចក្តីសង្ឃឹមសំរាប់ការអភិវឌ្ឍនៃវិស័យឯកជន ។

ធនាគារមានផែនការជំរុញមូលធនចូលហ៊ុនគ្នា ដោយម្ចាស់សណ្ឋាគារយល់ថាប្រជាជនកម្ពុជាមានគំនិតរកស៊ី ប៉ុន្តែមិនអាចធ្វើទៅកើត ដោយសារខ្វះខាតធនធានហិរញ្ញវត្ថុ ។ ធានាគារបានចាត់វិធានការខ្លះហើយក្នុងទិសដៅនេះ ។ ធនាគារបានចាប់ផ្តើមកសាងសេវាជារូបិយវត្ថុអឺរ៉ូ ហើយសង្ឃឹមថាក្នុងពេលដ៏ខ្លីខាងមុខ ធនាគារធ្វើប្រតិបត្តិការជាអឺរ៉ូ និងមានបញ្ចេញមូលប្បទានប័ត្រ និងមូលប្បទានប័ត្រទេសចរណ៍ (travelers cheque) ជាអឺរ៉ូ ។ ចំពោះការពង្រីកសេវាក្នុងស្រុក វិស័យមួយដែលត្រូវជំរុញនៅកម្ពុជា គឺកំចីមានទ្រព្យបញ្ចាំជាលំនៅដ្ឋាន ឬអគារពាណិជ្ជកម្ម ជាពិសេសសំរាប់ប្រជាជនថ្នាក់កណ្តាល ។ ធនាគារមានគោលបំនងស្រាវជ្រាវពីវិស័យនេះ ។

សណ្ឋាគារមានផែនការតំលើងគ្រឿងអេឡិចត្រូនិច ព្រោះចង់ផ្គត់ផ្គង់សេវាផ្តល់តំលៃបន្ថែម ដូចជាលទ្ធភាពប្រើអ៊ិនធឺណិតនៅតាមបន្ទប់ថ្នាក់ប្រណិតជាដើម ។ ក្រុមហ៊ុន C-T-P មានបំណងពង្រីក និងធ្វើសមាហរណកម្មបញ្ឈរសកម្មភាពដាំដុះ

ជាមួយនឹងការកែច្នៃកសិផល និងធ្វើកិច្ចសន្យាដាំដុះជាមួយកសិដ្ឋានតូចៗ ដើម្បីពង្រីកសមត្ថភាពរោងចក្រកែច្នៃរបស់ក្រុមហ៊ុន ។ ការពង្រីងអាជីវកម្ម ដែលរកស៊ីខាត (loss-making business) គឺជាបញ្ហាអាទិភាព ។ វិនិយោគខ្លះរបស់ C-T-P ស្ថិតនៅក្នុងវិស័យដែលអាចហុចផលតែក្នុងរយៈពេលដ៏យូរខាងមុខ ប៉ុន្តែដោយសារនេះជាក្រុមហ៊ុនតែមួយដែលបណ្តាក់ទុនក្នុងសកម្មភាពរយៈពេលវែង ដូច្នេះគេរំពឹងថាទៅអនាគតក្រុមហ៊ុននឹងក្លាយជាអ្នកផ្គត់ផ្គង់តែមួយគត់សំរាប់មុខផលិតផលទាំងនេះ ។

កសិករចិញ្ចឹមមាន់ មិនបានលើកពីគោលបំណងពង្រីកជាក់លាក់ទេ ប៉ុន្តែបានប្រាប់ថា គាត់ចង់ធ្វើយ៉ាងណាឱ្យមានការរកស៊ីស្មើភាពគ្នាក្នុងមុខអាជីវកម្មនេះ ។ ឯក្រុមហ៊ុនប្លាស្ទិកក៏មានទស្សនៈប្រហែលគ្នាដែរ ។ សិប្បកម្មផលិតវត្ថុសិល្បៈមានផែនការពង្រីកទៅតាមខេត្តមួយចំនួនទៀត ជាពិសេសខេត្តសៀមរាប ដែលមានទេសចរច្រើន ។ ម្ចាស់សិប្បកម្មសង្ឃឹមថា នឹងអាចកសាងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរខេត្ត ដើម្បីជំរុញអាជីវកម្មនេះ ។ ម្ចាស់ហាងនំប៉ុងមានផែនការនាំចេញទៅចិន អូស្ត្រាលី ជប៉ុន និងអាមេរិក ពីព្រោះនៅទីនោះមានអ្នកចូលចិត្តរសជាតិនំខ្មែរ និងមានតំរូវការផលិតផលគាត់ ។ គាត់ក៏ចង់ឱ្យអាជីវកម្មគ្រប់គ្រងតាមបែបគ្រួសាររបស់គាត់មានលក្ខណៈវិជ្ជាជីវៈជាក់លាក់ល្អដែរ ដោយគាត់បានបញ្ជូនកូនឱ្យទៅរៀនសាលាពាណិជ្ជសាស្ត្រដើម្បីសំរេចគោលដៅនេះ ។ កសិករដាំបន្លែពាណិជ្ជកម្មបានបញ្ជាក់ថា គាត់មានផែនការបង្កើនមុខដំណាំ និងដំណើរការដាំផ្សិត ។ ផលិតករទឹកត្រីមានផែនការពង្រីកអាជីវកម្មសំរាប់បំរើប្រភេទទីផ្សារដូចសព្វថ្ងៃ ទៅតាមខេត្តមួយចំនួនទៀត ។ អាជីវករផលិតឥដ្ឋមានបំណងកែលំអបច្ចេកវិទ្យា ដើម្បីអាចជ្រៀតចូលទីផ្សារថៃ ។

សរុបមក ការបកស្រាយនៅខាងលើ មានខ្លឹមសារសង្ខេបដូចតទៅ:

- អាជីវកម្មភាគច្រើនមានផែនការពង្រីក និងលូតលាស់ថែមទៀត គឺគ្មានទស្សនៈទុទិដ្ឋិនិយមចំពោះអនាគតកាលឡើយ ។

- អាជីវកម្មខ្លះ មានផែនការពង្រីកទៅក្នុងវិស័យដែលជាប់ទាក់ទិន ឯខ្លះទៀតចង់កែតំរូវចំណុចខ្សោយសព្វថ្ងៃរបស់ខ្លួន ។
- អាជីវកម្មធំៗមានផែនការជាក់លាក់ ដើម្បីចូលទៅក្នុងទីផ្សារថ្មីៗទៀតដែលទាក់ទិនគ្នា ចំនែកឯអាជីវកម្មតូចៗមាននិន្នាការពង្រីកទទឹងៈ *ពោលគឺធ្វើសកម្មភាពដដែល ប៉ុន្តែកាន់តែច្រើននៅតាមកន្លែងផ្សេងទៀត* ។ ជំហរបែបនេះ វាឆ្លុះបញ្ចាំងពីគំនិតប្រាកដនិយម និងការអនុវត្តន៍ជាក់ស្តែងក្នុងក៏រិតណាមួយ ។

## ៤.៥ បញ្ហាសំខាន់ៗ និងអនុសាសន៍ខាងគោលនយោបាយ

បញ្ហាចំបងៗដែលលេចចេញពីការវិភាគកន្លងមកបង្ហាញថា នៅកម្ពុជាមិនខ្វះសហគ្រិនភាពទេ ។ ក្នុងគំរូតាងនេះ អាជីវករគឺជាមនុស្សប្រឹងប្រែងធ្វើការ ចេះសន្សំសំចៃ ប៉ិនប្រសព្វ ចិត្តលុះ និងមានការប្តេជ្ញាចិត្តដើម្បីជោគជ័យ ។ កម្ពុជាមានឧត្តមភាពមួយដោយបានចូលជាសមាជិកភាពនៃ ASEAN និងមានជនកម្ពុជាយ៉ាងច្រើនប្រកបដោយជំនាញខ្ពស់ដែលនៅឯក្រៅប្រទេស ហើយត្រៀមត្រឡប់មកជួយកសាងប្រទេសជាតិវិញ ។

ការស្រាវជ្រាវនេះមានទំហំតូច មិនអាចផ្តល់អនុសាសន៍ច្រើនទេ ។ ការពិតការសិក្សាថ្មីៗធ្វើដោយក្រសួងពាណិជ្ជកម្ម បានពិនិត្យបញ្ហាជាច្រើនដែលទាក់ទិននឹងពាណិជ្ជកម្មអំណោយផលដល់អ្នកក្រីក្រ (pro-poor trade) ដោយមានការពិភាក្សាពីទិដ្ឋភាពមួយចំនួនទាក់ទងនឹងលទ្ធផលប្រតិបត្តិការម៉ាក្រូសេដ្ឋកិច្ច (ប្រតិបត្តិការថវិកា និងឥណទាន) ការជួយសំរួលពាណិជ្ជកម្ម, ដឹកជញ្ជូន និងកំណើនក្នុងវិស័យប្រាំមួយ ។ ឯកសារនេះបានផ្តោតលើទិដ្ឋភាពផ្សេងៗដែលផុសឡើងក្នុងករណីសិក្សាខាងលើ ។ ប៉ុន្តែជាដំបូងគួរបញ្ជាក់ឡើងវិញពីការព្រួយបារម្ភទាំង ៧ចំណុច ។

### ៤.៥. ១ ការព្រួយបារម្ភ

១. អាជីវកម្មមានដំណើរការនៅតាមសកម្មភាពនានា មានតិចមុខពេក (ទាំងក្នុងវិស័យបឋម និងវិស័យសេវាកម្ម) ហើយប្រមូលផ្តុំភាគច្រើននៅក្នុងចំនែកទីផ្សារនៃទំនិញមិនអាចលក់ដូរបាន ។ អាជីវកម្មនានាមិនបានក្លាយជាអតិថិជនឱ្យគ្នាទៅវិញទៅមកទេ ហើយក៏មិនបានជួយទប់ទល់ឱ្យបន្ទុកចំនាយនៅទាបដែរ ។ ជាលទ្ធផល តំលៃបន្ថែមមានកំរិតទាប និងមិនបានរក្សាទុកនៅក្នុងប្រទេសទេ ។

២. ប្រភេទបច្ចេកវិទ្យាបង្កប់ក្នុងគ្រឿងចក្រ និងរោងចក្រនានា មានលក្ខណៈអន់ថយដែលធ្វើឱ្យផលិតភាពទាប និងកំលាំងប្រកួតប្រជែងនៅខ្វះខាត ។

៣. លទ្ធភាពប្រើប្រាស់ឥណទានសឹងតែគ្មានសោះ និងចំនាយខ្ពស់លើកំចី ធ្វើឱ្យអាជីវកម្មភាគច្រើនគ្មានប្រសិទ្ធិភាពខាងបន្ទុកចំណាយ ។

៤. បន្ទុកចំនាយខ្ពស់ កើតពីភាពយ៉ាប់យ៉ឺននៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាទាក់ទិន ធ្វើឱ្យផលិតករក្នុងស្រុកមិនសូវមានលក្ខណៈប្រកួតប្រជែង ។

៥. ដោយទីផ្សារសឹងតែបើកចំហទាំងស្រុង ផលិតករក្នុងស្រុកត្រូវចាញ់ប្រៀបគេរហូត ។ ក្នុងច្បាប់មានពន្ធនាំចេញ-នាំចូល ប៉ុន្តែការដាក់អនុវត្តន៍មិនបានពេញលេញទេ ។

៦. ចំណាយក្រៅផ្លូវការ បានបង្កើនចំណាយដំណើរការអាជីវកម្ម ។

៧. តាមចំណុចខាងលើ សេដ្ឋកិច្ចបើកចំហត្រូវជួបការប៉ះទង្គិច ហានិភ័យច្រើនពេកដែលបានប៉ះពាល់ដល់សេដ្ឋកិច្ចផ្ទៃក្នុងរបស់ក្រុមហ៊ុនក្នុងស្រុក ។

គេមើលឃើញច្បាស់ថា ចំណុចខាងលើនេះជាប់ទាក់ទងគ្នាទៅវិញទៅមក ។ សកម្មភាពមានតិចមុខ ពីព្រោះហេដ្ឋារចនាសម្ព័ន្ធយ៉ាប់យ៉ឺន និងបច្ចេកវិទ្យាចាស់ហួសសម័យ ហើយចំណុចខ្សោយខាងហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យានេះក៏កើតមានព្រោះតែកង្វះធនធានមនុស្សមានជំនាញ និងអភិបាលកិច្ចមិនសូវមានប្រសិទ្ធិភាព ។

ដោយពិនិត្យឃើញនូវចំណងទាក់ទងទៅវិញទៅមកនេះ គេគួរមានការប្រុងប្រយ័ត្ន ដោយធ្វើការបែងចែកអនុសាសន៍ជាបួនក្រុមគឺ *បញ្ហាម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនធានមនុស្សនិងបច្ចេកវិទ្យា និងការទ្រទ្រង់ដល់ផ្នែកផ្គត់ផ្គង់* ។ ចំណុចនីមួយៗមានបកស្រាយដូចខាងក្រោម៖

### *៤.៥.២ បញ្ហាម៉ាក្រូសេដ្ឋកិច្ច*

គេឃើញមានរបាយការណ៍ជាច្រើនពីរឿងនេះ ព្រមទាំងមានការរីកចំរើនច្រើនហើយដែរក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច (MoC 2001b) ដូច្នេះក្នុងឯកសារនេះពុំមានការពិភាក្សាលំអិតពីបញ្ហាទាំងអស់ទេ ។ ដំណើរការខាងរូបិយវត្ថុ និងខាងច្បាប់ជាច្រើន ត្រូវបានដាក់អនុវត្តហើយ ប៉ុន្តែត្រូវមានការត្រួតពិនិត្យឱ្យជិតដល់ ឬជាបន្តទៀត ដូចមានពិភាក្សារនៅខាងក្រោម។ ឧទាហរណ៍៖ ចំពោះដុល្លារូបនីយកម្ម ថ្វីបើប្រាក់ដុល្លារផ្តល់ស្ថិរភាពយ៉ាងច្រើនដល់ប្រព័ន្ធរូបិយវត្ថុក្តី, ការឡើងថ្លៃដុល្លារធៀបនឹងស្ទើរតែគ្រប់រូបិយវត្ថុក្នុងមួយទសវត្សរ៍កន្លងមក បានធ្វើឱ្យប្រទេសដែលមានសេដ្ឋកិច្ចចងភ្ជាប់ជាមួយដុល្លារ (ដូចជាកម្ពុជា) ត្រូវចាញ់ប្រៀបគេខាងថ្លៃដើម គឺធ្វើឱ្យការនាំចេញធ្លាក់ចុះ និងការនាំចូលកើនឡើង ។ ករណីសិក្សាដូចខាងលើ បានបង្ហាញថាប្រាក់បាតថៃ និងប្រាក់ដុងវៀតណាមដែលចុះថោក បានគំរាមកំហែងជាប់រហូតដល់លក្ខណៈប្រកួតប្រជែងរបស់អាជីវកម្មក្នុងស្រុក ហើយសហគ្រិនមួយចំនួនបានប្រឹងប្រែងទប់ទល់ ដោយកាត់បន្ថយបុគ្គលិក និងប្រាក់កំរៃ ឯខ្លះទៀតបានបិទទ្វារទាំងស្រុង ឬក៏មិនចូលប្រកួតប្រជែងក្នុងចំណែកទីផ្សារនោះទេ ។ ដូច្នេះតំលៃបន្ថែមគិតក្នុងមួយឯកតាសកម្មភាពនៅតែទាបដដែល[៥៧] ។ ដូច្នេះការលូតលាស់នេះមិនអំនោយផលដល់អ្នកក្រីក្រទេ (pro-poor growth) ។ តើមានចំនុចអ្វីខ្លះអាចបត់បែនបាន ដើម្បី

[៥៧] អ្នកខ្លះអាចជំទាស់ថា ដុល្លារូបនីយកម្មធ្វើឱ្យធាតុចូលនាំចូលចុះថោក និងផ្តល់ឧត្តមភាពមួយក៏តែខាងថ្លៃដើមដល់ឧស្សាហកម្ម ។ ប៉ុន្តែឧស្សាហកម្មកម្ពុជា មិនទាន់រីកធំធាត់គ្រប់គ្រាន់ដើម្បីទាញយកអត្ថប្រយោជន៍ពីលទ្ធភាពបែបនេះទេ ។

ការពារផលិតកម្មក្នុងស្រុកដែលកំពុងលូតលាស់ ទប់ទល់នឹងឥទ្ធិពលអាក្រក់នៃការឡើងថ្លៃរូបិយវត្ថុ? ដំណោះស្រាយអាចជាការចងភ្ជាប់អត្រាពន្ធនាំចេញ-នាំចូល ជាមួយនឹងកំរិតឡើងថ្លៃប្រាក់ដុល្លារ, និងការដាក់អនុវត្តន៍ច្បាប់យ៉ាងតឹងរ៉ឹង ។

គួរបញ្ជាក់ដូចគ្នាដែរថា ទោះបីប្រទេសមានរចនាសម្ព័ន្ធពន្ធនាំចេញនាំចូលជាក់លាក់ក្តី ក៏ផ្នែករដ្ឋបាលមិនអាចដាក់អនុវត្តវិធានច្បាប់ទាំងនេះបានគ្រប់គ្រាន់ទេ ។ ព្រំដែនគ្រប់ទិសមានចន្លោះប្រហោងជាច្រើន ដូច្នេះហើយទើបមានការរត់ពន្ធច្រើនណាស់ដែលប៉ះពាល់យ៉ាងខ្លាំងដល់ផលិតកម្មក្នុងស្រុក ។ នៅកម្ពុជា ដំណោះស្រាយស្ថិតនៅលើការកាត់បន្ថយអំពើពុករលួយ ។ តើគេអាចទប់ស្កាត់ការរត់ពន្ធទ្រង់ទ្រាយធំបានទេ? គេគិតថា ធនាគារពិភពលោកកំពុងធ្វើការជាមួយរដ្ឋាភិបាលលើចំណុចនេះ និងបណ្តាបញ្ហាប្រហាក់ប្រហែលគ្នាផ្សេងទៀត ។ ដំណោះស្រាយដ៏សាមញ្ញមួយដែលបានលើកឡើង គឺត្រូវយកពន្ធ ឬផាកពិន័យលើផលិតផលរត់ពន្ធនៅចំណុចចុងក្រោយ គឺនៅកំរិតលក់រាយ ។ ដោយសារផលិតផលភាគច្រើន គេដាក់លក់នៅក្នុងក្រុងដែលតែងមានវត្តមានកំលាំងរដ្ឋាភិបាលច្រើនណាស់ ដូច្នេះការហូតពន្ធ ឬផាកឱ្យធ្ងន់រហូតដល់ទំនិញរត់ពន្ធលែងមានចំណេញ គឺអាចធ្វើបាន ។ វិធីសាស្ត្រនេះអាចសក្តិសិទ្ធិយ៉ាងហោចណាស់ក៏ចំពោះផលិតផលមុខខ្លះនៅក្នុងទីផ្សារដែរ ។ ប្រទេសជាច្រើនបានអនុវត្តតាមរបៀបនេះ ។

ការបង់ប្រាក់ក្រៅផ្លូវការបានបង្កើនចំណាយ (MoC 2001a, c): ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ថា មូលហេតុតែមួយគត់ដែលធ្វើឱ្យអង្ករកម្ពុជា មិនអាចប្រកួតប្រជែងនៅទីផ្សារសឹង្ហបុរី គឺការបង់ប្រាក់ក្រៅផ្លូវការច្រើនពេក ដែលអ្នកនាំចេញត្រូវចំណាយ ។ ដំនោះស្រាយបញ្ហានេះមិនមែនងាយស្រួលទេ ទោះបីមានមនុស្សជាច្រើនកំពុងប្រឹងប្រែងកំចាត់អំពើពុករលួយក្តី (World Bank 2000) ។

វិធានមួយដើម្បីទប់ស្កាត់ការរត់ពន្ធគឺ ដំបូងត្រូវកំណត់ទំហំតំរូវការប្រើប្រាស់ក្នុងស្រុកនូវមុខទំនិញនាំចូលមួយចំនួន ។ អង្កេតទីផ្សារ និងអង្កេតអ្នកប្រើប្រាស់

បានផ្តល់ពត៌មានច្បោលៗពីរឿងនេះ ។ បន្ទាប់មក ត្រូវកំណត់ផែនការចំណូលពន្ធគយ តាមចំនួនរំពឹងទុកនៃការនាំចូល ។ គួរដាក់អនុវត្តនូវប្រព័ន្ធលើកទឹកចិត្ត និងទោសទ័ណ្ឌ ដើម្បីធានាឱ្យមានការគោរពច្បាប់ ។ លទ្ធភាពមួយទៀតដែលបំពេញបន្ថែមចំពោះវិធីសាស្ត្រខាងលើ គឺការបង្កើតសមាគមពាណិជ្ជកម្មដ៏សកម្ម ។ បច្ចុប្បន្ន សមាគមនេះមិនសូវមានដំនើរការទេ ហើយគេមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីចាប់យកបញ្ហាធំៗ ដូចជាអំពើពុករលួយជាដើម នៅក្នុងវេទិការួមជាមួយរដ្ឋាភិបាល[៥៨] ។

សព្វថ្ងៃមានលទ្ធភាពតិចតួចណាស់ ក្នុងកិច្ចការពារទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅ ទៅលើសេដ្ឋកិច្ចដែលពឹងធ្ងន់លើការនាំចេញផលិតផលតែពីរបីមុខនោះ ។ វិធីសាស្ត្រមួយដែលគេឧស្សាហ៍លើកឡើងដើម្បីទប់ទល់នឹងការប៉ះទង្គិចបែបនេះ គឺត្រូវអភិវឌ្ឍទីផ្សារក្នុងប្រទេស ប៉ុន្តែការងារនេះមិនមែនប្រើរយៈពេលខ្លីទេ ។

### *៤.៥.៣ ហិរញ្ញវត្ថុ*

ដូចបានបញ្ជាក់ពីខាងដើម មានកំណែទំរង់សំខាន់ៗកំពុងមានដំណើរការដើម្បីពង្រឹងធនាគារកណ្តាល និងប្រព័ន្ធច្បាប់សំរាប់ធនាគារពាណិជ្ជឯកជន ហើយឯកសារនេះគ្មានអ្វីបន្ថែម ឬរួមវិភាគទានក្នុងរឿងនេះទេ ។ ការពិតជាក់ស្តែងដែលបានពិនិត្យឃើញក្នុងករណីសិក្សានានា បានផ្តល់គំនិតថា អាជីវកម្មនៅកម្ពុជាបានធ្វើឡើងដោយការប្រើប្រាក់សន្សំផ្ទាល់ខ្លួន និងការខ្ចីបុលពីសាច់ញាតិ និងមិត្តភក្តិ ។ រឿងនេះក៏បានពិនិត្យក្នុងសហគ្រាសអាជីវកម្មផ្សេងៗ ក្រៅពីករណីសិក្សាទាំងនេះផងដែរ (Biddulph 2000; Sedara, Chan and Acharya 2002) ។ ក្នុងឯកសារនេះ នឹងមានការពិភាក្សាពីបញ្ហាជាក់លាក់មួយចំនួន ។

---

[៥៨] បញ្ហានឹងដោះស្រាយបានស្រេចបាច់នៅពេលមានកំណែទំរង់រដ្ឋបាលស៊ីវិល ដែលក្នុងនេះមានការផ្តល់ប្រាក់ខែអាចរស់បានដល់មន្ត្រីរាជការគ្រប់គ្នា ។ គេជឿថា សំណើផ្សេងៗសំដៅដោះស្រាយបញ្ហានេះ កំពុងត្រូវបានពិនិត្យពិចារណា ។

១. ការផ្គត់ផ្គង់ឥណទានមានកំរិតទាប ពីព្រោះសុវត្ថិភាពនៃការសងវិញក៏នៅទាបដែរ ។ អាជីវកម្មទំនើបៗទាមទារភាពប្រាកដប្រជាលើសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ, ការធ្វើអាជីវកម្មប្រកបដោយតម្លាភាព, ពត៌មានទីផ្សារអំពីសកម្មភាពរបស់អ្នកជំពាក់បំណុល, និងប្រព័ន្ធតុលាការដែលមានដំណើរការជាក់ស្តែងលឿន និងយុត្តិធម៌ ។ ដោយការធ្វើអង្កេតពីដីធ្លី ក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្ម កំពុងដោះស្រាយបញ្ហាខាងលើបានមួយភាគ ។ ប៉ុន្តែផែនការក្រសួងមានរយះពេល ១០ឆ្នាំ ដែលយូរខ្លាំងពេក ទោះបីវាជារឿងមិនអាចជៀសវាងផុតក៏ដោយ ។ ប៉ុន្តែរឿងដែលល្អគឺថា សកម្មភាពសុរិយោដីក្នុងតំបន់ទីក្រុង នឹងអាចចប់សព្វគ្រប់នៅក្នុងពេលឆាប់ៗ ហើយវានឹងជួយបង្កើនចរន្តឥណទានពាណិជ្ជកម្ម ។

២. តម្លាភាព និងពត៌មានទីផ្សារ ត្រូវការស្ថាប័នទ្រទ្រង់អាជីវកម្ម ដូចជាអាជ្ញាធរធានារ៉ាប់រងឯករាជ្យ សវនកម្មតាមច្បាប់កំនត់ សហគ្រាសសេវាច្បាប់ពាណិជ្ជកម្ម ភ្នាក់ងារវាយតំលៃស្ថានភាពក្រុមហ៊ុន... ដែលមានការទទួលស្គាល់ និងការគោរពពីអន្តរជាតិ ។ ប្រទេសកម្ពុជាខ្វះខាតស្ថាប័នទាំងនេះ ហើយពិនិត្យតាមឯកសារដែលមានស្រាប់ វាមិនច្បាស់ទេថាតើគេបានយកចិត្តទុកដាក់ឬទេដល់រឿងនេះ ពីព្រោះបើគ្មានស្ថាប័នដូចខាងលើ ឬសេវាប្រហាក់ប្រហែលទេ អាជីវកម្មនានា ក៏មិនអាចរកបាននូវឥណទានងាយស្រួល/មានតំលៃថោកដែរ ។ ស្ថាប័នទាំងនេះមិនអាចកើតឡើងតាមគំនិតផ្តួចផ្តើមរបស់ឯកជនទាំងអស់ទេ គឺត្រូវមានជាចាំបាច់នូវការគាំទ្រ និងការចូលរួមជាដៃគូពីសំណាក់រដ្ឋាភិបាល ។

៣. ធនាគារនៅកម្ពុជា មានលក្ខណៈដូចគ្នានឹងធនាគារក្នុងប្រទេសអភិវឌ្ឍន៍នានាដែរ គឺមានការិយាល័យធំនៅភ្នំពេញ (ជារឿយៗមានតែមួយនេះទេ) ហើយធ្វើប្រតិបត្តិការលើទឹកប្រាក់ច្រើន និងធ្វើសកម្មភាពក្នុងបរិស្ថានមានហានិភ័យទាប ។ តាមពិត និយមន័យនៃហានិភ័យ មិនដែល

បានកំណត់ជាផ្លូវការនៅកម្ពុជាទេ ហើយរឿងនេះត្រូវមានការស្រាវជ្រាវបន្ថែម ។ បន្ទាប់មក ត្រូវចោទសំនួរមួយចំនួនដូចជាអំពី ទំហំតំរូវការឥណទានសំរាប់កសិកម្ម, ប្រព័ន្ធទីផ្សារលក់រាយនៅជនបទ, ការធ្វើវិមជ្ឈការសហគ្រាសអាជីវកម្ម និងពាណិជ្ជកម្ម, លក្ខណៈរដូវកាលនៃតំរូវការឥណទាន, សមត្ថភាពសងប្រាក់វិញរបស់កូនបំណុល... ។ បច្ចុប្បន្នសំនួរទាំងនេះគ្មានចម្លើយច្បាស់លាស់ទេ ។ ដូច្នេះប្រព័ន្ធហិរញ្ញវត្ថុផ្នែកខាងផ្គត់ផ្គង់ គឺមានតំរូវការគោលនយោបាយគាំទ្រធំណាស់ ។

៤. ការពិតដែលថា សកម្មភាពសេដ្ឋកិច្ចភាគច្រើនត្រូវការឥណទាន និងបានទទួលឥណទាន (មិនឃើញមានឆ្លុះបញ្ចាំងនៅក្នុងរណើសិក្សានានាខាងលើទេ ប៉ុន្តែការសិក្សាឯទៀតៗបានបង្ហាញពីចំណុចនេះ) ដោយត្រូវបង់អត្រាការប្រាក់ពី ៦០-១២០%/ឆ្នាំតាមពេលកំនត់ទៀងទាត់ នេះគឺជាភស្តុតាងបង្ហាញថា ស្ថាប័នឥណទានអាចចំនេញថែមបានដោយធ្វើអាជីវកម្មជាមួយស្រទាប់ប្រជាជនធំជាងសព្វថ្ងៃ ។ បច្ចុប្បន្ននេះ ធនាគារពុំមានជំនាញ ឬបទពិសោធន៍ ដើម្បីធ្វើប្រតិបត្តិការជាមួយអាជីវកម្មតូចៗ ឬសហគ្រាសវិមជ្ឈការទេ ។ ពួកគេអាចចាត់ចែងកំចីធំៗជាមួយអតិថិជនមួយចំនួនតូច មិនមែនចាត់ចែងកំចីតូចៗសំរាប់អតិថិជនច្រើនៗនោះទេ ។ ការចាត់ចែងកំចីតូចៗ ធ្វើឱ្យបន្ទុកចំនាយប្រតិបត្តិការកើនឡើង ដូច្នេះធនាគារក៏ចៀសវាងមិនអនុវត្តវា ។ ធនាគារត្រូវមានវិធីសាស្ត្រផ្សេង ដើម្បីធ្វើប្រតិបត្តិការជាមួយអាជីវកម្មតូចៗ ឬសហគ្រាសវិមជ្ឈការ ហើយនេះជារបៀបគ្រប់គ្រងមួយដែលមិនទាន់ពេញនិយម ប៉ុន្តែដល់ពេលត្រូវធ្វើហើយ ។

៥. ចំពោះអាជីវកម្មតូចៗបំផុត បទពិសោធន៍ថ្មីៗក្នុងប្រទេសកំពុងអភិវឌ្ឍន៍បង្ហាញថា អាជីវករតូចតាចជាបុគ្គលអាចពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមបទដ្ឋានកំនត់ដើម្បីទទួលឥណទាន ប៉ុន្តែកិត្តិនាមនឹងកើនឡើង បើសិនពួកគេរួមគ្នាជាក្រុម (Hulme and Mosley 1996; Tilakaratna 1996) ។

ក្រុមឥណទាន (ឬសមាគម) រួមផ្សំដោយអ្នកខ្ចីតិច១ ជារឿយ១តែង ចាប់ផ្តើមធ្វើជាក្រុមសន្សំប្រាក់ ហើយនៅពេលកិត្តិនាមជាក្រុមសន្សំប្រាក់ កើនឡើង គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីសុំកំចីជាក្រុម (ក្នុងចំនួន ដែលធនាគារអាចឱ្យខ្ចីដោយមានបន្ទុកចំណាយទាប) ហើយបែងចែក កំចីទៅឱ្យសមាជិកក្រុមខ្លួនតាមតំរូវការរបស់ម្នាក់១ (ADB 1996) ។ គ្មាន សម្បទានអ្វីទេលើអត្រាការប្រាក់ និងកាលបរិច្ឆេទសងប្រាក់ៈ ក្នុងករណី នេះ អត្រាការប្រាក់សំរាប់ក្រុម គឺស្មើគ្នានឹងអត្រាការប្រាក់ថោកបំផុត របស់ធនាគារ (prime lending rate) ។ វិធីនេះពេញនិយមនៅក្នុងប្រទេស ជាច្រើន ហើយជាទូទៅអត្រាសងកំចីឡើងដល់ ៩០% ឬខ្ពស់ជាង ។ ដើម្បីឱ្យប្រព័ន្ធនេះ ដំនើរការបាននៅទូទាំងប្រទេសតំរូវឱ្យមានការរៀបចំ និងបទប្បញ្ញត្តិច្បាប់ ។ ការពង្រឹងអាជ្ញាធរមូលដ្ឋាន (ក្នុងករណីនេះគឺក្រុម ប្រឹក្សាឃុំ-សង្កាត់ ដែលអាចធ្វើសកម្មភាពជាអាជ្ញាធរចេញបទប្បញ្ញត្តិ) ព្រមទាំងសមាគមអាជីវករផ្សេង១ អាចជាជំហានមួយក្នុងទិសដៅនេះ ។ លក្ខខណ្ឌមួយដែលត្រូវបំពេញឱ្យបានជាមុន គឺការបណ្តុះបណ្តាល និងការ ច្នៃប្រឌិតថ្មីជាច្រើនដែលត្រូវធ្វើ ។ បញ្ហាប្រឈមដ៏ចំបងមួយ គឺការតំរង់ ទិសប្រាក់ទុនចេញពីវិស័យធនាគារជាផ្លូវការ ឆ្ពោះទៅកាន់មីក្រូហិរញ្ញវត្ថុ និងបណ្តាញធនាគារវិមជ្ឈការផ្សេង១ ។ ការកសាងធនាគារអភិវឌ្ឍន៍ជន បទគឺជាជំហានមួយក្នុងទិសដៅនេះ ប៉ុន្តែគេត្រូវធ្វើការច្រើនទៀត[៥៩] ។

[៥៩] មានការជជែកវែកញែកពីបញ្ហាមួយចំនួនរបស់ធនាគារអភិវឌ្ឍន៍ ពីព្រោះនៅក្នុងប្រទេសខ្លះ ធនាគារមានខ្ទង់ទ្រព្យសកម្មមិនដំណើរការ (non-performing asset) យ៉ាងច្រើន ។ ប៉ុន្តែ គេមិនត្រូវទាត់ចោលគំនិតនេះជាស្វ័យប្រវត្តិទេ ។

### ៤.៥.៤ ធនធានមនុស្ស និងលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា

ឯកសារនេះក៏គួរអធិប្បាយពីរឿងធនធានមនុស្សផងដែរ ដោយមានបញ្ហាធំៗ ចំនួន ៥ ដូចតទៅ:

១. ខ្វះខាតបុគ្គលិកដែលមានការអប់រំល្អ ក្នុងកំលាំងពលកម្ម មិនមានមនុស្សគ្រប់គ្រាន់ដែលអាចឱ្យគេជ្រើសចូលឱ្យធ្វើការ ហើយអាចទទួលការបណ្តុះបណ្តាលដោយផ្ទាល់ នៅក្នុងសកម្មភាពស្របនឹងអាជីវកម្មណាមួយ ឬបច្ចេកទេសណាមួយដ៏ជាក់លាក់ទេ ។ បញ្ហានេះត្រូវតែដោះស្រាយ ។

២. សព្វថ្ងៃ មានកង្វះជាខ្លាំងនូវបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈបច្ចេកទេសថ្នាក់កណ្តាល ពោលគឺអ្នកដែលមិនមែនជាវិស្វករពេញលេញទេ ប៉ុន្តែបានទទួលការបណ្តុះបណ្តាលក្នុងជំនាញខាងមេកានិច អគ្គិសនី អេឡិចត្រូនិក វិស្វកម្មស៊ីវិល... ។ សាលាបច្ចេកទេសដែលអាចផ្តល់ជំនាញទាំងនេះបន្ទាប់ពីសិក្សានៅសាលាចំណេះទូទៅ អស់រយៈពេល ៨. ១០ និង១២ឆ្នាំ ហើយមានទីតាំងក្នុងទូទាំងប្រទេស (ជាការល្អបើមានមួយយ៉ាងតិចក្នុងមួយខេត្ត) អាចជួយដោះស្រាយកង្វះខាតនេះបានយ៉ាងច្រើន ។

៣. ដូចបានបញ្ជាក់ពីខាងដើម ការវិនិយោគធ្វើអាជីវកម្មតែងមាននៅក្នុងក្រុមជនភាគតិចមួយចំនួនតូចដោយសារហេតុផលប្រវត្តិសាស្ត្រ ។ ទាំងសាលាពាណិជ្ជកម្មពេញម៉ោង និងសាលាពាណិជ្ជកម្មសំរាប់អ្នកមានអាជីពហើយ ដែលអាចបង្រៀនវគ្គខ្លីៗស្តីពីសហគ្រិនភាព ហិរញ្ញវត្ថុ ឬបច្ចេកវិទ្យាណាមួយ គឺមានប្រយោជន៍ច្រើនក្នុងការបំពេញចំណេះដឹងឱ្យអាជីវករ ។

៤. ចំពោះបញ្ហាបន្ទុកចំណាយ វាជាប់ទាក់ទងនឹងការបណ្តុះបណ្តាលនៅគ្រប់កំរិត ។ ដោយបានទទួលគំនិតខ្លះៗអំពីសេដ្ឋកិច្ចទីផ្សារមានការអភិវឌ្ឍន៍, ឧត្តមសិក្សានៅកម្ពុជាត្រូវបានធ្វើឯកជននីយកម្ម ។ ប៉ុន្តែសំរាប់ប្រទេសមានប្រាក់ចំណូលទាប ទង្វើបែបនេះបានរារាំងមនុស្សច្រើនណាស់ មិនឱ្យ

ចូលបានទៅក្នុងចរន្តឧត្តមសិក្សា និងបណ្តាញអប់រំជំនាញ ។ ក្នុងចំនុចនេះ ដាច់ខាតត្រូវមានការគាំទ្រពីរដ្ឋ ដូចជា របបបង់ថ្លៃសិក្សាទាប, ការផ្តល់អាហារូបករណ៍ផ្អែកលើកំពស់សមត្ថភាព, ហើយជារឿយៗត្រូវធ្វើទាំងពីរមុខនេះតែម្តង ។ បទពិសោធន៍នៃប្រទេសមានប្រាក់ចំនូលទាប តែមានកំរិតអប់រំខ្ពស់ ដូចជា ស្រីលង្កា ចិន វៀតណាម... អាចជាមេរៀនដ៏ល្អ ។

៥. ការកសាងធនធានមនុស្ស អាចជួយពង្រឹងមូលដ្ឋានបច្ចេកវិទ្យាបានមួយកំរិត ប៉ុន្តែសំខាន់ត្រូវប្រឹងប្រែងថែមទៀតដើម្បីបញ្ចូលបច្ចេកវិទ្យាទំនើបមកក្នុងប្រទេស ។ គ្មានរូបមន្តណាមួយដែលច្បាស់ថាបានសំរេចនោះទេ ប៉ុន្តែវិធីសាស្ត្រមួយគឺបង្កើតអង្គការត្រីភាគី ដែលមាននិយោជក ពលករ និងរដ្ឋាភិបាល ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការផលិតភាពអាស៊ី (Asian Productivity Organisation) មានទីតាំងនៅក្រុងតូក្យូ ។ ប្រទេសជាច្រើននៅអាស៊ី មានក្រុមប្រឹក្សាផលិតភាពជាតិ ដែលចែករំលែក និងផ្សព្វផ្សាយបច្ចេកវិទ្យានៅកំរិតជាតិ និងតាមរយៈ ពិធីសារផ្ទេរជាអន្តរជាតិផង ។ វិធីសាស្ត្រនេះគួរយកមកពិចារណា ។

### *៤.៥.៥ សេវាអភិវឌ្ឍន៍អាជីវកម្ម និងការពង្រឹងផ្នែកផ្គត់ផ្គង់*

គ្រប់អាជីវកម្មត្រូវការសេវាជួយបំរើ ដែលអាចទាក់ទិននឹងហិរញ្ញវត្ថុ ទីផ្សារ ធាតុចូល បច្ចេកវិទ្យា ថ្លៃដើម... ។ ក្នុងប្រទេសអភិវឌ្ឍន៍ សេវាបែបនេះមាននៅក្នុងគ្រឹះស្ថានសិក្សា ទស្សនាវដ្តីអាជីព អ៊ិនធឺណិត និងតាមរយៈទីភ្នាក់ងារពិគ្រោះយោបល់ជាច្រើន ។ សេវាខ្លះត្រូវបង់ប្រាក់ ឯខ្លះទៀតគ្មានបង់ថ្លៃទេ ។ សំរាប់ប្រទេសមិនសូវអភិវឌ្ឍន៍ជាច្រើនរួមទាំងកម្ពុជាផង បរិស្ថានអាជីវកម្មត្រូវតែផ្តួចផ្តើមបង្កើតឡើងក្នុងដំណាក់កាលដំបូង ។ បើចាំបាច់ សេវាទាំងនេះត្រូវផ្តល់តាមរយៈជំនួយពីក្រៅប្រទេសមុនពេលទីផ្សារអាចចាប់ដំនើរការផ្តល់សេវាអាជីវកម្មបាន ។ ដូច្នេះការពង្រឹង

ផ្នែកផ្គត់ផ្គង់ ជាវិធានការគោលនយោបាយដ៏សំខាន់[៦០] ហើយក្នុងនេះ វិធីសាស្ត្រមួយគឺការកសាងសេវាអភិវឌ្ឍន៍អាជីវកម្ម (Business Development Services: BDS) ។

BDS រួមមាន ការបណ្តុះបណ្តាល, សេវាទីប្រឹក្សា ពិគ្រោះយោបល់, ជំនួយការម៉ាឃីទីង ពត៌មាន ការអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិទ្យា ការពង្រឹងចំណងទាក់ទងអាជីវកម្ម... ។ BDS អាចបំរើប្រតិបត្តិការផង និងបំរើយុទ្ធសាស្ត្រផង ។ សេវាបំរើប្រតិបត្តិការ គឺជាសេវាដែលមានតំរូវការ និងត្រូវផ្តល់ប្រចាំថ្ងៃ ចំណែកឯសេវាជាយុទ្ធសាស្ត្រ គឺមានតំរូវការសំរាប់ការធ្វើផែនការ និងការពង្រីកអាជីវកម្មក្នុងរយៈពេលមធ្យម និងវែង ។ BDS អាចជាសេវាពិសេសណាមួយ និងជាសេវាមួយក្រុមដោយយោលទៅលើទីផ្សារដែលត្រូវបំរើ (ILO 2001) ។

តួអង្គផ្សេងៗនៅក្នុង BDS រួមមាន សហគ្រាសឯកជន (អតិថិជន) អ្នកសំរបសំរួល (ទីប្រឹក្សា អ្នកពិគ្រោះយោបល់ពីគោលនយោបាយ) អ្នកផ្គត់ផ្គង់ (អ្នកបញ្ជាក់លើផលិតផល អ្នកផ្តល់បច្ចេកវិទ្យា ជាងជុសជុល អ្នកបណ្តុះបណ្តាល) និងទាយក/រដ្ឋាភិបាល ។ ទំនាក់ទំនងរវាងភ្នាក់ងារផ្សេងៗមានដូចតទៅ៖




[៦០] ការពង្រឹងផ្នែកផ្គត់ផ្គង់ មិនមែនជាគោលនយោបាយប្រឆាំងទីផ្សារទេ ។ រដ្ឋាភិបាលអាមេរិក ក៏ធ្លាប់អនុវត្តវាដែរ (ក្នុងរូបភាពផ្សេង) នៅក្នុងទសវត្សរ៍១៩៨០ ។

អតិថិជនស្វែងរកសេវាតាមតំរូវការផ្ទាល់និងសុខចិត្តបង់ថ្លៃ, អ្នកផ្គត់ផ្គង់គឺជាទីភ្នាក់ងារឯកជនដែលដើរតាមតំរូវការដើម្បីបានប្រាក់ចំណេញ ឯទាយក NGOs, ឬរដ្ឋាភិបាល ជួយទ្រទ្រង់ដល់អ្នកសំរបសំរួលនានានៅក្នុងដំនាក់កាលដំបូងនៃការបង្កើតអាជីវកម្ម ។ នៅចុងបញ្ចប់ អ្នកសំរបសំរួលខ្លួនឯងក៏ក្លាយជាអ្នកដើរតាមទីផ្សារដែរ ។ ជួនកាលធនាគារដើរតួជាអ្នកសំរបសំរួល ។ នៅប្រទេសខ្លះ ធនាគារឯកទេសទទួលបំរើសេវាទាំងនេះ ។ WB (2001) និង ILO (2001) បានផ្តល់ឧទាហរណ៍ជាច្រើននៃរូបភាពខុសៗគ្នានៃ BDS ។

មានសេវាច្រើនទៀតដែលរដ្ឋ ឬទាយកអាចផ្តល់ ដើម្បីជំរុញវិស័យឯកជន ហើយមិនមែនឧបត្ថម្ភធន ឬសម្បទានជាប្រាក់ ។ សេវាទាំងនេះ រួមមាន ការបណ្តុះបណ្តាល (ក្នុងឬក្រៅប្រទេស) ការបង្កើតឧទ្យានបច្ចេកវិទ្យាឬឧស្សាហកម្ម និងការកសាងសំភារៈផ្តល់ការងាយស្រួលសំរាប់ការប្រើប្រាស់ទូទៅ (ម៉ាស៊ីនបង្កកត្រជាក់ខ្លាំងសំរាប់អ្នកនេសាទតូចតាច) ឬមជ្ឈមណ្ឌលរចនាម៉ូត (សំរាប់ផលិតកម្មគ្រឿងស្បែក ឬសហគ្រាសកាត់ដេរតូចតាច) ឬក៏អាចជួយរៀបចំសមាគមអាជីវករទៀតផង ។ សរុបមក ការផ្តល់សេវានៅក្រោម "ហេតុផលឧស្សាហកម្មក្មេងខ្ចី" គឺជាសកម្មភាពត្រឹមត្រូវតាមច្បាប់[៦១] ។ ចំណុចគួរប្រុងប្រយ័ត្នមួយៈ ក្នុងប្រទេសខ្លះ BDS ក្នុងការពិតជាក់ស្តែងគឺបានដើរតាមពួកអ្នកផ្គត់ផ្គង់ ដូច្នេះត្រូវប្រឹងប្រែងធ្វើយ៉ាងណាកុំឱ្យធ្លាក់ចូលក្នុងអន្ទាក់បែបនេះ ។

គេទទួលស្គាល់ច្បាស់ហើយពីហេដ្ឋារចនាសម្ព័ន្ធដែលខ្វះខាត និងយ៉ាប់យ៉ឺននៅក្នុងប្រទេសកម្ពុជា ព្រមទាំងដំណើរការកែទំរង់ និងការសិក្សាធំៗធ្វើដោយក្រសួងពាណិជ្ជកម្មដូចបានលើកឡើងពីខាងដើម ដើម្បីដោះស្រាយរឿងនេះ ។ ចំពោះករណីសិក្សាទាំងនេះវិញ បញ្ហាចំបងគឺវត្តមាននិងតំលៃអគ្គីសនី វត្តមាននិងតំលៃដឹកជញ្ជូន

---

៦១ The infant industry argument សំដៅទៅលើការផ្តល់គ្រឿងលើកទឹកចិត្ត ឬការការពារឧស្សាហកម្មក្មេងខ្ចីនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងរយៈពេលកំនត់មួយ ។

និងតំលៃនៃបច្ចេកវិទ្យានិងជំនាញ ។ បញ្ហាទាំងនេះពុំមានចម្លើយសាមញ្ញ ឬឆាប់រហ័សនោះទេ ។

## ៤.៦ សេចក្តីសន្និដ្ឋាន

ជំពូកនេះគឺជាការប្រឹងប្រែងដំបូង ដើម្បីពិនិត្យបញ្ហាផ្សេងៗជាប់ទាក់ទិននឹងការអភិវឌ្ឍន៍វិស័យឯកជនកម្ពុជាដែលគេយល់ឃើញជាទូទៅថា ជាអាយុជីវិតនៃឧស្សាហូបនីយកម្មនៅកម្ពុជា, និងការធ្វើសមាហរណកម្មទៅក្នុងអាស៊ាន និងប្រព័ន្ធសាកល និងដើម្បីកាត់បន្ថយភាពក្រីក្រ និងកសាងស្ថិរភាពក្នុងប្រទេស ។ ការសិក្សាក្នុងជំពូកនេះ ផ្អែកលើទិន្នន័យបានពីគំរូតាងនៃករណីសិក្សាមួយចំនួនតូច លើសហគ្រិនមានជោគជ័យ (និងមិនសូវមានជោគជ័យ) ដែល វបសអ បានធ្វើឡើង ។ គំហើញចំបងៗមានសង្ខេបដូចខាងក្រោម ។

វិស័យឯកជនមានទំហំតូចមែន ប៉ុន្តែរស់រវើក ដោយសារជាប់ទាក់ទងនឹងប្រវត្តិសាស្ត្រនៃការវិវត្តន៍ក្នុងពេលថ្មីៗនៅកម្ពុជា ។ អាជីវកម្ម និងសហគ្រាសនានាបានចំណេញ និងបានរីកចំរើនពីព្រោះ មួយចំនួនបានចេញដំណើរអាជីវកម្មមុនគេ, ខ្លះបានក្តោបក្តាប់កន្លែងរកស៊ីសំខាន់នៅក្នុងទីផ្សារ, ខ្លះបានកសាងសម្ព័ន្ធភាពជាយុទ្ធសាស្ត្រជាមួយដៃគូផ្សេងៗ, ខ្លះបានពឹងផ្អែកលើបណ្តាញធំទូលាយដើម្បីរកទុន ទីផ្សារ និងចំណេះធ្វើខាងបច្ចេកទេស, ហើយទាំងអស់គ្នាហ៊ានប្រថុយនឹងហានិភ័យ និងបានប្រឹងប្រែងធ្វើការខ្លាំងណាស់ដើម្បីបានជោគជ័យ ។

តាមរយៈបទសម្ភាសន៍ វិស័យឯកជនហាក់ដូចជានៅមានទំហំតូចដោយសារតែបញ្ហាមួយចំនួនដែលវិស័យឯកជនមិនអាចដោះស្រាយបាន ។

១. ដោយមានទីផ្សារបើកចំហ ព្រមទាំងព្រំដែនបិទមិនជិត ឧស្សាហកម្មដែលកំពុងចាប់ដំណើរការ មិនអាចប្រកួតប្រជែងជាមួយផលិតផលនាំចូលពីក្រៅប្រទេសបានទេ ។

២. ដោយសារកម្ពុជាមានសេដ្ឋកិច្ចរាក់ណាស់ (very shallow economy) គឺបានន័យថា តំលៃឯកតាក្នុងសកម្មភាពនីមួយៗមានកំរិតទាប ដូច្នេះសេដ្ឋកិច្ចនេះ មិនសូវមានឧត្តមភាពប្រៀបធៀបទេ ក្រៅតែពីការប្រើប្រាស់ពលកម្មថោក ហើយប្រការនេះ មិនសូវអំណោយផលដល់សេដ្ឋកិច្ចទេ សំរាប់រយៈពេលវែង ។

៣. កង្វះហិរញ្ញវត្ថុ បច្ចេកវិទ្យា និងទីផ្សារ បានរាំងខ្ទប់ឧស្សាហកម្មឯកជន ។

៤. អវត្តមាន ឬថ្លៃដីខ្ពស់នៃហេដ្ឋារចនាសម្ព័ន្ធ បានបង្កើនបន្ទុកចំណាយ ។

៥. ស្ថាប័នមួយចំនួនទៀត ដូចជា ទីភ្នាក់ងារវាយតំលៃ សវនករ និងក្រុមហ៊ុនផ្តល់ពិគ្រោះយោបល់ សំរាប់បំរើដល់ការគ្រប់គ្រងអាជីវកម្មទំនើបមិនទាន់គ្រប់គ្រាន់ទេ ។

៦. បរិស្ថានម៉ាក្រូសេដ្ឋកិច្ច មិនមែនអំនោយផលដល់អាជីវកម្មក្នុងស្រុកគ្រប់ៗពេលនោះទេ ។

៧. ការបង់ប្រាក់ក្រៅផ្លូវការ បានបង្កើនថែមទៀតនូវបន្ទុកចំណាយ ហើយវាជាគ្រឿងបង្អាក់ទឹកចិត្តមួយយ៉ាងធំ ។

ថ្វីបើបញ្ហាភាគច្រើន ត្រូវបានលើកមកដោះស្រាយនៅក្នុងដំណើរការកែទំរង់ដែលរដ្ឋាភិបាលបានដាក់អនុវត្ត ដោយមានការជួយជ្រោមជ្រែងដោយទីភ្នាក់ងារផ្តល់ជំនួយក៏ដោយ ក៏ការសិក្សានេះបានបង្ហាញថា នៅមានការខ្វះចន្លោះខ្លះៗ ។ គេត្រូវផ្តល់សារៈសំខាន់ដល់ចំនុចទាំងនេះ ពីព្រោះពួកសហគ្រិនខ្លួនឯងបានអំពាវនាវឡើង ។ ចំពោះដំណោះស្រាយ ការសិក្សាបានស្នើឡើងនូវវិធានការមួយចំនួន សំរាប់បំពេញបន្ថែម ឬពង្រឹងគោលនយោបាយនានាដែល រដ្ឋាភិបាល និង/ឬទីភ្នាក់ងារផ្តល់ជំនួយគួរកំពុងពិនិត្យពិចារណាហើយ នៅក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនធានមនុស្ស បច្ចេកវិទ្យា និងសេវាអភិវឌ្ឍន៍អាជីវកម្ម ។ លើសពីនេះទៀត ការសិក្សាបានរកឃើញ

តួនាទីដែលសមាគមនានាក្នុងវិស័យឯកជនអាចទទួលបំពេញ ដើម្បីជួយជំរុញការលូតលាស់វិស័យឯកជននៅកម្ពុជា ។

# តារាងស្ថិតិបន្ថែម


តារាង១. អាំងឌីកាទ័រសេដ្ឋកិច្ចសំខាន់ៗ........................................................... ១២៧

តារាង ២. ប្រតិបត្តិការថវិកា (លានដុល្លារ) ........................................................១២៩

តារាង៣. ជញ្ជីងទូទាត់ (លានដុល្លារ)............................................................... ១៣១

តារាង៤. អង្កេតរូបិយវត្ថុ (លានដុល្លារ) ...........................................................១៣៣

តារាង៥. វិនិយោគ និងប្រាក់សញ្ជ័យ តាមប្រភេទ (លានដុល្លារ) ........................... ១៣៤

តារាង៦. ការងារ (ពាន់នាក់)......................................................................... ១៣៥

តារាង៧. ផសស តាមប្រភពដើមនៃឧស្សាហកម្ម តាមថ្លៃចរន្ត (លានដុល្លារ) ............ ១៣៧

តារាង៨. ផសស តាមប្រភពដើមនៃឧស្សាហកម្ម តាមថ្លៃថេរឆ្នាំ១៩៩៣ (លានដុល្លារ) .១៣៩

តារាង៩. សន្ទស្សន៍បរិត្តផរណាថ្លៃនៃ ផសស តាមប្រភពដើមនៃឧស្សាហកម្ម ............ ១៤១

តារាង១០. ផសស តាមប្រភេទចំណាយ និងតាមថ្លៃចរន្ត (លានដុល្លារ) ................... ១៤៣

តារាង១១. ផសស តាមប្រភេទចំណាយ និងតាមថ្លៃថេរឆ្នាំ១៩៩៣ (លានដុល្លារ)........ ១៤៤

តារាង១២. សន្ទស្សន៍បរិត្តផរណាថ្លៃនៃ ផសស តាមប្រភេទចំណាយ ........................ ១៤៥

## តារាង១. អាំងឌីកាទ័រសេដ្ឋកិច្ចសំខាន់ៗ

| | 1960 | 1970 | 1985 | 1990 | 1991 | 1992 | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផសស ថ្លៃចរន្ត (ពាន់លានរៀល) | 22 | 60 | 47 | 610 | 1,150 | 2,917 | 6,053 | 6,256 | 7,176 | 8,271 | 9,125 | 10,795 | 11,797 | 12,149 | 12,724 |
| ផសស ថ្លៃចរន្ត (លានដុល្លារ) | 616 | 1,072 | 593 | 1,135 | 1,406 | 1,754 | 2,151 | 2,435 | 2,915 | 3,131 | 3,042 | 2,841 | 3,088 | 3,149 | 3,234 |
| ផសស ក្នុងម្នាក់ (ដុល្លារ) | 113 | 153 | 74 | 120 | 143 | 173 | 205 | 225 | 262 | 273 | 258 | 234 | 248 | 247 | 247 |
| ផសស ក្នុងម្នាក់ (ដុល្លារ១៩៩៣) | 643 | 680 | 125 | 166 | 177 | 195 | 205 | 210 | 219 | 227 | 222 | 222 | 231 | 238 | 244 |
| ផសស ពិត (% កំណើន) | 4.8 | -6.7 | 18.8 | 8.0 | 10.5 | 13.9 | 8.5 | 5.3 | 7.6 | 6.7 | 0.7 | 2.9 | 6.8 | 5.5 | 5.3 |
| ផសស សន្ទស្សន៍បរិត្តផរណាជារៀល (% កំនើន) | 2.0 | 29.9 | 15.9 | 147.8 | 70.7 | 122.7 | 91.2 | -1.9 | 6.6 | 8.0 | 9.5 | 15.0 | 2.3 | -2.4 | -0.5 |
| ផសស សន្ទស្សន៍បរិត្តផរណាជា $ (% កំនើន) | 2.0 | 5.9 | 1.4 | 3.2 | 12.1 | 9.5 | 13.0 | 7.4 | 11.2 | 0.7 | -3.6 | -9.2 | 1.8 | -3.4 | -2.5 |
| អតិផរណាជារៀល (% កំនើនមធ្យម ប្រចាំឆ្នាំ) | 4.0 | 31.3 | 16.6 | 141.0 | 60.0 | 101.7 | 75.1 | -0.5 | 7.8 | 7.1 | 8.1 | 14.7 | 4.0 | -0.8 | -0.6 |
| អតិផរណាជារៀល (% កំនើន Q4/Q4) | 4.9 | 50.0 | 20.0 | 151.0 | 150.0 | 112.0 | 41.0 | 17.8 | 3.5 | 9.0 | 9.1 | 12.6 | 0.0 | 0.5 | -1.3 |
